ត្រឹង ងា

# ប្រវត្តិសាស្ត្រខ្មែរ

( សំរាប់មធ្យមនិងឧត្តមសិក្សា )



៩១០.
១១

ភ្នំពេញ គ.ស. ១៩៧៣

www.budinst.gov.kh www.elibraryofcambodia.org

**ស្នាដៃនេះ**

កើតឡើងពីកិច្ចសហការគ្នា រវាង
**ពុទ្ធសាសនបណ្ឌិត្យ** និង **បណ្ណាល័យអេឡិចត្រូនិចខ្មែរ**
ក្នុងគោលបំណងយ៉ាងមុតមាំដើម្បីថែរក្សា ការពារ កុំឲ្យបាត់បង់តទៅទៀត
ព្រមទាំងផ្សព្វផ្សាយស្នាដៃ-ឯកសារទាំងនេះ
សម្រាប់សាធារណជនប្រើប្រាស់ដោយមិនគិតកម្រៃ។

សូមថ្លែងអំណរគុណដល់
**អង្គការរីស្ស៊ូ កូសី-កៃ  វិទ្យាស្ថានបើកទូលាយ**
**ករុណាខ្មែរ** និង **មូលនិធិខ្មែរសម្រាប់ការសិក្សា**
ដែលបានគាំទ្រគម្រោងការស្នាដៃនេះ សម្រាប់ទុកក្នុងបណ្ណាល័យអេឡិចត្រូនិច។

Buddhist Institute of Ministry of Cult and Religion and eLibrary of Cambodia have made a cooperative effort to digitalize books and manuscripts in order to preserve our Cambodian literary heritage. This will promote and provide easy, instant access, free of charge to the public and future generations to come.

A sincere thank you to our generous supporters: Rissho Kosei-Kai, Open Institute, Karuna Cambodia and Cambodian Education Excellence Foundation, who made this endeavor possible.

www.budinst.gov.kh www.elibraryofcambodia.org

www.budinst.gov.kh www.elibraryofcambodia.org

www.budinst.gov.kh www.elibraryofcambodia.org

៩១០.១១

ក្រើង ៣

សាស្ត្រាចារ្យបរិញ្ញាផ្នែកវប្បធម៌ និង អរិយធម៌អាស៊ី

សាស្ត្រាចារ្យប្រវត្តិសាស្ត្រខ្មែរនៅមហាវិទ្យាល័យអក្សរសាស្ត្រ និង មនុស្សសាស្ត្រ

# ប្រវត្តិសាស្ត្រខ្មែរ

## ភាគ ២

(ពីការកសាងរាជធានីចតុមុខដល់ចុងរជ្ជកាលព្រះបាទស៊ីសុវត្ថិមុនីវង្ស)

*

ការផ្សាយរបស់អ្នកនិពន្ធ

ពុទ្ធសាសនបណ្ឌិត្យ បណ្ណាល័យ LIBRARY BUDDHIST INSTITUTE

៣១៥/៩៥

www.budinst.gov.kh www.elibraryofcambodia.org

- រក្សាសិទ្ធិគ្រប់យ៉ាង -

ភ្នំពេញ គ.ស. ១៩៧៤ ព.ស. ២៥១៨

www.budinst.gov.kh www.elibraryofcambodia.org

# បញ្ជីអត្ថបទ

* បុព្វកថា . . . . . . . . . . ទំព័រ ក

* លិខិតដែលយើងបានទទួល . . . . . . ឃ

ជំពូកទី ៩ : ប្រទេសខ្មែរនៅពាក់កណ្ដាលទី ២ នៃ ស.ត. ទី១៥ : វិបត្តិក្នុងរាជវង្សខ្មែរ . . . . ១

ក- ការកសាងភ្នំពេញ . . . . . . . . ១

ខ- ការកសាងរាជធានីចតុមុខ . . . . . . ២

គ- វិបត្តិក្នុងរាជវង្សខ្មែរ . . . . . . . ៦

ឃ- អន្តរាគមន៍របស់សៀម . . . . . . . ៩

ជំពូកទី ១០ : ប្រទេសខ្មែរនៅ ស.ត. ទី ១៦ : វិបត្តិក្នុងរាជវង្សខ្មែរ និង ការជ្រៀតជ្រែករបស់សៀម. . ១២

ក- ចម្បាំងគ្នាឯងក្នុងស្រុក . . . . . . ១២

ខ- ការកសាងក្រុងលង្វែកនិងការប៉ុនប៉ងរំដោះអាណាខេត្តខាងលិច . . . ២០

គ- ការបែកបាក់ក្រុងលង្វែកនិងផលវិបាក . . . . . ៣១

ជំពូកទី១១ : អរិយធម៌ខ្មែរនៅសម័យក្រោយអង្គរ

( សម័យភ្នំពេញចតុមុខ--សម័យលង្វែក--សម័យទួលបាសាន--ស្រីសន្ធរ ) ៤៨

ក- នយោបាយ . . . . . . . . ៤៩

ខ- រដ្ឋបាល . . . . . . . . ៥៨

គ- អំពីកងទ័ព . . . . . . . . ៦២

ឃ- ជីវភាពសង្គម . . . . . . . . ៧២

ង- វប្បធម៌ . . . . . . . . ៨១

www.budinst.gov.kh www.elibraryofcambodia.org

**ជំពូកទី១២ : ប្រទេសខ្មែរនៅស.វ. ទី ១៧ និង ទី ១៨: វិបត្តិក្នុងរាជវង្សខ្មែរនិងការជ្រៀតជ្រែករបស់យួន** ៨៦

ក- ប្រតិកម្មប្រឆាំងសៀមនិងចំណងមេត្រីភាពជាមួយយួន . . . ៨៦

ខ- វិបត្តិក្នុងរាជវង្សខ្មែរនិងអន្តរាគមន៍របស់យួន . . . . ១០០

គ- ការបាត់បង់ទឹកដីកម្ពុជាក្រោម . . . . . . ១០៦

**ជំពូកទី១៣ : ការប្រណាំងប្រជែងរវាងសៀមនិងយួនដើម្បីត្រួតត្រាប្រទេសខ្មែរ ( ស.វ.ទី១៨និងទី១៩ )** . ១៣៣

ក- ឥទ្ធិពលដ៏ខ្លាំងក្លារបស់យួន . . . . . . ១៣៣

ខ- ឥទ្ធិពលដ៏ខ្លាំងក្លារបស់សៀម . . . . . . ១៣៨

គ- យួនមានឥទ្ធិពលខ្លាំងឡើងវិញ . . . . . ១៤៣

ឃ- សៀមនិងយួនស្រុះស្រួលគ្នាដើម្បីត្រួតត្រាខ្មែរ . . . ១៥៤

**ជំពូកទី១៤ : ប្រទេសខ្មែរក្រោមអាណាព្យាបាលភាពបារាំង ( ស.វ.ទី១៩និងទី២០)** . . . . ១៦៦

ក- ហេតុអ្វីបានជាមានអាណាព្យាបាលភាពបារាំង ? . . . ១៦៦

ខ- បារាំងបានធ្វើអ្វីខ្លះជាប្រយោជន៍ដល់ខ្មែរ? . . . . ១៨៣

* សេចក្តីបញ្ចប់ . . . . . . . ១៩៣

* បញ្ជីឯកសារពិគ្រោះ . . . . . . . ១៩៥

* *

*

www.budinst.gov.kh www.elibraryofcambodia.org

# បុព្វកថា

ការចងក្រងប្រវត្តិសាស្ត្រខ្មែរនៅចុងសម័យអង្គរ ផង សម័យ៥ តា មកទៀតរហូតដល់ពេលបារាំងមកតាំងអាណាព្យាបាលភាពលើប្រទេសយើងនៅ គ.ស. ១៨៦៣ ជាកិច្ចការមួយពិបាកយ៉ាងក្រៃលែង ។ ឧបសគ្គចម្បងគឺ បណ្តាលមកពីកង្វះឯកសារជាពិសេសកង្វះខាងផ្នែកគុណសម្បត្តិនេះឯង ។ ឯកសារដែលយើងមាន គឺ ច្រើនតែជារាជពង្សាវតារ ។ ដូចយើងបានជំរាបអ្នកអានម្តងរួចហើយ នៅក្នុងភាគទី ១ ត្រង់ចំពូកទី ៥ ស្តីពីប្រភពនៃប្រវត្តិសាស្ត្រខ្មែរថា : “រាជពង្សាវតារទាំងនេះបានរៀបចំឡើងនៅស.វ. ទី១៩ ដោយពឹងផ្អែកទៅលើការទន្ទេញចាំមាត់ខ្លះ និងលើអត្ថបទបុរាណខ្លះដែលពីដើមតំកល់ទុកនៅក្រុងឧដុង្គ” ។ គួរគប្បីជ្រាបថាមានតែក្បួនរាជពង្សាវតារមួយគត់ដែលបានចងក្រងឡើងនៅ ស.វ. ទី ១៨ ហើយដែលសព្វថ្ងៃត្រូវបានគេយកទៅថែរក្សាទុកនៅឯប្រទេសថៃឯណោះ ។

បើដូច្នេះ អ្នកនិពន្ធដែលរស់នៅជំនាន់ក្រោយដល់ទៅ ៤ ឬ ៥ សតវត្សមិនអាចជៀសវាងនូវការភ័ន្តច្រឡំក្នុងការរៀបរាប់ព្រឹត្តិការណ៍ឡើយ ។ អាស្រ័យហេតុនេះហើយទើបមានភាពខុសប្លែកគ្នាក្នុងផ្នែកព្រឹត្តិការណ៍ផង និងក្នុងផ្នែកកាលបរិច្ឆេទផង ពីក្បួនមួយទៅក្បួនមួយទៀត ។ មានក្បួនខ្លះដូចជាក្បួនរបស់ឧកញ៉ានង និង ក្បួនវត្តសិត្បូរ មានកាលកំណត់ថយទៅក្រោយខ្លាំងពេក ក្បួនរបស់លោកវាំងជួន ឬ ក្បួនឆ្នាំ ១៩០៧ ហើយប្រហែលជាក្បួនដែលគេបានប្រើប្រាស់ក្នុងការចារឹកអក្សរតំកល់នៅចេតិយវត្តភ្នំសព្វថ្ងៃនេះ មានកាលកំណត់ជាមធ្យម ឯក្បួនខ្លះដូចជាក្បួនវត្តកោកកាកមានកាលកំណត់នោះខិតមកមុខពេក ។ ម្យ៉ាងទៀត ក្បួនរាជពង្សាវតារទាំងនោះរមែងបានគេកត់ចម្លងទុកត ៗ គ្នាមកទៀត ជាហេតុនាំអោយរឹងរិតតែមានការខុសឆ្គងផ្សេង ៗ ទៀតជាមិនខាន ។ ចំពោះឯកសាររាជពង្សាវតារនេះ លោក Etienne Aymonier បានសរសេរថា :



www.budinst.gov.kh www.elibraryofcambodia.org

" C'est un document farci de dates peu sûres . . . . une indigeste compilation de manuscrits douteux et incomplets „ (1) (នេះជាឯកសារដែលពោរពេញទៅដោយកាលកំណត់មិនជាក់លាក់ . . . . . ជាកំរងសរុបនៃអត្ថបទសរសេរដៃពោរពេញដោយការសង្ស័យ និង ការខ្វះចន្លោះ) ។

កង្វះខាតខាងគុណសម្បត្តិនៃឯកសាររាជពង្សាវតារ គឺពិតជាមានដូច្នេះហើយ តែទោះបីយ៉ាងហ្នឹងក៏ដោយ ក៏អ្នកសិក្សាស្រាវជ្រាវនៅតែជៀសវាងមិនយកឯកសារនោះទៅប្រើពុំបានឡើយ ។ ចំពោះយើងវិញ យើងក៏ត្រូវជួបប្រទះនឹងឧបសគ្គយ៉ាងធំដូចដែលអ្នកសិក្សាស្រាវជ្រាវមុនយើងបានជួបប្រទះរួចហើយ ។ ប៉ុន្តែក្នុងការចងក្រងសៀវភៅ " ប្រវត្តិសាស្ត្រខ្មែរ " ភាគ ទី២ នេះ យើងនឹងខិតខំធ្វើយ៉ាងណាអោយស្របស្រួលទៅនឹងវិធីវិទ្យាសាស្ត្រជាអតិបរិមា ។ ក្នុងផ្នែកព្រឹត្តិការណ៍ ទោះបីមានក្បួនរាជពង្សាវតារខ្លះនិយាយក្បោះក្បាយ និង ពិស្ដារជាងក្បួនឯទៀតក៏ដោយក៏យើងពុំយកតាមតែក្បួនមួយ ៗ ហើយលះបង់ចោលនូវក្បួនឯទៀតទេ : យើងនឹងជ្រើសរើសយកតែត្រង់ចំណុចណាដែលក្បួនទាំងនោះនិយាយស្របគ្នា ឬក៏លើកមកជំរាបទាំងអស់តែម្តង ទុកអោយមិត្តអ្នកអានវិនិច្ឆ័យខ្លួនឯងតាមគួរទៅចុះ ។ ម្យ៉ាងទៀត ទាំងខាងផ្នែកព្រឹត្តិការណ៍ និងទាំងខាងផ្នែកកាលកំណត់ យើងនឹងខិតខំធ្វើការផ្ទៀងផ្ទាត់ជាមួយនឹងឯកសារបរទេសនៅជិតខាងយើង និងឯកសារផ្សេង ៗ ទៀត ក្នុងករណីណាដែលយើងអាចធ្វើទៅកើត ។

សៀវភៅ " ប្រវត្តិសាស្ត្រខ្មែរ " ភាគទី ២នេះជាកិច្ចការបន្តពីសៀវភៅ " ប្រវត្តិសាស្ត្រខ្មែរ " ភាគទី ១ ។ ដូច្នេះ គោលបំណងរបស់យើងក៏មិនប្លែកអ្វីពីគោលបំណង ដូច យើងបានបញ្ជាក់ម្តងរួចហើយនោះទេ ។ ពេលនេះ យើងគ្រាន់តែប្រសិទ្ធពរសូមអោយកិច្ចការរបស់យើងនេះ បានចូលរួមចំណែកយ៉ាងសកម្មក្នុងការបំរើជាតិដែរ ហើយសូមមិត្តអ្នកអានមេត្តាខន្តីអភ័យទោសអោយយើងផងទៅទៀតចំពោះរាល់ពិតត្រូវ កង្វះ

(1)(2)(3) . . . ជាលេខយោងទៅឯកសារពិគ្រោះ ដែលមានចុះនៅក្នុងបញ្ជីនៅខាងចុងសៀវភៅនេះ ។


www.budinst.gov.kh www.elibraryofcambodia.org

ខាតគ្រប់បែបយ៉ាងដែលនឹងកើតឡើងដោយអចេតនាក្នុងការចងក្រងសៀវភៅ ភាគទី ២ នេះ ។

ទៅទីបញ្ចប់នេះ យើងសូមថ្លែងអំណរគុណដ៏ជ្រាលជ្រៅនិងដ៏ស្មោះស្ម័គ្រជាទីបំផុតរបស់យើងចំពោះវេជន មិត្តភក្តិ និងសហការីផ្ទាល់ ដែលបានផ្តល់ [illegible] ទាំងខាងធុរចិត្តក្តី ខាងផ្ទាល់កាយក្តី ខាង [illegible] ដែលនោះបានទទួលនូវកុសលផលបុណ្យ ដែលហូរចេញពីកិច្ចការនេះគ្រប់ ៗ គ្នាផង ។

ភ្នំពេញ ថ្ងៃ ទី ២៧ ខែ មេសា ១៩៧៤

**អ្នកនិពន្ធ**



www.budinst.gov.kh www.elibraryofcambodia.org

# លិខិតដែលយើងបានទទួល

## ( ទាក់ទងនឹងសៀវភៅ " ប្រវត្តិសាស្ត្រខ្មែរ " ភាគ ១ )

**តាន់ គីមហួន**

**TAN KIMHUON**
PRESIDENT DE L'ASSEMBLÉE NATIONALE
PHNOM-PENH
( RÉPUBLIQUE KHMÈRE

ជំរាបមកលោក ត្រឹង ងា

លោក

ខ្ញុំមានចិត្តសោមនស្សជាពន្ទឹក ដោយបានទទួលនូវសៀវភៅពង្សាវតារមួយក្បាលដែលលោកបានរៀបរៀង ហើយបានធ្វើអំណោយចំពោះមករូបខ្ញុំ ។ សៀវភៅនេះនឹងផ្តល់អត្ថប្រយោជន៍ដល់ខ្លួនខ្ញុំជាច្រើន ក្នុងការស្រាវជ្រាវរកឯកសារផ្សេងៗដែលមានទាក់ទងអំពីប្រវត្តិសាស្ត្រខ្មែរ ។

ខ្ញុំសូមថ្លែងអំណរគុណ ចំពោះលោកដែលបានផ្តល់នូវអំណោយនេះ ហើយសូមលោកទទួលនូវសេចក្តីរាប់អានដ៏ស្មោះស្ម័គ្រអំពីខ្ញុំ ។

ភ្នំពេញ ថ្ងៃទី ១៨ កុម្ភៈ ១៩៧៤

ហត្ថលេខា៖ **តាន់ គីមហួន**

ប្រធានសភាជាតិ


www.budinst.gov.kh www.elibraryofcambodia.org

**KHOCH KYLENG**
B.A. ( Delhi ), M.Ed. (Ohio)
Under Secretary of State
for Education, Youth and Sports
**Tel. : 2.3927**

ថ្ងៃទី ៤ មីនា ១៩៧៤

---

មកលោក ត្រឹង ងា ជាគតិមាន,

ខ្ញុំបានទទួលសៀវភៅ « ប្រវត្តិសាស្ត្រខ្មែរ » មួយក្បាលដែលលោកបានផ្ញើមកឱ្យខ្ញុំ ដោយសេចក្ដីរីករាយពន់ពេក ។

ខ្ញុំបានអានសៀវភៅដែលជាស្នាដៃរបស់លោកនេះយ៉ាងហ្មត់ចត់ ហើយឃើញថាលោកបានស្រាវជ្រាវដោយយកចិត្តទុកដាក់ សំរាប់ចិញ្ចឹមឯកសារទៅមុខទៀត ហើយជាពិសេសសំរាប់ការសិក្សាគ្រប់ផ្នែក ក្នុងបច្ចុប្បន្នកាលនេះ ។

គេគប្បីតែអានសៀវភៅឯកសារបែបនេះ សំរាប់បណ្ដុះគំនិតជាតិនិយម ដែលមានលក្ខណៈផ្ទុយនឹងសៀវភៅដទៃទៀត ដែលបំផ្លាញគំនិតជាតិនិយមនិងយុវភាពនៃយុវជននិងយុវនារីយើង ។

សូមលោកខំប្រឹងប្រែងតទៅក្នុងគោលគំនិតធ្វើវិភាគទានជាឯកសារផ្សេងៗ ក្នុងក្របខណ្ឌនៃអរិយធម៌ជាតិ ។

សូមទទួលនូវសេចក្ដីរាប់អានដ៏ស្មោះអំពីខ្ញុំ ។

**ហត្ថលេខា : ឃួច គីឡេង**
**អនុរដ្ឋលេខាធិការ**
**ក្រសួងអប់រំជាតិ យុវជននិងកីឡា**


www.budinst.gov.kh www.elibraryofcambodia.org

ភ្នំពេញ ថ្ងៃទី ៤ ខែមិនា ឆ្នាំ ១៩៧៤

សូមជំរាបមកលោក ត្រឹងងា អគ្គលេខាធិការវិជ្ជាឋានខ្មែរ-មន
ក្រុងភ្នំពេញ ។

លោកអគ្គលេខាធិការ

ខ្ញុំបានអានសៀវភៅ " ប្រវត្តិសាស្ត្រខ្មែរ " ភាគ ១ ដែលលោកបានផ្តល់ជាអំណោយផ្ទាល់មកខ្ញុំចប់សព្វគ្រប់ហើយ ។ ស្នាដៃដ៏ថ្លៃថ្លារបស់លោកនេះពិតជាឯកសារជាតិមួយដ៏កម្រសម្រាប់ជាជំនួយចំពោះប្រវត្តិវិទូ អ្នកសិក្សាស្រាវជ្រាវ សាស្ត្រាចារ្យនិងនិស្សិតនៅឧត្តមសិក្សា ។

ចំពោះអត្ថរូបនៃសៀវភៅ ខ្ញុំមានការចាប់អារម្មណ៍ខ្លះ ដូចតទៅ:

- របៀបចែកផ្នែកមេរៀន ពិសេសការចែករយៈកាលនៃកាលប្រវត្តិគឺច្បាស់លាស់ ហើយងាយស្រួលដល់ការសិក្សា ទេះចាំណាស់ ។
- ពាក្យពេចន៍ និងឃ្លាប្រយោគ ងាយស្តាប់ ងាយយល់ ។ ប៉ុន្តែចំពោះឈ្មោះស្តេចគប្បីរក្សាទុកនូវស័ព្ទសម្រាប់ហៅ ដែលជាតម្លៃនៃភាសាជាតិនិងប្រពៃណីល្អ គឺជាទុកពាក្យ « ព្រះបាទ ... » ឧទាហរណ៍ «ព្រះបាទជ័យវរ្ម័ន» យ៉ាងនេះល្អជាជាងហៅ:ទទេត្រឹមតែ « ជ័យវរ្ម័ន » ដូច្នេះ ។ ឬមួយ បើមិនបាច់មានស័ព្ទដើម «ព្រះបាទ ...» ក៏សុំឲ្យមានឯកភាពពីដើមដល់ចប់គឺហៅត្រឹមតែឈ្មោះចំៗ តែម្តងដូចជា«ជ័យវរ្ម័នទី ១ ជ័យវរ្ម័ន ទី ២ ។ល។» យ៉ាងនេះក៏បាន កុំម្តង «ព្រះបាទ . . . » រួចតមកហៅឈ្មោះតែទទេ នាំឲ្យមិនរៀបរយក្នុងរបៀបគាត់តែងទៅវិញ ។

ខ្ញុំសង្ឃឹមថា ស្នាដៃដ៏វិសេសរបស់លោកនេះ ពិតជាជួយឲ្យប្រវត្តិវិទូខ្មែរទិតទំស្រាវជ្រាវ និងបញ្ចេញអ្វីដែលជាពិត ដែលជាខ្មែរមែន ។ ហើយត្រឹមត្រូវទៅខាងមុខ ។

www.budinst.gov.kh www.elibraryofcambodia.org

ខ្ញុំសូមឧទ្ទិសឡៃស្នាដៃទី ២ ទី ៣ និងត ៗ ទៅទៀតរបស់លោកបានសំរេច ឡើងហើយចេញផ្សាយដើម្បីជាគុណប្រយោជន៍ដល់ប្រទេសជាតិ និងដល់វប្បធម៌-អរិយធម៌ ខ្មែរ ៗ

សូមលោកអគ្គលេខាធិការមេត្តាទទួលនូវកតញ្ញុតា ការគោរពសរសើរ និង សេចក្ដីរាប់អានយ៉ាងស្មោះរបស់ខ្ញុំ ៗ

ហត្ថលេខាៈ ឈាង ហ៊័ម រាន

សមាជិកនៃក្រុមប្រឹក្សាជាតិ អប់រំ និងវប្បធម៌



www.budinst.gov.kh www.elibraryofcambodia.org

**សាធារណរដ្ឋខ្មែរ**

ក្រសួងអប់រំជាតិ

**នាយកដ្ឋាន**

សាកលវិទ្យាល័យ ភ្នំពេញ

លេខ ១២៩៤ ស.ភ.ព.ល.

ភ្នំពេញ នៅថ្ងៃ ១៣ ឧសភា ១៩៧៤

នាយក សាកលវិទ្យាល័យ ភ្នំពេញ

មកលោក ត្រឹង ងា នាយករង នៃវិជ្ជាស្ថានខ្មែរ - ម

ភ្នំពេញ

លោកនាយក រង

ខ្ញុំបានទទួលដោយរីករាយនូវសៀវភៅប្រវត្តិសាស្ត្រខ្មែរ សំរាប់មធ្យម និងឧត្តមសិក្សារបស់លោកមួយក្បាល ។ ខ្ញុំសូមអរគុណលោកជាពន្ទឹកចំពោះ អំណោយដ៏ថ្លៃថ្លានេះ និងសូមសរសើរលោកជាអនេកប្បការចំពោះស្នាដៃដ៏ វិសេសនេះ ដែលអាចផ្តល់ប្រយោជន៍ជាច្រើនដល់សិស្ស និង និស្សិត ព្រមទាំងជនជាតិខ្មែរយើងទាំងមូលផង ។

ជាមួយនឹងអំណរគុណដ៏កក់ក្តៅរបស់ខ្ញុំ សូមលោកនាយករងទទួលនូវសេចក្តីរាប់អានដ៏ខ្ពង់ខ្ពស់របស់ខ្ញុំ ។

ហត្ថលេខា: គីខ គុន



www.budinst.gov.kh www.elibraryofcambodia.org

ចំពូកទី ៩

# ប្រទេសខ្មែរនៅពាក់កណ្ដាលទី ២ នៃសតវត្សទី ១៥ៈ វិបត្តិក្នុងរាជវង្សខ្មែរ

## ក.- ការកសាងភ្នំដូនពេញៈ-

រាជពង្សាវតារខ្លះបានរិទានពីប្រវត្តិនៃក្រុងភ្នំពេញដោយមានសេចក្ដីសង្ខេបដូចតទៅ ៖

ក្នុងកាលដែលកន្លងយូរទៅហើយ មានស្ត្រីមេម៉ាយម្នាក់ជាអ្នកមានទ្រព្យស្ដុកស្ដម្ភ ដែលអ្នកជិតហៅថា **ដូនពេញ** ។ ផ្ទះគាត់តាំងនៅលើទួលខ្ពស់មួយនៅលើត្រើយខាងលិចនៃ **ឆន្លេច្រាបឈាម** ( ទន្លេចតុមុខសព្វថ្ងៃ ) ។

នាសម័យថ្ងៃមួយ ក្នុងរដូវវស្សាមានទឹកជំនន់នៅប្រទេសលាវយ៉ាងធំបណ្ដាលអោយបាក់ច្រាំងរលំដើមគគីរជាច្រើន ហើយអណ្ដែតបណ្ដោយទឹកតាមទន្លេមេគង្គរហូតមកដល់ទន្លេច្រាបឈាម ។ ក្នុងចំណោមនោះ មានដើមគគីរធំមួយ បានអណ្ដែតមកវិលនៅត្រង់មាត់កំពង់របស់ដូនពេញ ។ គាត់ក៏បានបបួលញាតិមិត្តជិតខាងជិះទូកទៅចងដើមគគីរនោះ ហើយនាំយកមកលើគោក ។ កាលបើអ្នកទាំងនោះរើសំរាមនៅគល់គគីរ ស្រាប់តែឃើញព្រះពុទ្ធរូបបួនព្រះអង្គ និងរូបបដិមាថ្ម មានលក្ខណៈជាព្រាហ្មណ៍ នៅក្នុងប្រហោងឈើនោះ ។ ពួកអ្នកស្រុកបានដង្ហែរូបបដិមាទាំងនោះ យកទៅតំកល់ទុកនៅផ្ទះដូនពេញ

www.budinst.gov.kh www.elibraryofcambodia.org

។ ហើយគាត់បានអោយគេជញ្ជូនដី ពូនដំបូកធំខាងឦសានផ្ទះ និងអោយគេយកឈើគគីរនោះសង់ព្រះវិហារតូចមួយនៅលើកំពូលភ្នំនោះ ហើយបានយកព្រះពុទ្ធរូបទៅតំកល់នៅក្នុងព្រះវិហារនោះនៅក្នុងឆ្នាំជូត ឆស័ក ព.ស. ១៩១៦ គ.ស. ១៣៧២ ។ តមកទៀតដូនពេញបានអោយគេសង់ខ្ទមមួយខាងទិសឦសានព្រះវិហារ រួចយកបដិមាថ្មទៅតំកល់ទុកនៅទីនោះ ហើយបានសន្មតថា **អ្នកតាព្រះចៅ** តរៀងមក ( សព្វថ្ងៃគេហៅថា **លោកតាព្រះចៅ** ) ។ ពិធីបុណ្យសម្ពោធក៏ត្រូវបានប្រារព្ធធ្វើឡើង ដើម្បីសម្ពោធពុទ្ធសេនាសនៈ យ៉ាងអធិកអធម ។ ដោយអាស្រ័យហេតុនេះ ភ្នំនោះក៏មានឈ្មោះហៅថា **ភ្នំដូនពេញ** ហើយដែលយូរ ៗ ទៅក្លាយនៅត្រឹមតែ **ភ្នំពេញ** ដូចយើងហៅសព្វថ្ងៃនេះ ។

គួរគប្បីបញ្ជាក់ថាចំពោះរូបបដិមាដែលដូនពេញបានរកឃើញក្នុងដើមគគីរនោះ រាជពង្សាវតារ និងអត្ថបទចម្លងត ៗ មកទៀត និយាយមិនស្របគ្នាសោះ : ខ្លះថាមានព្រះពុទ្ធរូបដិមា ៤ អង្គធ្វើពីលង្ហិន និងបដិមាថ្មកាន់ស័ង្ខនិងគទា ( ព្រះនារាយណ៍ ? ) (2) ខ្លះថាមានព្រះពុទ្ធរូបពីរព្រះអង្គមានព្រះភ័ក្ត្រឈមជា ៤ ទិស (3) ខ្លះទៀតថាមានព្រះពុទ្ធរូបសំរិទ្ធិមួយព្រះអង្គមានព្រះភ័ក្ត្រ ៤ តាំងសមាធិ និងរូបសិលា ១ ដៃកាន់ស័ង្ខមានផ្នួងសក់ដូចជាពួកព្រាហ្មណ៍ (4) ។ តែបើតាមរូបតំណាងដែលមានតំកល់ក្នុងព្រះវិហារវត្តភ្នំ (ភ្នំដូនពេញ ) សព្វថ្ងៃគឺជាព្រះពុទ្ធរូបប្រក់នាគ ៤ អង្គគង់លើបុស្សបុកទល់ព្រះប្រឹស្ឋ (ខ្នង)នឹងគ្នា ។

## ខ-ការកសាងរាជធានីចតុមុខ.-

ក្នុងភាគ ១ យើងបានឃើញថានៅ គ.ស ១៤៣១ ព្រះបាទបរមរាជាចៅពញាយ៉ាត ទ្រង់បានលើករាជធានីទៅតាំងនៅទួលបាសានក្នុងខេត្ត ស្រីសឈរវិញ តែគង់នៅទីនោះបានតែ ១ ឆ្នាំ ( ក្បួនខ្លះថាជាង ៩ ឆ្នាំ ) ដោយមានទឹកជំនន់ធំខុសធម្មតា ព្រះអង្គក៏បញ្ជាអោយលើករាជធានីពីទួលបាសានទៅតាំងនៅក្រុងភ្នំពេញវិញ នៅលើត្រើយខាងលិចនៃទន្លេប្រាបណាម ។

ព្រះអង្គទ្រង់ត្រាស់បង្គាប់អោយ **សម្តេចចៅពញាតែ** និង **ឧកញ៉ាហោរាធិបតី**

www.budinst.gov.kh www.elibraryofcambodia.org

**ទៀត** ព្រមដោយមន្ត្រីឯទៀតខ្លះផងអោយទៅពិនិត្យមើលទីដីដែលស្ថិតនៅជិត ៗ ភ្នំពេញ ។ លុះទៅធ្វើការពិនិត្យតាមក្បួនតម្រាសព្វគ្រប់ហើយ មន្ត្រីទាំងនោះក៏ថ្វាយដំណឹងទៅព្រះរាជាវិញថា តំបន់ដែលស្ថិតនៅទិសអគ្នេយ៍នៃភ្នំពេញ មានជ័យភូមិល្អល្មមស្ថាបនារាជធានីបាន ។ ព្រះអង្គក៏ទ្រង់ត្រាស់អោយអស់ចៅហ្វាយស្រុកកែនរាស្ត្រ មកជួយកសាងព្រះរាជនិវេសន៍ លើកដីធ្វើកំពែង សង់ប្រាសាទនិងតំណាក់តូចធំក្នុងរយៈពេលដ៏ខ្លីបំផុត ។ លុះកិច្ចការបានបំពេញចប់សព្វគ្រប់ហើយ ព្រះអង្គក៏យាងបកគង់នៅរាជវាំងភ្នំពេញតាមផ្លូវទឹកដោយមាននាម៉ឺនសព្វមុខមន្ត្រីដង្ហែមកផង ។

លុះយាងមកដល់ហើយ ព្រះអង្គក៏ទ្រង់ត្រាស់បង្គាប់ **ចៅពញាតេជោ** ចៅហ្វាយស្រុក ខេត្តសំរោងទង អោយកែនរាស្ត្រលើកដីទៅចាក់បំពេញតំបន់នៅជុំវិញវត្តភ្នំ និងក្នុងរាជវាំង ។ ដូច្នេះតំបន់នោះក៏បានរាបស្មើល្អ រហូតដល់មាត់ទន្លេ ដែលអ្នកជងនិយមហៅ **តំបន់ទាប** ចាប់តាំងពីពេលនោះមក ។ ឯទីដែលចៅពញាតេជោអោយរាស្ត្រជីកយកអាចម៍ដីនោះ ក៏ក្លាយទៅជាបឹងមួយធំទូលាយ ។ ទើបបានគេអោយឈ្មោះហៅ **បឹងតេជោ** តរៀងមក គឺទីដីត្រង់ផ្សារថ្មីសព្វថ្ងៃ ។

តមកទៀត ព្រះរាជាទ្រង់ត្រាស់បង្គាប់ **ឧកញ៉ាខ្សោរអនុជិតផ្លុង** ចៅហ្វាយស្រុកខេត្តបាទី អោយជីកព្រែកបង្ហូរទឹកទន្លេចូលទៅក្នុងបារាយមួយ នៅក្នុងរាជធានីសំរាប់យកទឹកប្រើប្រាស់ដល់ប្រជារាស្ត្រទាំងអស់គ្នា ព្រែកនោះគេហៅថា **ព្រែកឧកញ៉ាផ្លុង** ។ បើតាមស្រាវជ្រាវទៅឃើញថា ពីដើមព្រែកនេះស្ថិតនៅតាមបណ្តោយសួនច្បារនៅមុខស្ថានីយកណ្តាលនៃអយស្ម័យយាន គឺស្របនឹងវិថីឧកញ៉ាផ្លុងសព្វថ្ងៃនេះឯង ។

ដើម្បីជាកិច្ចការពារ ព្រះរាជាទ្រង់បញ្ជាអោយជីកគូនិងលើកដីជាកំពែង តាំងជាស៊ើនជាបន្ទាយព័ទ្ធជុំវិញរាជធានី ។ ដូច្នេះនៅទិសខាងត្បូងគឺ **ព្រែកតាកែវ** ខាងលិច **ព្រែកអូរ-គរ** ខាងជើង **ព្រែកពោធិឈាយ** ឬ **ព្រែកចិនដំដែក** ព្រោះនៅកន្លែងនោះមានផ្ទះជាតិចិនរកស៊ីរបរដំដែក ។ ក្រៅពីមុខងារការពារក្រុង ព្រែកទាំងនោះនៅមានមុខងារសំខាន់មួយទៀតគឺយកទឹកសំរាប់អោយរាស្ត្រធ្វើស្រែនៅទិសខាងលិច ។


www.budinst.gov.kh www.elibraryofcambodia.org

ពួកនាម៉ឺនសព្វមុខមន្ត្រី និងពួកប្រជារាស្ត្របានសង់គេហដ្ឋានរៀង ៗ ខ្លួនក្នុងបរិវេណនៃរាជធានី ។

លុះសំរេចការកសាងហើយ ព្រះរាជាទ្រង់តាំងប្រទាននាមព្រះនគរថា **ក្រុងចតុមុខមង្គល សកលកម្ពុជាធិបតី សិរីធរ បវរ ឥន្ទបត្តបុរី រដ្ឋរាជ សីមា មហានគរ** ។ ចំណែកឯទន្លេប្រាបឈាមក៏ត្រូវបានប្រសិទ្ធិនាមថ្មីថា **ទន្លេចតុមុខ** វិញដែរ ។

ក្រោយបន្តិចមក ព្រះរាជបុត្រច្បងព្រះនាម **នារាយណ៍រាជា** ទ្រង់បានតែងតាំងជាឧបរាជ ហើយយាងទៅគង់ក្នុងព្រះតំណាក់នៅ **ជ្រោយរលួស** ។ ឯព្រះរាជបុត្រទីពីរព្រះនាម **ស្រីរាជា** យាងទៅគង់នៅខាងលិច ត្រង់ដីទួលមួយកន្លែងដែលតមកគេហៅថា **ទួលព្រះស្រី** ( ម្តុំវត្តព្រះពុទ្ធមានបុណ្យសព្វថ្ងៃ ) ។ នៅគ្រានោះ ព្រះវិហារកសាងឡើងដោយដូនពេញក៏បានទ្រុឌទ្រោមខ្លះទៅតាមកាលវេលា ។ ព្រះបាទបរមរាជាចៅពញាយ៉ាតទ្រង់បានកសាងវិហារនោះជាថ្មីឡើងវិញ ដោយពង្រីកនិងពូនភ្នំនោះអោយកាន់តែខ្ពស់ជាងដើម ហើយទ្រង់ចាត់អោយក្រាលថ្មនៅកំពូលខាងលើ និងកសាងចេតិយមួយយ៉ាងធំពីខាងក្រោយព្រះវិហារ ។ រួចព្រះអង្គទ្រង់បញ្ជាអោយទៅយកព្រះពុទ្ធបដិមាលង្ហិនដែលសេសសល់នៅនគរវត្ត ព្រមទាំងរូបសិង្ហតោ មកតំកល់និងតាំងនៅលើភ្នំនោះ ។ ពិធីបុណ្យត្រូវធ្វើអស់រយៈពេលបីថ្ងៃ គេយកព្រះពុទ្ធបដិមាដែលដូនពេញបានរកឃើញពីក្នុងដើមគគីរពីមុននោះទៅតំកល់ក្នុងជាន់ខាងលើនៃចេតិយធំ ឯព្រះពុទ្ធបដិមាដែលយកពីនគរវត្ត ត្រូវបានតំកល់នៅក្នុងជាន់ក្រោម ។ វត្តភ្នំដូនពេញត្រូវប្រសិទ្ធិនាមថ្មីថា **វត្តព្រះចេតិយបពិត** វិញ ។

ក្រៅពីនេះ ព្រះរាជាទ្រង់បានចាត់អោយកសាងវត្តអារាមនៅច្រើនកន្លែងក្នុងរាជធានី៖ វត្តពីរនៅខាងកើតវត្តភ្នំគឺ **វត្តធម្មលង្កា** និង **វត្តកោះ** វត្តមួយនៅខាងត្បូងអូរចិនដំដែកគឺ **វត្តព្រះពុទ្ធឃោសា** ( សព្វថ្ងៃហៅ **វត្តព្រះពុទ្ធឃោសារាម** ឬ **វត្តចិនដំដែក** នៅជាប់នឹងវត្ត ពិភពទូរស្សន៍មានវិថីឧកញ៉ាអ៊ុំចំណុចកណ្តាល ។ នៅខាងមុខព្រះវិហារវត្តនេះ សព្វថ្ងៃគេឃើញមានរូបទ្វារបាលពីរនាក់ជារូបចិនដែលគេអាចមើលស្គាល់យ៉ាងងាយ

www.budinst.gov.kh www.elibraryofcambodia.org



www.budinst.gov.kh www.elibraryofcambodia.org

ដោយសារលក្ខណៈ មុខមាត់ សំលៀកបំពាក់និងគ្រឿងអាវុធ ) វត្តមួយនៅត្រង់មាត់ទន្លេ ក្បែរពាមព្រែកឧកញ៉ាជួន គឺ **វត្តពាមជ្វា** វត្តមួយនៅត្រង់ចេតិយធំ **វត្តឧណ្ណាលោម** ហើយវត្តមួយទៀតហៅ **វត្តខ្ពបតាយ៉ង** ។ គួរគប្បីកត់សំគាល់ជាវត្តចុងក្រោយនេះ ស្ថិតនៅត្រង់ វត្តបទុមវតី ។ បើតាមអក្សរចារឹកតំកល់នៅទីនោះ ព្រះបាទបរមរាជចៅពញាយ៉ាតបានសាងវត្តនេះនៅ គ.ស. ១៤៤២ លើទីដីមួយមានទំហំ ២០២ម X ២៦០ម ។ វត្តនេះគេហៅជា **វត្តខ្ពបតាយ៉ង** ព្រោះនៅខាងត្បូងមាន ខ្ពបរបស់តាយ៉ង ។ ព្រះវិហារវត្តនេះត្រូវបានកសាងជាថ្មីពីរលើកទៀតៈ លើកទី ១ នៅ គ.ស ១៨៦៥ ក្នុងរជ្ជកាលព្រះបាទសម្តេចនរោត្តម លើកទី ២ នៅ គ.ស. ១៩៣៧ ក្នុងរជ្ជកាលរបស់ព្រះបាទស៊ីសុវត្ថិមុនីវង្ស ។ គួរគប្បីជ្រាបម្យ៉ាងទៀតថា វត្តឧណ្ណាលោមនៅរក្សាឈ្មោះដដែលតាំងពីពេលកសាងរហូតមកដល់សព្វថ្ងៃ ហើយឈ្មោះនេះត្រូវបានប្រសិទ្ធឡើងដោយយកតាមឈ្មោះចេតិយដែលគេបញ្ចុះព្រះឧណ្ណាលោម គឺរោមប្រជុំចិញ្ចើមនៃព្រះ **មហាកស្សបត្ថេរ** (5) ។ នៅខាងមុខវត្តនេះ គឺនៅជិតមាត់ទន្លេ ព្រះរាជាទ្រង់អោយសាងខ្ទមមួយ ( អ្នកតាចាំស្រុក) ឈ្មោះ**អ្នកតាព្រះចន្ទ** ។

## គ- និបត្តិក្នុងរាជវង្សខ្មែរ.-

### ១— ព្រះបាទបរមរាជា ចៅពញាយ៉ាត ( ១៣៩៣-១៤៦៣ ) -

ព្រះបាទបរមរាជាចៅពញាយ៉ាត បានសោយរាជ្យនៅរាជធានីចតុមុខដោយបានសុខសាន្តរហូតរៀងមក ។ ឯកសារខ្លះបាននិយាយថា ប្រទេស ចិន យួន ចាម ថៃ បាននាំគ្រឿងបណ្ណាការមកក្រាបថ្វាយពីងបុណ្យបារមីជាច្រើន ។ ឯកសារខ្លះទៀត (6) បានបញ្ជាក់ថា ពួកយួនដែលកំពុងចាប់ផ្តើមមកតាំងនៅប្រទេសកម្ពុជា គឺសុទ្ធសឹងជាពួកអ្នកជំនួញនិងពួកជាង តែការផ្ទៀងផ្ទាត់ជាមួយសៀវភៅប្រវត្តិសាស្ត្រយួនពុំឃើញមានបញ្ជាក់ពីចំណុចនេះសោះ ។ ចំពោះទំនាក់ទំនងជាមួយប្រទេសចិនវិញ លោក **Etienne**

www.budinst.gov.kh www.elibraryofcambodia.org

Aymonier (7) បានសរសេរដោយរំលឹកសំដីរបស់លោក Moura ថា: « នៅឆ្នាំ ១៦៦១ ស្តេចចៅពញាយ៉ាតដែលពួកអ្នកកាលប្បវត្តិចិន ដោយហៅ Chieu - binh - nha បានបញ្ជូនរាជទូតទៅគាល់ព្រះចៅក្រុងចិន ៗ រាជទូតរូបនេះបាននាំយកព្រះរាជសារដែលព្រះរាជាទ្រង់បានសរសេរដោយព្រះហស្តផ្ទាល់ ហើយតំកល់ក្នុងហិបតូចមួយធ្វើពីមាសដែលត្រូវថ្វាយជាជង្វាយដល់ព្រះចៅក្រុងចិន ព្រមជាមួយនឹងដំរី កុកដំរី ល័ក្ត ម្រេច ក្រមួន គុយរមាស គ្រឿងក្រអូប សត្វក្ងោក ... » ៗ គណៈបេសកកម្មទូតបញ្ជូនទៅប្រទេសចិន ត្រូវជុតរលត់ស៊ីងតែអស់រលីងចាប់ពី គ.ស. ១៤៣៥ ប៉ុន្តែគេឃើញពួកអ្នកកាលប្បវត្តិចិនបានកត់ត្រាទុកពីគណៈបេសកកម្មទូតមួយនៅ គ.ស. ១៦៥២ មានសេចក្តីដូចតទៅ: « តាមក្រមនៃស្ថាប័នរាជវង្សមិង ឆ្នាំទី ៣ តិងចៃ ( ១៦៥២) នៃរជ្ជកាលព្រះបាទ Tai-tsoung គេបានថ្វាយទៅព្រះចៅប្រទេសចិនឡានូវកំណាត់សូត្រចាក់ ២ ផ្ទាំង សំពត់ផ្កា ៦ ផ្ទាំង សៀធ្វើពីសូត្រ ៤ ផ្ទាំង ៗ គេបានថ្វាយទៅព្រះអគ្គមហេសីសំពត់ផ្កា ៤ ផ្ទាំងនិងសៀ ៣ ផ្ទាំង លោកប្រធានគណៈបេសកកម្ម អ្នកបកប្រែភាសាទាំងអស់ និងពួកភ្នាក់ងារឯទៀត ៗ បានទទួលនូវអាវជាយធំ សំពត់ផ្កានិងសំពត់សូត្រ ៗ ពួកនេះបានទទួលការជប់លៀងភោជ-នាហារយ៉ាងអឹកធឹក ៗ នៅពេលធ្វើដំណើរត្រឡប់មកស្រុកវិញ នាយក្រុមភស្តុភារនៃខេត្តក្វាងទុងបានទទួលបញ្ជាអោយធ្វើបដិសណ្ឋារកិច្ចចំពោះពួកនេះទៀត ៗ ក្នុងរយៈពេលជប់ថ្ងៃដែលស្នាក់នៅ នៅប្រទេសចិន គេបានចែកអោយពួកនេះក្នុងមួយក្រុម ៗ មាន ១០នាក់ នូវ ចៀម២ ក្ងាន២ មាន់ញី២ ស្រា២០ដប អង្ករ មៀវម៉ី និងបន្លែសំរាប់ចំអិនធ្វើជាអាហារបរិភោគ » ៗ

គួរគប្បីជ្រាបថា ក្បួនរាជពង្សាវតារផ្សេង ៗ បាននិយាយស្របគ្នាថា ព្រះបាទបរមរាជាចៅពញាយ៉ាត មានរាជបុត្របីអង្គ តែពុំសូវស្របគ្នាចំពោះនាមមហេសីរបស់ព្រះអង្គៈ

**១–នារាយណ៍រាជា** រាជបុត្រ **អ្នកម្នាងពេទី** ( ក្បួនខ្លះថាជារាជបុត្ររបស់អ្នកម្នាងស្រីសៀម ស្រសៀម ឬ ស៊ុំសាដាម )

**២–ស្រីរាជា** រាជបុត្រ **អ្នកម្នាងបទុមកេសរ** ( ក្បួនខ្លះថាជារាជបុត្រអ្នកម្នាង

www.budinst.gov.kh www.elibraryofcambodia.org

ចន្ទ ឬ ចាន់ )

៣–ធម្មរាជា រាជបុត្រ **អ្នកម្នាងស្រីសៀមស្រខៀម ឬ ស៊ីសាខាម**

## ២– ព្រះបាទនារាយណ៍រាជា (១៤៦៣-១៤៦៩)-

មកដល់ គ.ស. ១៤៦៣ ព្រះបាទបរមរាជាចៅពញាយ៉ាត ទ្រង់បានបង្វែររាជសម្បត្តិទៅអោយបុត្រច្បងគឺនារាយណ៍រាជាដែលមាននាមសំរាប់រាជ្យថា **ព្រះបាទសម្តេចព្រះរាជឱង្ការព្រះនារាយណ៍រាជារាមាធិបតី ព្រះស្រីសុរិយោពណ៌ធម្មិកមហារាជាធិរាជបរមបពិត្របណ្ឌិតជាឥស្សរ** គង់នៅរាជវាំងចតុមុខតរៀងមក ។

នៅ គ.ស. ១៤៦៦ ព្រះវររាជបិតាបានសោយទីវង្គតទៅដោយជរារោគ ក្នុងជន្មាយុជាង ៧០ ឆ្នាំ ។ នៅ គ.ស. ១៤៦៧ ព្រះអង្គទ្រង់បានសាងព្រះចេតិយនៅលើភ្នំដូនពេញ ដើម្បីធ្វើបុណ្យបញ្ចុះព្រះបរមអដ្ឋិព្រះបិតា ។ សព្វថ្ងៃមានអក្សរចារឹកលើថ្មតាមបញ្ជារបស់ព្រះបាទសម្តេចព្រះស៊ីសុវត្ថិគង់នៅទីនោះតាំងពី គ.ស. ១៩១៧ រៀងមក ។

## ៣— ព្រះបាទស្រីរាជា (១៤៦៩-១៤៨៥) –

ព្រះបាទសម្តេចព្រះនារាយណ៍រាជាសោយរាជ្យបានតែ ៥-៦ ឆ្នាំ (១៤៦៣-១៤៦៩) គឺសោយទីវង្គតទៅដោយប្រឈួនជាទម្ងន់ ។ ឯកសារខ្លះបានបញ្ជាក់ថាព្រះអង្គមានរាជបុត្រជាមួយ **អ្នកម្នាងកែវ** ព្រះនាម**ស្រីសុរិយោទ័យ** ។ គេមិនដឹងច្បាស់ថាពេលនោះព្រះរាជបុត្រមានជន្មាយុប៉ុន្មានឆ្នាំទេ តែបើតាមចាំស្មានមើលទៅឃើញថាទំនងជានៅក្មេងពេកទើបព្រះរាជវង្សានុវង្ស និងនាម៉ឺនសព្វមុខមន្ត្រីសូមយាងព្រះស្រីរាជាជាព្រះអនុជបន្ទាប់អោយឡើងសោយរាជ្យស្នងព្រះជេដ្ឋា ដោយមានព្រះនាមសំរាប់រាជ្យថា **ព្រះរាជឱង្ការព្រះស្រីរាជារាមាធិបតីធម្មិកនរោត្តមបរមមហាចក្រពត្រាធិរាជ ព្រះបរមនាថមហាបពិត្រ** ។

នៅ គ.ស. ១៤៧០ ព្រះអង្គទ្រង់បានសាងព្រះចេតិយនៅជើងភ្នំដូនពេញត្រង់ទិស

www.budinst.gov.kh www.elibraryofcambodia.org

ឲ្យសាងដើម្បីធ្វើបុណ្យបញ្ចុះព្រះបរមអដ្ឋិព្រះនារាយណ៍រាជា ។ ចេតិយនេះបានស្ថិតនៅរហូតដល់សព្វថ្ងៃ ហើយមានអក្សរចារឹកតាមបន្ទាប់របស់ព្រះបាទស៊ីសុវត្ថិតំកល់នៅទីនោះតាំងពី គ.ស. ១៩១៧ រៀងមក ។

គឺចាប់តាំងពីរជ្ជកាលរបស់ព្រះបាទស្រីរាជានេះហើយ ដែលប្រទេសខ្មែរត្រូវពើបប្រទះនូវទុក្ខវេទនាយ៉ាងខ្លាំងបណ្តាលមកពីវិបត្តិក្នុងរាជវង្សខ្មែរ ។

ក្បួនរាជពង្សាវតារខ្លះបានសរសេរថានៅ គ.ស.១៤៧៥ ទៀតនូវកាលដែលព្រះ-បិតុលា (ឪពុកមា) លើកទ័ពទៅវាយរំដោះយកអាណាខេត្តខាងលិចដែលត្រូវសៀមត្រួតត្រាយូរមកហើយនោះដោយបានកៀរយកមនុស្សជាច្រើនពាន់នៅបស្ចិមបុរី នគរនាយកចូលមកប្រទេសខ្មែរ (8) ក្មួយរបស់ព្រះអង្គគឺស្រីសុរិយោទ័យមានចិត្តលោភចង់យករាជ្យសម្បត្តិសោយ ក៏ជួយពីចតុមុខទៅសង្កត់រាស្ត្រកទ័ពបានច្រើន ។ ពេលនោះព្រះធម្មរាជាជាឧប-រាជ បានចាត់មន្ត្រីអោយទៅឈរខេត្តពីសំរោងទងដល់ទឹកខ្មៅហើយទ្រង់ចាត់អោយយកដំណឹងទៅថ្វាយព្រះស្រីរាជា ។ ព្រះអង្គក៏ប្រញាប់លើកទ័ពត្រឡប់មកវិញ ហើយចម្បាំងក៏ផ្ទុះឡើងរវាងមានិងក្មួយ ។ ក្បួនខ្លះនិយាយខ្លីជាងនេះ គឺមិនបានបញ្ជាក់ហេតុផលអ្វីអោយច្បាស់លាស់ទេ ។ ចំពោះប្រវត្តិវិទូបរទេសខ្លះមានលោក Dauphin Meunier ជាដើម ទំនាស់នេះបណ្តាលមកពីព្រះសុរិយោទ័យយល់ថា ព្រះអង្គត្រូវតែមានសិទ្ធិសោយរាជ្យតពីព្រះបិតា គឺព្រះនារាយណ៍រាជា (9) ។

## ឃ - អន្តរាគមន៍របស់សៀម·-

ក្បួនរាជពង្សាវតារផ្សេង ៗ សុទ្ធតែបាននិយាយពីអន្តរាគមន៍របស់សៀម ក្នុងជម្លោះរវាងស្តេចខ្មែរ ប៉ុន្តែរបៀបធ្វើអន្តរាគមន៍នោះឃើញថា មានបែបផែនខុសៗគ្នា ។

ក្បួនខ្លះបញ្ជាក់ថា គឺព្រះធម្មរាជាដែលត្រូវជាបុត្ររបស់អ្នកម្នាងសៀមស្រងៀមនេះឯង ដែលទៅពឹងកម្លាំងសៀមដើម្បីដោះស្រាយបញ្ហាចម្បាំងក្នុងគ្រួសារផង និងដើម្បីបានសោយរាជ្យតែម្នាក់ឯងផង ។

www.budinst.gov.kh www.elibraryofcambodia.org

**ព្រះបាទធម្មរាជា ( ១៤៨៦–១៥០៤ )—**

នៅ គ.ស. ១៤៨៥ ព្រះចៅមហាចក្រពត្រាធិរាជស្តេចសៀមសោយរាជ្យនៅក្រុងអយុធ្យា ទ្រង់បានយល់ព្រមតាមសំណូមរបស់ស្តេចធម្មរាជា ហើយទ្រង់បានបញ្ជាអោយលើកទ័ពចូលមកក្នុងប្រទេសខ្មែរ ។ ដោយយល់ឃើញថាប្រជានុរាស្ត្របានទៀយណាយនឹងសង្គ្រាមខ្លាំងពេកហើយ ព្រះបាទស្រីរាជាក៏ទ្រង់យល់ព្រមចូលមកជ្រះជ្រាបញ្ចប់សង្គ្រាម ។ ចំណែកឯខាងព្រះស្រីសុរិយោទ័យ ដោយពួករហ៍គលពុំព្រមច្បាំងតទៅទៀត ព្រះអង្គក៏ត្រូវបង្ខំព្រះហឫទ័យយាងចូលរួមក្នុងកិច្ចចរចារកសន្តិភាពដែរ ។ ជាកិច្ចដោះស្រាយ ព្រះចៅចក្រពត្រក៏បានសំរេចថាត្រូវតែចាប់ព្រះស្រីរាជានិងស្រីសុរិយោទ័យទៅគង់នៅឯស្រីអយុធ្យា ទើបប្រទេសខ្មែរបានសុខសន្តិភាពឡើងវិញ ។

ក្បួនខ្លះបាននិយាយថា ទៀតនកាលដែលប្រទេសខ្មែរកំពុងតែមានចលាចលដោយសង្គ្រាមរវាងស្រីរាជា និងស្រីសុរិយោទ័យ សៀមបានលើកទ័ពចូលមកច្បាំងយកបានចន្ទបុរីមហានគរវត្ត នគរសេមាហើយចាប់បានទាំងស្រីរាជា ទាំងស្រីសុរិយោទ័យ និងគ្រប់គ្រូនាំទៅស្រីអយុធ្យា ហើយទុកនាយគង់អោយនៅថែរក្សាស្រុកភ្នំពេញ ។ គ្រានោះ ស្តេចធម្មរាជាដែលទៅឈរនៅនគរវត្ត បានថយទៅបាភ្នំកទ័ពមកច្បាំងយកបានភ្នំពេញហើយឡើងសោយរាជ្យដោយមានព្រះនាមថា **ព្រះបាទសម្តេចព្រះរាជឱង្ការព្រះធម្មរាជាមហាចក្រពត្រាធិរាជ** ។

ក្បួនខ្លះទៀតបាននិយាយថា គឺស្រីសុរិយោទ័យអង្គឯងតែម្តងដែលបានទៅពឹងអោយសៀមជួយ (9) ។ ពួកនេះបានលើកទ័ពចូលមកវាយយកបាននគររាជ អង្គរ ចន្ទបូរ ។ ចំណែកឯធម្មរាជា ដែលមានភារកិច្ចការពារក្រុងចតុមុខក៏បែរជាក្បត់ចូលដៃជាមួយសត្រូវប្រទង់និងព្រះស្រីរាជា ជាស្តេចពេញច្បាប់ទៅវិញ ។ ស្រីសុរិយោទ័យលុះឃើញដូច្នោះក៏យាងទៅជួបនិងស្តេចសៀម តែត្រូវចាប់នាំយកទៅប្រទេសសៀម ។

គួរគប្បីបញ្ជាក់ថាព្រះស្រីរាជានិងស្រីសុរិយោទ័យសុទ្ធតែបានសុគតនៅប្រទេសសៀមទាំងពីរអង្គ (ក្បួនខ្លះថាសុគតនៅតាមផ្លូវ) ។ ព្រះស្រីរាជាមានបុត្រជាមួយ **អ្នកម្នាង**

www.budinst.gov.kh  www.elibraryofcambodia.org

**គេសរ** នាម **ចៅពញាអុង** ។ ចំណែកឯព្រះធម្មរាជាត្រូវបានអភិសេកអោយឡើងសោយរាជ្យ នៅ គ.ស. ១៤៨៦ ហើយប្រទេសខ្មែរក៏បានសុខរៀងមករហូតដល់ពេលសោយទិវង្គតនៅគ.ស. ១៥០៤ ។ ព្រះអង្គមានបុត្រពីរអង្គ :

**១ — ចៅពញាដាំខាត់រាជា** បុត្រអគ្គមហេសី **សម្តេចព្រះតេជតីស្រីទេពធីតា**

**២ — ពញាចន្ទរាជា** បុត្រ **អ្នកម្នាងទេពបុត្តា**

ឯកសារខ្លះបានបញ្ជាក់ថា ព្រះអង្គជាព្រះរាជាដែលទ្រង់ប្រកបដោយទសពិធរាជធម៌ យកព្រះហឫទ័យទុកដាក់ទីងក់សនាប្រជារាស្ត្រ និងព្រះពុទ្ធសាសនាខ្លាំងណាស់ ។ ព្រះអង្គទ្រង់បានសាងព្រះចេតិយនៅខេត្តអាសន្ទុក ដើម្បីតំកល់ព្រះសារីរិកធាតុហើយមានព្រះហឫទ័យប្រាថ្នាចង់បានជាពុទ្ធភូមិទៀតផង ។

* *

*

ក្នុងរយៈពេលជាងដប់ឆ្នាំគឺពី គ.ស.១៤៧៥ ដល់ ១៤៨៥ ប្រទេសខ្មែរបានជួបនូវវិបត្តិមួយដ៏ធ្ងន់ដែលបណ្តាលមកពីទំនាស់ក្នុងរាជវង្សដែលដឹកនាំជាតិក្នុងពេលនោះ ។ ចំបាំងដែលជាវិធីដែលគេប្រើសំរាប់ដោះស្រាយជម្លោះនោះ បានធ្វើអោយអាណាប្រជារាស្ត្រមានទុក្ខវេទនាយ៉ាងសម្បើម បានធ្វើអោយសេដ្ឋកិច្ចចុះនថយ និងជាពិសេសធ្វើអោយប្រជាជាតិខ្មែរធ្លាក់ផុនដាបជាលំដាប់ ។ នេះជាលើកទី១ក្នុងប្រវត្តិសាស្ត្រខ្មែរ ដែលគេឃើញមានស្តេចខ្មែរទៅអង្វរពីឯពាក់បរទេសជិតខាងអោយចូលមកជួយដោះស្រាយបញ្ហារបស់ជាតិឯងផ្ទាល់ នេះគឺគំរាប់អាក្រក់មួយសំរាប់ព្រះរាជាសោយរាជ្យតៗមក ហើយដែលបានរត់ទៅសុំជំនួយពីបរទេស ជាលេសអោយគេមានឱកាសលូកដៃចូលមកជ្រៀតជ្រែកក្នុងផ្ទៃក្នុងរបស់ខ្មែរ ហើយទាញយកផលប្រយោជន៍អោយគេ ។ នេះក៏ជាលើកទី១ដែរដែលមានស្តេចខ្មែរទៅរស់នៅឯបរទេស **(ពញាអុង)** ក្នុងការទំនុកបំរុងរបស់គេ ។ ចំពោះរឿងនេះលោក **Moura** បានចាត់ទុកថាជាគលយុទ្ធមួយរបស់ស្តេចសៀម សំរាប់ទុកជាគ្រូប្រជែងនឹងព្រះមហាក្សត្រខ្មែរអង្គណាដែលចង់រំដោះព្រះអង្គអោយរួចពីចំណុះរបស់សៀម **(10)** ។

www.budinst.gov.kh www.elibraryofcambodia.org

# ជំពូកទី ១០

# ប្រទេសខ្មែរនៅសតវត្សទី១៦ វិបត្តិក្នុងរាជវង្សខ្មែរនិងការគ្រៀតគ្រែករបស់សៀម

## ក- ចម្បាំងគ្នាឯងក្នុងស្រុក .-

ចម្បាំងគ្នាឯងក្នុងស្រុកដែលបានកើតឡើងជាលើកដំបូងក្នុងសង្គមខ្មែរនៅពាក់កណ្ដាលទី ២ នៃស.វ. ទី ១៥ ត្រូវបាត់ស្ងាត់ទៅអស់មួយរយៈពេលហើយបានកំរើកឡើងវិញយ៉ាងខ្លាំងនៅខាងដើមនៃ ស.វ. ទី ១៦ ។

### ១— ព្រះបាទស្រីសុគន្ធបទ (១៥០៤ - ១៥១២) និងការប្រែក្បត់របស់ស្ដេចកន .-

នៅពេលដែលព្រះបាទធម្មរាជា សោយទិវង្គត នៅ គ.ស. ១៥០៤ បុត្រច្បងរបស់ព្រះអង្គគឺ **ចៅពញាដាំខាត់ឆាជា** បានឡើងសោយរាជ្យស្នងព្រះអង្គ ដោយមានព្រះនាមសំរាប់រាជ្យថា **ព្រះបាទស្រីសុគន្ធបទ** គង់នៅរាជធានីចតុមុខ ។

ក្រោយបន្តិចមក ព្រះអង្គទ្រង់សព្វព្រះហឫទ័យលើករាជធានីទៅតាំងនៅ **ទួលបាសាន**

www.budinst.gov.kh www.elibraryofcambodia.org

វិញ ដោយព្រះអង្គទ្រង់យល់ថាទីនោះជាចំណុចយុទ្ធសាស្ត្រមួយ មានឧបសគ្គធម្មជាតិ (បឹងធំ ទន្លេ ព្រៃញឹក) ស្រួលការពារខ្លួនជាងនៅក្រុងចតុមុខ ។ ឯព្រះអនុជនាម **ពញាចន្ទរាជា** ត្រូវបានតែងតាំងជាមហាឧបរាជនៅ គ.ស. ១៥០៨ ហើយនៅការពារក្រុងចតុមុខមើលខុសត្រូវលើអាណាខេត្តត្រើយខាងលិច ។

រាជពង្សាវតារក្សនខ្លះបាននិយាយថា កាលដែលព្រះបាទ**ស្រីសុគន្ធបទ**យាងទៅគង់នៅរាជធានី**ទួលបាសាន**នោះ ព្រះអង្គបានលើកនាង **ស** (ឯកសារខ្លះថាឈ្មោះនាង **ពៅ**) ជាស្នំឯកមាននាមថា **កេសរបុប្ផា** ទើបស្រុកនោះមានឈ្មោះថា **ស្រីសឈរ** ដែលតមកទៀតបានក្លាយជា **ស្រីសន្ធរ** រៀងរហូតមក ។ នាង **ស** នេះជាកូនរបស់មន្ត្រីម្នាក់ឈ្មោះ **ពិជ័យនាគ** និងនាង **បាន** ដែលជាពលព្រះស្រីរតនត្រ័យ ។ ប្អូនប្រុសរបស់នាង **ស** ឈ្មោះ **កៅឬគន** ត្រូវបានតែងតាំងជាមហាតលិក ក្រោយមកទៀត បានឡើងឋានៈជា **ឃុនហ្លួងព្រះស្ដេច** មាននាទីមើលខុសត្រូវលើពលព្រះខាំងអស់ និងលើកិរិយាមារយាទនៃពលវង្គទូទៅ ។

រាជពង្សាវតារបាននិយាយទៀតថា នៅ គ.ស. ១៥១៩ ព្រះបាទ **ស្រីសុគន្ធបទ** ទ្រង់សុបិនឃើញនាគរាជដេញខាំព្រះអង្គ ហើយខាំពាំស្វេតច្ឆត្រ ថែមទៀត ។ ព្រះអង្គទ្រង់បញ្ជាអោយហោរទាយ ជាមានគោលាហល អ្នកបង្កគឺ **ឃុនហ្លួងព្រះស្ដេចគន** ដែលកើតនៅឆ្នាំរោង (នាគ) ។ ស្របពេលជាមួយគ្នានោះមានពាក្យបណ្ដឹងមកថា មានកើតហេតុចម្លែកផ្សេង ៗ នៅក្នុងព្រះរាជាណាចក្រ ។ ដោយខ្លាចក្រែង**ស្ដេចគន**ក្បត់ដណ្ដើមរាជសម្បត្តិ សមដូចទំនាយរបស់ហោរានោះ ព្រះរាជាទ្រង់បានធ្វើការប្រជុំសម្ងាត់នៃពួកមន្ត្រីជំនិត ដើម្បីរករកមធ្យោបាយកំចាត់ **ស្ដេចគន** អោយបាន តែស្នំឯកលបលួចស្ដាប់ដឹងការណ៍ ហើយផ្ញើសំបុត្រទៅប្រាប់ប្អូនព្រះនាងយ៉ាងប្រញាប់ ។

តមក ព្រះរាជាទ្រង់បញ្ជាអោយពួកមន្ត្រីរៀបចំដង្ហែព្រះអង្គទៅក្រសាលបឹង បង់សំណាញ់កំសាន្តទៅតាមចំណូលព្រះហឫទ័យរបស់ព្រះអង្គដែលធ្លាប់តែធ្វើពីមុនរៀងមក ។ **ស្ដេចគន**ក៏ត្រូវបានគេចាត់អោយទៅហែហមព្រះរាជាជាមួយនឹងមន្ត្រីឯទៀត ១ ផែរ ។ ដូច

www.budinst.gov.kh www.elibraryofcambodia.org

[illegible]ស្រេច ព្រះរាជាទ្រង់ធ្វើកលថា សំណាញ់ព្រះអង្គជាប់សំរាស់សើកញាំង ហើយទ្រង់បញ្ជាអោយ**ស្តេចគន**មុជទឹកទៅដោះ ។ **ស្តេចគន** ទទួលបញ្ជាហើយលោតទៅក្នុងទឹកធ្វើហាក់ដូចជាពុំដឹងខ្លួន ហើយមុជដយចេញពីកន្លែងនោះអោយឆ្ងាយទៅ ។ ពេលនោះពួកបរិវារដែលជាជំនិតស្មានថា **ស្តេចគន** បានធ្លាក់ខ្លួនអន្ទាក់របស់ខ្លួនហើយ ក៏ប្រញាប់បង់សំណាញ់ព្រមគ្នាគ្របត្រង់កន្លែងដែល **ស្តេចគន** លោតចុះទៅនោះ ដោយមានចេតនាធ្វើអោយ **ស្តេចគន** ជាប់សំណាញ់មិនរួច ស្លាប់នៅក្នុងទឹកនោះទៅ ។

លុះបានបាក់ផុតពីគ្រោះថ្នាក់ហើយ **ស្តេចគន** បានភៀសខ្លួនទៅដល់ខេត្តបាភ្នំ ហើយប្រើឧបាយកលបោកបញ្ឆោតពួកចៅហ្វាយខេត្តថា ខ្លួនបានទទួលបញ្ជាពីព្រះរាជាអោយមកកេណ្ឌទ័ពទៅកំចាត់មហាឧបរាជ **ចន្ទរាជា** ដែលមានចិត្តក្បត់ចង់ឡើងសោយរាជ្យនៅក្រុងចតុមុខ ។ ព្រះរាជា លុះបានជ្រាបដំណឹងថា **ស្តេចគន** នៅរស់ហើយបានកកើតប្រ-ឆាំងព្រះអង្គថែមទៀត ក៏ទ្រង់បញ្ជាអោយចាប់ឪពុកនិងបងស្រី **ស្តេចគន** សរសេរសំបុត្រហៅត្រឡប់ទៅវិញ ។ **ស្តេចគន** ប្រើឧបាយម្តងទៀត ដោយប្រាប់ទៅពួកចៅហ្វាយខេត្តនិងអ្នកស្រុកថា ហ្លួងទ្រង់គៀរគំរៀងសង្គ្រាមទៅវិញ ។

ពាក្យចចាមអារ៉ាមរបស់**ស្តេចគន**បានលេចលឺទៅដល់មហាឧបរាជ **ចន្ទរាជា** ។ ព្រះអង្គនឹកស្មានថាមានហេតុមិនស្រួល ក៏នាំព្រះរាជវង្សានុវង្សប្រញាប់ប្រញាល់ភៀសខ្លួនទៅសុំជ្រកកោននឹងស្តេចសៀមទៅ ។ កាលដែលយាងមកដល់ខេត្តពោធិ៍សាត់ ព្រះ**ចន្ទរាជា** ទ្រង់បានទៅសំណាក់ផ្ទះមន្ត្រីម្នាក់ឈ្មោះ **ពេជ** ហើយទ្រង់បានទទួលការឧបត្ថម្ភផ្សេង ៗ ពីមន្ត្រីរូបនេះ ។

លុះដឹងថាព្រះ **ចន្ទរាជា** ព្រះអនុជ **ស្រីសុគន្ធបទ** បានយាងចេញផុតពីប្រទេសហើយ **ស្តេចគន** ក៏ចាប់ផ្តើមការកេណ្ឌលុកលុយរាជធានីចតុមុខ ។ ព្រះរាជាទ្រង់បានច្បាំងតទល់ផ្ទាល់ព្រះអង្គ តែត្រូវទទួលបរាជ័យ ហើយថយទៅកាន់ទីតាំងនៅព្រែកឫស្សី ។ **ស្តេចគន** លើកទ័ពដេញតាមវាយបែកបន្ទាយភ្នំពេញទៀត ព្រះបាទ **ស្រី-សុគន្ធបទ** ដែលទៅគង់នៅលង្វែក ។ លុះបន្ទាយលង្វែកត្រូវវាយបែក ព្រះអង្គក៏យាង

www.budinst.gov.kh www.elibraryofcambodia.org

ទៅគង់នៅស្រុកបរិបូណ៌ ( **អម្រិន្ទបុរ** ) រួចទៅទីបំផុត ទៅគង់នៅបន្ទាយស្នងសែន ខេត្តអាសន្ទុកនៅ គ.ស. ១៥១២ ។ ពេលនោះ **ឃុនហ្លួងព្រះស្តេចកន** ទៅតាំងទ័ពបោះបន្ទាយនៅទួលបាសាន ហើយព្រាហ្មណ៍ធ្វើពិធីលើកខ្លួនឯងឡើងជាមហាឧបរាជ ។ រួចស្រេចហើយ ទ្រង់បានបញ្ជាអោយទ័ពលើកទ្ទ័ងទៅបោះនៅកំពង់សៀមទៀត ។ **ស្តេចកន** បានក្រេងសំបុត្រផ្ញើទៅហ្លួងសុំចុះចូល តែសុំអោយម្តាយនិងបងប្អូនបានមកមុនសិន ។ ហ្លួងបញ្ជាអោយឆ្លើយវិញថាត្រូវតែ **ស្តេចកន** ចូលខ្លួនមកមុន បើពុំដូច្នោះទេនឹងសម្លាប់ម្តាយនិងបងប្អូនទាំងអស់ ។ **ស្តេចកន** លើកទ័ពទៅជិតអាសន្ទុក រកឧបាយយកម្តាយនិងញាតិសន្តានមកវិញ ។ ពេលនោះ មានមន្ត្រីម្នាក់ស្ម័គ្រចិត្តទទួលបំពេញកិច្ចការនេះថ្វាយ **ស្តេចកន** ឈ្មោះ **ឱកម៉ឺនសុរិន្ទកែវ** ។ កលនោះគឺគេចោទថាមន្ត្រីរូបនេះក្បត់ ស្រាប់តែមានទាហាន ២០០ នាក់ជួយយកអាសា នាំទៅខាងបន្ទាយហ្លួងសុំចុះចូល ។ បន្ទាប់មក **ឃុនហ្លួងព្រះស្តេចកន** នាំទ័ពចូលវាយលុកបន្ទាយស្នងសែនយ៉ាងខ្លាំង ។ ដោយទ្រង់ឈ្លងយល់ថាមិនអាចទប់ទល់យូរអង្វែងតទៅទៀតបាន ព្រះរាជាក៏ដកថយតាមជើងទឹកទៅកាន់ខេត្តពោធិ៍សាត់ តែពេលនោះ **ឱកម៉ឺនសុរិន្ទកែវ** និងបក្សពួកបះឡើងចូលចោមធ្វើគត់ព្រះអង្គបានក្នុងបន្ទាយស្នងសែននោះ នៅ គ.ស. ១៥១២ ។ ព្រះរាជបុត្ររបស់ព្រះអង្គនាម **ពញាយសរាជា** ( បុត្រជាមួយម្នាងកេសរបុប្ផា ) និងបរិវារមួយក្រុមបានគៀសទៅជ្រកកោនក្នុងប្រទេសសៀមជាមួយព្រះ **ចន្ទរាជា** ។

**ឃុនហ្លួងព្រះស្តេចកន** ត្រឡប់មកទួលបាសានវិញ ប្រកាសអោយរកព្រះខាន់រាជ្យ ព្រះលំពែងជ័យនិងគ្រឿងព្រះបញ្ចក្សត្រដើម្បីឡើងសោយរាជសម្បត្តិ ។ រាជពង្សាវតារខ្លះបានបញ្ជាក់ថា កាលដែលឡើងសោយរាជ្យនោះ **ស្តេចកន** មានព្រះជន្មាយុទើបតែបាន ២៩វស្សា ហើយមាននាមសំរាប់រាជ្យថា **ស្រីជេដ្ឋាធិរាជរាមាធិបតី** ។ ព្រះអង្គទ្រង់បានបញ្ជាអោយមេទ័ព **កៅ** ដែលត្រូវជាឪពុកមាបង្កើត អោយលើកទៅបង្ក្រាបយកខេត្តទាំងឡាយណាដែលមិនទាន់ចុះចូលព្រះអង្គនៅឡើយ ។ លុះបានសុខសន្តិភាពបរិបូណ៌ឡើងវិញហើយ ព្រះអង្គទ្រង់លើកឪពុកមាអោយឡើងឋានៈជាសម្តេចចៅហ្វាទឡ្ហៈ ឯពួកបរិវារឯទៀតក៏បានទទួលយសសក្តិទៅតាមគុណបំណាច់រៀងៗខ្លួនដែរ ។

www.budinst.gov.kh www.elibraryofcambodia.org

នៅប្រមាណ គ.ស. ១៥១៤ ព្រះបាទ **ស្រីជេដ្ឋា** ទ្រង់បានលើករាជធានីទៅតាំងនៅ **ចន្ទក់ជួនគិរី** (នៅបានតែ ៥ ខែ) រួចលើកទៅតាំងនៅភូមិស្រឡប់នៅទល់ដែនខេត្តត្បូងឃ្មុំ និងខេត្តបាភ្នំ ៖ រាជធានីថ្មីនេះជាបន្ទាយមួយយ៉ាងមាំដែលព្រះអង្គប្រទានឈ្មោះថា ក្រុង **ស្រឡប់ពិជ័យព្រៃនគរ** ។

រាជពង្សាវតារខ្លះបានបញ្ជាក់ថា ព្រះបាទ **ស្រីជេដ្ឋា** ទ្រង់មានចំណូលហឫទ័យខាងបរបាញ់សត្វ ចាប់ត្រី ល្បែងស្រី ទតទាំមហោស្រព តន្ត្រី ។ ក្នុងរជ្ជកាលរបស់ព្រះអង្គ មានបោះប្រាក់ស្លឹង (សាច់ប្រាក់សុទ្ធ) មានរូបនាគសំរាប់ប្រើប្រាស់ក្នុងប្រទេស ហើយមានប្រវត្តិវិទូខ្លះបានសង្កត់សេចក្ដីថា នៅសម័យនោះអាណាប្រជានុរាស្ត្របានសុខសម្បូណ៌-សប្បាយថែមទៀតផង (11) ។

## ២ - ចម្បាំងព្រះបាទស្រីជេដ្ឋា និង ព្រះចន្ទរាជា (១៥១៦-១៥២៥).—

និយាយពីព្រះ **ចន្ទរាជា** កាលដែលទៅសុំជ្រកកោនជាមួយព្រះចៅសៀមនោះ តែងតែយករបរទាក់ដំរីទៅបំរើព្រះអង្គ ។ លុះទ្រង់ជ្រាបថាព្រះរៀមត្រូវបក្សពួក **ឃុនហ្លួងព្រះស្ដេចកន** ធ្វើគត់បានហើយ ព្រះ **ចន្ទរាជា** ទ្រង់រករកគ្រប់មធ្យោបាយដើម្បីបាននិវត្តត្រឡប់ចូលមាតុប្រទេសវិញ ។ នៅ គ.ស. ១៥១៥ ព្រះអង្គទាក់បានដំរីសមកទៅថ្វាយព្រះចៅសៀម ហើយសុំអនុញ្ញាត អោយធ្វើនិវត្តន៍ចូលស្រុកវិញ តែពុំបានសំរេចដូចប្រាថ្នាឡើយៗ ដោយហេតុនោះ ព្រះអង្គក៏ទ្រង់ប្រឌិតថា មានដំរីសខ្ពស់ ១០ ហត្ថ (ខម.) នៅក្នុងព្រៃភូមិ-ភាគខាងកើតនៃប្រទេសសៀម ។ លុះទ្រង់ជ្រាបដំណឹងនេះហើយ ព្រះចៅសៀមក៏ទ្រង់ត្រាស់បញ្ជាអោយព្រះ **ចន្ទរាជា** ចេញទៅទាក់ដំរីនោះយកមកថ្វាយព្រះអង្គអោយបាន ។ ក្នុងការបំពេញបេសកកម្មក្លែងបន្លំនេះ ព្រះ **ចន្ទរាជា** ទ្រង់បានទូលសុំពលចំនួន ៥ ០០០ នាក់ ដំរីធ្លាក់ ១០០ គ្រឿងសស្ត្រាវុធ ស្បៀងអាហារ និងដាវអាជ្ញាសឹក ។ ព្រះចៅសៀមក៏ទ្រង់បានយល់ព្រមតាមសំណូមពរគ្រប់ប្រការ ។

នៅ គ.ស. ១៥១៦ មុននឹងចេញបំពេញបេសកកម្មទាក់ដំរីនេះ ព្រះ **ចន្ទរាជា** ទ្រង់

www.budinst.gov.kh www.elibraryofcambodia.org

បានយាងទៅជួបជាសម្ងាត់ជាមួយ នឹង **ពញាអុង** ហើយបបួលព្រះអង្គអោយវិលត្រឡប់ចូលប្រទេសវិញ ។ កាលណោះ **ពញាអុង** ជាបុត្រធម៌របស់ព្រះចៅសៀម ហើយត្រូវបានតែងតាំងអោយកាន់តំណែងជាចៅហ្វាយខេត្ត **សុវណ្ណខាត់លោក** ផងទៀត ។ ព្រះអង្គទ្រង់បានប្រកែកពុំព្រមវិលចូលមាតុប្រទេសទេ ដោយទ្រង់យល់ថា បានសុខសាន្តនិងបានយសសក្តិគ្រប់សព្វណាស់ទៅហើយ ។

ដោយមិនអាចទាក់ទាញ **ពញាអុង** អោយធ្វើតាមព្រះអង្គទេ ព្រះ **ចន្ទរាជា** ទ្រង់បញ្ជាទ័ពអោយធ្វើដំណើរឆ្ពោះទៅទិសខាងកើត ធ្វើហាក់ដូចជាទៅតាមដានដំរីស ហើយនៅទីបំផុតបានទៅដល់ព្រំដែនប្រទេសខ្មែរ ។ ព្រះ **ចន្ទរាជា** ទ្រង់ចាត់អោយគេនាំសារទៅថ្វាយព្រះចៅសៀមថា សុំទ័ពជាបន្ថែមទៀត ។ ប៉ុន្តែ **ពញាអុង** បានទូលថ្វាយពីល្បិចកិច្ចកលគ្រប់សព្វរបស់ព្រះ **ចន្ទរាជា** ព្រះចៅសៀមទ្រង់ខ្ញាល់ណាស់ ហើយទ្រង់បញ្ជាអោយលើកទ័ពទៅនាំព្រះ **ចន្ទរាជា** មកវិញ ។ ក្នុងកំឡុងពេលនោះ ព្រះ **ចន្ទរាជា** បានលើកទ័ពចូលក្នុងដីខ្មែររួចជាស្រេច ។ លុះទៅដល់បាត់ដំបង ព្រះអង្គកេនបានពល ១០ ០០០ នាក់ ហើយលើកបន្តស់ឆ្ពោះទៅអាពាធ៍សាត់ ។ លោកឧកញ៉ា **សួគ៌ាលោកកែវ** ចៅ-ហ្វាយស្រុកខេត្តនេះ លុះបានដឹងហើយក៏ប្រញាប់ចាត់អោយនាំដំណឹងនេះទៅថ្វាយព្រះបាទ **ស្រីជេដ្ឋាធិរាជ** ។ ចំណែកឯតា **ពេជ** បានប្រមូលបក្សពួក ហើយទៅវាយទុកលុកចូលបន្ទាយ ហើយសម្លាប់ ចៅហ្វាយស្រុក **កែវ** បាន ។ គាត់ក៏រឹតទំបញ្ចុះបញ្ចូលអោយពលទាហានចូលខាងព្រះ **ចន្ទរាជា** ។ ព្រះអង្គសព្វព្រះហឫទ័យយ៉ាងខ្លាំងចំពោះថ្វីដៃរបស់តា **ពេជ** ហើយបានតាំងគាត់ជា **ចៅពញាសួគ៌ាលោក** ជាជំនួស **ឧកញ៉ាកែវ** ។ ម្យ៉ាងទៀត ព្រះ **ចន្ទរាជា** បានតែងតាំងតា **ពេជ** ជាមេទ័ពធំនិងកូនទាំង ៤ នាក់របស់គាត់ជាមេទ័ពរង ហើយទ្រង់បញ្ជាអោយលើកទៅវាយយកខេត្តក្រគរ ខ្ទុំ ក្រង ។

លុះបានទទួលដំណឹងពីការវិលត្រឡប់មកវិញរបស់ព្រះ **ចន្ទរាជា** ភ្លាម ព្រះបាទ **ស្រីជេដ្ឋា** ទ្រង់បានបញ្ជាអោយចៅហ្វ៊ា **កែវ** លើកទ័ពទៅតទល់នៅត្រង់ក្រគរ ។ ដោយមានពលទាហានស្លាប់ច្រើនពេក តា **ពេជ** បញ្ជាអោយទ័ពថយចូលទៅក្នុងបន្ទាយពោធិ៍-សាត់សិន ។ ទ័ពខាងព្រះបាទ **ស្រីជេដ្ឋា** ក៏ដេញតាម ហើយទៅព័ទ្ធបន្ទាយជាប់អស់


www.budinst.gov.kh www.elibraryofcambodia.org
BUDDHIST INSTITUTE LIBRARY

[illegible] ថ្ងៃ ដែលឃើញកងពលតិចបានកោះ ក៏ដកថយទៅតាំងទ័ពឆ្ងាយពីនោះ ដើម្បីរង់ចាំកងជំនួយមកដល់ ។

គឺនៅក្នុងកាលៈទេសៈបែបនោះហើយដែលគា **៣៥** បានធ្វើពលិកម្មបូជាជីវិតដើម្បីទៅកែនទ័ពបិសាចមកជាទ័ពជំនួយ ។ បន្ទាប់ពីនោះ ការប្រយុទ្ធបង្ហូរឈាមបានកើតឡើងសាជាថ្មីទៀតរវាង ទ័ពព្រះ **ចន្ទរាជា** និងទ័ពព្រះបាទ **ស្រីជេដ្ឋា** ។ នៅលើកនេះជ័យជំនះត្រូវបានទៅខាង ព្រះ **ចន្ទរាជា**ចំណែកឯចៅហ្វា **កៅ** បាក់ទ័ពថយទៅត្រើយខាងកើតវិញ ។

ក្នុងដំណើរជំរុលទៅមុខ ព្រះ **ចន្ទរាជា** បានលើកទ័ពវាយយកបានខេត្តជាច្រើនជាបន្តបន្ទាប់គ្នា គឺ ក្រគរ ខ្ទះ ក្រង បរិបូណ៌ កំពង់សៀម ជើងព្រៃ ស្ទឹងត្រង់ ។ គ្រានោះ មានពួកខាងព្រះបាទ **ស្រីជេដ្ឋា** ដែលទទួលបរាជ័យនោះមកសុំចុះចូលជាច្រើន ឯពួកដែលរត់ពួនកាលព្រះបាទ **ស្រីសុគន្ធបទ** ច្បាំងចាញ់ ឥឡូវ ចេញមកថ្វាយខ្លួនទាំងអស់ ។ ពួកនោះបានសុំអោយព្រះ **ចន្ទរាជា** ឡើងសោយរាជ្យ ព្រះអង្គក៏ព្រមឡើងគ្រងរាជ្យសិន ដោយមានព្រះនាមសំរាប់រាជ្យថា **ព្រះបរមរាជាចន្ទរាជា** នៅ គ.ស. ១៥១៦ ។

នៅឆ្នាំបន្ទាប់ ( គ.ស. ១៥១៧ ) ដោយត្រូវទទួលបរាជ័យអស់ច្រើនលើកច្រើនសាមកហើយ ព្រះបាទ **ស្រីជេដ្ឋា** ទ្រង់ស្នើទៅព្រះ **ចន្ទរាជា** អោយផ្អាកសង្គ្រាមដើម្បីអោយរាស្ត្រធ្វើស្រែសិន ។ សំណើនេះក៏បានទទួលសេចក្ដីយល់ព្រមពីព្រះ **ចន្ទរាជា** ។

ដល់ពេលចេញវស្សា ព្រះបាទ **ស្រីជេដ្ឋា** បានផ្ដើមការវាយលុកម្ដងទៀតដោយមានប្រើកលល្បិចអោយទាហានសុំចុះចូលខាងព្រះ **ចន្ទរាជា** ផងក្នុងបំណងធ្វើគត់ស្ដេចអង្គនេះអោយបាន តែមិនបានសំរេច ឯខាងព្រះ **ចន្ទរាជា** ក៏មានប្រើល្បិចដូចគ្នាហើយមិនបានសំរេចដូចគ្នាដែរ ។ ព្រះអង្គក៏ថយទៅគង់នៅខេត្តពោធិ៍សាត់ ។ នៅគ.ស. ១៥២០ អគ្គមហេសីគឺ **សម្ដេចតគគចតី សិរីចក្រពត្តិ** បានប្រសូតបុត្រនាម **ព្រះរាមាធិបតី** ហើយឆ្នាំបន្ទាប់មក ស្នំឯក **មនុមបុប្ផា** បានប្រសូតបុត្រនាមព្រះ **បរមេន្ទរាជា** ។

នៅគ.ស. ១៥២៥ ព្រះ **ចន្ទរាជា** ក្រោយដែលទ្រង់បានចាត់អោយទៅទិញកាំភ្លើង

www.budinst.gov.kh www.elibraryofcambodia.org

ពិតួចពីប្រទេសម៉ាឡាយូមក ទ្រង់បានផ្ដើមការវាយលុកទៅលើទ័ពព្រះបាទ **ស្រីជេដ្ឋា** ដែលទ្រង់បានរៀបចំធ្វើចម្បាំងដូចគ្នានេះដែរ ។ ព្រះ **ចន្ទរាជា** បានលើកទ័ពចេញជាបីជួរ ។ ព្រះអង្គទ្រង់នាំទ័ពទៅវាយបន្ទាយស្រីសឈរដោយផ្ទាល់ព្រះអង្គ ។ ព្រះបាទ **ស្រីជេដ្ឋា** និងចៅហ៊្វា **កៅ** ទំវាយទម្លុះគេចូលទៅក្នុងបន្ទាយ **ស្រឡប់ពិជ័យ** ។ ព្រះ **ចន្ទរាជា** បញ្ជាអោយលើកទ័ពទៅវាយបន្ទាយនោះទៀត ។ នៅទីបំផុត ក្រោយពីបានតស៊ូយ៉ាងប្ដូរផ្ដាច់អស់រយៈពេល ៣ ខែមក ព្រះបាទ **ស្រីជេដ្ឋា** ត្រូវគេកាត់ព្រះសិរបានយកទៅដោតនៅមុខបន្ទាយក្រុង **ស្រឡប់ពិជ័យ** ឯចៅហ៊្វា **កៅ** ក៏ត្រូវគេសម្លាប់បានក្នុងបន្ទាយនោះដែរ ។ ដូច្នេះ សង្គ្រាមគ្នាឯងដែលមានរយៈពេល ៩ ឆ្នាំ (១៥១៦ - ១៥២៥) ត្រូវបានបញ្ចប់នៅពេលនោះទៅ ។






www.budinst.gov.kh www.elibraryofcambodia.org

## ៣- ការកសាងក្រុងលង្វែកនិងការប៉ុនប៉ងរំដោះអាណាខេត្តខាងលិច

### ១- ព្រះបាទចន្ទរាជា (១៥១៦-១៥៦៦) និងចំណាត់ចំណងជាមួយជនជាតិអឺរ៉ុប.-

ដោយ **ពញាយសរាជា** រាជបុត្ររបស់ព្រះបាទ **ស្រីសុគន្ធបទ** សោយទីវង្គតទៅ ព្រ[ះ] **ចន្ទរាជា** ទ្រង់បានយល់ព្រមឡើងគ្រងរាជ្យតាំងពី គ.ស. ១៥១៦ ម្ល៉េះទៅតាមសំណូមព[រ] របស់រាជវង្សានុវង្ស និង នាម៉ឺនសព្វមុខមន្ត្រីរបស់ព្រះអង្គ ។ ក្រោយពីបានទទួលមហា ជោគជ័យលើព្រះបាទ **ស្រីជេដ្ឋា** ហើយក៏ព្រះអង្គនៅតែបន្តការគ្រងរាជ្យតទៅទៀត ឯពិ[ធី] រាជាភិសេកឡើងសោយរាជ្យមិនត្រូវប្រារព្ធធ្វើនៅពេលក្រោយទៀត ពីព្រោះពេលដែល[...] រកឃើញព្រះខាន់រាជ្យ លំពែងជ័យ និង គ្រឿងបញ្ចក្សត្រ ។ ព្រះអង្គមានរាជធានីតាំ[ង] ជាបណ្ដោះអាសន្ននៅក្នុងខេត្តពោធិសាត់ ។

### ១-១- ការកសាងក្រុងលង្វែក.-

ក្រោយមក ព្រះអង្គទ្រង់សព្វព្រះរាជហឫទ័យលើករាជធានីមកតាំងនៅក្រុង **លង្វែ[ក]** វិញ ។ រាជធានីថ្មីនេះត្រូវបានកសាងឡើងអស់រយៈពេលប្រហែល ៣ ឆ្នាំ គឺ ពី គ.ស[.] ១៥២៧ ដល់ ១៥២៩ ។ ឯហេតុដែលនាំអោយជ្រើសរើសយកលង្វែក ដើម្បីជាទីតាំ[ង] រាជធានីថ្មីនេះ គឺព្រះ **ចន្ទរាជា** ទ្រង់ឈ្វេងយល់ថាកន្លែងនោះជាចំណុចយុទ្ធសាស្ត្រមួយ ស្រួលការពារខ្លួន ព្រោះនៅពីក្រោយនោះមានទន្លេ អាងបឹង និង មានព្រៃទៀតផង ។ បន្ទាយនេះមានរាងបួនជ្រុងទ្រវែង ទទឹងមានប្រវែង ២ គ.ម. ឯបណ្ដោយមានប្រវែងជិ[ត] ៣ គ.ម. មានកំពែងដី គូទឹក និងរបងឫស្សីកំរាស់ពីរសិន (១៦០ ម) ព័ទ្ធជុំវិញ (សូមមើល ផែនទី ដែលយើងបានគូរតាមពត៌មានផ្ដល់ដោយលោក អ៊ុក អ៊ូ ដែលបានកាន់តំណែងជា មេឃុំ ឃុំលង្វែកអស់រយៈពេលជាង ១០ ឆ្នាំ និងតាមការដែលយើងបានទៅពិនិត្យដល់ ទីកន្លែងកាលពីថ្ងៃ ទី ៨ ខែ មីនា ១៩៧០ នៅតំបន់ឧដុង្គនិងលង្វែក) ។ តាមពាក្យជ-

www.budinst.gov.kh www.elibraryofcambodia.org



www.budinst.gov.kh www.elibraryofcambodia.org

ណាលេត ៗ មក គេថាលង្វែកជាបន្ទាយមួយធំសមៀមអស្ចារ្យណាស់ សូម្បីតែសេះដែលមានកម្លាំងខ្លាំងក្លាយ៉ាងណាក៏ដោយ ក៏មិនអាចបោលអោយជុំបន្ទាយនេះបានឡើយ ។ ម្យ៉ាងទៀត តាមជំនឿរបស់ខ្មែរយើងថា នៅក្នុងបន្ទាយលង្វែកនេះគេមានតំកល់រូបបដិមា **ព្រះគោ** មួយអង្គនិង **ព្រះកែវ** មួយអង្គ ដែលជាបងប្អូនបង្កើតនឹងគ្នា ហើយដែលអ្នកស្រុកតែងតែគោរពបូជាទុកជាវត្ថុសក្តិសិទ្ធ ។ ដោយហេតុនោះ គេតែងតែយកក្បួនច្បាប់ផ្សេងៗទៅទុកនៅក្នុងពោះ ព្រះគោ នោះ(12) ។ ទោះបីជំនឿខាងលើនេះមានលក្ខណៈជារឿងព្រេងក៏ដោយ ក៏ចំណុចនេះបង្ហាញអោយយើងឃើញថាលង្វែកជាបន្ទាយមួយមាំមួនសំរាប់ការពារសត្រូវឈ្លានពានដែន និងជាឃ្លាំងវប្បធម៌មួយរបស់ជាតិបន្ទាប់ពីរាជធានី **អង្គរ** មកផង ។

លុះការស្ថាបនាព្រះរាជវាំងនិងដំណាក់ដំកល់បានចប់សព្វគ្រប់ហើយ ព្រះបាទ **ចន្ទរាជា** ទ្រង់យាងមកគង់នៅរាជធានីថ្មីនេះប្រមាណឆ្នាំ ១៥២៩ ។ ព្រះអង្គជាមហាក្សត្រមួយអង្គដែលមានជំនឿមុតមាំលើព្រះពុទ្ធសាសនា ។ ក្រៅពីវត្តអារាមជាច្រើនដែលព្រះអង្គទ្រង់បញ្ជាអោយសាងនៅពោធិ៍សាត់និង **បរិបូណ៌** និង អោយសាងនិងជួសជុលនៅ **ឧដុង្គ** មានវត្តលើ **ភ្នំព្រះរាជទ្រព្យ** ជាដើម (ព្រះពុទ្ធរូបចូលនិព្វាន) ព្រះអង្គបានអោយសាង **វត្តត្រឡែងកែង** នៅក្នុងបន្ទាយលង្វែកទៀត ។ តាមដែលមើលឃើញសព្វថ្ងៃ ព្រះវិហារវត្តនេះស្ថិតនៅលើដីទួលមួយមានរាងជាជើងក្អែក ។ ក្នុងព្រះវិហារ មានតំកល់ព្រះ **ពុទ្ធរូបត្រឡែងកែង** គឺព្រះពុទ្ធរូប ៤ អង្គគង់ឈរ ទល់ព្រះប្រឹស្ឋ (ខ្នង) នឹងគ្នា ហើយបែរព្រះភក្ត្រទៅទិសទាំង ៤ ។ ក្នុងសម័យនោះ ខ្មែរយើងបានចាត់ទុកថាព្រះពុទ្ធរូបត្រឡែងកែងនេះជាវត្ថុសក្តិសិទ្ធិមួយដែរ ។

## ១-២- ទំនាក់ទំនងជាមួយសៀម.

លុះដឹងថាព្រះ **ព្រះចន្ទរាជា** បានកាន់កាប់អំណាចសិប់នៅប្រទេសខ្មែរហើយ ហើយដោយចាត់ទុកថា ប្រទេសនេះជាចំណុះប្រទេសសៀមតាំងពីរាជព្រះបាទ **ធម្មរាជា** ទី ១ មក-


www.budinst.gov.kh www.elibraryofcambodia.org

ម្ទើះនោះ ព្រះចៅសៀមបានចាត់ទូតមកបញ្ជាអោយព្រះ **ចន្ទរាជា** លើកស្ទួយសាអាករជាសត្វដំរីសេះទៅថ្វាយតាមទំលាប់ពីមុនរៀងមក ។ ដោយព្រះ **ចន្ទរាជា** ទ្រង់ប្រកែកមិនព្រមចំណុះសៀម សៀមលើកទ័ពចូលមកលុកលុយខេត្តអង្គរ ។ ព្រះអង្គទ្រង់កែនទ័ពហើយលើកទៅតទល់នៅត្រង់ស្ទឹងអង្គរ ត្រង់ភូមិមួយដែលជាប់ឈ្មោះហៅថា **សៀមរាប** ហេតុដល់សព្វថ្ងៃ ជាអនុស្សាវរីយ៍នៃជោគជ័យរបស់ខ្មែរទៅលើសត្រូវឈ្លានពាន ។ ក្បួនរាជពង្សាវតារខ្លះបានបញ្ជាក់ថាក្នុងការប្រយុទ្ធលើកនេះ ខ្មែរចាប់បានឈ្លើយសង្គ្រាមអស់ជាច្រើន ។ ដើម្បីជាការសងសឹក នៅគ.ស. ១៥៣០ ព្រះចៅសៀមទ្រង់បញ្ជាអោយ**ពញាអុច**លើកទ័ព ៩ ម៉ឺននាក់ មកវាយខ្មែរម្តងទៀត ។ ព្រះ **ចន្ទរាជា** ទ្រង់លើកទ័ពទៅតទល់គ្នានៅពោធិ៍សាត់ ។ នៅតាមផ្លូវពីលង្វែកទៅសមរភូមិ ព្រះអង្គទ្រង់ទតឃើញដើមពោធិ៍ ១ ដើមងាប់យូរហើយ តែលាស់ឡើងវិញ ។ ដោយទ្រង់ឈ្ងល់ថា នេះជាប្រផ្នូលល្អ ព្រះអង្គទ្រង់យក ផ្កា ស្លា ម្លូ ទៀន ធូប ទៅធ្វើការបូជា ហើយលើកទ័ពចេញទៅច្បាំងបានទទួលជោគជ័យយ៉ាងត្រចះត្រចង់ដូចប្រាថ្នា ។ ឯទ័ពសៀមដែលមកឡើងគោកនៅត្រង់ឈូងសមុទ្រសៀមនោះ ក៏ត្រូវក្រឡាហោមខ្មែរវាយអោយបាក់ទ័ពថយទៅវិញដែរ ។ ប្រភពខ្លះបានបញ្ជាក់ទៀតថា ក្នុងចម្បាំងដើងគោកនៅពោធិ៍សាត់ មេទ័ពសៀមត្រូវស្លាប់អស់ជាច្រើន ក្នុងចំណោមនោះមាន **ពញាអុច** ផងដែរ ដែលត្រូវព្រួញនៅលើខ្នងដំរី ឯពលទាហានស្លាប់អស់ពាក់កណ្តាល ដំរីងាប់អស់ច្រើន អាវុធយុទ្ធភ័ណ្ឌក៏ត្រូវរឹបអូសអស់រន្ទឹកសន្ធាប់ ។ ព្រះ **ចន្ទរាជា** ទ្រង់បញ្ជាអោយធ្វើបុណ្យថ្វាយព្រះភ្លើងព្រះសព **ពញាអុច** សាងព្រះវិហារបញ្ចុះធាតុ ឯដើមពោធិ៍ដែលរស់ឡើងវិញនោះទ្រង់ត្រាស់អោយហៅ **ព្រះពោធិមានបុណ្យ** រួចទ្រង់យាងត្រឡប់ចូលបន្ទាយលង្វែកវិញ ។

នៅគ.ស.១៥៣១ ឆ្លៀតពេលដែលខ្មែរកំពុងតែមានប្រៀបលើទ័ពសៀម ព្រះ **ចន្ទរាជា** ទ្រង់បានលើកទ័ពទៅរំដោះអាណាខេត្តខាងលិច ដែលត្រូវបាត់បង់ក្នុងរាជ្យមុន ៗ ហើយទ្រង់វាយបានខេត្ត **បស្ចិមបុរី**មកវិញ ។

ចាប់ពី គ.ស. ១៥៥៦ នៅភូមាមានស្តេចមួយអង្គនាម **បាយិណោង** (Bayin Naung) បានលើកទ័ពចូលមកវាយសៀម ហើយផ្តើមយកបានរាជធានី **អយុធ្យា** នៅ

www.budinst.gov.kh www.elibraryofcambodia.org

គ.ស. ១៥៦៦ ។ ពួកសៀមបានបះបោរឡើងប្រឆាំងនឹងភូមាដែរ តែត្រូវបង្ក្រាបអោយរាបទាបទៅវិញអស់ និងត្រូវចាប់ជាឈ្លើយអស់ជាច្រើនថែមទៀត (13) ។ ទៀតយកឱកាសពេលសៀមកំពុងតែចុះទន់ខ្សោយយ៉ាងនោះ ព្រះ **ចន្ទរាជា** ទ្រង់បានលើកទ័ពចូលវាយសៀមនៅ គ.ស. ១៥៥៧ ហើយយកបានខេត្ត **ចន្ទបុរី** និងខេត្តផ្សេង ៗ ទៀតនៅជិត ៗ នោះ ។ ខ្មែរបានលើកទ័ពទៅវាយសៀមពីរលើកទៀត គឺនៅ គ.ស. ១៥៥៩ និង ១៥៦២ ហើយចាប់បានឈ្លើយជាច្រើននាំមកស្រុកវិញ ។

## ១-៣- ទំនាក់ទំនងជាមួយជនជាតិអឺរ៉ុបជាលើកដំបូង .—

នៅក្នុងសៀវភៅ" ប្រវត្តិសាស្ត្រខ្មែរ" ភាគ ១ យើងបានលាតត្រដាងជូនអ្នកអានម្ដងមូលហេតុដែលនាំអោយជនជាតិអឺរ៉ុបធ្វើដំណើរមកកាន់ភូមិភាគអាស៊ីអាគ្នេយ៍យើងនេះ រួចហើយ ។ យើងបានដឹងរួចហើយថា ក្រោយពីបានពង្រឹងជំហររបស់ខ្លួននៅជ្រោយម៉លយូហើយ ពួកព័រទុយកាល់គឺជាជនជាតិអឺរ៉ុបដំបូងដែលបានចូលមកទាក់ទងនឹងខ្មែរនៅខាងចុងរជ្ជកាលរបស់ព្រះ **ចន្ទរាជា** ។ យ៉ាងណាមិញ នៅ គ.ស. ១៥៥៥ មានបព្វជិតជាតិព័រទុយ-កាល់ខាងគណៈដូមីនិកាំង (dominicain) នាម Gaspar da Cruz ជាមិត្តភក្តិស្និទ្ធស្នាលរបស់លោក Albuquerque បានមកដល់ក្រុងលង្វែក ។ បព្វជិតអង្គនេះមានបំណងមកផ្សាយសាសនាគ្រិស្តនៅប្រទេសខ្មែរ ។ ព្រះរាជាទ្រង់សព្វរាជហឫទ័យទទួលរាក់ទាក់ណាស់ ប៉ុន្តែ បេសកកម្មរបស់លោកមិនបានទទួលផ្លែផ្កាដូចបំណងឡើយ ព្រោះប្រជារាស្ត្រខ្មែរនៅសម័យនោះកំពុងតែដាក់ចិត្តស៊ប់ទៅលើព្រះពុទ្ធសាសនា ហើយមិនព្រមលះបង់ព្រះ-រតនត្រ័យ ដើម្បីងាកទៅរកសាសនាដទៃទៀតឡើយ ។

ដោយលោកពុំបានសំរេចគោលបំណងយ៉ាងនេះហើយ លោកក៏ធ្វើដំណើរទៅកាន់ប្រទេសចិននៅឆ្នាំ ១៥៥៦ ។ ចំពោះរឿងនេះ លោក Dauphin Meunier បានសរសេរថា លោកប្រញាប់វិលទៅវិញ ប្រហែលដើម្បីរាយការណ៍ប្រាប់ទៅនាយចៅហ្វាយរបស់លោកពីបេសកកម្មរបស់លោក ឬក៏ដោយលោកត្រូវចាត់អោយទៅបំពេញបេសកកម្មនៅទីដទៃទៀត (9) ។

www.budinst.gov.kh www.elibraryofcambodia.org

ក្នុងសម័យនោះ ក្រៅពីអ្នកផ្សាយសាសនានៅមានអ្នកផ្សេងព្រេងខ្លះទៀតដែលបានធ្វើដំណើរទេសន្តរប្រទេសយើងហើយបានកត់ត្រាទុកនូវហេតុការណ៍ដែលខ្លួនបានឃើញ ៗ គឺកំណត់ហេតុទាំងនោះហើយ ដែលអ្នកប្រវត្តិសាស្ត្រ បានយកធ្វើជាឯកសារសំរាប់ទុះមើលសង្គមខ្មែរនៅ ស.វ. ទី ១៦ ៗ អត្ថបទខាងក្រោមនេះរបស់លោក Diogo do Couto ជាតិព័រទុយក៏លជាភស្តុតាងមួយស្រាប់ ៗ លោកបានសរសេរជាអាទិ៍ថា: « ប្រមាណជាក្នុងឆ្នាំ ១៥៥០ ឬ ១៥៥១ នៅពេលដែលព្រះមហាក្សត្រិយ៍នៃប្រទេសកម្ពុជាទ្រង់យាងទៅទាក់ដំរីនៅក្នុងព្រៃស្បាតនេះក្នុងរាជាណាចក្រនោះ បរិវាររបស់ព្រះអង្គដោយលុកចូលទៅក្នុងព្រៃដើម្បីដេញសត្វ ក៏ប្រទះនឹងសំណង់យ៉ាងសម្បើម ៗ ដែលមានព្រៃគម្លោត ដុះពេញខាងក្នុងហើយដែលគេមិនអាចកាប់ឆ្ការដើម្បីចូលទៅខាងក្នុងបាន ៗ ដំណឹងនេះទ្រង់ជ្រាបដល់ព្រះរាជា ព្រះអង្គក៏យាងទៅដល់ទីនោះ ហើយទ្រង់ទតឃើញនូវវិសាលភាពនិងកំពស់នៃជញ្ជាំងខាងក្រៅ ទ្រង់បញ្ជាអោយកាប់ឆ្ការនិងដុតព្រៃក្លាមមួយរំពេច ដើម្បីទ្រង់បានទតឃើញខាងក្នុង ៗ ក្រោយដែលព្រៃគម្លោតត្រូវបានបោសសំអាតអស់ហើយព្រះរាជាក៏ទ្រង់យាងទតគ្រប់សព្វទិសទ្វែងហើយ ទ្រង់មានសេចក្ដីស្ញប់ស្ញែងចំពោះទំហំធំធេងនៃសំណង់ទាំងនោះ ៗ ហើយដោយហេតុនោះ ព្រះអង្គទ្រង់ត្រាស់បញ្ជាអោយនាំពួកបរិវារទៅគង់នៅទីនោះវិញ (14) ៗ សេចក្ដីនៃអត្ថបទនេះគឺចង់ដៅចំពោះការរកឃើញឡើងវិញនូវប្រាសាទសិលានៅតំបន់អង្គរដែលត្រូវគេបោះបង់ចោលអស់រយៈពេលជាងមួយសតវត្សមកហើយ ៗ

*

* *

ក្រៅពីថ្វីព្រះហស្តក្នុងចំបាំងរំដោះនិងការពារទឹកដីរបស់ខ្មែរ និងព្រះរាជូបត្ថម្ភយ៉ាងកក់ក្ដៅក្នុងពុទ្ធសាសនា ព្រះ **ចន្ទរាជា** ទ្រង់បានយកព្រះហឫទ័យទុកដាក់យ៉ាងខ្លាំងក្នុងវិស័យផ្សេង ៗ ទៀត ដូចជាវិស័យអក្សរសាស្ត្រ និងសេដ្ឋកិច្ចជាដើម ៗ គេដឹងថា ក្រោយដែលព្រះអង្គបានឡើងគ្រងរាជសម្បត្តិហើយ ព្រះអង្គទ្រង់ចាត់អោយគេដើរស៊ើបរកពួកអ្នក

www.budinst.gov.kh

www.elibraryofcambodia.org

បណ្ឌិតមកពិញីមទំនុកបំរុងទុកជាគ្រឹះនៃប្រទេសជាតិ ។ នេះជាគុណសម្បត្តិមួយដែលគេកម្រឃើញមានក្នុងសន្តានចិត្តរបស់អ្នកដឹកនាំជាតិក្នុងសម័យនោះ ដែលច្រើនតែព្យាយាមធ្វើទុក្ខបុកម្នេញចំពោះពួកបញ្ញវន្ត ពួកខ្វាំងពូកែ មានអ្នកសិល្បជាដើម ។ ក្នុងវិស័យសេដ្ឋកិច្ច ព្រះអង្គទ្រង់បង្គាប់អោយកាប់ឆ្ការព្រៃដើម្បីយកដីពង្រីកទំហំស្រែចំការ និងជួយទំនុកបំរុងយ៉ាងខ្លាំងចំពោះការស្ទូយកដែក ។

សូមបន្ថែមថាក្នុងវិស័យការគ្រប់គ្រងរដ្ឋ ព្រះ **ចន្ទរាជា** ទ្រង់បានតាំងព្រះរាជបុត្រច្បងនាម **រាមាធិបតី** ជាឧភយោរាជ និងព្រះរាជបុត្របន្ទាប់នាម **បរមេន្ទរាជា** ជាមហាឧបរាជ ។ ក្បួនរាជពង្សាវតារខ្លះបានបញ្ជាក់ថា ព្រះ **រាមាធិបតី** ដោយយកបុត្រីឯងជាភរិយា ក៏ត្រូវព្រះធរណីស្រូបទៅ ។ ក្រៅពីនេះ ព្រះអង្គទ្រង់បានតាំងស្តេចត្រាញ់ ៥ អង្គ គឺចៅហ្វាយស្រុកខេត្តអាសន្ទុក ១ ខេត្តពោធិសាត់ ១ ខេត្តត្បូងឃ្មុំ ១ ខេត្តបាភ្នំ ១ ខេត្តទ្រាំង ១ ។ ក្បួនខ្លះទៀតបានបន្ថែមថា ក្នុងរាជ្យរបស់ព្រះអង្គ ព្រះអង្គទ្រង់ព្រះពស្ត្រ ៨ ហត្ថ នាម៉ឺនពាកសៃ្ប ៨ ហត្ថដែរ ខូលធ្វើយត្រូវថាព្រះបាទអម្ចាស់ ជិះគ្រែកាន់ផ្ចិតស៊ីកន្ត្រាតចូលគាល់ ។

ព្រះ **ចន្ទរាជា** ទ្រង់សោយទិវង្គតនៅក្រុងលង្វែកនៅគ.ស. ១៥៦៦ ។ ព្រះចេតិយតំកល់ព្រះអដ្ឋិធាតុរបស់ព្រះអង្គស្ថិតនៅលើភ្នំព្រះរាជទ្រព្យសព្វថ្ងៃ ។

## ២—ព្រះបាទបរមរាជាទី ៤ ( ១៥៦៦-១៥៧៦ ) និងការរំដោះអាណាខេត្តខាងលិច.—

ក្រោយពីព្រះ **ចន្ទរាជា** សោយទិវង្គតទៅ ព្រះមហាឧបរាជ ដែលត្រូវជាព្រះរាជបុត្របន្ទាប់នាម **បរមរាជា** ឡើងសោយរាជ្យស្នងព្រះបិតាដោយមានព្រះនាមសំរាប់រាជ្យថា **ព្រះសម្តេចព្រះបរមរាជាធិរាជរាមាធិបតី** ។

ក្បួនរាជពង្សាវតារខ្លះ បានអោយពត៌មានថា ព្រះបាទ **បរមរាជាទី ៤** មានបុត្រា ៤ អង្គ គឺ :

១— **ព្រះសត្ថា** (ប្រសូតនៅគ.ស. ១៥៣៩)

២— **ព្រះស្រីសុរិយោពណ៌** (បុត្រ **ព្រះម្នាងកេសរមាលា** ប្រសូតនៅគ.ស. ១៥៥៤)

www.budinst.gov.kh www.elibraryofcambodia.org

៣- ពញាន្ទ (បុត្រព្រះម្នាងកេសរមាលា ប្រសូតនៅគ.ស.១៥៥៨)

៤- ចៅពញាអន (បុត្រព្រះម៉ែនាងទង ប្រសូតនៅគ.ស. ១៥៦៣)

ប្រភពដដែលបានអោយដឹងថា ព្រះ **ស្រីសុរិយោពណ៌** បានយកបុត្រីរបស់ **ពញាយសពជា** (មិនបានសោយរាជ្យ) **ឈ្មោះ** **ជាតិក្សត្រី** ហើយមានបុត្រនាមព្រះ **ជ័យជេស្ឋា** ។

## -១- ទំនាក់ទំនងជាមួយសៀមនិងការរំដោះអាណាខេត្តខាងលិច —

ទៀតយកឱកាសដែលប្រទេសសៀមកំពុងតែទន់ខ្សោយដោយការវាយលុកពីសំណាក់ស្តេចភូមានាម **បាយិណោង** (Bayin Naung) ដែលបានវាយយករាជធានី **អយុធ្យា** នៅគ.ស. ១៥៦៤ នោះ ព្រះបាទ **បរមរាជាទី ៤** ទ្រង់បានបន្តកិច្ចការរបស់ព្រះបិតាព្រះអង្គ គឺការវាយរំដោះយកអាណាខេត្តខាងលិចមកវិញថែមទៀត ។

ចំពោះរឿងនេះ ឯកសារសៀម (8) បានអោយដឹងថា: "ក្នុងរជ្ជកាលព្រះ **មហាធម្មរាជា** ព.ស. ២១១២ (គ.ស. ១៥៦៨) ដែលជាវេលាក្រុងស្រីអយុធ្យាត្រូវបាក់-បង់ដោយភូមាវាយ ខ្មែរបានវាយបន្ថែម ព្រោះគ្រានោះភូមាកៀរមនុស្សយកទៅជាច្រើន ។ ស្រុកទេសក៏យ៉ាប់យុឺនមិនមានកម្លាំងដូចពីមុន ព្រះ **បរមរាជា** ស្តេចក្រុងកម្ពុជាលើកកងទ័ពប្រមាណ ២០ ០០០ នាក់ ចូលមកវាយក្រុងស្រីអយុធ្យា លើកចូលមកបានដល់ជាយក្រុង តែពួកសេហ៍ពលក្នុងកងទ័ពខ្មែរ កាលដែលបាញ់មេទ័ពមុខរបស់ខ្មែរស្លាប់ហើយ កងទ័ពខ្មែរក៏ត្រឡប់ទៅកៀរមនុស្សនៅខេត្តតាមផ្លូវជាឈ្លើយអស់ជាច្រើន" ។ ឯរាជពង្សាវតារខ្មែរបានអះអាងថា ទ័ពខ្មែរបានចូលលុកក្រុង **អយុធ្យា** តែយកមិនបាន ក៏ថយមកកៀរគ្រួសៀមមកជាច្រើន ។ ដូច្នេះ ទោះបីមានល្អៀងបន្តិចបន្តួចក៏ដោយ ក៏ឃើញថាប្រភពសៀមនិងប្រភពខ្មែរបាននិយាយស្របគ្នា ចំពោះព្រឹត្តិការណ៍ដ៏សំខាន់នេះដែរ ។

នៅគ.ស. ១៥៦៩ ស្តេចភូមានាម **បាយិណោង** លើកទ័ពចូលវាយសៀមយកបានរាជធានី **អយុធ្យា** ម្តងទៀត ហើយដាក់ប្រទេសសៀមជាចំណុះអស់រយៈពេល ១៥ ឆ្នាំ ។

ទៀតឱកាសមានវិកវរនេះ នៅគ.ស. ១៥៧០ គឺនៅពេលដែលព្រះបាទ **បរមរាជា** យាងទៅគង់នៅតំបន់អង្គរគ្រង់កំពង់ក្រសាំង ខ្មែរបានលើកទ័ពលុកចូលទៅយកបានខេត្ត **នគររាជ-សីមា** ហើយដាក់មន្ត្រីខ្មែរអោយនៅឈរត្រួតត្រាទីនោះ ។

www.budinst.gov.kh

www.elibraryofcambodia.org

ចំពោះទំនាក់ទំនងខ្មែរ-សៀម ឯកសារសៀម(8)បានសរសេរបន្ថែមទៀតថា: «ក្នុ
ព.ស. ២១១៨ ( គ.ស. ១៥៧៤ ) ខណៈដែលសម្ដេចព្រះ **មហាធម្មរាជា** និងសម្ដេ
ព្រះ **នរេសូរ** លើកទ័ពទៅជួយព្រះចៅ **មាតុឡាធិបតី** វាយស្រុក **វៀងចន្ទ** ព្រះចៅក្រុ
កម្ពុជាលើកទ័ពជើងទឹកមកវាយក្រុង **អយុធ្យា** ម្ដងទៀត តែជាចៃដន្យ កងទ័ពថៃត្រឡប់
មកវិញព្រោះសម្ដេចព្រះ **នរេសូរ** ប្រឈួនកើតគ្រុនសន្និ ស្ដេចត្រឡប់មកទាន់កងទ័ពខ្មែ
ល្មម ថៃវាយកងទ័ពខ្មែរអោយថយម្ដងទៀត » ។ ត្រង់ការវាយលុករបស់ភូមាទៅលើស្រុក
**វៀងចន្ទ** នេះ យើងមានសេចក្ដីបញ្ជាក់ពីឯកសារលាវ (15) ដែលបានថ្លែងថា នៅ
គ.ស. ១៥៧៤ ទ័ពភូមា ក្រោមបញ្ជាការរបស់ស្ដេច Bureng Naung (Bayin Naung)
បានចូលវាយលុករាជធានី **វៀងចន្ទ** ជាលើកទី ៣ ។ មេទ័ពលាវឈ្មោះ Phaya-Sèn-
Soulinthara ដែលបានតាំងខ្លួនជាជារជ្ជទាយាទពីមុនមក ចង់ធ្វើសង្គ្រាមធ្មក់ដើម្បីរំដោះ
**វៀងចន្ទ** ប៉ុន្តែនៅពេលនោះពួកលាវបាក់បែកគ្នាខ្លាំង គំរោងការរបស់លោកក៏ត្រូវទទួល
បរាជ័យទៅ ។ ចំពោះចម្បាំងខ្មែរ-សៀមលើកនេះ ( គ.ស ១៥៧៤ ) រាជពង្សាវតារខ្មែរ
បាននិយាយថា ខ្មែរស៊ើបការណ៍ដឹងថាស្ដេចសៀមរវល់តែធ្វើចម្បាំងជាមួយលាវ ( ជួយភូ
មាដោយបង្ខំ ? ) ទុកកូនអោយនៅថែរក្សានគរក៏លើកទ័ពទៅវាយសៀមទៀត ។ ទ័ពខ្មែរ
ចិនត្រូវនាំដោយ **ចៅពញាចិនចាន់តុក** បានប្រើកលល្បិចគឺវាយស្រុកតូច ១ គឺ **ចន្ទបុរី**
ដល់ **ធនបុរី** ដើម្បីអោយស្ដេចសៀមចេញជួយទើបលុកយកក្រុង **អយុធ្យា** ។ បើដូច្នេះ
អាណាខេត្តខាងលិចទាំងមូលពី **នគររាជសីមា** ចុះមករហូតដល់ **ចន្ទបុរី** ត្រូវទ័ពខ្មែរ
រំដោះបានទាំងស្រុង ។ កាលណោះ ដោយត្រូវភូមានិងខ្មែរគៀបសង្កត់ខ្លាំងពេក ស្ដេច
សៀមត្រូវបង្ខំចិត្តធ្វើសន្ធិសញ្ញាចងស្ពានមេត្រីជាមួយខ្មែរនៅ គ.ស. ១៥៧៦ [illegible] ហើយបាន
ថ្វាយចំពោះព្រះមហាក្សត្រខ្មែរនូវខេត្ត **នគររាជសីមា បស្ចិមបុរី ចន្ទបុរី** ។

## ២.២– ទំនាក់ទំនងជាមួយលាវ.—

ចំពោះទំនាក់ទំនងខ្មែរ-លាវនេះ យើងមានតែឯកសាររាជពង្សាវតារខ្មែរ ចំណែកឯ
ឯកសារលាវដែលសរសេរជាភាសាលាវក្ដី (16) ជាភាសាបារាំងក្ដី (15) ពុំមានផ្ដល់ពត៌មាន


www.budinst.gov.kh www.elibraryofcambodia.org

អ្វីបន្តិចបន្តួចសោះ ។ នេះជាហេតុនាំអោយយើងមានចំងល់ ចេះតែឆ្ងល់ថាចុះហេតុអ្វីបានជារាជពង្សាវតារលាវមិនព្រមនិយាយពីព្រឹត្តិការណ៍ដ៏សំខាន់នេះ ។ តើនេះជាការភ្លេចភ្លាំងដោយអចេតនា ឬក៏ជាការបំភ្លេចចោលដោយចេតនាព្រោះតែខ្មាសអាម៉ាស់ ?

រាជពង្សាវតារខ្មែរច្រើនក្បួនបាននិយាយថា នៅ គ.ស. ១៥៧២ ស្តេចលាវនគរលានជាង ទ្រង់ត្រាស់បញ្ជាអោយនាម៉ឺន ២ នាក់ ពល ១០០០ នាក់ មកបបួលខ្មែរប្រជល់ដំរីដាក់នគរ គឺថាបើដំរីនគរណាចាញ់ នគរនោះនឹងត្រូវចំណុះនគរម្ខាងទៀតដែលមានដំរីឈ្នះ ។ កាលណោះ ព្រះបាទ បរមរាជាទី ៤ គង់...ពង់ក្រសាំងនាតំបន់អង្គរ ព្រះអង្គទ្រង់យល់ព្រមចំពោះសំណើរបស់លាវ ។ ការប្រយុទ្ធរវាងដំរីទាំងពីរក៏ប្រព្រឹត្តទៅនៅក្បែរក្រុងលង្វែក ។ រាជពង្សាវតារខ្មែរក្បួនខ្លះបានទាំងបញ្ជាក់ថា ដំរីលាវមានកំពស់ដល់ ៨ ហត្ថ (៤ ម.) ឯដំរីខ្មែរមានកំពស់តែ ៧ ហត្ថ (៣,៥ម.) ។ ទោះបីចាញ់...ប្រៀបដំរីលាវបន្តិចក៏ដោយ ក៏ដំរីខ្មែរបានទទួលជោគជ័យយ៉ាងត្រចះត្រចង់ ។ ខ្មែរបានឃាត់ពួកលាវខ្លះ (១០០ នាក់) ទុក អោយតែនាម៉ឺន ២ នាក់នាំដំណឹងទៅថ្វាយស្តេចលាវ ហើយអោយនាំបណ្ណាការមកថ្វាយស្តេចខ្មែរ ។

ស្តេចលាវខ្វាល់ខ្វាយ បញ្ជា...អោយលើកទ័ពចូលវាយខ្មែរទាំងផ្លូវគោកនិងទាំងផ្លូវទឹក ។ ទ័ពលាវចូលចោមវាយបន្ទាយខ្មែរនៅស្រុកសន្ធុក ហើយចាប់បានខ្មែរជាឈ្លើយអស់ច្រើន ។ ស្តេចលាវនិងស្តេចខ្មែរកើតទំពាតទល់គ្នាផ្ទាល់ព្រះអង្គ ។ ស្តេចលាវចាញ់ ។ ខ្មែរចាប់លាវបានជាឈ្លើយ អោយ ១០០៤ នាក់នៅត្រង់ បារាយណ៍ សល់ពីនេះអោយទៅនៅខេត្តខាងត្បូងនិងខាងលិច ។ ខាងជើងទឹកក៏ខ្មែរមានជ័យជំនះលើទ័ពលាវដែលស្ថិតនៅក្រោមបញ្ជាការរបស់មហាឧបរាជលាវ ។ ព្រះ បរមរាជាទី ៤ ទ្រង់យាងមកលង្វែកវិញ ទ្រង់ចាត់អោយធ្វើបុណ្យខួងជោគជ័យ អោយលាវ ៨០០ នាក់ទៅនៅស្រុក បាត្តី អោយ ៥០០ នាក់នៅសំរាប់ថែវត្តភ្នំពេញ ។ ពួកនេះខ្មែរហៅថាលាវចាក់ខ្លួក ។

នៅគ.ស. ១៥៧៤ ក្នុងបំណងសងសឹកអោយបាន លាវគិតលើកទ័ពមកវាយខ្មែរទៀត គាប់ជួនពេលនោះភូមានាំសៀមចូលវាយ ស្មៀងមន្ទ ទៀតហើយដោយមានភ្លៀងធ្លាក់

www.budinst.gov.kh www.elibraryofcambodia.org

ប្រជាជនដែលរាស្ត្រលីនដាក់ជាប់តទៅវិញអស់ ។ ក្រុងនេះ ក្សត្រាជពង្សាវតារខ្មែរថាលាវវាយបាញ់ខ្មែរទៀត ឯឧបរាជបានត្រឡប់ចូលទៅស្រុកវិញ ។

ព្រះ បរមរាជាទី ៤ ក៏ជាព្រះមហាក្សត្រមួយអង្គដែលបានជួយឧបត្ថម្ភព្រះពុទ្ធសាសនាដែរ ។ ព្រះអង្គទ្រង់អោយសាង វត្តព្រះឥន្ទទេព នៅក្នុងបរិវេណបន្ទាយលង្វែក ។

ព្រះអង្គទ្រង់សោយទិវង្គតនៅគ.ស. ១៥៧៦ ។ ប៉ុន្តែ បើតាមឯកសារសៀមព្រះអង្គត្រូវក្សយព្រះជន្មនៅគ.ស.១៥៧៤ម៉្លេះ គឺកាលដែលព្រះអង្គលើកទ័ពទៅវាយក្រុងអយុធ្យានោះ ។

## ២-៣- ទំនាក់ទំនងជាមួយជនជាតិអឺរ៉ុប.-

តាមកំណត់ហេតុរបស់បព្វជិត Gabriel de San Antonio គេដឹងថាព្រះបរមរាជាទី៤ ដោយទ្រង់យល់ថាសកម្មភាពខាងជំនួញនឹងកើតមានឡើងបន្ទាប់ពីការមកដល់របស់ពួកបព្វជិត ព្រះអង្គក៏ទ្រង់បានអំពាវនាវសុំអោយអង្គការកណ្តាលនៅ Malacca បញ្ជូនអ្នកផ្សាយសាសនាមកកាន់ប្រទេសព្រះអង្គ ។ ដោយហេតុនោះ គេឃើញបព្វជិតពីរអង្គបាននិមន្តមកកាន់ប្រទេសខ្មែរ គឺបព្វជិត Lopo Cardoso និង Joao Madeira ។ គេមិនដឹងច្បាស់ថាបព្វជិតទាំងពីរអង្គបាននិមន្តមកក្នុងឆ្នាំណាទេ តែបើតាមហេតុការណ៍ដែលមានតមកទៀត នោះឃើញថាបព្វជិតទាំងពីរអង្គត្រូវនិមន្តមកដល់លង្វែកមុន គ.ស. ១៥៧០ (19) ។

អ្នកនិពន្ធជាតិអឺរ៉ុបជាច្រើនបានអះអាងថា នៅគ.ស. ១៥៧០ អ្នកផ្សាយសាសនាព័រ-ទុយហ្គាល់ម្នាក់បានរកឃើញប្រាសាទតំបន់អង្គរ ហើយបានកត់ទុកក្នុងកំណត់ហេតុរបស់លោក ។ គេមិនបានបញ្ជាក់ពីឈ្មោះរបស់អ្នកផ្សាយសាសនារូបនេះទេ តែបើតាមស្មានមើលទៅ គឺមានតែបព្វជិត Cardoso ឬ Madeira ប៉ុណ្ណោះ ។

ដោយហេតុថាវត្តមានរបស់អ្នកផ្សាយសាសនា ពុំបានញាំងជំនួញអោយមានសកម្មភាពដូចព្រះបំណងនោះ ព្រះរាជាក៏ទ្រង់ចាប់ផ្តើមធ្វើទុក្ខបុកម្នេញលើរូបពួកបព្វជិត ។ បព្វជិត Sylvestre d'Acevedo បានមកជំនួសបព្វជិត Madeira ឯបព្វជិត Cardoso ក៏ត្រូវត្រឡប់ទៅវិញ ។ បន្ទាប់មក មានបព្វជិតពីរអង្គបាននិមន្តមកដល់ទៀត តែគង់នៅមិន

www.budinst.gov.kh www.elibraryofcambodia.org

យូរប៉ុន្មានក៏ត្រឡប់ទៅវិញទៀត ។ ដូច្នេះ ក្នុងរយៈពេលយ៉ាងយូរ បព្វជិត Sylvestre d'Acevedo បានស្ថិតនៅក្នុងប្រទេសខ្មែរ តែមិនអាចផ្សាយសាសនាគ្រិស្តអោយជ្រួតជ្រាបចូលក្នុងសង្គមខ្មែរបានឡើយ (19) ។

## គ–ការបែកបាក់ក្រុងលង្វែក និងផលវិបាក.–

### ១- ព្រះបាទសត្ថាទី១ (១៥៧៦-១៥៩៥)–

ក្រោយពីព្រះបិតាសោយទីវង្គតទៅ ព្រះរាជបុត្រច្បងនាម **សត្ថា** ឡើងសោយរាជ្យស្នងដោយមាននាមសំរាប់រាជ្យថា **ព្រះបាទសម្តេចព្រះបរមរាជាធិរាជរាមាធិបតី** ។ អ្នកប្រវត្តិសាស្ត្រនិយមហៅស្តេចអង្គនេះថាព្រះ **សត្ថាទី១** ឬ **ព្រះបរមរាជាទី៥** ។ ព្រះអង្គទ្រង់អភិសេកអ្នកនាង **ពៅ** ជាអគ្គមហេសីនាម **សម្តេចព្រះភគវតីស្រីចក្រពត្តិរាជ** និងអភិសេកព្រះអនុជបន្ទាប់នាម **ស្រីសុរិយោពណ៌** ជាមហាឧបរាជ ។ កាលគ.ស. ១៥៧៤ បានសម្ភពនឹងអគ្គមហេសី នូវបុត្រនាមព្រះ **ជ័យជេដ្ឋា** ហើយកាលសោយរាជ្យបាន ៤ ឆ្នាំ (១៥៨០) បានសម្ភពរាជបុត្រមួយអង្គទៀតនាម **ចៅពញាតន់** ។ ព្រះអង្គមានម្នាងលាវមួយទៀត ឈ្មោះអ្នកម្នាង **ពេជមាលា** ហើយបានសម្ភព នឹង អ្នកម្នាងនេះនូវបុត្រនាម **ចៅពញាញោម** ។ ឯព្រះអនុជមានព្រះរាជបុត្រពីរអង្គនាមព្រះ **ជ័យជេស្ឋា** ១អង្គ ព្រះ **ឧទ័យ** ១ អង្គ

### ១–១– ទំនាក់ទំនងជាមួយសៀម.–

បើតាមឯកសារសៀម ព្រះ **សត្ថា** បានលើកទ័ពចូលវាយក្រុង **ពេជ្របុរី** ពីរដងក្នុងចន្លោះ ព.ស. ២១១៩ ដល់ ២១២៤ (គ.ស. ១៥៧៤-១៥៨០) ។ ទីបំផុតចូលវាយមឿង **ពេជ្របុរី** បាន បោសសំអាតមនុស្សយកទៅទៀត ។ ដែលឯកសារសៀមថាដូច្នេះ ព្រោះបានចាត់ទុ ថាព្រះ **បរមរាជាទី៤** បានសោយទីវង្គតតាំងពីគ.ស. ១៥៧៤ ដូចយើងបានពិភាក្សាមកហើ ។ បើតាមរាជពង្សាវតារខ្មែរវិញ: ព្រះ **សត្ថា** ទ្រង់បានលើកទ័ពទៅ

www.budinst.gov.kh www.elibraryofcambodia.org

វាយក្រុង**អយុធ្យា** ហើយចាប់បានឈ្លើយសៀមជាច្រើន ទំនងជាក្នុងគ.ស. ១៥៧៩ ឬ ១៥៨០ ។ មានក្បួនរាជពង្សាវតារខ្លះទៀតនិយាយថា នៅគ.ស. ១៥៨០ នោះប្រទេសសៀមនៅជាប្រទេសចំណុះរបស់ស្តេចភូមានាម Bayin Naung នៅឡើយ ។ ព្រះរាជបុត្រស្តេចសៀមនាម **នរេសួរ** បានទៅនៅបំរើស្តេចភូមានៅក្រុង**ហង្សាវតី** ។ ថ្ងៃមួយ **នរេសួរ** បានលើកដៃថ្វាយបង្គំស្តេចភូមា ស្តេចភូមាទ្រង់ទតឃើញមានព្រះហស្តប្អូន ទ្រង់ជ្រាបថាជាអ្នកមានបុណ្យ គិតកលសម្លាប់ ។ **នរេសួរ** ដឹងខ្លួន រត់មកក្រុង**អយុធ្យា** វិញ ។ ពួកភូមាដេញតាម (17) ។ ព្រះចៅសៀមទ្រង់ផ្ញើសារមកសុំជំនួយពីខ្មែរ ។ ដោយទ្រង់គោរពតាមសន្ធិសញ្ញាសម្ព័ន្ធភាពខ្មែរ-សៀមកាលពីគ.ស. ១៥៧៤ ព្រះបាទ **សត្ថា ទី ១** ទ្រង់បញ្ជាអោយមហាឧបរាជ **ស្រីសុរិយោពណ៌** លើកទ័ពទៅជួយតាមសំណូមពរ ។ ទ័ពខ្មែរបានជួយច្បាំងព្រះ **នរេសួរ** រហូតដល់បានជ័យជំនះលើភូមា ។ លុះលើកទ័ពមកវិញ ព្រះ **នរេសួរ** ទ្រង់ទតឃើញព្រះ **ស្រីសុរិយោពណ៌** គង់សំយុងព្រះបាទ ពុំបានគង់ស្របដូចអ្នកដទៃ ក៏ទ្រង់ព្រះពិរោធណាស់ ។ ម្យ៉ាងទៀត ព្រះ **នរេសួរ** ទ្រង់បានកាត់ករាស្ត្រក្នុងខេត្តដែលត្រូវឡើងមកស្តេចខ្មែរ ។ ព្រះ **ស្រីសុរិយោពណ៌** ទ្រង់ខ្ញាល់ពីរឿងនេះខ្លាំងណាស់ ហើយលើកទ័ពត្រឡប់ចូលនគរវិញ ។ ចំពោះរឿងនេះ មានឯកសារខ្លះសរសេរថា: "ប៉ុន្តែជ័យជំនះនេះពុំបានធ្វើអោយសៀមអរសាទរឡើយ ផ្ទុយទៅវិញ ជ័យជំនះនេះបណ្តាលអោយអាម៉ាស់ដល់កងទ័ពសៀម ហើយជាពិសេសអាប់កិត្តិយសរបស់រាជបុត្រស្តេចសៀមនាមព្រះ **នរេសួរ** ។ ចាប់តាំងពីពេលនោះមក ព្រះ **នរេសួរ** តែងមានគំនិតចង់យកស្រុកខ្មែរជាចំណុះដោយរំលោភលើកិច្ចចរចាឆ្នាំ ១៥៧៦" (18) ។ គួរគប្បីជ្រាបថា ចំពោះជំនួយទ័ពរបស់ខ្មែរខាងលើនេះ ឯកសារសៀមពុំឃើញមាននិយាយដល់ទេ ។

នៅគ.ស. ១៥៨១ ខ្មែរបានលើកទ័ពទៅវាយរំដោះបាន **នគររាជសីមា ចន្ទបុរី** និង **នគរនាយក** ។ ឯកសារសៀមថា សម្តេចព្រះ **នរេសួរ** បានលើកទ័ពទៅតស៊ូ ។ ឯកសារខ្មែរថា ព្រះ **នរេសួរ** វាយយកបាន **នគររាជសីមា** វិញនៅ គ.ស. ១៥៨២ គឺស្របនឹងឯកសារសៀមដែរ តែឯកសារសៀមគ្មានបានបញ្ជាក់ថាយកបានខេត្តណាទេ ។

www.budinst.gov.kh www.elibraryofcambodia.org

ឯកសារសៀមនិយាយថា កាលសម្តេចព្រះ **នរេសូរ** ប្រកាសឯករាជ្យរំដោះប្រទេសសៀមពីចំណុះភូមា ( គ.ស. ១៥៨៤ ? ) ទ្រង់មានកិត្តិសព្ទល្បីល្បាញ ព្រះ **សត្ថា** ក្រែងថាសៀមនឹងត្រឡប់មករុករានស្រុកកម្ពុជា ទើបតែងព្រះរាជមេត្រីសារភាពទទួលខុសព្រមចំណុះក្រុង **ស្រីអយុធ្យា** (8) ។ ត្រង់ចំណុចនេះ ឯកសារខ្មែរគ្មាននិយាយដល់ឡើយ ។ យើងគ្រាន់តែឆ្ងល់ថា តើការពិតស្ថិតនៅត្រង់ណា បើកាលណោះខ្មែរអាចជួយសៀមច្បាំងឈ្នះភូមាថែមទៀត ហេតុដូចម្តេចក៏ត្រឡប់ជាខ្លាចសៀមវិញ ?

គួរគប្បីជ្រាបថា នៅប្រទេសភូមាឯណោះ ស្តេចនាម **Nanda Bayin** បានឡើងសោយរាជ្យស្នងព្រះបិតានាម **Bayin Naung** ពី គ.ស. ១៥៨១ ដល់ ១៥៩៩ ។ ស្តេចអង្គនេះជាស្តេចមានមហិច្ឆតា ទ្រង់បានបន្តនយោបាយវាតទឹកដីរបស់ព្រះបិតាព្រះអង្គ ។ ដោយហេតុនោះហើយបានជានៅ គ.ស. ១៥៨៥ ព្រះអង្គបានលើកទ័ពចូលវាយក្រុង **អយុធ្យា** ម្តងទៀត ។ ឯកសារសៀមថា ព្រះ **សត្ថា** ជឿថាក្រុង**អយុធ្យា**គង់នឹងបាត់បង់ដោយភូមាដូចគ្រាមុន ទ្រង់បានផ្តាច់មេត្រីភាពហើយលើកទ័ពចូលវាយស្រុក **បស្ចិមបុរី** ។ ត្រង់នេះ ឯកសារខ្មែរថាទ័ពខ្មែរយកបាន **បស្ចិមបុរី នគររាជ** និង **នគរនាយក** ។ លុះសៀមលើកទ័ពមក ខ្មែរក៏ថយសិន ហើយដោយមានដំណឹងថា **សម្តេចព្រះតតនតី** ប្រឈួន ព្រះ **សត្ថា** ក៏លើកទ័ពត្រឡប់មកបន្ទាយលង្វែកវិញ ។ ឯកសារសៀមបាននិយាយថា: «សម្តេចព្រះ **នរេសូរ** ទ្រង់ខ្ញាល់នឹងព្រះ **សត្ថា** ដូច្នេះក្នុង ព.ស ២១៣០ ( គ.ស. ១៥៨៦ ) កាលភូមាលើកទ័ពត្រឡប់ទៅវិញហើយ ទើបស្តេចលើកទ័ពទៅវាយក្រុងកម្ពុជា វាយបានស្រុក **បាត់ដំបង** និងស្រុក **ពោធិសាត់** ហើយលើកទ័ពត្រឡប់មកព្រះនគរវិញព្រោះខ្វះស្បៀងអាហារ (8) ។ ត្រង់នេះ ឯកសារខ្មែរខ្លះនិយាយថា: «សៀមក៏ចាប់ធ្វើសង្គ្រាមទន្ទ្រានទឹកដីខ្មែរដោយគ្មានលេសអ្វីឡើយ » (18) ។ ឯក្បួនរាជពង្សាវតារខ្មែរខ្លះនិយាយថានៅគ.ស. ១៥៨៤ ( គ.ស. ១៥៨៦ សមជាងព្រោះពេលនេះភូមាថយទៅវិញហើយ ) ព្រះ **នរេសូរ** លើកទ័ពមកវាយខ្មែរ ខ្មែរបានលើកទ័ពទៅប្រយុទ្ធគ្នាយ៉ាងខ្លាំងនៅបាត់ដំបងរួចនៅស៊ី **តិពង់ប្រាក់** តែទន់ដៃជាងក៏ដកថយសិន ។

www.budinst.gov.kh www.elibraryofcambodia.org

សៀមវាយយកបាន **បន្ទាយមានជ័យ** រួចយកបាន **បន្ទាយបរិបូណ៌** ទៀត ។ ព្រះ **ស្រីសុរិយោពណ៌** នាំទ័ពថយចូលទៅក្នុង **បន្ទាយលង្វែក** ។ រាជពង្សាវតារខ្មែរខ្លះបញ្ជាក់ថា ក្នុងចម្បាំងលើកនោះសៀមមានទ័ពចំនួន ១០០.០០០ នាក់ ដំរី ៨០០ និងសេះ ១៨៥០ ។ ទោះបីមានទ័ពច្រើនសន្ធឹកសន្ធាប់និងខ្លាំងពូកែយ៉ាងនេះក៏ដោយ ក៏សៀមពុំអាចវាយលុកយកបានបន្ទាយលង្វែកឡើយ ។ ក្រោយពីឡោមព័ទ្ធបន្ទាយនេះអស់រយៈពេល ៣ ខែ ដោយខ្វះស្បៀងអាហារនិងដោយត្រូវជម្ងឺឆ្លងរាតត្បាតស្លាប់អស់ច្រើនផងសៀមក៏ដកទ័ពថយទៅវិញ ព្រោះខ្មែរដឹងចំណុចខ្សោយរបស់សៀម ហើយនាំគ្នាចេញពីបន្ទាយទៅវាយលុកយ៉ាងខ្លាំង ។ មានប្រវត្តិវិទូខ្លះ (9) ថាមានកងទ័ពខ្មែរមួយមកពីក្រៅជួយធ្វើអន្តរាគមន៍កំចាត់សៀមទៅវិញ ។

ឯកសារខ្មែរខ្លះនិយាយថា ទ័ពសៀមឈឺស្លាប់ច្រើន គឺបណ្ដាលមកពីបិសាចធ្វើ ។ ព្រះ **នរេសួរ** បានចាត់អោយសាកសួរខ្មែរ ក៏បានដឹងថាមានទេវតា ១៣ អង្គជួយថែរក្សានគរខ្មែរ ⑦ ម្យ៉ាងទៀត មុននឹងរត់ដកខ្លួនទៅ សៀមបានប្រើឧបាយកលបាញ់ប្រាក់ដួងជាច្រើនចូលក្នុងគុម្ពឫស្សីដែលជារបងយ៉ាងមាំមួនជាទីបំផុតសំរាប់ការពារបន្ទាយលង្វែក ។

ក្រោយមក ព្រះចៅសៀមបានចាត់អោយចារបុរសពីរនាក់ ចូលមកធ្វើវិទ្ធង្សនាបង្កើតអោយមានចលាចលក្នុងផ្ទៃក្នុងរបស់ខ្មែរ ៖ មហាតលិកសៀមពីរនាក់បានក្លែងធ្វើជាអ្នកបួសនាម **តិបញ្ញោ** និង **សុប្បញ្ញោ** ចូលមកធ្វើពិធីដកសិល្បសាស្ត្រដែលបញ្ចុះក្នុងរូបទេវតា ។ **សុប្បញ្ញោ** ប្រើមន្តអាគមធ្វើអោយអ្នកស្រុកឈឺ **តិបញ្ញោ** ជាអ្នកដោះអោយជាសះស្បើយឡើងវិញ ។

នៅប្រមាណជា គ.ស. ១៥៨៦ ព្រះបាទ **សត្ថាធី ១** ទ្រង់សព្វព្រះរាជហឫទ័យដាក់រាជ្យ ថ្វាយទៅព្រះរាជបុត្រច្បងនាមព្រះ **ជ័យជេដ្ឋា** ដែលមានព្រះជន្មទើបបាន ១១ វស្សា អោយឡើងសោយរាជ្យស្នងព្រះអង្គដោយមានព្រះនាមសំរាប់រាជ្យថា **ព្រះបាទសម្ដេចព្រះបរមរាជាជ័យជេដ្ឋាធិរាជរាមាធិបតី** ។ ព្រះរាជបុត្រទី ២ **ពញាតន់** ដែលមានព្រះជន្មទើបបាន ៦ វស្សា ត្រូវបានតាំងអោយឡើងជាឧបរាជ ។ ឯព្រះ **ស្រីសុរិយោពណ៌** ត្រូវបានលើកឡើងជាឧភយោរាជ ។ ដោយព្រះរាជបុត្រសុទ្ធតែនៅក្មេងៗ

www.budinst.gov.kh www.elibraryofcambodia.org

ពេកកិច្ចការគ្រប់គ្រងរដ្ឋត្រូវស្ថិតនៅក្នុងកណ្ដាប់ព្រះហស្ដព្រះ**សត្ថា**ទាំងអស់ ។ ត្រង់នេះមានសំនួរចោទឡើងថា បើព្រះអង្គនៅតែកាន់កាប់អំណាចដដែលដូច្នេះ ហេតុអ្វីក៏ចាំដាក់រាជ្យថ្វាយទៅព្រះរាជបុត្រ ? អ្នកប្រវត្តិសាស្ត្រខ្លះបានអោយយោបល់ថា ហេតុដែលនាំអោយព្រះ **សត្ថា** ទ្រង់ប្រព្រឹត្តដូច្នេះ ព្រោះព្រះអង្គខ្លាចក្រែងរាជ្យសម្បត្តិពុំបានទៅព្រះរាជបុត្រតែបានទៅព្រះ **ស្រីសុរិយោពណ៌** វិញនៅពេលដែលព្រះអង្គសោយទីវង្គត ព្រោះព្រះអនុជអង្គនេះជាស្ដេចមានសមត្ថភាពហើយត្រូវបានប្រជារាស្ត្រភាគច្រើនគោរពស្រឡាញ់រាប់អានទៀតផង ។

ឯកសារខ្មែរបានបញ្ជាក់ថា អំពើរបស់ព្រះ **សត្ថា** ខាងលើនេះ បានបណ្ដាលអោយមានការអាក់អន់ស្រពន់ចិត្តជាច្រើន ពីសំណាក់រាជវង្សានុវង្ស នាម៉ឺនសព្វមុខមន្ត្រីនិងអាណាប្រជានុរាស្ត្រ ។ ចោរលួច ចោរប្លន់ក៏កើតឡើងគ្រាំងគ្រាត ។

•រីឯប្រជារាស្ត្រខ្មែរកាលបើដឹងថា គ្រាប់ដែលសៀមបាញ់ចូលក្នុងរបងឫស្សីជាប្រាក់សុទ្ធ ក៏មានចិត្តត្រេកអរពន់ពេក នាំគ្នាកាប់ឆ្ការព្រៃឫស្សីដើម្បីយកប្រាក់នោះទោះបីមានបំរាមពីព្រះរាជាយ៉ាងណាក៏ពុំព្រមស្ដាប់ ហើយចេះតែនាំគ្នាប្រព្រឹត្តអំពើនោះរហូតដល់ធ្លុះធ្លាយរបងឫស្សីអស់ ។

•នៅគ.ស.១៥៩៣ សៀមបានលើកទ័ពចូលវាយបន្ទាយលង្វែកម្ដងទៀត ។ ព្រះ**នរេសូរ** បានបញ្ជាអោយទ័ពចូលជា ៣ ផ្លូវ ។ ខ្មែរលើកទ័ពចេញទៅតទល់ តែលើកនេះក៏ដូចជាលើកមុនសៀមវាយយកបានជាបន្តបន្ទាប់គ្នានូវ **បន្ទាយពោធិសាត់** និង **បន្ទាយបរិបូណ៌** ។ ព្រះឧភយោរាជ **ស្រីសុរិយោពណ៌** បកសំបុត្រទៅអោយកែនទ័ព ប្រមូលស្បៀងចូលការពារក្នុង **បន្ទាយលង្វែក** ។ ទ័ពដែលចេញទៅទប់ខាង **នគរវត្ត** ក៏ទប់ពុំជាប់ ។ ឯខាងជើងទឹក ក៏ចាញ់សៀមទៀត ។ សៀមវាយកាន់តែខ្លាំងឡើង ព្រះ-ឧភយោរាជថយមកនៅ **បន្ទាយរលាប្អៀរ** ហើយសុំជំនួយពីលង្វែក ។ សៀមលើកទ័ពមកព័ទ្ធបន្ទាយទៀត ។ លុះទ័ពសៀមមកជិតដល់ ព្រះ **សត្ថាទី១** នាំបុត្រនាម **ជ័យជេដ្ឋា** និង **ពញាតន់** ភៀសទៅតាំងនៅស្រីសន្ធរ ក្រោយមកទៀតភៀសទៅស្ទឹងត្រែង ហើយ

www.budinst.gov.kh www.elibraryofcambodia.org

**យកកាំបិតផុតកៀសរោងទានធំ**ទៅ **ខៀវចន្ទ** ជារាជធានីប្រទេសលាវ **ឈានឆាង** ។

ចំណែកឯព្រះ **ស្រីសុរិយោពណ៌** បានស្កត់នៅក្នុងបន្ទាយលង្វែកដើម្បីប្រយុទ្ធនឹងខ្មាំង ៗ តែទោះបីព្រះអង្គបានចិត្តទុកការពារបន្ទាយយ៉ាងស្វិតស្វាញយ៉ាងណាក៏ដោយ ក៏បន្ទាយនេះត្រូវធ្លាក់ទៅក្នុងកណ្ដាប់ដៃខ្មាំង ក្រោយពីត្រូវឡោមព័ទ្ធអស់រយៈពេល ៣ ខែ ព្រោះវាបានយកចំបើងជុតរបងឫស្សីដែលនៅសល់បន្តិចបន្តួចនោះនៅគ.ស. ១៥៩៣ ។ សៀមចាប់បានព្រះឧភយោរាជ **ស្រីសុរិយោពណ៌** និងបុត្រទាំងពីរ គឺ ព្រះ **ជ័យចេស្ដា** (ព្រះជន្ម ១៥ វស្សា) និង ព្រះ **ឧទ័យ** (ព្រះជន្ម ៥ វស្សា) នាំយកទៅប្រទេសសៀមព្រមជាមួយនឹងក្បួនខ្នាត អ្នកប្រាជ្ញបណ្ឌិតកវី រូបបដិមា **ព្រះគោព្រះកែវ** និងឈើយខ្មែរជាច្រើនទៀត ។ ក្រោយពីបានស្នាក់នៅក្នុងប្រទេសខ្មែរអស់ ៣ ខែ ព្រះ **នរេសួរ** បានយាងត្រឡប់ទៅក្រុង **អយុធ្យា** វិញ ទុកអោយមេហាមន្ត្រីសៀមនៅឈរនៅក្រុងឧដុង្គ ។ គួរគប្បីជ្រាបថា នៅខាងមុខព្រះ **វិហារព្រះកែវ** នៅក្រុងបាងកកប្រទេសថៃសព្វថ្ងៃ មានរូបបដិមា **ព្រះគោ** ដែលមានទំហំសឹងប៉ុនសត្វគោធំ ពោះប្រហោងក្នុង ។ តើនេះជានិមិត្តរូប **ព្រះគោព្រះ-កែវ** ដែលសៀមនាំយកបានទៅនៅគ្រាដែលបានវាយបែកបន្ទាយលង្វែក ឬយ៉ាងណា?

•ចំពោះចំបាំងខ្មែរ-សៀមនៅ គ.ស. ១៥៩៣ នេះ ឯកសារសៀមបាននិយាយថា មកតែពីខ្មែរមិនរក្សាពាក្យសច្ចៈទើបព្រះ **នរេសួរ** លើកទ័ពមកសងសឹក ។ សម្ដេចព្រះ **នរេសួរ** ឃើញកម្លាំងកម្ពុជាទន់ខ្សោយ ទើបមានតម្រាស់អោយព្រះ **សត្ថា** មកគាល់ តែព្រះ **សត្ថា** ត្រឡប់ជាចាប់ទូតថៃដែលអញ្ជើញព្រះបរមរាជឱង្ការៈឃុំទុក ហើយក៏បញ្ជូនទ័ពតស៊ូយ៉ាងខ្លាំង (8) ។ ម្យ៉ាងទៀត រាជពង្សាវតារសៀមបានអះអាងថាទ័ពសៀមបានចាប់បានទាំងព្រះមហាក្សត្រខ្មែរ ហើយព្រះចៅសៀមទ្រង់បញ្ជាអោយប្រហារជីវិតព្រះអង្គដើម្បីយកព្រះលោហិតទៅលាងព្រះបាទទៀតផង (9) និង (10) ។ សព្វថ្ងៃនេះ នៅវត្ត **ជ័យមង្គល** នាខេត្ត **អយុធ្យា** គេឃើញមានរូបគំនូរ ២ ផ្ទាំងដែលគួរអោយចាប់អារម្មណ៍ ៖ រូបទី ១ ជារូបស្ដេចខ្មែរគង់អង្គុយលើកៅអី ១ ទាប មានព្រះសុវត្ថិ ព្រះបាទនិងព្រះហស្តជាប់ចំណងនិងច្រវាក់ រូបទី ២ បង្ហាញពីបុរសម្នាក់ស្លៀកពាក់សក់ពុងកំពុងតែលុតជង្គង់ **យកលោហិត**ស្ដេចខ្មែរទៅលាងព្រះបាទអោយស្ដេចសៀម ។ តើរឿងនេះជាការពិតឬក៏

www.budinst.gov.kh www.elibraryofcambodia.org

ជារឿងប្រឌិតសំរាប់តែលើកសរសើរតាមឫទ្ធិរិទ្ធិព្រះចៅសៀមនាសម័យនោះ ? រាជពង្សាវតារខ្មែរគ្រប់ក្បួនទាំងអស់ពុំឃើញមាននិយាយពីព្រឹត្តិការណ៍នេះឡើយ

## ២. ទំនាក់ទំនងជាមួយអឺរ៉ុប.—

បើតាមប្រភពអឺរ៉ុប **ព្រះសត្ថា** ជាក្សត្រទន់ខ្សោយ ហើយទ្រង់មានព្រះហឫទ័យព្រួយណាស់ចំពោះព្រះអនុជគឺព្រះ **ស្រីសុរិយោពណ៌** ។ ដោយហេតុថាព្រះអង្គត្រូវការជំនួយដើម្បីប្រឆាំងនឹងសត្រូវខាងក្នុងនិងខាងក្រៅ ព្រះអង្គក៏ទ្រង់បានយកចិត្តពួកអ្នកផ្សាយសាសនាយ៉ាងខ្លាំង ។ ពួកនេះមានសិទ្ធិពេញលេញក្នុងការផ្សាយលទ្ធិរបស់ខ្លួន មានសិទ្ធិសង់ព្រះវិហារនៅគ្រប់ទីកន្លែងក្នុងព្រះរាជាណាចក្រ ។ ព្រះរាជាទ្រង់បានជួយឧបត្ថម្ភពួកនេះរហូតដល់បានបញ្ជូនអក្សរនិងវត្ថុផ្សេងៗ ទៀតទៅអោយអង្គការភូមិភាគនៅ Malacca ។ នៅគ.ស. ១៥៨៥ នាយចៅហ្វាយរបស់បព្វជិត Sylvestre បានសំរេចចិត្តថាត្រូវតែគាំទ្រលោក ហើយបានបញ្ជូនមកជាបន្ថែមនូវបព្វជិតទៀត គឺបព្វជិត Antonio Dorta និងបព្វជិត Antonio Caldeira ។ ក្នុងពេលជំណាលគ្នានោះ មានបព្វជិតខាងគណៈហ្វ្រង់ស៊ីស្កាំង (Franciscain) ក៏បានមកប្រទេសខ្មែរដែរ ៖ ក្នុងចំណោមនេះ មានបព្វជិតនាម Gregorio Ruiz ។ តែដោយមានការធ្វើទុក្ខបុកម្នេញកើតឡើងជាថ្មីទៀត បព្វជិតទាំងពីរអង្គខាងក្រោយនេះក៏និមន្តត្រឡប់ទៅវិញអស់ ។ ពេលនោះ បព្វជិត Sylvestre បានប្រើឥទ្ធិពលរបស់លោក ហើយព្រះសត្ថាធី ១ក៏ទ្រង់អនុញ្ញាតនៅគ.ស. ១៥៨៩ ថាបព្វជិតអង្គណាក៏ដោយ អាចផ្សាយសាសនាបាននៅគ្រប់ទីកន្លែងក្នុងប្រទេសខ្មែរ ហើយជនជាតិខ្មែរណាក៏ដោយក៏អាចកាន់សាសនាថ្មីនេះបានដោយគ្មានខ្លាចពីការសងសឹកឡើយ ។ ដោយហេតុនោះ បព្វជិត Sylvestre ក៏បានសុំអោយអង្គការកណ្ដាលបញ្ជូនបព្វជិតមកបន្ថែម ។ ជាការឆ្លើយតបនឹងសេចក្ដីអំពាវនាវនេះ បព្វជិត Jorge de Mota និង Luis de Fonseca ក៏ត្រូវបានគេបញ្ជូនមកទៀត តែនៅពេលលោកទាំងពីរនិមន្តមកដល់ បព្វជិត Sylvestre ក៏បានសុគតរួចទៅហើយ (19) ។

គួរគប្បីជ្រាបថា នៅគ្រានោះមិនគ្រាន់តែមានពួកបព្វជិតទេ ដែលបានមកប្រទេសខ្មែរ ពួកអ្នកផ្សងព្រេងខ្លះក៏បានមកក្នុងពេលជាមួយគ្នាដែរ ។ នៅគ.ស. ១៥៨៥ ជនជាតិព័រទុយហ្គាល

www.budinst.gov.kh www.elibraryofcambodia.org

ដែលមាននៃយនៅក្នុង (២០ឆ្នាំ) ឈ្មោះ Diogo Veloso បានមកដល់ប្រទេសខ្មែរជាមួយបក្ខពួកមួយក្រុមគឺ Carneiro, Machado, Sagrado, Diogo de Chaves Carnizares ។ល។ ប៉ុន្មានឆ្នាំក្រោយមកទៀត (ដើម គ.ស. ១៥៩៣) អ្នកផ្សងព្រេងជាតិអេស្ប៉ាញក៏បានមកដល់ គឺលោក Ruiz de Hernan Gonzalès និង Vargas Machuca ។

ពួកជនផ្សងព្រេងទាំងនេះត្រូវបានព្រះ សត្ថា ស្រឡាញ់រាប់អានយ៉ាងខ្លាំងហើយពួកនេះក៏ជាប់ជំពាក់ចិត្តយ៉ាងខ្លាំងជាមួយនឹងព្រះអង្គវិញដែរ ។ ព្រះ សត្ថា ទ្រង់សព្វព្រះទ័យរៀបអភិសេកប្អូនជីដូនមួយស្រីម្នាក់របស់ព្រះអង្គអោយទៅលោក Diogo Veloso ឯចំណែកលោក Ruiz ត្រូវបានព្រះអង្គតែងតាំងជាអង្គរក្សរបស់ព្រះអង្គ (9) ។

ចមកហើយ យើងឃើញថានៅ គ.ស. ១៥៩៣ ព្រះចៅសៀមនាមព្រះ នរេសួរ បានលើកទ័ពចូលមកវាយខ្មែរជាលើកទី២ ដោយមានរេហ៍ពលច្រើនជាងលើកទី១ទៅទៀត។ តាមរយៈ Veloso ព្រះ សត្ថាទី១ ទ្រង់បានទាក់ទងជាមួយអ្នកកាន់អំណាចព័រទុយហ្គាល់នៅ Malacca តែពួកព័រទុយហ្គាល់មិនអាចជួយខ្មែរព្រោះរវល់តែជាប់ដៃច្បាំងនឹងពួកម៉ាឡាយូនៅ Acheh និងនៅ Johore (20) ។ ដោយហេតុនោះ ព្រះ សត្ថាទី១ ទ្រង់ងាកទៅរកជំនួយពីពួកអេស្ប៉ាញវិញ តាមការថ្វាយយោបល់របស់លោក Ruiz និង Vargas ។

គួរគប្បីជ្រាបថាជនជាតិអេស្ប៉ាញ ជាជនជាតិអឺរ៉ុបដែលបានមកកាន់អាស៊ីអគ្នេយ៍បន្ទាប់ពីពួកព័រទុយហ្គាល់ ។ ពួកនេះបានវាយយកប្រទេសហ្វីលីពីនដាក់ជាអាណានិគមរបស់ខ្លួនក្នុងរាជ្យស្តេច Philippe ទី២ ហើយការវាយយកប្រទេសហ្វីលីពីននេះជាស្នាដៃរបស់មេទ័ពជើងទឹកម្នាក់ឈ្មោះ Miguel Lopez de Legaspi ។ ពួកអេស្ប៉ាញបានត្រួតត្រាប្រទេសហ្វីលីពីន ពីគ.ស. ១៥៦៧ ដល់ គ.ស. ១៨៩៦ ហើយបានតាំងរាជធានីរបស់ខ្លួននៅក្រុងម៉ានីល ។

នៅខែ កក្កដា ១៥៩៣ ព្រះសត្ថាទី១ ទ្រង់ចាត់អោយលោក Veloso មួយអន្លើនឹង Vargas និង Carneiro នាំយកព្រះរាជសារទៅជូនលោកទេសាភិបាលអេស្ប៉ាញនៅក្រុងម៉ានីលដើម្បីសុំជំនួយទ័ពមកច្បាំងនឹងសៀម ។ ដើម្បីជាសគុណ ព្រះអង្គទ្រង់បានសន្យា


www.budinst.gov.kh www.elibraryofcambodia.org

ជាទីងបើកសិទ្ធិអោយពួកអេស្ប៉ាញមកផ្សាយសាសនានិងធ្វើជំនួញនៅប្រទេសខ្មែរ ។ លោកទេសាភិបាលអេស្ប៉ាញឈ្មោះ Gomez Perez Dasmarinas បានសរសេរលិខិតចុះថ្ងៃ២៨ ខែកញ្ញា ១៥៩៣ ឆ្លើយតបមកព្រះរាជាខ្មែរវិញ ថាទីងជួយជ្រះជ្រាជម្លោះរវាងខ្មែរនិងសៀម ។ លោកពុំបានបញ្ជូនជំនួយទ័ពមកជួយខ្មែរទេ ព្រោះលោកកំពុងតែរៀបចំទ័ពទៅវាយយកកោះម៉ូលុក (Moluques) ។ ជាអកុសល នៅពេលដែលចេញដំណើរនៅថ្ងៃ ៣០ ខែតុលា ១៥៩៣ លោកត្រូវពួកចិនអ្នកអុំសំពៅលោកលួចធ្វើឃាតលោកទៅ(9) ។

កូនប្រុសរបស់លោកឈ្មោះ Luis Perez Dasmarinas បានឡើងកាន់អំណាចជាជំនួសឪពុកលោក ។ លោកទេសាភិបាលថ្មីនេះបានសរសេរលិខិតមួយទៀតផ្ញើទៅថ្វាយព្រះរាជាខ្មែរ ។ Veloso និងបក្សពួកបានសំបុត្រនោះហើយក៏ធ្វើដំណើរត្រឡប់មកប្រទេសខ្មែរវិញ ។ តែជាអកុសល ទ័ពសៀមបានវាយលុកយកបានបន្ទាយលង្វែកជាស្រេច ។

Veloso និង Carneiro បានធ្វើសង្គ្រាមវាយធ្មក់ប្រឆាំងនឹងពួកសៀមតែត្រូវចាប់បានហើយយកទៅឃុំឃាំងជាមួយនឹង Ruiz ជាអ្នកនៅការពារបន្ទាយលង្វែកជាមួយនឹងព្រះឧកញ៉ារាជ **ស្រីសុរិយោពណ៌** ។ ក្រៅពីនេះ មានបព្វជិតជាតិអឺរ៉ុបខ្លះទៀតត្រូវសៀមចាប់យកទៅក្រុងអយុធ្យាដែរ គឺបព្វជិត Jorge de Mota និង Luis de Fonseca ។

ពួកឈ្លើយសង្គ្រាមទាំងនោះ ខ្លះត្រូវបានដឹកនាំទៅតាមផ្លូវគោក ខ្លះទៀតទៅតាមផ្លូវទឹក ។ លោក Ruiz, Carneiro និង Machado ត្រូវគេដឹកទៅតាមសំពៅមួយ ។ លោក Ruiz បាននាំពួកឈ្លើយបះបោរឡើង ដណ្តើមយកបានសំពៅ ហើយធ្វើដំណើរឆ្ពោះទៅក្រុងម៉ានីល (ទៅដល់នៅខែមិថុនា ១៥៩៤) ។

ចំណែកឯលោក Veloso នៅក្រុង**អយុធ្យា**ត្រូវបានព្រះ**នរេសួរ**ចាត់អោយនាំរាជទូតសៀមទៅក្រុងម៉ានីលដើម្បីសុំចងសម្ព័ន្ធមេត្រីជាមួយពួកអេស្ប៉ាញនៅគ.ស. ១៥៩៥ ។ លុះសំពៅមកដល់ច្រកទន្លេមេគង្គ គេក៏បានដំណឹងតាមទាហានសៀមដែលបាក់ទ័ពពីលង្វែកថាស្តេចខ្មែរដណ្តើមអំណាចបានវិញហើយ ។ លោក Veloso មិនដឹងថាព្រះ **រាមជើងព្រៃ** ស្មានថាព្រះ **សត្ថា** ។ លោកក៏បន្តដំណើរទៅដល់ក្រុងម៉ានីលនៅពាក់កណ្តាលខែមិថុនា

www.budinst.gov.kh www.elibraryofcambodia.org

១៥៩៥ ហើយបានជួបនឹងមិត្តរបស់លោក គឺ Ruiz, Carneiro និង Machado ។ ដូច្នេ
ន្នែដែលត្រូវការការផលប្រយោជន៍របស់សៀម លោក Veloso បែរជាមានគំនិតគិតត្រឡប់
មកជួយខ្មែរវិញ ។ ដោយហេតុនោះ លោកបានស្រុះស្រួលជាមួយមិត្តភក្តិលោកធ្វើអន្ត
រាគមន៍សុំជំនួយពីពួកអេស្ប៉ាញ ដើម្បីមកជួយព្រះរាជាខ្មែរ ហើយបានទទួលការគាំទ្រយ៉ាង
សកម្ម ជាពិសេសពីសំណាក់លោកទេសាភិបាល Luis Perez Dasmarinas ។

## ២— ផលវិបាកនៃការបែកបាក់ក្រុងលង្វែក.—

ការវាយបែកក្រុងលង្វែកដោយជនជាតិសៀមមានផលវិបាកអាក្រក់យ៉ាងខ្លាំងសំរាប់ប្រ
ជាជាតិខ្មែរ ។ គឺពីនេះទៅ ប្រទេសខ្មែរត្រូវជួបប្រទះនឹងវិបត្តិកាន់តែច្រើនឡើង ។ យ៉ាង
ណាមិញ ទំនាស់ផ្ទៃក្នុងប្តូករួមជាមួយនឹងកត្តាផ្សេង ៗ ជាទៅទៀត បានញាំងមហាអំណា
ខ្មែរអន្តរអោយចុះទន់ខ្សោយបន្តិចម្តង ៗ រហូតដល់លើករាជធានីពី **យសោធរបុរ** មកតាំងនៅ
ទួលបាសាន រួចនៅចតុមុខ ។ នៅសម័យលង្វែក ជាពិសេសក្នុងរជ្ជកាលរបស់ព្រះបា
**ចន្ទរាជា** និង **បរមរាជាទី ៤** ខ្មែរបានពង្រឹងជំហររបស់ខ្លួនបានវិញ ហើយមានលទ្ធភា
លើកទ័ពទៅវាយលុករាជធានីស្រីអយុធ្យានិងវាយរំដោះយកអាណាខេត្តខាងលិចមកវិញបា
ជាច្រើន ។ ប៉ុន្តែក្រោយពីបន្ទាយលង្វែកត្រូវបែកបាក់ទៅ ទឹកដីមួយភាគធំនៅឯនាយ
ដងរែកនិងនៅខាងលិចត្រូវបាត់បង់ទៅវិញជាស្ថាពរ ។

ការបែកបាក់បន្ទាយលង្វែកជាហេតុញាំងប្រទេសខ្មែរអោយអស់ឫទ្ធានុភាព ធ្លាក់ខ្លួ
ជាវត្ថុតូចតាចនៅភូមិភាគអាស៊ីអាគ្នេយ៍ ។ នេះជាលើកទី ៣ ហើយដែលខ្មែរត្រូវបាត់ប
អស់ក្បួនខ្នាត អ្នកប្រាជ្ញបណ្ឌិតកវីដែលត្រូវខ្មាំងកៀរយកទៅស្រុកវា ។ ម្យ៉ាងទៀ
អនាធិបតេយ្យក៏កើតមានឡើងហើយនៅចុងសតវត្សទី ១៦ នេះ គេឃើញមានការជ្រែករា
រហូតដល់ទៅពីរលើក ។

## ២-១-ការគ្រងរាជ្យនៃព្រះរាមជើងព្រៃ ( ១៥៩៤ – ១៥៩៦ ) .—

**ព្រះរាមជើងព្រៃ** ត្រូវជាព្រះញាតិរបស់ព្រះ **សត្ថាទី ១** ។ នៅគ.ស. ១៥៩៤ព្រះអ

www.budinst.gov.kh www.elibraryofcambodia.org

បានលើកទៅវាយសៀមនៅបន្ទាយខដុត្ត ។ សៀមចាញ់ក៏ដកថយទៅស្រុកវិញអស់ទៅ ។ **ព្រះរាមជើងព្រៃ** (តាមឯកសារព័រទុយហ្គាល់ ហៅថា Anacaparan) បានឡើងសោយរាជ្យនៅស្រីសន្ធរ (Siri Strol ឬ Sistor) ។

រួចមកហើយ យើងបានឃើញថាលោក Veloso កាលដែលទៅសុំជំនួយពីទេសាភិបាលអេស្ប៉ាញនៅប្រទេសហ្វីលីពីនបំរុងយកមកជួយព្រះ **សត្ថា** ទី ១ នោះ ឃើញថាបានទទួលការគាំទ្រយ៉ាងសកម្ម ជាពិសេសពីសំណាក់លោកទេសាភិបាល Luis Perez Dasmarinas តែម្ដង ។

បើតាមឯកសារអឺរ៉ុប លោក Veloso បានធ្វើបញ្ជីផែនការហើយដាក់ជូនទៅលោកទេសាភិបាល ។ ក្នុងបញ្ជីនោះ មានគ្រោងពីការតាំងអាណាព្យាបាលភាពរបស់អេស្ប៉ាញមកលើប្រទេសខ្មែរ និងការផ្លាស់សាសនារបស់ប្រជារាស្ត្រខ្មែរទាំងស្រុង (19) ។ កងនាវាបានចេញដំណើរពីក្រុងម៉ានីលនៅថ្ងៃទី ១៩ មករា ១៥៩៦ ហើយត្រូវស្ថិតនៅក្រោមបញ្ជាការរបស់មេទ័ពឈ្មោះ Jaurez Gallinato : ពលទាហានមានប្រមាណពី ១២០ ទៅ-១៣០ នាក់ ជនជាតិជប៉ុនកាន់សាសនាគ្រិស្ត ២០នាក់ ជនជាតិហ្វីលីពីនខ្លះ និងបព្វជិតគណៈដូមីនីកាំង ៣ អង្គ ។ មេដឹកបព្វជិតគណៈដូមីនីកាំង គឺបព្វជិត Alonso Jimenez ជាសហ-មេបញ្ជាការនៃប្រតិបត្តិការនេះ (19) ។

លុះធ្វើដំណើរមកដល់ក្រុងចតុមុខ (churdumuco) លោក Ruiz និងលោក Veloso បានភ្ញាក់ខ្លួនដឹងថាព្រះ **សត្ថា** ទី ១ (Apran Langara) និងរាជបុត្រ ២ អង្គបានភៀសទៅប្រទេសលាវហើយ ហើយមានក្សត្រអង្គថ្មីឡើងសោយរាជ្យរួចជាស្រេចដែរ ។ នៅថ្ងៃទី មេសា ១៥៩៦ ជម្លោះមួយបានផ្ទុះឡើងរវាងពួកឈ្មួញចិននិងពួកទាហានជើងទឹកអេស្ប៉ាញ ។ ឈ្មួញចិនប្រមាណ ១៨០ នាក់ត្រូវស្លាប់ ហើយទំនិញនិងសំពៅរបស់ខ្លួនក៏ត្រូវរឹបអូសទាំងអស់ ។ លោក Veloso បានសុំអនុញ្ញាតពីព្រះ **រាមជើងព្រៃ** អោយចូលគាល់ដើម្បីបំភ្លឺព្រះអង្គពីឧបត្តិហេតុដែលបានកើតឡើងនោះ តែព្រះរាជាដាក់លក្ខខណ្ឌថា ទាល់តែពួកអេស្ប៉ាញត្រូវសងទំនិញទៅពួកចិនទាំងអស់ជាមុនសិន ទើបព្រះអង្គទ្រង់អនុញ្ញាតអោយ

www.budinst.gov.kh www.elibraryofcambodia.org

បាន(១) ។ ដោយហេតុនោះលោក Veloso និងលោក Ruiz បានសំរេចថាត្រូវតែប្រើកម្លាំងទ័ពវិញ ៖ ជាមួយនឹងទាហាន ៣៨ នាក់ គេបាននាំគ្នាទៅឡោមព័ទ្ធវាំងនៅស្រីសន្ធរនៅពេលយប់ ធ្វើគត់ព្រះ **រាមជើងព្រៃ** បានមុនពេលថ្ងៃរះ ( ឯកសារខ្លះថានៅម៉ោង ៦ ល្ងាច) រួចវិលត្រឡប់មកក្រុងភ្នំពេញវិញ ហើយបានជួបនឹងកងនាវារបស់លោកGallinato ដែលត្រូវខ្យល់បក់ញាំប្រានរហូតទៅដល់សិង្ហបុរីនិងត្រូវសំចតនៅ Malacca ដើម្បីធ្វើការជួសជុលខ្លះ ។ លោក Gallinato មានសេចក្ដីមិនពេញចិត្តចំពោះសកម្មភាពរបស់ទាហានលោក ។ លោកបានបង្ខំអោយទាហានលោកសងទំនិញដែលបានប្លន់យកពីពួកឈ្មួញចិន ហើយក្រោយពីបានធ្វើការពិនិត្យអោយស្គាល់ទឹកដីបន្តិចបន្តួច ក៏បានចេញដំណើរឆ្ពោះទៅប្រទេសចាម្ប៉ា ទោះបីមានការប្រឆាំងតវ៉ាពីសំណាក់លោក Veloso និងពួកបព្វជិតយ៉ាងណាក៏ដោយ ។ លោកបានចូលសំចតនៅ Cachan (Faifo) ដើម្បីអោយលោក Ruiz និងលោក Veloso ធ្វើដំណើរទៅវៀងច័ន្ទនាំយកពត៌មានទៅថ្វាយព្រះ **សត្ថាទី ១** ស្ដីពីហេតុការណ៍នៅក្នុងប្រទេសខ្មែរ ។ ក្រុមនាវិករបស់លោក Gallinato មានជម្លោះជាមួយឈ្មួញជប៉ុននិងជនជាតិយួននៅលើឆ្នេរសមុទ្រ ហើយដោយខ្វាចរដូវភ្លៀងមកដល់ លោកក៏ចេញដំណើរឆ្ពោះទៅក្រុងម៉ានីលវិញនៅដំណាច់ គ.ស.១៥៩៦ ។

## ២-២-ព្រះបរមរាជាទី ៦ ចៅពញាតន់ (១៥៩៦-១៥៩៩).—

លុះទៅដល់ក្រុងវៀងចន្ទដោយបានទទួងកាត់តាមផ្លូវភ្នំអាណ្ណាមមក លោក Ruiz និង Veloso មានសេចក្ដីសោកស្ដាយយ៉ាងខ្លាំងដោយដឹងថាព្រះ **សត្ថាទី១** និងព្រះរាជបុត្រច្បង **ជ័យជេដ្ឋា** បានសោយទីវង្គតរួចទៅហើយ ។ លោកទាំងពីរក៏បានដង្ហែព្រះរាជបុត្របន្ទាប់ **ចៅពញាតន់** រាជវង្សានុវង្សនិងទាហានលាវខ្លះអោយត្រឡប់ចូលមកប្រទេសខ្មែរវិញ ។ នៅតាមផ្លូវ គេបានជួបប្រទះនឹងកងទ័ពជើងទឹកមួយដែលស្ថិតក្រោមបញ្ជាការរបស់ថ្នាម្នាក់ដែលព្រះ **រាមជើងព្រៃ** បានតាំងអោយធ្វើជាមេទ័ព ។ មេទ័ពថ្នារូបនេះបានគាំទ្រនិងការពារបុត្រមួយអង្គរបស់ព្រះ **រាមជើងព្រៃ** ប៉ុន្តែនៅពេលដែលពួកនាម៉ឺនសព្វមុខមន្ត្រីបានទទួលស្គាល់ **ចៅពញាតន់** ជាក្សត្រមានសិទ្ធិឡើងសោយរាជ្យ គាត់ក៏យល់ស្របតាមគេដែរ ។

www.budinst.gov.kh www.elibraryofcambodia.org

ដូច្នេះ **ចៅពញ្ញាតន់** ក៏បានឡើងសោយរាជសម្បត្តិនៅរាជធានីស្រីសន្ធរៈ ដោយមានព្រះនាមសំរាប់រាជ្យថាព្រះ **បរមរាជា ទី៦** ហើយឯកសារអឺរ៉ុបហៅថា Prauncar ។ គួរកត់សំគាល់ថា គ្រានោះបុត្ររបស់ព្រះ **រាមជើងព្រៃ** ត្រូវបានពួកថៃ ចិន និងជប៉ុនខ្លះគាំទ្រយ៉ាងសកម្ម ចំណែកឯព្រះ **បរមរាជា** មានតែពួកព័រទុយហ្កាល់ អេស្ប៉ាញ និងជប៉ុនភាគច្រើនគាំទ្រប៉ុណ្ណោះ ។

តាមឯកសារអឺរ៉ុបថា មេទ័ពថៃដែលមានងារជា **លក្សិណា** ( ឯកសារខ្មែរថាជាឈ្មោះទៅវិញ ) មានការប្រណែននិន្ទានឹងជនជាតិអឺរ៉ុប ហើយពុំបានបំពេញកិច្ចការផ្ញើអោយបានជិតដល់ទេ ។ ចំណែកឯពួកទាហានលាវដែលបានជន្លៀស **ចៅពញ្ញាតន់** ត្រឡប់ចូលស្រុកវិញនោះបានបះបោរ ហើយនៅទីបំផុតក៏ត្រឡប់ទៅវិញអស់ទៅ ។ ដើម្បីជាសគុណ ព្រះ **បរមរាជាទី៦** បានតែងតាំងលោក Veloso ជាចៅហ្វាយស្រុកខេត្តបាភ្នំ ឯលោក Ruiz ជាចៅហ្វាយស្រុកខេត្តត្រាំង ។

ក៏ដូចជាព្រះបិតារបស់ព្រះអង្គដែរ ព្រះ **បរមរាជាទី ៦** ទ្រង់បានផ្ញើសារទៅក្រុងម៉ានីលដើម្បីសុំអោយពួកបព្វជិតនិមន្តមកប្រទេសខ្មែរ ដោយទ្រង់សន្យាថានឹងជួយសង់ព្រះវិហារ និងទ្រង់អនុញ្ញាតអោយជនជាតិខ្មែរចូលសាសនាគ្រិស្តទៅតាមជំនឿរបស់ខ្លួន ។ បន្ទាប់ពីនោះ គេឃើញមានបព្វជិតខ្លះបានមកដល់ប្រទេសខ្មែរ ខ្លះដោយចេតនា ខ្លះដោយចៃដន្យ ។ ប៉ុន្តែស្ថានភាពរបស់ជនជាតិអឺរ៉ុបពុំបានធឹងធម ។ គេថាព្រះ **បរមរាជាទី ៦** ជាមនុស្សខិលខ្ជិលជាងព្រះបិតាព្រះអង្គទៅទៀត ហើយត្រូវដឹកនាំដោយពួកមហេសីនិងព្រះមាតាក្មេកដែលក្លាយជាសហាយរបស់មេទ័ពថៃឈ្មោះ **លក្សិណា** ។ បើតាមលោក Ruiz ជានៅពាក់កណ្តាល គ.ស. ១៥៩៨ ទៅហើយ ព្រះរាជាពុំទាន់បានទទួលរាជាភិសេកសោយរាជសម្បត្តិនៅឡើយ ឯលោក Ruiz និងលោក Velcso ក៏ពុំទាន់បានទៅកាន់អំណាចក្នុងខេត្តរបស់ខ្លួនដែរ ។

ដើម្បីពង្រឹងអំណាចរបស់ព្រះអង្គ ហើយដោយមានសំណើពីលោក Ruiz ផង ព្រះរាជាទ្រង់បានផ្ញើសារទៅជូនលោកទេសាភិបាលថ្មីនៃប្រទេសហ្វីលីពីន ដើម្បីសុំជំនួយជាទ័ពនិង

www.budinst.gov.kh www.elibraryofcambodia.org

អ្នកផ្សាយសាសនា ។ កាលណោះ មានការជំទាស់យ៉ាងខ្លាំងចំពោះការសុំជំនួយនេះ មន្ត្រីលោក Luis Perez Dasmarinas ទទួលរៀបចំប្រតិបត្តិការមួយដោយចេញសោហ៊ុយផ្ទាល់ខ្លួនលោក ។ នៅថ្ងៃ ១៧ ខែកញ្ញា ១៥៩៥ កងនាវាមួយដឹកនាំទាហានអេស្ប៉ាញ ២០០ នាក់ បព្វជិតដូមីនីកាំង ២ អង្គ បព្វជិតហ្វ្រង់ស៊ីស្កាំង ២ អង្គ បានចេញដំណើរពីក្រុងម៉ានីលឆ្ពោះមកប្រទេសខ្មែរ ក្រោមបញ្ជាការរបស់លោក Luis Perez Dasmarinas ។ ប៉ុន្តែជាអកុសល កងនាវាត្រូវជួបប្រទះនឹងខ្យល់ព្យុះបក់ទៅវង្វេងនៅប្រទេសចិនជិតក្រុងកង់តុង ។ ជនដែលរស់រានមានជីវិតទាំងប៉ុន្មានបានត្រឡប់ទៅក្រុងម៉ានីលវិញ ។ កប៉ាល់មួយដែលបានទទួលបេសកកម្មអោយស្វែងរកពួកជនវង្វេង នោះ ហើយដែលបានដឹកនាំទាហាននិងបព្វជិតបានមកដល់ចតុមុខនៅគ.ស.១៥៩៥ ។ ជម្លោះមួយបានកើតឡើងរវាងពួកនាវិកអេស្ប៉ាញនិងពួកជ្វា ។ លុះដឹងដំណឹងនេះ លោក Veloso និងលោក Ruiz បានមកដល់កន្លែងកើតហេតុ ហើយត្រូវគេសម្លាប់ទាំងពីរនាក់ ។ ព្រះរាជាលើកទ័ពមកដោយផ្ទាល់ព្រះអង្គហើយត្រូវធ្វើគត់នៅលើសមរភូមិដោយពួកចាមជ្វាប៉ះបោរទៀត(9) ។ គួរគប្បីជ្រាបថា ចំពោះការសោយទិវង្គតរបស់ព្រះបាទ **បរមរាជាទី ៦** នេះ ឯកសារខ្មែរបានផ្តល់ពតិមានប្លែកពីពតិមានរបស់ពួកអឺរ៉ុបទៅវិញ ។ យ៉ាងណាមិញ រាជពង្សាវតារខ្មែរខ្លះបាននិយាយថា កាលព្រះអង្គមានព្រះជន្មបាន ២១ វស្សា ស្តេចព្រះរាជដំណើរលើកទ័ពចេញទៅចាប់ស្រុកត្បូងឃ្មុំ នោះមានចាមឈ្មោះ **ប៉ោទិត** ១ ជ្វាឈ្មោះ **លក្សិណា** ១ វាលុកស្តេចក្សយព្រះជន្មទៅ ។

## ៦-៣- ព្រះបរមរាជាទី ៧ ប៉ោពញាអន (១៥៩៩–១៦០០).—

**ប៉ោពញាអន** ជារាជបុត្រពៅរបស់ព្រះ **សត្ថា** ត្រូវបានពួកនាម៉ឺនសព្វមុខមន្ត្រីយាងអោយឡើងសោយរាជ្យនៅស្រីសន្ធរ ដោយមានព្រះនាមថាព្រះ **បរមរាជា ទី៧** ។ ព្រះអង្គទ្រង់បានបន្តនយោបាយរបស់ជនតាព្រះអង្គដោយអំពាវនាវអោយពួក អ្នកផ្សាយ សាសនាគ្រិស្តចូលក្នុងប្រទេសព្រះអង្គ និងអោយពួកទាហានមកជួយការពារផងដែរ ។

រាជពង្សាវតារខ្មែរបានបញ្ជាក់ថា ស្តេចអង្គនេះជាក្សត្រមិនប្រកបដោយទសពិធរាជ

www.budinst.gov.kh www.elibraryofcambodia.org

ធម៌ ។ ថ្ងៃមួយ យាងទៅប្រពាតព្រៃ លុះទៅដល់ភូមិតាមាត់ ទ្រង់សព្វព្រះហឫទ័យស្រឡាញ់ស្ត្រីម្នាក់ជាប្រពន្ធរបស់មេស្រុក ឈ្មោះពញាចឺ ។ ព្រះអង្គទ្រង់បញ្ជាអោយចាប់យកដោយបង្ខំ ហើយដោយស្ត្រីនោះប្រកែកមិនព្រមផិតក្បត់នឹងប្តីរបស់នាង នាងក៏ត្រូវទទួលទារុណកម្មរហូតដល់បាត់បង់ជីវិត ។ ប្តីរបស់នាងមានសេចក្តីក្តៅក្រហាយក្រាំងចំពោះអំពើរំលោភជិះជាន់បែបនេះក៏រត់ទៅចូលខាង **កែវព្រះភ្លើង** ។ ក្នុងកាលបុណ្យចំរើនព្រះជន្មព្រះ **បរមរាជាទី៧ កែវព្រះភ្លើង** បានចាប់កព្រួកបង្ខំចូលធ្វើគត់ព្រះអង្គបាននៅរាជវាំងស្រីសន្ធរនៅ គ.ស ១៦០០ ។

## ២.៤- សម្តេចព្រះកែវហ្វា ៖ចៅពញាញោម ( ១៦០០-១៦០៣ ).—

**ចៅពញាញោម** ( ឯកសារអឺរ៉ុបហៅថា **Nacque Sumaday Peraorachyoncar** ) ជាបុត្រពៅរបស់ព្រះ **សត្ថាទី១** ។ រាជពង្សាវតារខ្មែរថា ព្រះអង្គបានឡើងគ្រងរាជសម្បត្តិស្នងព្រះបិតុច្ឆានៅពេលដែលព្រះអង្គមានព្រះជន្មាយុ ២១ ព្រះវស្សា ។ ព្រះអង្គមានព្រះនាមសំរាប់រាជ្យថា **សម្តេចព្រះកែវហ្វា** គង់នៅព្រះរាជវាំងស្រីសន្ធរ ។

ឯកសារអឺរ៉ុបនិយាយថា ព្រះអង្គទ្រង់បានប្រយុទ្ធប្រឆាំងនឹងព្រះបិតុច្ឆាព្រះនាម **ស្រី-សុរិយោពណ៌** ដើម្បីបានឡើងសោយរាជ្យ ។ ព្រះអង្គទ្រង់បានលើករាជធានីមកតាំងនៅភ្នំពេញវិញ ( គ.ស. ១៦០១ ) ។ ព្រះអង្គបានប្តូរគោលនយោបាយរបស់ក្សត្រសោយរាជ្យមុនៗ ព្រះអង្គ គឺទ្រង់បានទាក់ទងជាមួយអង្គការផ្សាយសាសនានៅ Malacca ។ នៅដើម គ.ស. ១៦០៣ ទេសាភិបាលអេស្ប៉ាញនៅម៉ានីលបានបញ្ជូនទាហាននិងបព្វជិតខ្លះមកប្រទេសខ្មែរជាកិច្ចឆ្លើយតបចំពោះសេចក្តីអំពាវនាវរបស់**ចៅពញាអន** ។ ពេលនោះប្រទេសកំពុងតែមានចលាចល ប៉ុន្តែ **ព្រះកែវហ្វា** ទ្រង់បានទទួលជនបរទេសទាំងនោះយ៉ាងរាក់ទាក់ណាស់ ។ ព្រះអង្គទ្រង់បានជួយកសាងព្រះវិហារ ព្រមទាំងផ្តល់ស្បៀងជាអង្ករ ផ្តល់នូវសេរីភាពផ្សាយសាសនានិងគរអង្គាស់សាសនាទៀត ។

ឯកសារអឺរ៉ុបបាននិយាយបន្ថែមទៀតថា នៅគ.ស. ១៦០៣ដដែលនេះ ព្រះ **ស្រីសុរិយោពណ៌** ដោយមានជំនួយពីពួកសៀមផង បានលើកមកវាយឈ្លះ **ព្រះកែវហ្វា** ហើយ

www.budinst.gov.kh www.elibraryofcambodia.org

ស្រុកខេត្តក៏បានសុខសន្តិភាពចាប់តាំងពីពេលនោះមក ។ ស្ដេចខ្មៅ (ព្រះធម្មសោករាជ) បាននាំពួកអ្នកផ្សាយសាសនាជាឈ្លើយយកទៅប្រទេសសៀម ។ ប្រភពដដែលនេះបានបញ្ជាក់ទៀតថា : ដោយទ្រង់ទទួលឥទ្ធិពលខ្លាំងពីសៀម ព្រះស្រីសុរិយោពណ៌ ទ្រង់មិននិយមរាប់អានសាសនាគ្រិស្តទេ ហើយទ្រង់បានបញ្ចូលទំនៀមទំលាប់សៀមមកក្នុងប្រទេសខ្មែរថែមទៀតផង ។

ចំណែកឯរាជពង្សាវតារខ្មែរបាននិយាយថា ព្រះកែវហ្វា ជាក្សត្រមិនរវល់នឹងកិច្ចការផែនដី ចូលចិត្តបណ្ដោយចិត្ត គង់សេះដេញសត្វ បៀតបៀនកូនប្រពន្ធអ្នកដទៃ ជាហេតុបណ្ដាលអោយនាម៉ឺនជិះជាន់រាស្ត្រ កើតចោរលួចចោរប្លន់ ទើបសម្ដេចព្រះឧទីក្សត្រីត្រូវជាសម្ដេចព្រះអយ្យកាជំនុំនឹងមន្ត្រីរួចផ្ញើសារទៅក្រុងស្រីអយុធ្យា ក្រាបទូលព្រះចៅសៀមបើកសម្ដេចព្រះ ស្រីសុរិយោពណ៌ អោយចេញមកក្រុងកម្ពុជាធិបតី ។

*

* *

## បញ្ជីស្ដេចខ្មែរសោយរាជ្យពីគ.ស. ១៣៩៣ ដល់ ១៦០៣

| លេខរៀង | នាមសំគាល់រាជ្យ<br>នាមផ្ទាល់ | កាលកំណត់រជ្ជកាល | រាជធានី | រាជវង្ស |
|---|---|---|---|---|
| ១ | បរមរាជាទី ២<br>ចៅពញាយ៉ាត | ១៣៩៣–១៤៦៣ | យសោធរបុរៈ<br>ទួលបាសាន<br>ភ្នំពេញ | បុត្រព្រះបាទ<br>សុរិយោវង្ស |
| ២ | នារាយណ៍រាជាទី ១ | ១៤៦៣–១៤៦៩ | ភ្នំពេញ | បុត្រស្ដេច ១ |
| ៣ | ស្រីរាជា | ១៤៦៩–១៤៨៥ | ភ្នំពេញ | បុត្រស្ដេច ១ |
| ៤ | ស្រីសុរិយោទ័យ | ១៤៨៥–១៤៩៥ | ទួលបាសាន | បុត្រស្ដេច ២ |

www.budinst.gov.kh www.elibraryofcambodia.org

| លេខរៀងកាល | នាមសំរាប់រាជ្យ<br>នាមផ្ទាល់ | កាលកំណត់រជ្ជកាល<br>(គ.ស.) | រាជធានី | រាជវង្ស |
|---|---|---|---|---|
| ៥ | ស្រីធម្មរាជាទី ១ | ១៤៨៦–១៥០៤ | ភ្នំពេញ | បុត្រស្ដេច ១ |
| ៦ | ស្រីសុគន្ធបទ<br>ចៅពញាដរីខាត់រាជា | ១៥០៤–១៥១២ | ទួលបាសាន | បុត្រស្ដេច ៥ |
| ៧ | ស្រីជេដ្ឋាធិរាជ<br>ចកន | ១៥១២–១៥២៥ | ទួលបាសាន<br>ចន្ទក់ជូនតី<br>ស្រីឡប់ពិជ័យ | ជ្រែករាជ្យ |
| ៨ | បរមរាជាទី ៣<br>ចៅពញាចន្ទរាជា | ១៥១៦–១៥៦៦ | ពោធិសាត់<br>លង្វែក | បុត្រស្ដេច ៥ |
| ៩ | បរមរាជាទី ៤<br>បរមេន្ទរាជា | ១៥៦៦–១៥៧៦ | លង្វែក | បុត្រស្ដេច៨ |
| ១០ | បរមរាជាទី៥<br>សត្ថាទី ១ | ១៥៧៦–១៥៩៥ | លង្វែក | បុត្រស្ដេច ៩ |
| ១១ | ជ័យជេដ្ឋាទី ១ | ១៥៨៦–១៥៩៤ | លង្វែក | បុត្រស្ដេច១០ |
| ១២ | ព្រះរាមជើងព្រៃ | ១៥៩៤–១៥៩៦ | ទួលបាសាន | ជ្រែករាជ្យ |
| ១៣ | បរមរាជាទី ៦<br>ចៅពញាតន | ១៥៨៦–១៥៩៩ | ទួលបាសាន | បុត្រស្ដេច ១០ |
| ១៤ | បរមរាជាទី ៧<br>ចៅពញាអន | ១៥៩៩–១៦០០ | ទួលបាសាន | បុត្រស្ដេច ៩ |
| ១៥ | កែវហ៊្វាទី១<br>ចៅពញាញោម | ១៦០០–១៦០៣ | ទួលបាសាន<br>ភ្នំពេញ | បុត្រស្ដេច ១០<br>(ជ្រែករាជ្យ ?) |

www.budinst.gov.kh www.elibraryofcambodia.org

# ចំពូកទី ១១

# អរិយធម៌ខ្មែរនៅសម័យក្រោយអង្គរ

( **សម័យភ្នំពេញ–ចតុមុខ សម័យលង្វែក សម័យទួលបាសាន–ស្រីសន្ធរ** )

តាមទស្សនៈថ្មី គេបានចាត់ទុកថា **ប្រវត្តិសាស្ត្រ** ជាធម៌សំយោគរវាង **វប្បធម៌** និង **សង្គមធម៌** ហើយពុំមែនជាកំរងព្រឹត្តិការណ៍នយោបាយដែលបានកើតឡើងជាបន្តបន្ទាប់គ្នាហូរហែតែប៉ុណ្ណោះទេ ។ យើងយល់ថាទស្សនៈនេះមានលក្ខណៈសមរម្យណាស់ ហើយយើងចង់យកមកអនុវត្តក្នុងកិច្ចការរបស់យើងនេះដែរ ដើម្បីបង្ហាញអោយអ្នកអានឃើញរូបភាពនៃសង្គមខ្មែរយើងក្នុងសម័យកាលនិមួយ ៗ ។ ប៉ុន្តែ ក្នុងការធ្វើអោយសំរេចបំណងរបស់យើងខាងលើនេះ យើងត្រូវជួបប្រទះនឹងឧបសគ្គជាច្រើន ។ យ៉ាងណាមិញ ឯកសារដែលយើងប្រើប្រាស់សំរាប់ចងក្រងប្រវត្តិសាស្ត្រខ្មែរសម័យក្រោយអង្គរនេះ ច្រើនតែជា **រាជពង្សាវតារ** ។ ដូចមិត្តអ្នកអានបានជ្រាបស្រាប់ហើយថា **រាជពង្សាវតារ** ជាឯកសារអធិប្បាយអំពីដំណើរប្រែប្រួលរបស់វង្សស្ដេចផែនដី ម៉្លោះហើយគតិមានដែលយើងអាចស្រង់ចេញពីឯកសារប្រភេទនេះច្រើនតែសង្កត់ទៅលើរឿងរ៉ាវដែលទាក់ទងនឹងព្រះមហាក្សត្រ រាជវង្សានុវង្ស នាម៉ឺន ចំបាំង ចំណែកឯគតិមានដែលទាក់ទងនឹងជីវភាពប្រជារាស្ត្រការរស់នៅ និងផ្នែកផ្សេងទៀតនៃ **វប្បធម៌** និង **សង្គមធម៌** មានតិចតួចស្ដួចស្ដើងណាស់ ។ តាមការសង្កេត ស្ទើរ..ប្រវត្តិសាស្ត្រជាភាសាជាតិក្ដី ជាភាសាបរទេសក្ដី ដែលបានចងក្រងឡើងមករហូតដល់ពេលនេះ ក៏ពុំអាចទៅដល់គោលដៅខាងលើនេះ



www.budinst.gov.kh www.elibraryofcambodia.org

តែទោះបីមានកង្វះឯកសារយ៉ាងណាក៏ដោយ ក៏យើងនឹងខិតខំសាកល្បងដោយប្រើឯកសារដែលមានស្រាប់មកហើយ ផ្សំជាមួយនឹងឯកសារបរទេសខ្លះៗដើម្បីធ្វើអោយសង្គមខ្មែរក្នុងអតីត–កាលលេចរូបរាងឡើងនៅចំពោះមុខអ្នកអានតាមលទ្ធភាពដែលយើងអាចធ្វើបាន ។

## –នយោបាយ.–

### –របបនយោបាយ.–

#### .១– ព្រះរាជា : ជីវភាពនិងអំណាច.–

ទោះបីលទ្ធិទេវរាជត្រូវខ្មែរបោះបង់ចោលជាស្ថាពរតាំងពីបដិវត្តន៍នាយត្រសក់ផ្អែមមកម្ល៉េះក៏ដោយ ក៏ព្រះមហាក្សត្រនៅមានលក្ខណៈពិសិដ្ឋពុំមានជនណាល្មើសបានឡើយះហើយដែលគេនិយមហៅថា **ព្រះសម្មតិទេព** គឺថាជាជនខ្ពង់ខ្ពស់ផុតគេឬក៏ជា **ទេវតា** ដោយសន្មតក្នុងចំណោមមនុស្សជាអាណាប្រជានុរាស្ត្ររបស់ព្រះអង្គ ។

លក្ខណៈពិសិដ្ឋរបស់ព្រះមហាក្សត្រខាងលើនេះ គឺបានមកពីពិធី**រាជាភិសេក**អោយឡើង **សោយរាជសម្បត្តិ** (manger la royauté) ។ ពាក្យ **សោយ** នេះខ្មែរពីបុរាណលោកបានប្រើជាហូរហែរៀងមក មានភស្តុតាងក្នុងសិលាចារឹកជាដើម តែលោកសរសេរថា **ស្វោយ** ទៅវិញ (ស្វោយព្រះធម្មិរាជ្យ-សិលាចារឹកប្រាសាទរលុះគ.ស.១០៤៩)។ គួរគប្បីជ្រាបថាក្សត្រអង្គណាដែលមិនទាន់បានអភិសេកហើយគ្រាន់តែបានទទួលរាជសម្បត្តិគ្រប់គ្រងអាណាប្រជានុរាស្ត្រជាបណ្ដោះអាសន្នសិននោះ តាមក្បួនលោកអោយហៅថា **គ្រងរាជសម្បត្តិ** ដូចជាករណីរបស់ **ព្រះបរមរាជាទី ២ ចៅពញាយ៉ាត** កាលដែលវាយរំដោះបានរាជធានីអង្គរពីកណ្ដាប់ដៃនៃទ័ពសៀម និងព្រះ**ចន្ទរាជា** កាលដែលមិនទាន់ច្បាំងឈ្នះ **ស្ដេចកន** ជាស្ថាពរនៅឡើយ ។ ម្យ៉ាងទៀត ប្រសិនបើអភិសេកក្នុងពេល



www.budinst.gov.kh www.elibraryofcambodia.org

ដែលគាំទបង្ក្រាបខ្មាំងសត្រូវអោយរាបទាបលោកអោយហៅថា ព្រះខ្លាតិសេក ទៅវិញ

ត្រង់នេះ គួរគប្បីជ្រាបថាក្សត្រដែលអាចអភិសេកឡើងសោយរាជ្យពេញលក្ខណៈ ព្រះមហាក្សត្របានលុះណាតែមាន **គ្រឿងសំខាន់រាជ្យ** គឺ **ព្រះខាន់រាជ្យ** ១ **ព្រះលំពែងជ័យ** ១ និង **គ្រឿងព្រះបញ្ចក្សេត្រ** ។ ប៉ុន្តែ បើតាមឯកសារខ្មែរខ្លះ (21) គេបញ្ចូល **ព្រះខាន់រាជ្យ** ឬ **ព្រះខាន់ជ័យ** នេះទៅក្នុងចំណោម **គ្រឿងបញ្ចក្សេត្រ** វិញដែលគេ ហៅថា **បញ្ចកកុធភ័ណ្ឌ** ឬ **រាជកកុធភ័ណ្ឌ** គឺ:

១ — ព្រះមកុដ

២ — ព្រះវាលវីជនី (ផ្លិតធ្វើដោយរោមសត្វពណ៌ស)

៣ — ព្រះខាន់

៤ — ស្វេតច្ឆត្រ

៥ — ព្រះសុវណ្ណបាទុកា (ស្បែកជើងមាស)

ប្រភពដដែលបាននិយាយទៀតថា: " កាលទីង់ស្តេចចេញទៅធ្វើរាជសង្គ្រាមក៏ត្រូវយក **ព្រះខាន់** ជាប់នឹងព្រះអង្គទៅជានិច្ចជារាប តែមិនមែនយកទៅប្រើកាប់សម្លាប់ផ្តេសផ្តាសដូចអាវុធឯទៀតទេ លុះតែកាលណាសត្រូវដែលអង់អាចចូលមកដល់ព្រះអង្គ ដែលត្រូវប្រើអាវុធខ្លីប្រហារនោះទោះនឹងយក **ព្រះខាន់** ប្រហារអោយវិនាសទៅបាន រួមសេចក្តីទៅជាត្រូវតែសម្លាប់ដោយកិត្តិយស " ។

ទោះបីចាប់ពីរជ្ជកាលព្រះបាទត្រសក់ផ្អែមតមក ខ្មែរយើងកាន់ខ្ជាប់តែព្រះពុទ្ធសាសនាហីនយានក៏ដោយ តែ **ព្រះខាន់រាជ្យ** និង **គ្រឿងបញ្ចក្សេត្រ** ត្រូវបានពួក **បាគូ** ជាអ្នកថែរក្សាយ៉ាងគឹងរ៉ឹង ហើយនឹងមានកិច្ចធ្វើពិធីបូជាជាទៀងរាល់ខែជានិច្ច ។ ពួកបាគូនេះជាកូនចៅមានតំណវង្សពីពួកព្រាហ្មណ៍បុរោហិត គឺពួកព្រាហ្មណ៍ដែលមាននាទីប្រារព្ធធ្វើរាជពិធីផ្សេងៗ ក្នុងព្រះរាជវាំងនាសម័យអង្គរ ដែលព្រះរាជាខ្មែរភាគច្រើននិយមរាប់អានសាសនាព្រាហ្មណ៍ ជាងព្រះពុទ្ធសាសនា ។



www.budinst.gov.kh www.elibraryofcambodia.org

តាមរាជពង្សាវតារខ្មែរ ថាកាលដែល **ស្តេចគន** មានជ័យជំនះហើយ **សម្តេច
ឥសីឥន្ទ** បានយក **ព្រះខាន់រាជ្យ ព្រះលំពែងជ័យ** និង **គ្រឿងព្រះបញ្ចក្សេត្រ** ទៅ
លាក់ទុកក្នុងរន្ធនៃប្រហោងដើមចំបក់មួយនៅក្នុងព្រៃ ។ លុះស្តេចគនទទួលអភិសេកឡើង
សោយរាជ្យ ព្រះអង្គទ្រង់ចាត់អោយគេដើររក **គ្រឿងសំរាប់រាជ្យ** ទាំងនោះនៅគ្រប់ទិស
ទីតែរកពុំឃើញសោះ ។ ចំណែកឯព្រះ **ចន្ទរាជា** កាលដែលនាម៉ឺនសព្វមុខមន្ត្រីសូមយាង
ព្រះអង្គទទួលប្រាប្តាភិសេកឡើងសោយរាជសម្បត្តិនោះ ព្រះអង្គទ្រង់ប្រកែកព្រោះរក **គ្រឿង
សំរាប់រាជ្យ**មិនទាន់ឃើញ ។ បើតាមរាជពង្សាវតារខ្មែរថា គ្រឿងទាំងនោះគេអាចរកឃើញ
ឡើងវិញដោយសារតែក្រឡាពាសម្នាក់ដេកយល់សប្តិឃើញទេវតាប្រាប់អោយទៅយក ។

រួមសេចក្តីមក យើងឃើញថា **គ្រឿងសំរាប់រាជ្យ** ដូចបានពោលខាងលើនេះ
មានសារសំខាន់ណាស់ ។ បុគ្គលដែលឡើងសោយរាជ្យតែពុំមានគ្រឿងនេះទេ គេចាត់
ទុកថាពុំមានលក្ខណៈជាស្តេចទ្រង់រាជ្យពេញលេញទេ ។ ដោយហេតុនេះ ក្នុងគ្រា
អាសន្នបើទោះបីមានគ្រោះថ្នាក់យ៉ាងណាក៏ដោយ ក៏ពួកព្រាហ្មណ៍បាគូសេវកាមាត្យត្រូវទំ
រំដោះគ្រឿងសំរាប់រាជ្យនេះអោយបាន ដូចយ៉ាងកាលពីគ.ស. ១៣៥២ នៅពេលដែល
សៀមវាយបែករាជធានីអង្គរក្នុងរជ្ជកាលព្រះបាទ **លំពង់រាជា** នោះ ពួករាជគ្រូបុរោហិត
បាននាំយក **គ្រឿងសំរាប់រាជ្យ** វាយទំលាយទ័ពសៀមរត់រួចចេញទៅ ។

ដូច្នេះ យើងឃើញថាអំណាចរបស់ព្រះរាជាស្ថិតនៅលើព្រះរាជពិធី **រាជាភិសេក**
នេះ១ និងលើ **គ្រឿងសំរាប់រាជ្យ**នេះ១ ។ អំណាចទាំងឡាយមានប្រភពចេញមកពី
ព្រះរាជា ។ ព្រះអង្គជាអ្នកតាក់តែងច្បាប់ ប៉ុន្តែជាច្បាប់សាធារណៈប៉ុណ្ណោះ (22) ។
ព្រះអង្គក៏ជាអគ្គមេបញ្ជាការលើកងទ័ពជាតិ ហើយតែងតែលើកទ័ពផ្ទាល់ព្រះអង្គទៅប្រយុទ្ធ
ប្រឆាំងនឹងមារសត្រូវទាំងខាងក្រៅប្រទេសក៏ដូចជាខាងក្នុងប្រទេស ៖ ដោយហេតុនេះបាន
ជាយើងឃើញ **ព្រះស្រីរាជា** លើកទ័ពផ្ទាល់ព្រះអង្គទៅរំដោះយកអាណាខេត្តខាងលិច ព្រះ
**ចន្ទរាជា** ព្រះ **បរមរាជាទី៤** និងព្រះ **សត្ថាទី១** សុទ្ធតែបានលើកទ័ពវាយយកទឹកដីខ្មែរ
ដែលត្រូវបាត់បង់ ហើយសុទ្ធតែបានទៅដល់រាជធានីស្រី **អយុធ្យា** ចំណែកឯព្រះ **បរមរាជា**

www.budinst.gov.kh www.elibraryofcambodia.org

**ឃ.៤** ទ្រង់បានលើកទ័ពចេញទៅតទល់និងស្តេចណាវដែលមកសងសឹកក្រោយពីប្រជល់ដំរីបាញ់ខ្មែរ

ដោយសារព្រះរាជពិធីរាជាភិសេក ព្រះរាជាក៏បានក្លាយទៅជាមេសាសនាផងដែរ : ព្រះអង្គមានសិទ្ធិជ្រើសរើសមន្ត្រីសង្ឃ និងមានសិទ្ធិដកសក្តិពីមន្ត្រីប្រភេទនេះទៀត ៗ ដោយសារព្រះរាជពិធីដដែលនេះ ព្រះរាជាក៏មានឋានៈ ជា**ម្ចាស់ជីវិតលើត្បូង** មានសិទ្ធិអោយស្លាប់អោយរស់លើសព្វសត្វនៅលើផែនដី បានសេចក្តីថាព្រះអង្គជាទេវក្រុមម្នាក់អាចវិនិច្ឆ័យទោសកំហុសផាយផាហេតុ ប៉ុន្តែក្នុងករណីចុងក្រោយនេះ ក៏ដូចជាក្នុងករណីឯទៀត ៗ ដែរ ព្រះអង្គត្រូវប្រកបដោយ**ទសពិធរាជធម៌** មាន **ទាន សីល** នេះជាដើម ៗ

ដូច្នេះ នោះបើព្រះរាជាជាប្រភពនៃអំណាចគ្រប់បែបយ៉ាង កាន់កាប់អំណាចគ្រប់ប្រភេទក៏ដោយ ក៏ពុំបានសេចក្តីថាព្រះអង្គជាអ្នកកាន់អំណាចផ្តាច់ការនោះទេ ៗ ផ្ទុយទៅវិញ ព្រះអង្គត្រូវប្រកបដោយសីលធម៌អោយបរិបូណ៌ និង គោរពច្បាប់ថែមទៀតផង ៗ ការដែលមានព្រះរាជាខ្លះដូចជា **ចៅពញាអន** និង **ចៅពញាញោម** ពុំគោរពក្រិត្យវិន័យសំរាប់ស្តេចទ្រង់រាជ្យហើយបែរជាប្រព្រឹត្ត អំពើអាយ៉ុខំលោភលើរូបប្រពន្ធកូនអ្នកដទៃបណ្តាលអោយមានវឹកវរក្នុងផ្ទៃប្រទេសនោះ គឺជាអំពើពុំសមរម្យចំពោះអ្នកដឹកនាំជាតិដែលត្រូវមានករណីយកិច្ចមើលសុខទុក្ខលើអាណាប្រជានុរាស្ត្រទេ ៗ

ក្នុងសម័យកាលដែលយើងបានលើកមកសិក្សាក្នុងទីនេះ យើងឃើញថាព្រះរាជាដែលសោយរាជ្យបន្តបន្ទាប់គ្នា ទ្រង់បានគង់នៅក្នុងរាជធានីបីសំខាន់ គឺរាជធានី **ភ្នំពេញចតុមុខ** រាជធានី **លង្វែក** និង រាជធានី **ទួលបាសានស្រីសន្ធរ** ៗ តាមពត៌មានដែលឯកសារផ្សេង ៗ បានផ្តល់និងតាមដែលយើងអាចពិនិត្យឃើញពេលសព្វថ្ងៃនេះ ឃើញថាទីតាំងនៃរាជធានីទាំងនោះសុទ្ធតែជាចំណុចយុទ្ធសាស្ត្រ ស្ថិតនៅជិតទន្លេ បឹង និង ព្រៃផានបសត្តសំរាប់ការពារខ្លួនបានស្រួល ៗ ម្យ៉ាងទៀត រាជធានីនិមួយ ៗ សុទ្ធតែមានកំពែង និង ភ្លឺ ឬ អូរ ព័ទ្ធជុំវិញ ហើយមានបន្ទាយមានលើននៅច្រើនកន្លែងសំរាប់ការពារទៀត ៗ រាជធានីលង្វែកជាបន្ទាយមួយមាំមួនជាងបន្ទាយឯទៀត នេះគឺដោយសារតែមានព្រៃឫស្សីយ៉ាងក្រាស់ដែលព័ទ្ធពីក្រៅទឹកទៀត ប៉ុន្តែនៅតែធ្លាក់ទៅក្នុងកណ្តាប់ដៃសៀម

www.budinst.gov.kh www.elibraryofcambodia.org

ដោយខ្មែរយើងចាញ់កលល្បិចគេ ។

គួរគប្បីបញ្ជាក់ថា ក្រៅពីអគ្គមហេសីព្រះរាជានៅមានស្រីស្នំស្រីក្ការជាច្រើនទៀត ដែលគេអាចចែកងារជាច្រើនថ្នាក់ គឺពីទាបទៅខ្ពស់ :

— **អ្នកនាង** (ឧ.អ្នកនាងពៅ មាតារបស់ព្រះជ័យជេដ្ឋាទី ១ និងចៅពញាគន់)

— **អ្នកម្នាង** (ឧ.អ្នកម្នាងទេវី មាតាព្រះនារាយណ៍រាជា )

— **ព្រះម៉ែនាង** (ឧ.ព្រះម៉ែនាងវង់ មាតាចៅពញាអន )

— **ព្រះម្នាង** ( ឧ.ព្រះម្នាងកេសរមាលា.មាតាព្រះស្រីសុរិយោពណ៌ )

ពេលសោយទីវង្គតទៅ គេតែងលើកព្រះសពតំកល់ក្នុងកោដ្ឋ ធ្វើបុណ្យថ្វាយព្រះភ្លើង រួចយកបរមអដ្ឋិធាតុទៅបញ្ចុះក្នុងចេតិយដែលច្រើនតែសាងនៅលើភ្នំ ដូចជាភ្នំជូនពេញ ( ចេតិយព្រះបរមរាជាទី ២ ចៅពញាយ៉ាត ) ភ្នំព្រះរាជទ្រព្យ ( ចេតិយព្រះចន្ទរាជា) ។ល។ ។ ក្នុងករណីគូបដិបក្សជាប់ញាតិវង្សហើយត្រូវធ្វើគត់ ក៏ព្រះរាជាតែងធ្វើបុណ្យថ្វាយព្រះភ្លើងដល់ព្រះសពអោយសមឋានៈជាក្សត្រដែរ ដូចជាព្រះ **ធម្មរាជាទី ១** ទ្រង់បានសុំសពព្រះរៀមគឺព្រះ **ស្រីរាជា** និងក្មួយគឺ **ស្រីសុរិយោទ័យ** ពីព្រះចៅសៀម និងព្រះ **ចន្ទរាជា** បានបញ្ជាអោយគេយកសព **ពញាអុង** ពីសមរភូមិកាលដែលលើកទ័ពចូលមកវាយខ្មែរ ដើម្បីយកទៅធ្វើពិធីថ្វាយព្រះភ្លើងតាមប្រពៃណីក្សត្រ ។

បណ្ណាល័យ LIBRARY BUDDHIST INSTITUTE

១-២- **ពួកបរិវារ** .–

គេឃើញមានជាអាទិរាជវង្សានុវង្ស គឺៈ

— **ឧភយោរាជ** : តាមន័យដើម ពាក្យនេះមានន័យថា ក្សត្រជាតិរាជ្យអោយអង្គណាមួយសោយតំណាងព្រះអង្គ ទទួលរាជសក្តិជាក្សត្រកណ្តាលជួយដាស់តឿនក្រើនរំលឹកក្សត្រទ្រង់រាជ្យនិងក្សត្រឧបរាជទាំងពីរអង្គ អោយស្ថិតនៅក្នុងទសពិធរាជធម៌ ប៉ុន្តែក្នុងភាពពិតជាក់ស្តែងវិញ **ឧភយោរាជ** ជាក្សត្រដែលមានព្រះឋានៈបន្ទាប់ពីក្សត្រទ្រង់រាជ្យ ( ឧ.ព្រះ **ស្រីសុរិយោពណ៌** ) ។

www.budinst.gov.kh www.elibraryofcambodia.org

—**ឧបរាជ** ឬ **មហាឧបរាជ** : ឋានៈជា **ឧបរាជ** នេះមានមកជាយូរណាស់មកហើយ ។ ត្រូវគេជ្រើសរើស **ឧបរាជ** ក្នុងចំណោមបុត្រច្បងឬអនុជក្សត្រទ្រង់រាជ្យដែលមានគុណវុឌ្ឍិខ្ពង់ខ្ពស់ ប៉ុន្តែក្នុងភាពពិតជាក់ស្តែងពុំមែនសុទ្ធតែមានដំណើរប្រព្រឹត្តទៅបែបនេះទេ ព្រោះកាលដែលព្រះ **សត្ថាទី ១** ដាក់រាជ្យថ្វាយទៅព្រះរាជបុត្រច្បងនាមព្រះ **ជ័យជេដ្ឋា** ដែលមានព្រះជន្ម ១១ វស្សាអោយឡើងសោយរាជ្យ និងលើកព្រះរាជបុត្របន្ទាប់នាម **ចៅពញាតន់** ដែលមានព្រះជន្មទើបបាន ៦ វស្សា អោយឡើងឋានៈជា **ឧបរាជ** នោះ អំពើនេះធ្វើអោយមានការអាក់អន់ស្រពន់ចិត្តច្រើន ក្នុងចំណោមនាម៉ឺនសព្វមុខមន្ត្រី និងអាណាប្រជានុរាស្ត្រ ។

—ព្រះ **ឧបរាជមាតា** ឬព្រះ **ឧបរាជអយ្យិកា** ក៏ទំនងជាមានឥទ្ធិពលខ្លាំងក្លាណាស់ដែរ ព្រោះកាលដែលព្រះ **កែវហ្វាទី១ ចៅពញាញោម** មិនប្រកបដោយទសពិធរាជធម៌ សម្តេចព្រះ **ទេវីក្សត្រី** ត្រូវជាសម្តេចព្រះអយ្យិកា បានជំនុំនឹងមន្ត្រីរួចផ្ញើសារទៅក្រុង **ឧស្សឹត្យ** ក្រាបទូលព្រះចៅសៀមបើកសម្តេចព្រះ **ស្រីសុរិយោពណ៌** អោយចេញមកក្រុងកម្ពុជាធិបតីវិញ ។

—**ចៅហ្វាឡហះ** : បើប្រៀបធៀបនឹងសព្វថ្ងៃ **ចៅហ្វាឡហះ** មានបណ្តាសក្តិស្មើនឹង **នាយករដ្ឋមន្ត្រី** ឬ **រដ្ឋមន្ត្រីទី ១** ។ បន្ទាប់ពី **ចៅហ្វាឡហះ** មកគេឃើញមានមន្ត្រីជាន់ខ្ពស់ ៤ រូបទៀត ដែលមានមុខងារជាអ្នកសំរេចរាជការនិងគ្រប់គ្រងដែនដីរួមនិងព្រះមហាក្សត្រ ។ មន្ត្រីជាន់ខ្ពស់ទាំង ៤ នេះគេចាត់ដូចសសរជើងរៀងទាំង ៤ នៃប្រាសាទ ទើបមាននាមរួមថា **ចតុស្តម្ភ** :

— **ឧកញ៉ាក្រឡាហោម**

— **ឧកញ៉ាវាំង**

— **ឧកញ៉ាយមរាជ**

— **ឧកញ៉ាចក្រី**

— **មហាតលិក**: នេះជាមន្ត្រីខុំរាជការដែលមានមុខងារគោលបំរើព្រះរាជា ។ ស្តេចគន កាលពីដើមជា **មហាតលិក** មួយរូបដែលត្រូវបានព្រះបាទ **ស្រីសុគន្ធបទ** តម្កើងអោយ



www.budinst.gov.kh www.elibraryofcambodia.org

ឡើងបានៈជា **យុវហ្លួងព្រះស្តេច** ។

– **ហោរា :** ជាមន្ត្រី ១ ប្រភេទដែលមានមុខងារសំខាន់ណាស់ដែរព្រោះក្នុងសម័យនោះ តាំងពីក្សត្រទ្រង់រាជ្យដល់អាណាប្រជារាស្ត្រសុទ្ធតែមានជំនឿលើការទស្សន៍ទាយ ។ មុននឹងលើករាជធានីពីទួលបាសានមកភ្នំពេញ ព្រះ**បរមរាជាទី ២ ចៅពញាយ៉ាត** ទ្រង់បានបញ្ជា **ឧកញ៉ាហោរាធិបតីខៀវ** និងមន្ត្រីឯទៀតអោយមកពិនិត្យមើលកន្លែងតាមក្បួនហោរាសិន ។ ឯព្រះបាទ**ស្រីសុគន្ធបទ** ពេលទ្រង់យល់សុបិនឃើញនាគដេញពាំស្វេតច្ឆត្រក៏បានអោយហោរាទស្សន៍ទាយទៅឃើញថាមានគេចង់ជ្រែករាជ្យគឺស្តេចកននេះឯង ។

– **ចៅខិត ចៅចម : ចៅខិត** គឺពួកស្ត្រីជាព្រះរាជបរិវារ មានមុខងារក្រាបបង្គំគាល់បំរើជិតស្និទ្ធក្នុងព្រះរាជត្រកូល ឯ **ចៅចម** គឺពួកស្ត្រីជារាស្ត្រសាមញ្ញដែលគេថ្វាយអោយធ្វើជាមហេសីស្តេច បានដល់ពួក**ស្រីស្អំស្រីខ្លារ** នេះឯង ។

## -៣- ការបន្តរាជសម្បត្តិ.–

ជាទូទៅ គេសង្កេតឃើញរាជសម្បត្តិត្រូវបានបន្តពីបិតាជាក្សត្រទ្រង់រាជ្យទៅបុត្របានសេចក្តីថានៅពេលដែលព្រះបិតាសោយទិវង្គតទៅឬក៏ដាក់រាជ្យ គឺបុត្រច្បងត្រូវមានសិទ្ធិឡើងសោយរាជ្យស្នង ហើយប្រសិនបើបុត្រច្បងត្រូវសុគតមុនសោយរាជ្យ គឺបុត្របន្ទាប់មានសិទ្ធិសោយរាជ្យស្នងព្រះបិតា ។ ដោយហេតុនេះហើយទើបយើងឃើញព្រះ**នារាយណ៍រាជា** ឡើងសោយរាជ្យស្នងព្រះ**បរមរាជាទី ២ ចៅពញាយ៉ាត** ព្រះសត្ថាទី ១ សោយរាជ្យស្នងព្រះ**បរមរាជាទី ៤** ឯព្រះ**បរមរាជាទី ៤** បានសោយរាជ្យស្នងពីព្រះ **ចន្ទរាជា** ព្រោះបុត្រច្បងនាម **រាមាធិបតី** បានសុគតមុនសោយរាជ្យ (តាមរាជពង្សាវតារខ្លះថាស្រូវព្រះធរណីស្រួប) ។

ក្នុងករណីដែលក្សត្រទ្រង់រាជ្យពុំមានបុត្រសោយរាជ្យស្នងទេ សិទ្ធិនេះត្រូវបានទៅព្រះអនុជជាបន្តបន្ទាប់គ្នា ។ ព្រះ **ចន្ទរាជា** បានឡើងសោយរាជ្យជាតំណាងវង្សពីព្រះបាទ**ស្រីសុគន្ធបទ** ព្រោះរាជបុត្រក្សត្រអង្គនេះ គឺ**ពញាយសរាជា** បានសុគតមុនសោយរាជ្យ។ ប្រសិនបើគេមិនគោរពទំលាប់នេះទេនោះវិបត្តិច្បាស់ជាកើតឡើងពុំខានមិនបាន : នេះគឺជា

www.budinst.gov.kh www.elibraryofcambodia.org

ករណីរបស់ **ស្រីសុរិយោតិយ** ដែលត្រូវបានឡើងសោយរាជ្យស្នងព្រះបិតាគឺព្រះ **នា-រាយណ៍រាជា** តែពុំថ្វីឡោះបែរជាបានទៅព្រះ **ស្រីរាជា** ជាអនុជសោយរាជ្យវិញ ជាហេតុនាំអោយមានចម្បាំងគ្នាឯងក្នុងស្រុកអស់រយៈពេល ១០ ឆ្នាំ (១៤៧៥-១៤៨៥) ។

ក្នុងសម័យកាលដែលយើងលើកយកមកសិក្សានេះ គេសង្កេតឃើញថាមានអន្តរា-គមន៍របស់ពួកមន្ត្រីក្នុងការជ្រើសរើសក្សត្រអោយឡើងសោយរាជ្យ ហើយអន្តរាគមន៍នេះមានប្រសិទ្ធិភាពខ្លាំងណាស់ដែរ ។ យ៉ាងណាមិញព្រះ **ស្រីរាជា** ព្រះ **បរមរាជាទី ៧ ចៅពញាអន** និង ព្រះ **ស្រីសុរិយោពណ៌** សុទ្ធតែបានឡើងសោយរាជ្យដោយសារតែមានអន្តរាគមន៍របស់នាម៉ឺនសព្វមុខមន្ត្រីនេះឯង ។

ក្នុងករណីដែលបុគ្គលណាមួយ ទោះជាមន្ត្រីជាន់ខ្ពស់ក្តី ទោះជាជាប់ព្រះញាតិនឹងក្សត្រទ្រង់រាជ្យក្តី តែបើពុំមានសិទ្ធិទទួលរាជសម្បត្តិទេ ហើយបែរជាប្រើកម្លាំងអាវុធដើម្បីបានឡើងសោយរាជ្យនោះ គេអោយឈ្មោះហៅថាស្តេចជ្រែករាជ្យ (**ស្តេចកន ព្រះរាមជើងព្រៃ**) ។

## - នយោបាយក្នុងប្រទេស.-

គេសង្កេតឃើញមានវិបត្តិក្នុងរាជវង្សជាញឹកញាប់ ជាហេតុបណ្តាលអោយមានចម្បាំងគ្នាឯងក្នុងស្រុក : ចម្បាំងរវាង **ស្រីរាជា - ស្រីសុរិយោតិយ - ធម្មរាជា** អស់រយៈពេល ១០ ឆ្នាំ (១៤៧៥-១៤៨៥) និងចម្បាំងរវាង **ស្រីសុគន្ធបទ - ស្តេចកន - ចន្ទរាជា** (១៥០៤-១៥១២ និង ១៥១២-១៥២៥) ។ មូលហេតុនៃចម្បាំងទាំងនេះ គឺបណ្តាលមកពីការគិតប្រយោជន៍ផ្ទាល់ខ្លួនច្រើនជាងប្រយោជន៍រួម ។ យ៉ាងណាមិញ ព្រះ **ស្រីសុរិ-យោតិយ** ច្បាំងនឹងព្រះ **ស្រីរាជា** មកតែពីគិតប្រយោជន៍ផ្ទាល់ពីព្រោះខ្លួនត្រូវបានសោយរាជ្យស្នងព្រះបិតា ព្រះបាទ **ស្រីសុគន្ធបទ** រកកលសម្លាប់ **ស្តេចកន** មកតែពីខ្លាចបន្ត្រើបនេះដណ្តើមរាជសម្បត្តិ ព្រះ **សត្ថាទី ១** បានដាក់រាជ្យថ្វាយទៅបុត្រដែលសុទ្ធតែមានវ័យនៅក្មេង ១ ព្រោះតែខ្លាចរាជសម្បត្តិបានទៅព្រះអនុជគឺ **ស្រីសុរិយោពណ៌** ដែលមានសមត្ថ-ភាពនិងមានប្រជាប្រិយភាពជាង ។

www.budinst.gov.kh www.elibraryofcambodia.org

លុះជម្លោះកើតឡើងហើយ អ្នកដឹកនាំជាតិមិននិយមការដោះស្រាយដោយសម្រុះសម្រួលគ្នាទេ បែរជាសុខចិត្តទៅពឹងពាក់អោយបរទេសជិតខាងចូលមកជ្រៀតជ្រែកផ្ទៃក្នុងរបស់ខ្មែរទៅវិញ ។ ដោយហេតុនេះហើយទើបព្រះ **ធម្មរាជា** ទ្រង់បានទៅអន្តរស្ដេចសៀមអោយលើកទ័ពចូលមក ធ្វើគលចាប់ព្រះ **ស្រីរាជា** និង **ស្រីសុរិយោពណ៌** យកទៅស្រុកសៀមអស់ទៅ ។

## ៣–នយោបាយក្រៅប្រទេស.–

នៅគ្រានោះ ខ្មែរមិនទាន់មានកង្វល់នៅព្រំដែនខាងកើតនៅឡើយទេ ព្រោះប្រទេស **ចាម្ប៉ា** កំពុងតែជាប់ដៃធ្វើចម្បាំងជាមួយ យួនពួក **ឡេ** ដែលបានលេបទឹកដីរបស់វាជា ណាចក្រនេះបន្តិចម្តង ៗ ។

ប៉ុន្តែនៅព្រំដែនខាងលិច ព្រះរាជាខ្មែរបានព្យាយាមវាយរំដោះយកទឹកដីដែលត្រូវបាត់បង់ទៅតាំងពី ស.វ. ទី ១៣ រៀងមក ។ គឺក្នុងគោលបំណងនេះហើយដែលព្រះ **ស្រីរាជា** ព្រះ **ចន្ទរាជា** ព្រះ **បរមរាជាទី ៤** ព្រះ **សត្ថាទី ១** បានលើកទ័ពទៅវាយលុករហូតដល់រាជធានី **ស្រីអយុធ្យា** ហើយរំដោះយកបានទឹកដីមកវិញជាច្រើនមែន ។ ហេតុដែលនាំអោយខ្មែរមានជោគជ័យបែបនេះ គឺបណ្ដាលមកពីភូមាបានលើកទ័ពចូលវាយសៀមជាញឹកញយ វាយយកបានរាជធានី **ស្រីអយុធ្យា**២លើក (គ.ស. ១៥៦៤ និង ១៥៦៩) និងដាក់ប្រទេសសៀមជាចំណុះអស់ ១៥ ឆ្នាំទៀតផង ហើយស្ដេចខ្មែរចេះឆ្លៀតយកឱកាសដែលសត្រូវកំពុងតែមន់ខ្សោយនោះលើកទ័ពចូលវាយបន្ថែមទៀត ហើយអាចរំដោះយកបានទឹកដីដែលត្រូវបាត់បង់មកវិញ ៗ ត្រង់ចំណុចនេះ ឯកសារអឺរ៉ុប (19) និយាយថាខ្មែរបានធ្វើសម្ពន្ធមិត្តជាមួយភូមាដើម្បីវាយសៀម ប៉ុន្តែឯកសារខ្មែរមិនបាននិយាយដល់រឿងនេះទេ ។ ប្រភពអឺរ៉ុបដដែលបានបន្ថែមទៀតថា ក្រោយមកខ្មែរបានជាកទៅចងសម្ពន្ធមេត្រីជាមួយសត្រូវខ្លួន ( សន្ធិសញ្ញាខ្មែរ – សៀម គ.ស. ១៥៧៤ ( ព្រះ **សត្ថាទី ១** បញ្ជាអោយ **ស្រីសុរិយោពណ៌** លើកទ័ពទៅជួយសៀមវាយឈ្នះភូមា ) ប៉ុន្តែមិនបានផលល្អ ព្រោះក្រោយពីបាន

www.budinst.gov.kh www.elibraryofcambodia.org

រំដោះខ្លួនពីចំណុះភូមាមក សៀមតែងបានលើកទ័ពចូលវាយខ្មែរជាញឹកញាប់ ជាព្រោះតែខ្មែរមិនរក្សាពាក្យសច្ចៈ ។ ការពិត សៀមធ្វើនេះគឺនៅក្នុងក្របខ័ណ្ឌពង្រីកទឹកដីរបស់គេតែប៉ុណ្ណោះ ។ ម្យ៉ាងទៀតហើយនៅចំពោះមុខគ្រោះថ្នាក់ដែលតែងតែគំរាមកំហែងមកលើប្រទេសជាតិនេះ ព្រះរាជាខ្មែរចាប់ពីព្រះ **សត្ថាទី ១** រៀងមក បានងាកទៅរកជំនួយពីពួកព័រទុយកាល់ ហើយក្រោយមកពីពួកអេស្ប៉ាញទៀត ។ ព្រះអង្គទ្រង់បានយកចិត្តអ្នកផ្សាយសាសនាអឺរ៉ុបយ៉ាងខ្លាំង ដើម្បីអោយពួកនេះជួយធ្វើអន្តរាគមន៍សុំជំនួយទ័ពមកប្រឆាំងនឹងសៀម ។ ព្រះអង្គទ្រង់បានសន្យាថានឹងបើកសិទ្ធិអោយពួកនេះផ្សាយសាសនាគ្រិស្តនៅគ្រប់ទិសទីក្នុងព្រះរាជាណាចក្ររបស់ព្រះអង្គ ជួយសង់ព្រះវិហារនិងផ្តល់ទេយ្យទាន មានអង្ករជាដើមដល់ពួកនេះ ។ ពួកអេស្ប៉ាញនៅម៉ានីល មានបំណងចង់មកតាំងអាណាព្យាបាលលើប្រទេសខ្មែរ ហើយបានបញ្ជូនទ័ពនិងអ្នកផ្សាយសាសនាមកប្រទេសខ្មែរជាច្រើនលើក តែពុំបានសំរេចដូចប្រាថ្នា ។ នៅទីបំផុត ព្រះ **ស្រីសុរិយោពណ៌** ដែលត្រូវទ័ពសៀមចាប់នាំយកទៅក្រុង **អយុធ្យា** បានត្រឡប់ចូលមកប្រទេសខ្មែរវិញដោយនាំយកឥទ្ធិពលរបស់សៀមមកផ្សាយទៀត ។ គួរគប្បីបញ្ជាក់ថា ពួកសៀមដែលកាន់ព្រះពុទ្ធសាសនាដូចខ្មែរដែរនោះ បានប្រឆាំងយ៉ាងខ្លាំងចំពោះការប៉ុនប៉ងផ្សាយសាសនារបស់ជនជាតិអឺរ៉ុប ជាពិសេសក្នុងរជ្ជកាលរបស់ព្រះ **នរេសូរ** ។

## ខ-- រដ្ឋបាល .-

### ១— ការបែងចែងអាណាចក្រ.—

នៅសម័យនោះ ប្រទេសខ្មែរលែងជាមហាអំណាចមួយខាងទឹកដីទៀតហើយ ៖ ទឹកដីជាន់ក្រៅគឺស្រុក **មច្ឆន្តឧនបទ** ដូចជាស្រុក **សុខោទ័យ** ស្រុក **ស្រីអយុធ្យា** ស្រុក **លពបុរី** ស្រុក **គោរ្ទ្របុរ ( តិម៉ាយ )** ត្រូវបាត់បង់អស់ទៅហើយ ឯប្រទេសសាមន្តរាជដូច **ចាម្ប៉ា អាណ្ណាម ច្វា មន** ក៏លែងមានទៀតដែរហើយ ។ ព្រំដែនខាងជើងរបស់

www.budinst.gov.kh www.elibraryofcambodia.org

ខ្មែរធ្លាក់មកនៅត្រឹម **ឥន្ទមូល** ឬនៅលើនេះបន្តិចនិងប្រទេសលាវ ។ ព្រំដែនខាងលិចទល់នឹង **បស្ចិមបុរី** និង **រយ៉ង** ខាងពាយ័ព្យទល់នឹងស្រុក **នាងរោងនគររាជ** ខាងកើតទល់នឹងប្រទេស **ចាម្ប៉ា** ខាងត្បូងទល់នឹងសមុទ្រចិននិងឈូងសមុទ្រសៀម ។

បើតាមរាជពង្សាវតារ រាជាណាចក្រខ្មែរសម័យនោះមានប្រមាណជា ៧០ **ខេត្ត** គឺ :

**លង្វែក អម្រិន្ទបុរ ក្រគរ ក្រង ពោធិសាត់ បាត់ដំបង ឫស្សីសាញ តាម-សីហា មង្គលបុរី រយ៉ង សុរិន្ទ សិង្ហារ កំពង់សៀម ស្ទឹងត្រែង ជើងព្រៃ គោកសេះ អន្លង់រាជ ព្រំទេព ព្រៃក្ដី ស្ទោង ជីក្រែង រលួស សៀមរាប កំពង់ស្វាយ មូព្រៃ ចាំក្សាន្ត ត្នោត ទឹកជោរ សៀមបូក សម្បុកសម្បូណ៌ ក្រចេះ ឆ្លូង ត្បូង បាសាន ធនិងថ្ង ព្រៃវែង ត្បូងឃ្មុំ បាភ្នំ រំដួល ស្វាយទាប រោងដំរី ព្រៃនគរ លង់ហោរ ជើងបាដែង សំរោងទង បាទី លើកដែក ត្រាំង បន្ទាយមាស ថ្កូវ ឯសាត់ បារៀ** (បាធ) **ពាម កោះ-ស្លាកែត កំពត កំពង់សោម ទឹកខ្មៅ ពាមមេសរ ព្រះត្រពាំង ក្រមួនស ដូនណៃ ។ល។**

គួរកត់សំគាល់ថាក្នុងចំណោមខេត្តទាំងប៉ុន្មាននេះ ខេត្តខ្លះនៅមានឋានៈជាខេត្តរហូតមកដល់សព្វថ្ងៃនេះដូចជា **ពោធិសាត់ បាត់ដំបង ស្ទឹងត្រែង សៀមរាប ក្រចេះ ព្រៃវែង** ។ល។ ឯខេត្តខ្លះទៀតធ្លាក់ឋានៈមកជាស្រុកវិញ ដូចជា **មង្គលបុរី ស្ទោង ជីក្រែង រលួស ទឹកជោរ** ។ល។ ឯខេត្តខ្លះទៀតត្រូវបាត់ឈ្មោះរលាយចូលនឹងខេត្តឯទៀតអស់ទៅ ។

**ខេត្ត**និមួយៗ ត្រូវបែងចែកជា **ស្រុក** ហើយស្រុកនិមួយៗ ត្រូវបែងចែកជា **ភូមិ** ជាច្រើនទៅទៀត ។ ប៉ុន្តែ ខេត្តជាច្រើនត្រូវបានប្រមូលផ្តុំជាតំបន់ធំៗ ដែលគេអោយឈ្មោះហៅថា ដី (22) ។

## ២- រដ្ឋបាលកណ្ដាល.-

ដោយហេតុព្រះរាជាជាប្រភពនៃអំណាចទាំងឡាយ ហើយពួកបរិវាររបស់ព្រះអង្គសុទ្ធ

www.budinst.gov.kh www.elibraryofcambodia.org

តែជារាជវង្សានុវង្ស និង មន្ត្រីជាន់ខ្ពស់ផងនោះ គេអាចយល់បានថាពីពួកបរិវារនេះហើយ ជាអ្នកញ៉ាំងម៉ាស៊ីនរដ្ឋបាលកណ្ដាលអោយប្រព្រឹត្តទៅ ។ ដូចយើងបានរៀបរាប់រួចមក ហើយក្នុងវគ្គនិយាយពីព្រះរាជបរិវារ ឃើញថាបន្ទាប់ពីស្ដេចទ្រង់រាជ្យមកមាន **ឧភយោរាជ ឧបរាជ** ឬ **មហាឧបរាជ** ព្រះ**វររាជមាតា វររាជអយ្យិកា ចៅហ្វាធឡ្ហះ** និងមន្ត្រីជាន់ខ្ពស់ ៤ រូបដែលគេនិយមហៅថា **ចតុស្ដម្ភ** គឺ :

– **ឧកញ៉ាយមរាជ** (រដ្ឋមន្ត្រីក្រសួងយុត្តិធម៌)

– **ឧកញ៉ាក្រឡាហោម** (រដ្ឋមន្ត្រីក្រសួងទ័ពជើងទឹក)

– **ឧកញ៉ាវាំង** (រដ្ឋមន្ត្រីក្រសួងព្រះបរមរាជវាំង)

– **ឧកញ៉ាចក្រី** (រដ្ឋមន្ត្រីខាងទ័ពជើងគោក)

ដូច្នេះ **ចៅហ្វាធឡ្ហះ** និង មន្ត្រីជាន់ខ្ពស់ទាំង ៤ រូបនេះប្រៀបបាននឹង**គណៈរដ្ឋមន្ត្រី** សព្វថ្ងៃ ហើយដែលពីដើមគេនិយមហៅថា **សេនាបតី** ។ មន្ត្រីជាន់ខ្ពស់ទាំង ៥ រូបនេះ គេហៅថា **មន្ត្រីសំរាប់ឯក** គឺជាមន្ត្រីដែលត្រូវឡើងទៅ**ព្រះមហាក្សត្រ** ៖ មន្ត្រីទាំងនេះ មានមុខងារញ៉ាំងរដ្ឋបាលកណ្ដាលអោយប្រព្រឹត្តទៅផង ហើយមានអំណាចត្រួតត្រាលើ ខេត្តខ្លះទៀតផង ។ ក្រៅពីនេះនៅមាន **មន្ត្រីសំរាប់ទោ** ត្រូវឡើងទៅព្រះ **ឧភយោរាជ មន្ត្រីសំរាប់ត្រី** ត្រូវឡើងទៅព្រះ**ឧបរាជ** ឬ **មហាឧបរាជ** និង **មន្ត្រីសំរាប់ចត្វា** ត្រូវ ឡើងទៅព្រះ **វររាជមាតា** ឬ ព្រះ**វររាជអយ្យិកា** ។ មន្ត្រីទាំង ៤ សំរាប់នេះ លើក លែងតែ **ចៅហ្វាធឡ្ហះ** ចេញដែលមានឋានន្តរសក្តិជា **សម្ដេចចៅពញា** សុទ្ធតែមាន ឋានន្តរសក្តិជា **ឧកញ៉ា** សក្តិ ១០ **ហ៊ូពាន់** (**ហ៊ូពាន់** : ពាក្យសៀមបានន័យថាក្បាលពាន់ គឺទ័ព ១០០០ នាក់ដែលនៅក្រោមបង្គាប់របស់មន្ត្រីណាម្នាក់) ។

ក្រៅពីមន្ត្រីជាន់ខ្ពស់ទាំងប៉ុន្មានដូចរៀបរាប់រួចមកហើយនេះ គេឃើញមានមន្ត្រីជាន់ កណ្ដាលនិងជាន់ទាបជាច្រើនទៀតដែលមានឋានន្តរសក្តិដូចតទៅ :

– **ព្រះ** ......... សក្តិ ៦ ហ៊ូពាន់

– **ហ្លួង** ......... សក្តិ ៥ ហ៊ូពាន់

www.budinst.gov.kh www.elibraryofcambodia.org

— ឃុនមុឺន ......សក្តិ ៤ ហ៊ូពាន់

— ឧត មុឺន ...... សក្តិ ៣ ហ៊ូពាន់

— ចះ មុឺន ...... សក្តិ ២ ហ៊ូពាន់

— មុឺន ....... សក្តិ ១ ហ៊ូពាន់

ចំណែកឯទីរាជការដែលមិនទាន់បានទទួលយសសក្តិនៅឡើយទេ នោះអោយហៅថា នាយ ។

៣ — រដ្ឋបាលភូមិភាគ.—

ក្នុងផ្នែកទី ១ ដែលទាក់ទងនឹងការបែងចែកអាណាចក្រ យើងបានឃើញថាទឹកដីខ្មែរ ត្រូវចែកជាប្រមាណ ៧០ ខេត្តហើយខេត្ត ទាំងនោះត្រូវប្រមូលផ្តុំជាតំបន់ដែលគេហៅថា ដី។ ក្នុងតំបន់និមួយ ៗ មាន ស្តេចត្រាញ់ មួយអង្គឈរត្រួតត្រា (ជូនកាលហៅថា ស្តេចត្រាញ់ ក៏បាន ពាក្យនេះទំនងជាក្លាយមកពីពាក្យបុរាណ ម្រតាញ ដែលមានប្រើក្នុងសិលាចារឹក ខ្មែរ ) ។ ស្តេចត្រាញ់ មួយអង្គ ។ មាននាទីគ្រប់គ្រងតំបន់របស់ខ្លួនផង ហើយមាននាទី គ្រប់គ្រងខេត្តរបស់ខ្លួនផ្ទាល់ផង ។ បើតាមឯកសាររាជពង្សាវតារខ្មែរ ក្នុងរជ្ជកាលព្រះបាទ ធម្មរាជាធិ ១ មានការតែងតាំងស្តេចត្រាញ់ ៥ អង្គគឺ :

— ពញាតេជោ ចៅហ្វាយស្រុកខេត្តកំពង់ស្វាយ ១

— ពញាសួគ៌លោក ចៅហ្វាយស្រុកខេត្តពោធិសាត់ ១

— ពញាស្រីធម្មាតេជោ ចៅហ្វាយស្រុកខេត្តបាភ្នំ ១

— ពញាពិស្ណុលោក ចៅហ្វាយស្រុកខេត្តទ្រាំង ១

— ពញាអរខ្លួន ចៅហ្វាយស្រុកខេត្តត្បូងឃ្មុំ ១

ដូចបានពោលរួចមកខាងលើនេះ យើងឃើញថាក្នុងខេត្តនិមួយ ៗ មានមន្ត្រីជាន់ ខ្ពស់ម្នាក់ឈរត្រួតត្រា ។ មន្ត្រីនេះគេនិយមហៅថា ចៅហ្វាយស្រុក : ឧ. មន្ត្រីឈរ ត្រួត ខេត្តទ្រាំង គេហៅថា ចៅហ្វាយស្រុកខេត្តទ្រាំង ។

www.budinst.gov.kh www.elibraryofcambodia.org

តាមប្រភពរាជពង្សាវតារខ្មែរដែល គេដឹងថា ចៅហ្វាយស្រុកសុទ្ធតែមានស
១០ ឬ ៩ ហ៊ូពាន់ពីបុរាណរៀងមក តាំងឡើងសុទ្ធតែជា សម្តេចចៅពញា ព្រោះ ចៅ
ហ្វាយស្រុក ទាំងនោះសុទ្ធតែជាព្រះញាតិនៃព្រះរាជា តែក្រោយមក ចៅហ្វាយស្រុ
ទាំងនោះច្រើនតែពុំសូវគោរពគោត្តខ្វាចសេនាបតី ទើបត្រូវទម្លាក់មកនៅត្រឹមតែទី ចៅ
ពញា ។ គួរគប្បីជ្រាបដែរថា ទី ចៅពញា នេះក៏ជាឋានន្តរសក្តិរបស់បុត្រស្តេចច្រ
រាជ្យដែរ ( ន.ចៅពញាជាំខាត់អាជា ចៅពញាចន្ទអាជា ចៅពញាតន់ ចៅពញ
អង ចៅពញាញោម ។ល។) ។ បើ ចៅហ្វាយស្រុកណាមានសក្តិ ៨ ឬ
ហ៊ូពាន់ ត្រូវតាំងជា ពញា ។

ខេត្ត និមួយ ។ ត្រូវបែងចែកជាច្រើន ស្រុក ដែលគ្រប់គ្រងដោយ មេស្រុក
ហើយស្រុកនិមួយ ។ ទំនងជាត្រូវចែកជា ឃុំ ជា ភូមិ ដែលមាន មេឃុំ និង មេភូ
ជាអ្នកគ្រប់គ្រង ។

## គ– អំពីកងទ័ព.–

### ១– ការរៀបចំកងទ័ព.–

ក្នុងសម័យនោះ កងទ័ពខ្មែរត្រូវបែងចែងជា **កងទ័ពជើងគោក** និង **កងទ័ពជើ
ទឹក** ។

### ១.១– កងទ័ពជើងគោក.–

**កងទ័ពជើងគោក** ស្ថិតនៅក្រោមអំណាចដឹកនាំរបស់ **ឧកញ៉ាចក្រី** ហើយត្រ
បែងចែកជា ៤ ពួក :

– ពួកទ័ព ដំរី ១
– ពួកទ័ព សេះ ១

www.budinst.gov.kh www.elibraryofcambodia.org

– ពួក ធំាង វេ ១

– ពួក ធំាង ថ្មើរជើង ១

ទ័ពទាំង ៤ ពួកនេះរួមគ្នាទៅហៅលោកអោយឈ្មោះ ហៅថា **ចតុរង្គ** ហើយត្រូវបានរាជការចិញ្ចឹមទុកអោយមាននៅប្រចាំការជានិច្ច (21) ។

**— ធំាងដំរី:** **ដំរី**ជាសត្វពាហនៈដ៏សំខាន់ ១ ។ ក្នុងសម័យបុរាណគេអាចប្រៀបសត្វ **ដំរី**ទៅនឹងរថក្រោះសព្វថ្ងៃបាន ក្នុងពេលធ្វើចម្បាំងគេប្រើសត្វ**ដំរី**ក្នុងការដឹកនាំនិងក្នុងការលុកចូលវាយទ័ពខាងសត្រូវ ។ ដោយហេតុនេះហើយ រាជការខ្មែរតាំងពីបុរាណរៀងមក ដរាបដល់បច្ចុប្បន្ននេះបានតាំងភ្នាក់ងារ ១ ក្រុមហៅថា **ក្រុមដំរី** មានមុខងារជាអ្នកថែរក្សា **ដំរី** ព្រះរាជទ្រព្យទាំងអស់ និងទាក់ដំរីព្រៃយកមកជង្រាំងបង្ហាត់អោយបានបទតាមដែលត្រូវការ ទុកសំរាប់ប្រើក្នុងរាជការ (21) ។

**— ធំាងសេះ** និង **ធំាងរថ:** ទ័ពទាំងពីរប្រភេទនេះឡើងសេនាបតីជើងគោកជាមួយគ្នា ។ **សេះ** ជាសត្វពាហនៈ ១ ដែលគេនិយមប្រើណាស់ ក្នុងការធ្វើសង្គ្រាមព្រោះវាមានល្បឿនចាត់ការបានទាប់ទាន់ពេលវេលា ។ **ធំាងរថ** ប្រើរថទឹមសេះក៏មាន ប្រើរទេះទឹមគោក៏មាន ។

**— ធំាងថ្មើរជើង:** គឺសំដៅយកពួកសេនាទាហានដែលមិនត្រូវជិះដំរី សេះឬរថ ។

ទ័ពទាំង ៤ ពួកខាងលើនេះសុទ្ធតែបានទទួលការបង្វឹកបង្ហាត់ក្នុងក្បួនយុទ្ធវិធី តាមសម័យនិយមយ៉ាងជំនាញ ។ ។ ឯកសារខ្មែរមួយ(21) បានសរសេរថា : "ការហាត់យុទ្ធវិធីក្នុងជាន់នោះ ក៏គឺការហាត់គុនដាវ គុនល្បុក្កតោ គុនដំបង ហាត់កាប់ដោយដាវ ដោយផ្គាក់ ហាត់ចាក់ដោយលំពែង ហាត់បាញ់ដោយធ្នូ ហាត់ដាល់ ហាត់ចំបាប់ ហាត់ជិះដំរី ជិះសេះ ជិះរថ ហាត់ក្បាច់អាវុធលើខ្នងដំរី ខ្នងសេះ និងរៀនប្រសិទ្ធិមន្តអាគមតាមលទ្ធិ-សៃយ ដូចយ៉ាងបញ្ចុះមន្តអាគម-យ័ន្តនៅអាវ នៅកន្សែងសំរាប់ជូតក្បាល សាក់តាមខ្លួននិងដឹកនាំគង់ជាដើម និងសិក្សាក្នុងក្បួនកលយុទ្ធ មានតម្រាពិជ័យសង្គ្រាមជាដើម សឹងប្រកបដោយយុទ្ធវិធីផ្សេងៗទៀតជាច្រើន បម្រុងទុកសំរាប់ប្រើការក្នុងយាមមានសឹកសង្គ្រាម" ។

www.budinst.gov.kh www.elibraryofcambodia.org

ក្រៅពីទាហានដែលប្រចាំការទាំង ៤ ពួកខាងលើនេះ នៅមាន **ទាហានក្រៅតំណែង** ជាច្រើនទៀត ។ ប្រភពដដែលខាងលើ (21) បានអោយគតិមានថា : " **ទាហានក្រៅតំណែង** នេះ សំដៅយកយុវជនដែលនៅក្នុងព្រះរាជាណាចក្រទាំងមូល ពួកនេះមិនបានកែនមកអោយនៅប្រចាំការទេ ដោយអនុញ្ញាតអោយនៅធ្វើការរកស៊ីតាមទីលំនៅរៀងខ្លួន តែបានដាក់អោយជាការៈរបស់អ្នករាជការដែលគ្រប់គ្រងនិគម ស្រុក ខេត្ត នោះ ទាត់ការបណ្ដុះបណ្ដាលវិជ្ជាខាងទាហាន និងអោយមាននិស្ស័យចិត្តជាទាហានខ្លួនទៅក្នុងប្រទេសតាមរបៀបដូចមានពោលហើយខាងដើម ..... ទាហានពួកនេះពិតមែនតែមិនបានកែនមកនៅប្រចាំការ តែមានព្រះរាជកំណត់ត្រាទុកថា ត្រូវកែនមកធ្វើការ **សមយុទ្ធ** ក្នុងក្រុងថ្វាយព្រះករុណាម្ចាស់ផែនដីខ្មែរ និងធ្វើ **ពិធីបន្តក់ប្រសិទ្ធិ ពិធីផឹកទឹកពិតន្តសច្ចា** រាល់ ។ ឆ្នាំក្នុង ១ ឆ្នាំ ២ដង " ។

## ១-២- កងទ័ពជើងទឹក.—

ទ័ពប្រភេទនេះត្រូវស្ថិតនៅក្រោមការដឹកនាំរបស់ **ឧកញ៉ាក្រឡាហោម** ។ រៀងរាល់ឆ្នាំទ័ពនេះត្រូវប្រជុំធ្វើសមយុទ្ធ ដូចទ័ពជើងគោកដែរ យើញមានស្នាមធ្វើរៀងមកដល់សម័យបច្ចុប្បន្ន តែក្លាយទៅជាការប្រណាំងទូកសំរាប់មើលលេង ក្នុងឱកាសបុណ្យបណ្ដែតប្រទីបបូជាព្រះពុទ្ធបាទនិងបុណ្យបូជាព្រះចន្ទទៅវិញ (21) ។

## ១-៣- ចំណែកទ័ព.—

តាមឯកសារខ្លះ (21) និងតាមការស្រាវជ្រាវរបស់អ្នកប្រវត្តិសាស្ត្រខ្មែរ ជាពិសេសការស្រាវជ្រាវខាងប្រវត្តិយោធាខ្មែរ (23) យើងអាចដឹងពីការបែងចែកទ័ពខ្មែរ ទោះជាខាងជើងគោកក្ដី ខាងជើងទឹកក្ដី ដូចតទៅ :

— **ពួក** : នេះជាឯកភាពតូចបំផុតនៃកងទ័ព មាន **មេពួកម្នាក់** ជាអ្នកគ្រប់គ្រង ។

— **ក្រុម** : មាន **មេ** ឬ **នាយក្រុម** ម្នាក់ជាអ្នកគ្រប់គ្រង ។

www.budinst.gov.kh www.elibraryofcambodia.org

— **គងរយ** : មានទាហានចំនួន ១០០ នាក់ ប្រៀបបាននឹងអនុសេនាធំ ១ ក្នុងពេលសព្វថ្ងៃ មាន **មេបញ្ជាប់** ម្នាក់ជាអ្នកគ្រប់គ្រង ។

— **គងពាន់** : មានទាហានចំនួន ១០០០ នាក់ មាន**មេបញ្ជាប់ការ** ម្នាក់ជាអ្នកគ្រប់គ្រង ។

— **គងទ័ពតូច ឬ គងពល** : មានទាហានចំនួន ១០ ០០០ នាក់មាន**មេបញ្ជាការគងពល** ម្នាក់ជាអ្នកគ្រប់គ្រង ។

— **គងទ័ព** ឬ **គងទ័ពធំ** ឬ **គងទ័ពហ្លួង** : មានទាហានចំនួនមួយសែននាក់ មាន **មេបញ្ជាការគងទ័ព** ម្នាក់ជាអ្នកគ្រប់គ្រង ឬព្រះរាជាអង្គឯងតែម្តងជាមេបញ្ជាការ ។

## ១.៤ – ទ័ពបិសាច.–

ក្នុងករណីខ្វះ ដោយទ័ពមនុស្សបានចំនួនមិនគ្រប់គ្រាន់ គេអាចពឹងពាក់ដល់ពួកទ័ពបិសាចអោយមកជួយយកអាសាបាន ។ រឿងនេះមានលក្ខណៈអស្ចារ្យបន្តិច ប៉ុន្តែរាជពង្សាវតារខ្មែរបានកត់ត្រាទុកមក ហើយមានលំនាំជាព្រឹត្តិការណ៍ប្រវត្តិសាស្ត្រមួយយ៉ាងពិតប្រាកដ ។ យ៉ាងណាមិញ នៅគ.ស.១៥១៦ ទ័ពខាង**ស្តេចកន** បានដេញតាមទ័ពព្រះ**ចន្ទរាជា** ហើយទៅឡោមព័ទ្ធបន្ទាយពោធិសាត់អស់រយៈពេល ១២ ខែ តែវាយលុកចូលពុំបានសោះ ។ គ្រានោះ **តាពេជ** បានធ្វើពលិកម្មបូជាជីវិតទៅកែនទ័ពបិសាចដោយលោតចូលទៅក្នុងរណ្តៅមួយដែលមានដោតសុទ្ធតែអាវុធស្រួចៗ ។

## ២– គ្រឿងសស្ត្រាវុធ និង យុទ្ធបករណ៍.–

គេសង្កេតឃើញថាមានគ្រឿងសស្ត្រាវុធខ្លះជារបស់ស្តេចខ្ទង់រាជ្យ ឬ របស់ស្តេចគ្រាញ់ និងសស្ត្រាវុធខ្លះទៀតអាចប្រើជាទូទៅក្នុងកងទ័ព :

— **ព្រះខាន់រាជ្យ** ឬ **ព្រះខាន់ជ័យ** និង**ព្រះលំពែងជ័យ** (សូមមើលសេចក្តី

www.budinst.gov.kh www.elibraryofcambodia.org

អធិប្បាយត្រង់វគ្គនិយាយពីគ្រឿងសំរាប់រាជ្យ) ។

— **ព្រះខាន់រាជ** ឬ **ព្រះខាន់ជ័យស្រី** មានរូបតួជាផងព្រះខាន់រាជ្យ ។

— **ព្រះខានស្តេចត្រាញ់** ដែលព្រះរាជាទ្រង់ប្រទានអោយស្តេចត្រាញ់ត្រាដែលចេញទៅឈរត្រួតស្រុក (បុរាណហៅថាចៅស្រុក) ។

— **ធ្នូ** ជាអាវុធមួយសំរាប់ព្រះរាជាផង សំរាប់ប្រើខ្លួនទៅផង ។

— **ស្នា**

— **ទ្រនូ** : មានលក្ខណៈប្រហែលគ្នានឹងលំពែង ប៉ុន្តែនៅគល់ដងមានកង្វ ។

— **ដាវវែង ដាវខ្លី**

— **ផ្គាក់ ឡុក**

— **លំពែងខ្លី លំពែងវែង**

— **ដំបង**

— **ខែល**

— **គ្រឹស**

— **កាំភ្លើងតូច** **កាំភ្លើងធំ** ជាអាវុធដែលគេច្រើនតែទិញពីពួកអឺរ៉ុបនៅស្រុកជ្វាម៉ាឡាយូ ។ ក្នុងដំណាក់ការចុងក្រោយនៃចម្បាំងរវាងព្រះ **ចន្ទរាជា** និង **ស្តេចគន** គេឃើញទាំងសងខាង បានចាត់អោយទៅទិញអាវុធពុននេះរាប់ពាន់ដើមយកមកប្រើ ។

ចំណែកឯយុទ្ធោបករណ៍ គេឃើញមាន :

— **អាវក្រោះ** : គឺអាវស្រោបដែក មានតែស្តេចសឹកនិងពួកមេទ័ព មេកងរេប៊ីសំរាប់ការពារព្រួញ និងដាវលំពែង ។

— **អាវយ័ន្ត** : គឺជាអាវដៃខ្លីហើយមានគូរជាយ័ន្ត បញ្ចុះសាច់មន្តអាគម ។

— **យ័ន្តគេជះ** ឬ **កន្សែងយ័ន្ត** : គឺជាសំពត់ ៤ ជ្រុង ហើយមានបញ្ចុះមន្តអាគម ។

www.budinst.gov.kh  www.elibraryofcambodia.org

— **ទង់ជាតិ** : ទង់សំរាប់ជាតិខ្មែរ ។

— **ទង់មហារាជ** : ទង់សំរាប់ស្តេចទង់រាជ្យ ។

— **ទង់ជ័យ** : ទង់ប្រចាំកងទ័ព ។

— **ស្គរជ័យ** : ស្គរដែលប្រើក្នុងចម្បាំង វាយសំរាប់ប្រជុំពល និងសំរាប់ប្រកាស អោយរេហ៍ពលដឹងថាមានជ័យជំនះហើយ ។

— **គងជ័យ** : សំរាប់ប្រើក្នុងក្បួនទ័ព ។

— **ភ្លេងស្គរខ្លា ឬ ភ្លេងខែក** : ក្នុង ១ រង់មានចំនួនស្គរ ២ ស្រឡៃ ១ ។ ភ្លេងនេះគេលេងក្នុងពេលលើកទ័ពចេញទៅច្បាំង ដើម្បីជាគ្រឿងសម្រើបចិត្តទាហានៗ

សេចក្តីដកស្រង់ខាងក្រោមនេះ អាចបង្ហាញពីទិដ្ឋភាពក្នុងការរៀបចំក្បួនទ័ពចេញដំណើរ ការប្រើយានជំនិះនិងយុទ្ធោបករណ៍ផ្សេងៗ (24) :

« ខណៈនោះ ស្តេច ( ព្រះធម្មរាជាទី ១ ) ទ្រង់គ្រឿងរាជរណាវុធយុទ្ធ ស្រេចហើយស្តេចឡើងគង់ព្រះទីនាំងហត្ថី ចងគ្រឿងគជាភរណៈ បាំងនូវព្រះបរមស្វេតច្ឆត្រធើតធាយ ដោយនូវអភិរមសែនក្ងាន ទង់ជ័យប្រពៃរនូវលព្រាលឆ្នៅគ្រប់កងគជសារ អស្សារាជពីយោធីគ្រឿងព្រម មកស្ថិតចាំស្តេចនៅព្រះលានជ័យ ។ លុះបានពិជ័យឫកល្អហើយ ហោរាក៏គោះគងខ្ទងស្គរ អ្នកមុខអ្នកការក៏ប្រគំរងំដោយនូវតូរ្យតន្ត្រីយ៍ ត្រែភ្លៀវលេងស្គរជ័យ ល្វាសល្វៃព្យុហៈ ទ័ពចេញចាកព្រះមហានគរទៅឧត្តរទិស » ។

## ២ ចម្បាំង.—

### ២.១ ប្រភេទចម្បាំង.—

ក្នុងសម័យកាលដែលលើកយកមកសិក្សានេះ គេសង្កេតឃើញមានចម្បាំង ៣ ប្រភេទដូចតទៅនេះ :



www.budinst.gov.kh www.elibraryofcambodia.org

**— ចម្បាំងរវាងក្នុងស្រុក.—**

ចម្បាំងប្រភេទនេះសុទ្ធតែបណ្តាលមកពីវិបត្តិក្នុងរាជវង្ស ។ ចម្បាំងរវាងព្រះស្រីរាជា **ស្រីសុរិយោពណ៌-ស្រីធម្មរាជ** ( ១៤៧៥-១៤៨៥ ) និងចម្បាំងរវាង **ស្រីសុគន្ធបទ-ស្តេចកន-ចន្ទរាជា** ( ១៥០៩-១៥១២ រួច ១៥១៦-១៥២៥ ) សុទ្ធតែជាចម្បាំងធ្លាងឯងក្នុងស្រុកទាំងអស់ ។

**— ចម្បាំងរំដោះទឹកដី .—**

ចាប់ពី ស.វ. ទី ១៣ ទៀងមក ខ្មែរយើងត្រូវបាត់បង់ទឹកដីចាប់ពីវាលទំនាបនៃ **ឥន្លេមេណាម** រហូតមកដល់ព្រំប្រទល់ខេត្តបាត់ដំបង សៀមរាប ។ ចាប់តាំងពីរជ្ជកាលព្រះ **ស្រីរាជា** ដល់រជ្ជកាល ព្រះ **សត្ថាទី ១** ខ្មែរយើងតែងបានលើកទ័ពទៅវាយរំដោះយកអាណាខេត្តដែលត្រូវបាត់បង់ទៅក្នុងកណ្តាប់ដៃសៀមនោះបានមកវិញ ។

**— ចម្បាំងការពារជាតិ .—**

ក្នុងករណីខ្លះ ជនជាតិជិតខាងមានសៀម-លាវ បានលើកទ័ពចូលមកវាយខ្មែរក្នុងបំណងពង្រីកទឹកដីរបស់គេដោយគេយកលេសផ្សេង ៗ ។ ដោយព្រះ **ចន្ទរាជា** ទ្រង់ប្រកែកមិនព្រមថ្វាយដំរីស ព្រះចៅសៀមបានលើកទ័ពចូលវាយខ្មែរពីរលើក លើកទី ១ នៅសៀមរាប លើកទី ២ នៅពោធិសាត់ ។ ក្រោយមក ក្នុងរជ្ជកាលព្រះ **បរមរាជាទី ៤** ដោយប្រជល់ដំរីចាញ់ខ្មែរ ស្តេចលាវបានលើកទ័ពចូលវាយខ្មែរពីរលើក ។ ប៉ុន្តែ ទាំងទ័ពសៀម ទាំងទ័ពលាវ សុទ្ធតែត្រូវទទួលបរាជ័យថយទៅវិញទាំងអស់ ។

## ២.២– យុទ្ធសាស្ត្រ និង គលយុទ្ធ.–

ជាទូទៅ គេសង្កេតឃើញថាទោះនៅក្នុងចម្បាំងប្រភេទណាក៏ដោយ សុទ្ធតែមាន

www.budinst.gov.kh www.elibraryofcambodia.org

គោលដៅចម្បងតែមួយគឺវាយដណ្ដើមយកទឹកដីនិងប្រជារាស្ត្រ ហើយប្រសិនបើវាយយកមិនបានទឹកដីទេក៏គេរិតទំកៀរយកអោយបានមនុស្សមកខាងគេដែរ ។ ដោយហេតុនោះហើយ ទើបយើងឃើញថានៅក្នុងរង្វង់ព្រំដែនទឹកដីខ្មែរសព្វថ្ងៃនៅមានជនជាតិបរទេសខ្លះដែលរស់រានរហូតមកដូចជាជនជាតិ **គុឡា** នៅប៉ៃលិនខេត្តបាត់ដំបង ជនជាតិ **ឈាន** នៅបារាយណ៍ នៅបាភ្នំជាដើម ។

នៅក្នុងការធ្វើចម្បាំងទាំងបីប្រភេទដូចបានរៀបរាប់មកហើយនោះ ឃើញថាគេច្រើនតែច្បាំងដោយទល់មុខគ្នា គឺថាគូបដិបក្ខទាំងសងខាងលើកទ័ពធំទៅតទល់គ្នាលើសមរភូមិតែម្តង (guerre de front) ។ ចំណែកឯរបៀបវាយទ័ពលើកទៅប្រយុទ្ធទង្វាំងសត្រូវ គេឃើញមានរបៀបសំខាន់តែមួយដែលគេច្រើនប្រើមានដូចតទៅ :

— **ទ័ពមុខ** (le corps d'avant - garde)

— **ទ័ពស្តាំ** (le corps de droite)

— **ទ័ពឆ្វេង** (le corps de gauche)

— **ទ័ពហ្លួង** ឬ **ទ័ពធំ** នៅកណ្ដាលគេ (le corps principal)

— **ទ័ពក្រោយ** (le corps d'arrière - garde)

គួរគប្បីបញ្ជាក់ថា ក្នុងករណីខ្លះ **ទ័ពមុខ** និង **ទ័ពក្រោយ** ពុំឃើញមានជងទេ ប៉ុន្តែមានទ័ពដែលមានមុខងារពិសេសខ្លះគឺ. **ទ័ពត្រួតខែល** **ទ័ពស្ទាត់** **ទ័ពជន្ល** **ទ័ពបង្កប់**។

— **ទ័ពត្រួតខែល** គឺពួកទាហានដែលគេអោយដើរល្បាត ដើម្បីឃ្លាំមើលចលនានិងសកម្មភាពរបស់ទ័ពសត្រូវ ។

— **ទ័ពស្ទាត់** គឺពួកទាហានដែលមានបេសកកម្មរារាំងកុំអោយទ័ពសត្រូវទាក់ទងគ្នាបាន ឬកុំអោយទ័ពសត្រូវផ្នែកណាមួយទៅជួយផ្នែកណាមួយទៀតបាន ។

— **ទ័ពជន្ល** គឺពួកទាហានដែលគេអោយទៅមុន សំរាប់ទាក់ទាញអោយទ័ពសត្រូវដេញតាម ។

— **ទ័ពបង្កប់** គឺពួកទាហានដែលគេបង្កប់ទុកក្នុងព្រៃមិនអោយសត្រូវដឹង មាន

www.budinst.gov.kh www.elibraryofcambodia.org

បេសកកម្មលើបឡើងវាយផ្ចប់សត្រូវពីគ្រប់ទិសកាល ណាពួកនេះធ្លាក់ក្នុងអន្ទាក់របស់គេ ។

ចំពោះចំនួនទាហានក្នុងប្រភេទទ័ពទាំងប៉ុន្មានដូចបានរៀបរាប់រួចមកហើយនោះ ឃើញថាមានចំនួនមិនស្មើគ្នាក្នុងកងទ័ពម្នាង ៗ ។ ចំនួននេះតែងតែផ្លាស់ប្តូរទៅតាមកាលៈទេសៈ គឺថាទៅតាមលទ្ធភាពដែលគួបផ្សំបង្គួរអាចកែនបានតិចឬច្រើន ។ ជាទូទៅ គេសង្កេតឃើញ **ទ័ពមុខ** ឬ **ទ័ពស្រួច** តែងមានចំនួនច្រើនជាង **ទ័ពស្តាំ** និង **ទ័ពឆ្វេង** ដែលមានស្មើគ្នា ។ ឯ**ទ័ពក្រោយ** មានចំនួនប្រហាក់ប្រហែលនឹង **ទ័ពស្តាំឆ្វេង** ដែរ ។ មានតែ**ទ័ពហ្លួង** ឬ **ទ័ពធំ** ទេដែលមានចំនួនទាហានច្រើនជាងគេ ។ ឯ**ទ័ពគ្រវែល** **ទ័ពឋន្ល** **ទ័ពបន្ទប់** មានចំនួនទាហានប្រហែល ៗ គ្នាហើយតិចជាងគេដង ។

ខាងក្រោមនេះជាឧទាហរណ៍មួយពីចំណាត់ទ័ពសំរាប់ចូលច្បាំង (25) :

— **ទ័ពមុខ** : ២០ ០០០ នាក់
— **ទ័ពស្តាំ** : ១០ ០០០ នាក់
— **ទ័ពឆ្វេង** : ១០ ០០០ នាក់
— **ទ័ពហ្លួង** : ៤០ ០០០ នាក់
— **ទ័ពបន្ទប់** : ៥០០០ នាក់

ក្នុងផ្នែកកលយុទ្ធ ដូចកាលគេធ្វើកលជាចាញ់ហើយបើសត្រូវដេញតាមទៅនោះ ច្បាស់ជាត្រូវពួក **ទ័ពបន្ទប់** និង **ទ័ពស្ពាត់** ដើបឡើងវាយផ្ចប់យកឈ្នះជាមិនខាន ។

ក្នុងករណីដែលទ័ពម្ខាង ១ ប្រយុទ្ធហើយទន់ដៃជាងទ័ពម្ខាងទៀត នោះគេច្រើនជយចូលការពារខ្លួនក្នុងបន្ទាយ ដូចកាលទ័ពព្រះបាទ **ស្រីសុគន្ធបទ** ជយចូលក្នុងបន្ទាយស្ទឹងសែន ទ័ពព្រះ**ចន្ទរាជា** ជយចូលក្នុងបន្ទាយពោធិសាត់ ទ័ព**ស្តេចកន** ជយចូលក្នុងបន្ទាយស្រឡប់ពិជ័យ ទ័ពព្រះ**ស្រីសុរិយោពណ៌** ជយចូលក្នុងបន្ទាយលង្វែក ។ ឯទ័ពម្ខាងទៀតក៏មកធ្វើការឡោមព័ទ្ធអស់ពេលជាច្រើនខែ ។ បន្ទាយនីមួយៗសុទ្ធតែមានស្បៀងមានបំរុងសំរាប់ការពារយ៉ាងណាស់ ឯទ័ពនៅខាងក្នុងសុទ្ធតែបានប្រមូលស្បៀងទុកបំរុងសំរាប់រស់នៅអោយ



www.budinst.gov.kh www.elibraryofcambodia.org

បានយូរពេល ។ ម្ល៉ោះហើយ ទ័ពម្ខាងទៀតដែលធ្វើការឡោមព័ទ្ធនោះមិនងាយចូល វាយលុកយកបន្ទាយបានដោយងាយៗទេ ។ **ស្តេចគន** អោយទាហានធ្វើកលជាក្បត់រត់ ចូលខាងព្រះបាទ**ស្រីសុគន្ធបទ** ហើយរកឱកាសល្អចូលលុកធ្វើគត់ព្រះអង្គបាន ។ ពេលនោះ ទ័ពខាង**ស្តេចគន** ក៏វាយលុកចូលយកបានបន្ទាយទៅ ។ កាលទ័ពសៀមលើកទ័ពចូលព័ទ្ធបន្ទាយលង្វែកលើកទី១ វាមិនអាចវាយយកបន្ទាយនោះទេ ព្រោះមានរបងឫស្សីព័ទ្ធពីក្រៅក្រាស់ពេក ។ ដោយហេតុនោះ សៀមបានធ្វើកលបាញ់ប្រាក់ដួងចូលក្នុងរបងឫស្សីមុននឹងដកថយទៅវិញ ហើយបញ្ជូនចារបុរសអោយមកស៊ើបយកការណ៍អោយដឹងថាតើខ្មែរខ្លាំងពូកែដោយសារអ្វី ។ ក្រោយមក ដោយខ្មែរយើងនាំគ្នាឆ្ការព្រៃឫស្សីដើម្បីយកប្រាក់នោះរហូតដល់ធ្លុះធ្លាយអស់ទើបទ័ពសៀមអាចវាយលុកចូលយកបន្ទាយបាន ។ កាលដែលទ័ពព្រះ **ចន្ទរាជា** ទៅព័ទ្ធ **ស្តេចគន** នៅក្នុងបន្ទាយស្រឡប់ពិជ័យ ហើយយកមិនបាននោះ ព្រះអង្គទ្រង់ចាត់អោយប្រកាសថា ព្រះអង្គនឹងវាយបន្ទាយអោយទាល់តែបាន ហើយនៅពេលយកបានបន្ទាយនោះ ជនណាដែលនៅក្នុងបន្ទាយនឹងត្រូវដាក់អោយទៅជាអ្នកងារ ។ ម្យ៉ាងទៀត ខាងព្រះ **ចន្ទរាជា** បានឃោសនាថា ព្រះចៅសៀមបានបញ្ជូនកងទ័ពមួយមកអោយជួយព្រះ **ចន្ទរាជា** ទៀត ។ ពាក្យនេះធ្វើអោយមនុស្សនៅក្នុងបន្ទាយមានការភិតភ័យយ៉ាងខ្លាំង ។ នៅពេលយប់ ព្រះ**ចន្ទរាជា** ទ្រង់បានចាត់អោយដុតស្មៅស្ងួតនៅជុំវិញបន្ទាយ ។ មនុស្សនៅក្នុងបន្ទាយឃើញដូច្នោះរឹតតែភិតភ័យខ្លាំងថែមទៀត ដោយនឹកស្មានថាភ្លើងទាំងនោះជាកន្លែងជំរុំរបស់កងទ័ពសៀមមែន ។ ម្ល៉ោះហើយ ទ័ពរបស់ **ស្តេចគន** ក៏នាំគ្នាពពាក់ពពូនរត់ចេញពីបន្ទាយ ដោយខ្លាចគេសម្លាប់ផង និង ខ្លាចគេដាក់អោយទៅជាអ្នកងារផង ។ គឺដោយហេតុនោះហើយ ទើបព្រះ **ចន្ទរាជា** អាចយកបន្ទាយស្រឡប់ពិជ័យ និង ចាប់**ស្តេចគន** បាន (11) ។

## ២.៣– សកម្មភាពចិត្តសាស្ត្រក្នុងពេលធ្វើចម្បាំង.

ក្នុងពេលធ្វើចម្បាំង មេម្ខាង ៗ តែងតែផ្តល់រង្វាន់ដល់សេនាទាហានដែលមានថ្វីដៃ

www.budinst.gov.kh www.elibraryofcambodia.org

ដើម្បីជាការលើកទឹកចិត្ត ។ នៅពេលច្បាំងសង្គ្រាមម្តង ។ តែងតែមានការប្រឡងថ្វីដៃ ហើយបើឈ្មោះណាបានជាសេនាទាហានហើយ យសសក្តិទ្រព្យសម្បត្តិជារង្វាន់មិនគ្រាន់ តែបានត្រឹមឈ្មោះនោះទេ តែបានដល់គ្រួសារខ្លួនទៀត ។

នៅរដូវវស្សា គេច្រើនតែព្រមព្រៀងគ្នារំសាយកងទ័ពបើកអោយទាហានត្រឡប់ទៅ ជួបជុំប្រពន្ធកូនផង និងអោយមានឱកាសធ្វើស្រែចំការ យកស្បៀងចិញ្ចឹមគ្រួសារនិង ចិញ្ចឹមកងទ័ពតទៅទៀត ។

ដើម្បីអោយអ្នកស្រុកនិងកងទ័ព ឬសត្រូវ ចូលខាងខ្លួន គេតែងតែឃោសនាបង្ហាញនូវ លក្ខណៈត្រឹមត្រូវពេញច្បាប់ខាងគេ ហើយបង្ហាញពីលក្ខណៈមិនគាប់ប្រសើររបស់គូបដិ- បក្ខ ដូចខាងព្រះ **ចន្ទរាជា** តែងតែឃោសនាប្រាប់រាស្ត្រថាព្រះអង្គជាពូជពង្សក្សត្រ ចំ- ណែកឯ **ស្តេចកន** ជាពលព្រះមនុស្សក្នុងវណ្ណៈថោកទាបជាដើម ។

នៅពេលលើកទ័ពទៅវាយត្រង់តំបន់ណាដែលម្ខាងទៀតធ្លាប់កាន់កាប់ គេតែងតែ បញ្ជូនអ្នកមានវោហាថ្វីមាត់ អោយទៅនិយាយបញ្ចុះបញ្ចូលចៅហ្វាយស្រុកនិងប្រជារាស្ត្រ អោយចូលមកខាងខ្លួនគេជាមុនសិន ។

ក្នុងការធ្វើចម្បាំង គេតែងតែចេញបញ្ជាហាមប្រាមមិនអោយទាហានទៅរំលោភជិះ ជាន់ប្លន់យកទ្រព្យសម្បត្តិពីប្រជារាស្ត្រឡើយ ។ បើមានជនណាល្មើសច្បាប់ធ្វើអោយរាស្ត្រ ក្តៅក្រហាយ នោះនឹងត្រូវទទួលទណ្ឌកម្មរហូតដល់ត្រូវប្រហារជីវិត ។

ម្យ៉ាងទៀត ខាងស្តេចបានបញ្ជាអោយយករាជប្រកាសទៅបិទនៅតំបន់សត្រូវកាន់ កាប់ ថាបើជនណាមានចិត្តស្មោះត្រង់ព្រមចុះចូលបំរើព្រះអង្គពីឥឡូវទៅ ព្រះអង្គនឹងលើក ទោសអោយ តែបើជួយទៅវិញកាលណាស្រុករាបទាបហើយ ព្រះអង្គនឹងទុកជាក្បត់ហើយ ត្រូវទទួលទោសជាទម្ងន់ មានការដាក់អោយទៅជាអ្នកងារជាដើម ។

## ឃ- ជីវភាពសង្គម.-

### ១- ថ្នាក់សង្គម.—

www.budinst.gov.kh www.elibraryofcambodia.org

ទោះបីខ្មែរបានទទួលឥទ្ធិពលពីឥណ្ឌាក្នុងការបែងចែកមនុស្សក្នុងសង្គមជាវណ្ណៈក៏ដោយ ក៏សង្គមខ្មែរពុំមានលក្ខណៈដូចសង្គមឥណ្ឌាបេះបិទទេ ។ យ៉ាងណាមិញ ក្នុងសង្គមឥណ្ឌា គេបានបែងចែកមនុស្សជា ៤ វណ្ណៈ គឺ៖

— វណ្ណៈទី ១ ជា វណ្ណៈរបស់ពួក **ព្រាហ្មណៈ**

— វណ្ណៈទី ២ ជា វណ្ណៈរបស់ពួក **ក្សត្រិយៈ**

— វណ្ណៈទី៣ ជា វណ្ណៈរបស់ពួក **វៃស្យៈ**

— វណ្ណៈទី ៤ ជា វណ្ណៈរបសពួក **សូទ្រៈ**

ចំណែកឯក្នុងសង្គមខ្មែរសម័យនោះ ពុំមានចែកជាវណ្ណៈទេតែចែកជា **ថ្នាក់** ទៅវិញ ( classes sociales ) ហើយមានទាំងអស់ ៥ ថ្នាក់ដូចតទៅ៖

## ១.១– រាជវង្សានុវង្ស.–

ផ្ទុយពីសង្គមឥណ្ឌា ក្នុងសង្គមខ្មែរគឺពួក **ក្សត្រិយៈ** អ្នកគ្រប់គ្រងប្រទេសជាថ្នាក់សង្គមដែលខ្ពស់ជាងគេ ។ តំណែងធំ ៗ ទាំងប៉ុន្មាន ច្រើនតែបានពួក **ក្សត្រិយ** ជាអ្នកកាន់កាប់ ។

## ១.២– ពួកមន្ត្រី.–

ពួកនេះមានឯកសិទ្ធិច្រើន ដូចជាមិនបាច់បង់ពន្ធនិងមិនបាច់បំពេញកិច្ចការសាធារណៈ ជាដើម ។ ពួកមន្ត្រីជាន់ខ្ពស់និងពួកចៅហ្វាយស្រុកសុទ្ធតែបានព្រះរាជាតែងតាំងឡើង ហើយត្រូវធ្វើសច្ចាប្រណិធានថាស្មោះត្រង់បំរើព្រះអង្គជានិច្ច ។

## ១.៣– បព្វជិត.–

— **បាគូ** ៖ ទោះបីខ្មែរលែងកាន់សាសនាព្រាហ្មណ៍ទៀតហើយក៏ដោយ ក៏ព្រះមហាក្សត្រខ្មែរពុំបានបោះបង់ចោលទាំងស្រុងនូវប្រពៃណីខាងសាសនាព្រាហ្មណ៍ផងទេ ។ ដោយ


www.budinst.gov.kh www.elibraryofcambodia.org

ហេតុនោះហើយ ទើបគេឃើញនៅក្នុងព្រះបរមរាជវាំងនូវវត្តមានរបស់ពួក **បាគូ** ដែល ជាកូនចៅរបស់ពួកព្រាហ្មណ៍បុរោហិតកាលពីសម័យមុន ៗ មានសម័យអង្គរជាដើម ៗ មាន ឯកសារខ្លះថា ពួក **បាគូ** អាចឡើងសោយរាជ្យបានក្នុងករណីណាដែលព្រះមហាក្សត្រសោយ ទីវង្គតទៅហើយគ្មានបុត្រឬញាតិណាអាចឡើងសោយរាជ្យស្នង (22) ប៉ុន្តែក្នុងភាពពិតជាក់ ស្តែង គេពុំដែលប្រទះករណីបែបនេះសោះឡើយ ។

ពួក **បាគូ** មានឯកសិទ្ធិជាអ្នកថែរក្សា **គ្រឿងសំរាប់រាជ្យ** មាន **ព្រះខាន់រាជ្យ** ព្រះ **លំពែងជ័យ** និង **គ្រឿងបញ្ចគ្រូស្រ** និងជាអ្នកប្រារព្ធធ្វើរាជពិធីផ្សេង ៗ ក្នុងព្រះ បរមរាជវាំង ។ ម្យ៉ាងទៀត ពួក **បាគូ** នៅមានឯកសិទ្ធិមិនបាច់បង់ពន្ធ មិនបាច់បំពេញ កិច្ចការសាធារណៈ និងមិនបាច់កែនធ្វើទាហានទៀតផង ។

— **ព្រះសង្ឃ** : ជាថ្នាក់សង្គមមួយពិសេស ព្រោះចៅក្រមដែលជាគ្រហស្ថ ពុំអាច កាត់សេចក្តីចំពោះទោសកំហុសរបស់ **ព្រះសង្ឃ** បានឡើយ ៗ មានតែ **ព្រះសង្ឃនាយក** ទើបអាចត្រួតពិនិត្យវិន័យ និងដាក់ទណ្ឌកម្មលើរូបព្រះសង្ឃបាន ។ ក្នុងករណីមានទោសធ្ងន់ ឬទោសឧក្រិដ្ឋ **ព្រះសង្ឃនាយក** អាចផ្សឹក **ព្រះសង្ឃ** ដែលមានទោសបានហើយបញ្ជូន ខ្លួនទៅអោយតុលាការពិសេសកាត់ទោស ។ **ព្រះសង្ឃ** មានឯកសិទ្ធិដូចពួក**បាគូ**ដែរ ។

## ១.៤— **អ្នកងារ** (ពួកពៃ្រងារ).—

គេអាចប្រៀបធៀបពួកនេះទៅនឹងពួក **ឝៃស្យ** នៅក្នុងសង្គមឥណ្ឌា ។ ពួកនេះ គឺ គេសំដៅយកប្រជារាស្ត្រទូទៅ ដែលប្រកបរបររស្រែចំការ លក់ដូរ នេសាទជាដើម ។

## ១.៥— ខ្ញុំ.—

គេអាចប្រៀបពួកនេះទៅនឹងពួក **ស្ទ្រូវ** នៅក្នុងសង្គមឥណ្ឌា ។ មានខ្ញុំបីប្រភេទ :

— **ខ្ញុំស្តេច** : ជនដែលធ្លាក់ខ្លួនទៅជាខ្ញុំស្តេច គឺពួកឈ្លើយសង្គ្រាម ជនប្រព្រឹត្តបទឧក្រិដ្ឋ ជនណានាអ្នកទោសឧក្រិដ្ឋដែលរត់រួច សម្លាប់គេ ធ្វើប្រាក់បន្លំ ដុតផ្ទះ ស្ត្រីដែលមានសហាយ

www.budinst.gov.kh www.elibraryofcambodia.org

ត្រវប្តីសម្លាប់ និងកូនពួកខ្ញុំរបស់ស្តេច ។

ខ្ញុំប្រភេទនេះ គេនៅហៅថា **អ្នកងារ** ដែលមានការបញ្ជាក់ពីឯកសារអក្សរសិល៍ ។ យ៉ាងណាមិញ រៀង **ឌុំនាទ** បានប្រាប់យើងថា អ្នកស្រុកត្បូងឃ្មុំដែលបណ្តោយអោយ **អរឡូន** សម្លាប់ **ម៉ឺនឯក** (ខ្ញុំ) ដែលមានព្រះរាជសារជាប់នៅនឹងខ្លួននោះសុទ្ធតែត្រូវដាក់អោយទៅជា **អ្នកងារ** ទាំងអស់ ។ ម្យ៉ាងទៀត នៅពេលដែលព្រះ **ចន្ទរាជា** មានជ័យជំនះលើ **ស្តេចកន** បក្សពួករបស់ **ស្តេចកន** សុទ្ធតែត្រូវដាក់ជា **អ្នកងារ** ទាំងអស់ដែរ ។

គួរគប្បីជ្រាបថា ពួកខ្ញុំប្រភេទនេះច្រើនតែត្រូវបង្ខំអោយធ្វើការជាទម្ងន់លើដីព្រះរាជទ្រព្យ ។ ក្នុងករណីខ្លះពួកនេះអាចរំដោះខ្លួនបាន ដោយសេចក្តីអនុគ្រោះរបស់ស្តេច ដោយលោះខ្លួនដោយប្រាក់ ដោយការជំនួស ដោយការសាងផ្នួស (22) ។

– **ខ្ញុំចក្ត** : ខ្ញុំប្រភេទនេះនៅមានឈ្មោះម្យ៉ាងទៀតហៅថា **ពលព្រះ** ឬ **ពលព្រះរតនត្រៃ** ។ រាជពង្សាវតារខ្មែរ (26) បាននិយាយថាពួកខ្ញុំប្រភេទនេះមានកំណើតកើតមកតាំងពីរជ្ជកាលព្រះបាទ **ធម្មរាជាទី១** ម៉្លេះ :

“ស្តេច (ព្រះបាទធម្មរាជា) គង់ក្នុងភេទជាភិក្ខុភាវៈ ៣ ថ្ងៃហើយទ្រង់សោយចាកសិក្ខាបទ ។ ទ្រង់បរិច្ចាគព្រះរាជទ្រព្យធ្វើទានព្រះរាជទានបណ្តារាស្ត្រជាអនេកអនន្តពន់ពេក ។ ទ្រង់ព្រះរាជសទ្ធាវេរភូមិ ២១ ស្រែ ២១ ខ្ញុំប្រុស ២១ នាក់ ខ្ញុំស្រី ២១ នាក់ រទេះគោ ២១ នឹម រទេះក្របី ២១ នឹម សេះ ២១ ដំរី ២១ នូវគ្រឿងប្រគំជៀង ៗ ថ្វាយទុកជាទាសាទាសីអោយរក្សាព្រះចេតិយ ព្រះវិហារសីមា សំរាប់បោសច្រាសសំអាត ។ ទ្រង់តាំងអោយមានមេពីរនាក់ជានាយត្រួតត្រារក្សា ។ អាស្រ័យហេតុនេះហើយ បានជាមាន **ពលព្រះស្រីរតនត្រៃ** តាំងពីនោះរៀងមក” ។

គួរគប្បីជ្រាបថា ពួក **ពលព្រះ** នេះ ទោះបីមានបុណ្យសក្តិខ្ពង់ខ្ពស់យ៉ាងណាក៏ដោយ ក៏នៅតែពុំអាចរំដោះខ្លួនអោយចេញផុតពីឋានៈនេះបានឡើយ ។ ព្រះបាទ **ស្រីសុគន្ធបទ** ទ្រង់មានបំណងរំដោះព្រះស្នំឯក (នាងស) និង **ស្តេចកន** ជាព្រះអនុជថ្លៃអោយរួចពីឋានៈ **ពលព្រះ** ។ ព្រះអង្គទ្រង់បានពិគ្រោះនឹងមន្ត្រីជាន់ខ្ពស់ **នៃមន្ត្រីទាំងនោះបានទូលថា**



www.budinst.gov.kh www.elibraryofcambodia.org

គ្រួសារណាមួយដែលធ្លាក់ខ្លួនទៅជាពលព្រះហើយ ត្រូវស្ថិតនៅក្នុងឋានៈនោះអស់រយៈពេល ៥០០០ ឆ្នាំ ហើយព្រះរាជាក៏ពុំអាចធ្វើការរំដោះបានដែរព្រោះបើព្រះអង្គហ៊ានប្រព្រឹត្តដូច្នោះ អ្នកផងទាំងឡាយនឹងថាព្រះអង្គពុំគោរពចំពោះព្រះរតនត្រ័យឡើយ(11) ។

ឯកសារខ្លះ (22) បានបញ្ជាក់ថាឋានៈ ពលព្រះ នេះគឺបានមកពី :

- ម្តាយជា ពលព្រះ
- ធ្វើឃាតព្រះសង្ឃ
- លួចទ្រព្យគរុភ័ណ្ឌ
- ដុតវត្ត
- ទោសកំហុសខ្លះប្រព្រឹត្តដោយព្រះសង្ឃ ដូចជាសហាយស្មន់ ឆប់ក្នុងកាមគុណ ធ្វើថ្នាំពន្លូតកូន ។ល។

ពួកខ្ញុំប្រភេទនេះទំនងជាមានជីវភាពមិនយ៉ាប់យ៉ឺនដូចខ្ញុំប្រភេទដទៃទៀតទេ ព្រោះព្រះសង្ឃតែងមានព្រះទ័យសប្បុរសចំពោះពួកនេះ ។

– ខ្ញុំគេ (ទាសៈ ទាសី) : ពួកនេះគឺជាខ្ញុំកំដររបស់ពួកអ្នកជាឬពួកមន្ត្រី ។ ឋានៈនេះត្រូវបានទៅជនណាដែលជំពាក់បំណុលគេហើយគ្មានប្រាក់សងវិញ បានទៅពួកឈ្លើយសង្គ្រាម ឬពួកអ្នកស្រុកភ្នំដែលគេទៅចាប់យកមកដោយបង្ខំ ។ ពួកខ្លះអាចរំដោះខ្លួនបានតែមានពួកខ្លះមិនអាចរំដោះខ្លួនបានឡើយ ។

## ២.- ការរស់នៅនិងសេដ្ឋកិច្ច.-

ការរស់នៅរបស់អាណាប្រជានុរាស្ត្រក្នុងគ្រាស្រុកមានសន្តិភាព និងក្នុងគ្រាស្រុកមានចម្បាំងរាំងផល់ ឃើញថាមានលក្ខណៈខុសប្លែកគ្នាឆ្ងាយណាស់ ។

សេចក្តីដកស្រង់ខាងក្រោមនេះពីសៀវភៅ « Le Sdach Kân » របស់លោក Adhémard Leclère អាចបញ្ជាក់ពីលក្ខណៈនេះបានខ្លះ :

**"Le royaume avait retrouvé la paix d'autrefois et les habitants se disaient plus heureux sous le roi Kân qu'ils ne l'avaient jamais été sous**

www.budinst.gov.kh www.elibraryofcambodia.org

les rois de l'ancienne monarchie » ។

ជាទូទៅ គេឃើញថាអាណាប្រជានុរាស្ត្រមានភារកិច្ចត្រូវ **បង់ពន្ធ** ជូនរាជការ ប៉ុន្តែក្នុងករណីខ្លះព្រះរាជាទ្រង់សព្វព្រះរាជហឫទ័យលើកលែងមិនយកពន្ធបាន ដូចព្រះ **ធម្ម-រាជា** ទ្រង់បានបញ្ជាអោយលើកលែងពន្ធរាជការខ្លួន និងពន្ធព្រះរាជធានីអស់រយៈកាល ៣ ឆ្នាំ ។ ចំណែកឯ ព្រះបាទ **ស្រីជេដ្ឋាធិរាជ** (ស្តេចកន) កាលច្បាំងឈ្នះព្រះបាទ **ស្រីសុគន្ធបទ** ហើយធ្វើពិធីរាជាភិសេកឡើងសោយរាជ្យនោះ ព្រះអង្គទ្រង់ពន្លាប់អោយរាជការលើកលែងអាណាប្រជានុរាស្ត្រទូទាំងប្រទេសមិនអោយបង់ពន្ធក្នុងរយៈពេលមួយឆ្នាំ ហើយគេបានបញ្ជាក់សេចក្តីថាអាណាប្រជានុរាស្ត្របានសម្បូណ៌សប្បាយ (11) ។

ម្យ៉ាងទៀត អាណាប្រជានុរាស្ត្រតែងតែត្រូវកែនអោយ **បំពេញកិច្ចការធំៗ** ដូចជាលើកផ្លូវ សង់ស្ពាន ជីកព្រែក ជីកអូរ លើកទំនប់ ។ល។ សំរាប់បំរើប្រយោជន៍រួមនិងកិច្ចការខ្លះទៀតសំរាប់បំរើផលប្រយោជន៍របស់ព្រះរាជា ។

ក្រៅពីកិច្ចការទាំងប៉ុន្មានដែលត្រូវបំពេញដូចបានរៀបរាប់រួចមកហើយនេះ ពួកយុវជនក្នុងព្រះរាជាណាចក្រត្រូវជាប់កំណែនជា **ពលទាហានត្រៀមកំណែន** ទៀត ។ នៅពេលណាស្រុកមានចម្បាំង ពួកទាហានប្រភេទនេះត្រូវគេកែនអោយចូលបំរើក្នុងកងទ័ពភ្លាម ៗ ។

ក្នុងករណីស្រុកកើតចម្បាំង ទោះជាចម្បាំងក្នុងឯងក្តី ចម្បាំងការពារជាតិក្តី អាណាប្រជានុរាស្ត្រត្រូវជួបប្រទះនឹងទុក្ខវេទនាយ៉ាងខ្លាំង ព្រោះក្រៅពីភារកិច្ចទាំងប៉ុន្មានដែលត្រូវបំពេញខាងលើ រាស្ត្រត្រូវប្រមូលទ្រព្យសម្បត្តិ ស្បៀងអាហារផ្គត់ផ្គង់អោយកងទ័ពថែមទៀត ។ ពិសេសទៅទៀតក្នុងចម្បាំងនៅសម័យណាក៏ដូចនៅសម័យណាដែរ អាណាប្រជានុរាស្ត្ររមែងតែងតែស្លាប់ដោយខ្មាំងសត្រូវប្រហារផង ដោយជម្ងឺដំកាត់ផ្សេង ៗ ផង ។ ទៀតឧកាសដែលមានការកែវរជូរឡោះ ចោរខ្មោញតែងតែកំរើកឡើងមកប្លន់កាប់ចាក់នៅគ្រប់ស្រុកគ្រប់តំបន់ ។

ក្នុងវិស័យសេដ្ឋកិច្ច គេសង្កេតឃើញមានសកម្មភាពផ្សេង ៗ ដូចតទៅ:

— **កសិកម្ម :** កសិកម្មទំនងជាសកម្មភាពសេដ្ឋកិច្ចសំខាន់ជាងគេ ព្រោះគេបានសង្កេត

www.budinst.gov.kh www.elibraryofcambodia.org

ឃើញថាអ្នកដឹកនាំជាតិតែងតែយកចិត្តទុកដាក់នឹងបញ្ហាទឹកណាស់ ។ ក្នុងការស្ថាបនារាជធានីថ្មីម្តង ៗ ព្រះរាជាតែងនឹកគិតទៅដល់ដីធ្លីសំរាប់អោយរាស្ត្រធ្វើស្រែចំការ និងការជីកអូរ ជីកប្រឡាយ ជីកត្រពាំងសំរាប់យកទឹកផ្គត់ផ្គង់ដល់មុខរបរនេះទៀត ។ ក្នុងរជ្ជកាលរបស់ព្រះ **ចន្ទរាជា** ព្រះអង្គទ្រង់បានបញ្ជាអោយកាប់ឆ្ការព្រៃ ដើម្បីពង្រីកទំហំដីស្រែចំការ ៗ ក្នុងគ្រាមានចម្បាំងគ្នាឯងក្នុងស្រុក តែកាលណាដល់រដូវវស្សាគេតែងតែស្រុះស្រួលគ្នាទាំងសងខាង ដើម្បីរំសាយទ័ពផ្អាកសង្គ្រាម អោយទាហានត្រឡប់ទៅកាន់ទីលំនៅរៀងខ្លួននិងប្រកបរបរស្រែចំការ ៗ ធ្វើយ៉ាងនេះឃើញថាដូនតាយើងលោកយល់ច្បាស់ណាស់នូវសារសំខាន់របស់សេដ្ឋកិច្ចក្នុងពេលធ្វើចម្បាំងគឺ " **ធ្វើស្រែនឹងទឹក ធ្វើសឹកនឹងបាយ** " ៗ យ៉ាងណាមិញ ប្រសិនបើគ្មានបាយទេ ទាហាននិងអាណាប្រជានុរាស្ត្រនឹងត្រូវដាច់ពោះស្លាប់ហើយគេក៏គ្មានលទ្ធភាពនឹងធ្វើចម្បាំងតទៅទៀតដែរ ៗ

ក្នុងសម័យលង្វែក គឺនៅពេលដែលព្រះរាជាខ្មែរបានទាក់ទងជាមួយអ្នកផ្សាយសាសនាគ្រីស្ទកាតូលិកនិងអេស្ប៉ាញ ព្រះអង្គតែងបានផ្តល់ទេយ្យទានជាអង្ករដល់ពួកអ្នកទាំងនោះដែលរស់នៅក្នុងប្រទេសខ្មែរផង និងដល់អង្គការផ្សព្វផ្សាយសាសនានៅ Malacca ផង ៗ

— **ពាណិជ្ជកម្ម** : ដោយសារទន្លេមេគង្គជាផ្លូវគមនាគមន៍មួយយ៉ាងសំខាន់ ក្រុងចតុមុខក៏ក្លាយទៅជាកំពង់ផែមួយដែលមានឈ្មួញបរទេសចេញចូលលក់ដូរតាំងពីរជ្ជកាល **ព្រះបរមរាជាទី ២ ចៅពញាយ៉ាត** ម្ល៉េះ ៗ ដល់មកសម័យព្រះ **ចន្ទរាជា** និង **ស្តេចគន** ច្បាំងគ្នាគេឃើញមេទាំងពីរនេះសុទ្ធតែបានបញ្ជាអោយដឹកទំនិញយកទៅលក់ឯបរទេស ហើយទិញយកគ្រឿងសស្ត្រាវុធមកវិញ ៗ តាមឯកសារអឺរ៉ុប(19) ព្រះ **បរមរាជាទី៤** កាលដែលទាក់ទងជាមួយជនជាតិអឺរ៉ុបនោះ ព្រះអង្គទ្រង់មានសង្ឃឹមថាសកម្មភាពខាងជំនួញនឹងកើតមានឡើងបន្ទាប់ពីការមកដល់របស់ពួកបព្ពជិត តែព្រះអង្គពុំបានទទួលផលល្អក្នុងវិស័យនេះឡើយ ៗ ក៏ប៉ុន្តែ បើតាមប្រភពដដែលនោះ ឃើញថាក្នុងរជ្ជកាលក្រោយ ៗ មកទៀតមានឈ្មួញបរទេសជាច្រើនគឺ ចិន ជប៉ុន ជ្វា បានមកធ្វើជំនួញក្នុងប្រទេសខ្មែរតាមផ្លូវទឹក ជាពិសេសនៅកំពង់ផែចតុមុខនេះឯង ដែលជាផ្សារលក់គ្រឿងទេស ភ្លុកដំរី ស្បែកសត្វ ជ័រកំញាន ។ល។

www.budinst.gov.kh www.elibraryofcambodia.org

— **សិប្បកម្ម និង ឧស្សាហកម្ម** : ឧស្សាហកម្មដែលសំខាន់ជាងគេទំនងជាការស្លដែកនេះឯង ។ ឧស្សាហកម្មប្រភេទនេះមានសន្ទុះខ្លាំងដោយមានការទំនុកបំរុងពីព្រះ **ចន្ទរាជា** ប៉ុន្តែរបរប្រើដែកជាវត្ថុធាតុដើម មានរបរដំដែកជាដើម ឃើញមានសកម្មភាពរួចទៅហើយ តាំងពីរជ្ជកាលព្រះបាទ **ចៅពញាយ៉ាត** ម្ល៉េះ ។

## ៣– ជំនឿនិងទំនៀមទំលាប់.—

ទោះបីនៅសម័យនោះ ព្រះពុទ្ធសាសនាបានជ្រួតជ្រាបចូលក្នុងសង្គមខ្មែរហើយក៏ដោយ ក៏ជនជាតិខ្មែរយើងពុំបានលះបង់ចោលនូវជំនឿដើមរបស់ខ្លួនឡើយ ។. យ៉ាងណាមិញ តាំងពីព្រះរាជាដល់ប្រជារាស្ត្រតូចតាចគ្រប់ជាន់ថ្នាក់សុទ្ធតែជឿលើខ្មោច បិសាច អារក្ស អ្នកតា បង់បត់ ។ល។ រាជពង្សាវតារខ្មែរបាននិយាយថាកាលកសាងរាជធានីចតុមុខ ព្រះ **បរមរាជាចៅពញាយ៉ាត** ទ្រង់ចាត់អោយសាង **ខ្លាចមឿង** ( អ្នកតាចាំស្រុក ) មួយ នៅខាងមុខ **វត្តឧណ្ណាលោម** និងរូបអ្នកតា បង់បត់ជាច្រើនកន្លែងទៀត ទុកជាទ្វារព្រះនគរ ជាបង្ការសឹកសង្គ្រាមពីប្រទេសជិតខាង ។ **តាពេជ** ដែលបានបូជាជីវិត ដើម្បីទៅកែនទ័ពបិសាច មកជួយយកអាសាព្រះ **ចន្ទរាជា** ក្នុងគ្រាច្បាំងជាមួយ **ស្តេចកន** នោះ បានក្លាយទៅជា**អ្នកតា**១រូប ដែលប្រជារាស្ត្រខ្មែរបានធ្វើពិធីគោរពបូជា ជារៀងរាល់ឆ្នាំ ។

ក្នុងវិស័យជំនឿលើខ្មោចនេះ គេជឿទៀតថា ដើម្បីកសាងទំនប់ទឹកឬព្រះវិហារអោយជាប់ល្អ គេត្រូវយកអ្នកទោសអស់ជីវិតទៅកប់ក្រោមទំនប់នោះ ឬគេត្រូវយកខ្មោចទៅទ្រាប់បាតសសរព្រះវិហារ ។

ម្យ៉ាងទៀត ខ្មែរនៅគ្រប់ជាន់ថ្នាក់សុទ្ធតែយល់ថា ការយល់សប្តិជាការប្រាប់អោយដឹងមុនពីហេតុការណ៍ដែលបំរុងនឹងកើតឡើង ម្ល៉ោះហើយគេតែងតែអោយហោរទស្សន៍ទាយមើលមិនដែលខាន ជាពិសេសក្នុងមជ្ឈដ្ឋានបរមរាជវាំងដែលពួកហោរាជាមន្ត្រីមួយប្រភេទចាំតែបំពេញមុខការខាងទស្សន៍ទាយនេះឯង ។

ក្រៅពីនេះ ខ្មែរនៅមានជំនឿមាំលើពាក្យសម្បថដែលគេយល់ថា មានលក្ខណៈ

www.budinst.gov.kh www.elibraryofcambodia.org

សក្តិសិទ្ធិណាស់ ។ ពួកនាម៉ឺនសព្វមុខមន្ត្រី ពួកសេនាទាហានសុទ្ធតែត្រូវផឹកទឹកពិភទ្ធ-សច្ចាជារៀងរាល់ឆ្នាំ ជាការសំដែងភក្តីភាពរបស់ខ្លួនចំពោះព្រះមហាក្សត្រ ។

រាជពង្សាវតារខ្មែរបានកត់ទុកនូវពិធីដាច់ខាតមួយទៀតមិនលាប់យ៉ាងសំខាន់ពីរ គឺពិធី **បុណ្យចូលឆ្នាំថ្មី** និងពិធី **បុណ្យអុំទូក** ។

**បុណ្យចូលឆ្នាំ** ទំនងជាពិធីបុណ្យសំខាន់ជាងគេ ពីព្រោះទោះបីមានកើតចម្បាំងគ្នាឯងក៏ដោយ ក៏គេត្រូវផ្អាកចម្បាំងនោះសិនដើម្បីបានរៀបចំពិធីបុណ្យនោះ ។ ឯពិធី **បុណ្យអុំទូក** ជាឱកាសមួយដែលគេធ្វើការប្រណាំងទូក លយកន្ទោងធំ ទូកប្រទីបនិងអុជកាំជ្រួច ។ គេថាធ្វើដូច្នេះ គឺដើម្បីថ្វាយទៅព្រះចន្ទ្រមកែវដែលគង់នៅពិភពនាគ ឯការអុជកាំជ្រួចនោះគឺថ្វាយទៅចូឡាមណីចេតិយ ដែលតំកល់ព្រះចន្ទ្រមកែវនៅស្ថានត្រៃត្រឹង្ស (27) ។

## ខ – វប្បធម៌ .–

### ១ – អក្សរ–ភាសា–អក្សរសិល្ប៍ .–

ក្នុងសម័យលង្វែកនេះ ចាប់តាំងពីដើម ស.វ. ទី ១៤ រៀងមក គេពុំឃើញមានសិលាចារឹកនៅប្រទេសខ្មែរទៀតទេ ។ លុះដល់មករជ្ជកាលរបស់ព្រះ **ចន្ទរាជា** ទោះបីពេលនោះរាជធានីពិតប្រាកដតាំងនៅក្រុងលង្វែកក៏ដោយ ក៏ព្រះរាជាខ្មែរតែងនិយមនាំពួកបរិវារទៅគង់នៅតំបន់អង្គរជាហូរហែរៀងមក ។ គឺក្នុងសម័យនោះហើយដែលខ្មែរបានកសាងសិលាចារឹកឡើងវិញ ។ សិលាចារឹកទាំងនោះ គេបានចារទុកនៅប្រាសាទ **នគរវត្ត** ជា ៣ អន្លើ គឺនៅទីដែលហៅថា **ព្រះពាន់** ត្រង់ដែលមានព្រះពុទ្ធរូបច្រើននោះខ្លះ នៅថ្នាក់លើបំផុតដែលហៅថា **បាកាណ** នោះខ្លះ និងនៅ**ព្រះវបៀង**ថ្នាក់ក្រោម ។ សិលាចារឹកទាំងនោះមានទាំងអស់៤០ផ្ទាំង មានចុះកាលកំណត់ពីគ.ស.១៥៦៥ដល់១៧៤៦ ម៉្យាងទៀតសករាជដែលប្រើគឺជា**មហាសករាជ** ។ សេចក្តីក្នុងសិលាចារឹកនោះនិយាយពីរឿង


www.budinst.gov.kh www.elibraryofcambodia.org

ធ្វើបុណ្យផ្សេងៗ គឺប្រោសខ្ញុំអោយរួចជាអ្នកជា បំបួសមនុស្ស ដើលាបំណន់ សាងព្រះ សាងពិតាន និងថ្វាយរបស់ជាពុទ្ធបូជា ។ល។ ជារបស់ស្តេចខ្លះ មន្ត្រីខ្លះ រាស្ត្រខ្លះ (28) ។

ចំពោះសេចក្តីក្នុងសិលាចារឹកទាំងនោះ អ្នកស្រាវជ្រាវខ្មែរមួយក្រុមបានបន្ថែមសេចក្តីទៀតថា : "សេចក្តីអស់នេះ ជាពាក្យរបស់អ្នកចាលចាញ់ ហើយមានទីពឹងទីរលឹកចំពោះព្រះរតនត្រ័យប៉ុណ្ណោះ ជាអ្នកសុខចិត្តព្រមទទួលសេចក្តីលំបាកវេទនាដោយយល់ថាជាផលនៃកម្មអាក្រក់ដែលខ្លួនបានប្រព្រឹត្តមកហើយក្នុងអតីតជាតិ តែពុំបានអស់កម្លាំងសេចក្តីប្រឹងប្រែងឡើយ តែងខំសន្សំបុណ្យកុសលដើម្បីសេចក្តីចំរើនដល់ខ្លួននឹងដល់ប្រទេស" (29) ។

ភាសាដែលប្រើក្នុងសិលាចារឹកទាំងនោះជាភាសាខ្មែរធម្មតាក្នុងសម័យកណ្តាល មានពាក្យពេចន៍បុរាណលាយឡំខ្លះដែរ តែយើងអាចមើលយល់សេចក្តីបានច្រើន ។

ជាការគួរអោយស្តាយពេកណាស់ **សាស្ត្រាស្លឹករឹត** និង **ក្រាំង** ក្នុងសម័យដែលយើងលើកយកមកសិក្សានេះត្រូវវិនាសបាត់បង់ខ្ទេចខ្ទីអស់ជាច្រើន ។ នេះទំនងជាមកពីសត្រូវជិតខាងកាលដែលចូលមកលុកលុយស្រុកទេសយើង គេនាំគ្នាដឹកជញ្ជូនយកទៅទុកជាទ្រព្យសម្បត្តិគេផ្ទាល់ទៅ ហើយម្យ៉ាងទៀតប្រហែលជាត្រូវភ្លើងឆេះក្នុងគ្រាមានសង្គ្រាមនោះហើយ ។ ប្រសិនបើមាននៅសេសសល់ គឺនៅតាមវត្តអារាម តែច្រើនពុំមានឈ្មោះអ្នកនិពន្ធ ។ ចំពោះរឿងនេះមានមតិខ្លះយល់ថា មកតែពីរបបគ្រប់គ្រងធ្វើអោយអ្នកនិពន្ធខ្លាចរអាពុំហ៊ានបញ្ចេញឈ្មោះរបស់ខ្លួនអោយអ្នកផងដឹងស្គាល់ទេ តែមានមតិខ្លះទៀតយល់ថា មកពីអ្នកចារមានទំលាប់អាក្រក់លុបបំបាត់ឈ្មោះអ្នកនិពន្ធចោល ហើយតាំងខ្លួនឯងជាអ្នកនិពន្ធជំនួសទៅវិញ ។

ស្នាដៃមួយដែលគេស្គាល់ឈ្មោះអ្នកនិពន្ធពិតប្រាកដគឺ **ល្បើកអង្គរ** និពន្ធដោយ **អ្នកផាំង** ក្នុង គ.ស. ១៥៩៨ ជាកាព្យនិយាយពីការកសាងប្រាសាទ **អង្គរវត្ត** តាមរបៀបរឿងទេពនិទាន ។ ប៉ុន្តែអ្នកស្រាវជ្រាវខ្មែរខ្លះបានដាក់កាលកំណត់រឿងនេះទិតមកមុខបន្តិចទៀត គឺនៅ គ.ស. ១៦០៩ វិញ (30) ។

www.budinst.gov.kh  www.elibraryofcambodia.org

## ២– សាសនានិងលទ្ធិផ្សេង ៗ .–

### ២.១– ព្រះពុទ្ធសាសនា .–

ព្រះពុទ្ធសាសនាបែបហីនយានប្រើភាសាបាលីដែលបានចូលមកប្រតិស្ឋានក្នុងប្រទេស ចាប់តាំងពីបដិវត្តន៍នាយត្រសក់ផ្អែមមក បានចាក់រឹសគល់យ៉ាងជ្រៅចូលក្នុងសង្គមខ្មែរ ៗ ជនជាតិខ្មែរគ្រប់ស្រទាប់ ចាប់តាំងពីព្រះមហាក្សត្រដល់ប្រជារាស្ត្រតូចតាចបំផុតសុទ្ធតែមានជំនឿមុតមាំលើព្រះពុទ្ធសាសនាដែលគេបានចាត់ទុកជាជាទីពឹងទីរលឹក ទោះបីគេពុំបានលះបង់ចោលជំនឿដើមរបស់គេលើខ្មោច បិសាច អារក្ស អ្នកតា បង់បត់ក៏ដោយ ៗ សង្គមខ្មែរលែងផាកទៅរកសាសនាព្រាហ្មណ៍ទៀតហើយ ៗ ប៉ុន្តែនៅក្នុងព្រះបរមរាជវាំង គេឃើញនៅមានពួក **បាគូ** ( ព្រាហ្មណ៍ ) ដែលគ្រាន់តែមាននាទីថែរក្សាព្រះ **ខាន់រាជ្យ** ព្រះ **សំពែងជ័យ** និង **គ្រឿងបញ្ចក្សត្រ** និងរៀបចំធ្វើព្រះរាជពិធីផ្សេង ៗ តែប៉ុណ្ណោះ ៗ

ក្នុងសម័យនោះ ចំនួនវត្តអារាមបានកើនឡើងជាលំដាប់ ៗ ព្រះ **មហាថេរ** ដែលមាននាទីមើលការខុសត្រូវលើការរៀបចំខាងសាសនា និងលើវត្តអារាមនៅក្នុងខេត្តនីមួយៗ លែងមានលទ្ធភាពបន្តការគ្រប់គ្រងនោះតទៅទៀតហើយ ៗ ដោយហេតុនោះ **សម្តេចព្រះសង្ឃរាជ** ដោយមានការព្រមព្រៀងជាមួយ **រាជាគណៈ ហានានុក្រម** និងសហការីទាំងអស់ ទ្រង់បានស្នើទៅព្រះរាជា សូមអោយមានការកែប្រែដែលមានបែបផែនដូចតទៅ :

ព្រះមហាថេរមួយអង្គ ១ ពីមុន ឥឡូវត្រូវតែងតាំងជា **មេគណ** ទទួលការខុសត្រូវលើគណៈសង្ឃក្នុងខេត្តនីមួយ ៗ ៗ ចំណែកឯ **រាជាគណៈ** ទាំង ៤ សំរាប់ និង **សម្តេចព្រះសង្ឃរាជ** ជាអ្នកត្រួតពិនិត្យ និងសំរេចកិច្ចការសាសនាទាំងពួងក្នុងព្រះរាជាណាចក្រទាំងមូល (31) ៗ

គួរគប្បីបញ្ជាក់ថា **រាជាគណៈ** ឬមន្ត្រីសង្ឃទាំង ៤ សំរាប់ ត្រូវចែកជា សំរាប់ឯក ទោ ត្រី ចត្វា ដូចមន្ត្រីជាន់ខ្ពស់ខាងអាណាចក្រដែរ :

— សំរាប់ឯក ជារាជាគណៈ របស់ក្សត្រិយ៍ទ្រង់រាជ្យ

www.budinst.gov.kh www.elibraryofcambodia.org

— សំរាប់ទេវៈ ជារាជាគុណៈ របស់ក្សត្រិយ៍នគរយោរាជ

— សំរាប់ត្រី ជារាជាគុណៈ របស់សម្តេចព្រះមហាឧបរាជ

— សំរាប់ចត្វា ជារាជាគុណៈ របស់សម្តេចព្រះវររាជជននី ។

គួរគប្បីបញ្ជាក់ម្យ៉ាងទៀតថា ព្រះសង្ឃនិងវត្តអារាមក្នុងសម័យនោះមានមុខងារយ៉ាងសំខាន់ក្នុងវិស័យសង្គមកិច្ច ។ យ៉ាងណាមិញ ព្រះសង្ឃពុំមែនគ្រាន់តែជាស្រែបុណ្យប៉ុណ្ណោះទេ តែព្រះអង្គជាអ្នកអប់រំ ផ្តល់ចំណេះវិជ្ជាគ្រប់បែបយ៉ាង គិតទាំងចំណេះខាងមុខរបរជនដល់ពុទ្ធបរិស័ទជើងវត្ត ។ នេះហើយជាកត្តាមួយធ្វើអោយរាស្ត្រខ្មែរកាន់តែជក់ចិត្តលើព្រះពុទ្ធសាសនាថែមទៀត ។ ពួកយុវជនតែងនិយមចូលទៅបួសអស់មួយរយៈកាលហើយសឹកមកវិញ ទើបអ្នកផងគេចាត់ទុកជាមនុស្សពេញលក្ខណៈ មានចំណេះចេះដឹង ស្គាល់ខុស ស្គាល់ត្រូវ ។ល។

## ២.២– សាសនាគ្រិស្ត .–

ជនជាតិអឺរ៉ុបមានពួកព័រទុយហ្គាល់ និង អេស្ប៉ាញ ជាដើមបានប៉ុនប៉ងយកសាសនាគ្រិស្តមកផ្សាយក្នុងប្រទេសខ្មែរចាប់ពីពាក់កណ្តាលទី២នៃស.វ.ទី១៦ ។ ទោះបីព្រះរាជាខ្មែរសព្វព្រះទ័រុទធំបានទទួលរាក់ទាក់និងផ្តល់ជំនួយផ្សេង ៗ ជាច្រើនដល់អ្នកផ្សាយសាសនា ក្នុងបំណងអោយពួកបព្វជិតជួយធ្វើអន្តរាគមន៍សុំជំនួយទ័ពមកទប់ទល់នឹងសត្រូវខាងក្នុង និង ខាងក្រៅប្រទេសក៏ដោយ ក៏ការប៉ុនប៉ងផ្សាយសាសនាថ្មីនេះតែងទទួលបរាជ័យគ្រប់ពេលវេលា។

បព្វជិត Gaspar da Cruz ដែលជាអ្នកផ្សាយសាសនាជាតិអឺរ៉ុបទី ១ នៅប្រទេសខ្មែរបានទទួលស្គាល់ភាពថាមានខ្មែរតែម្នាក់គត់ (?) ដែលបានចូលសាសនាគ្រិស្ត ហើយជននោះបានទទួលមរណភាពហើយទៅទៀត ។ បព្វជិតអង្គនេះបានបញ្ជាក់បន្ថែមទៀតថា ក្រោយមកពួកអ្នកផ្សាយសាសនាជាតិអឺរ៉ុបមានទំនាស់ជាមួយពួកព្រាហ្មណ៍នៅក្នុងវាំង ។ ខនលោកផ្ទាល់ក៏បានធ្វើអោយពួកព្រាហ្មណ៍អាក់អន់ចិត្ត ដោយលោកបានពន្យល់ដល់ប្រជារាស្ត្រថា "ព្រះអាទិទេពរបស់ពួកនេះពុំបានបង្កើតមេឃនិងដីទេហើយអាទិទេពនោះជា

www.budinst.gov.kh www.elibraryofcambodia.org

មនុស្សកាចសាហាវនឹងជាអ្នកធ្វើបាបគមទៀតផង" ។ បណ្ឌិត Cacega បានកត់ទុកថា បណ្ឌិត Sylvestre បានលាងបាបអោយបានផ្ទុកអ្នកទោសនិងជនបរទេស មានចិន ជប៉ុន ជ្វា តែគ្មានខ្មែរម្នាក់សោះ"

គេសង្កេតឃើញថា ការប៉ុនប៉ងបង្កើតអង្គការផ្សាយសាសនាគ្រិស្តនៅប្រទេសខ្មែរ ត្រូវបានទទួលបរាជ័យជាបន្តបន្ទាប់គ្នាគឺ

— ការប៉ុនប៉ងទី ១ នៅក្នុងរជ្ជកាលព្រះ **សុត្ថាធិ ១**

— ការប៉ុនប៉ងទី ២ នៅក្នុងរជ្ជកាលព្រះ **រាមជើងព្រៃ**

— ការប៉ុនប៉ងទី ៣ នៅក្នុងរជ្ជកាលព្រះ **បរមរាជាទី ៥ ចៅពញាតន់**

— ការប៉ុនប៉ងទី ៤ នៅក្នុងរជ្ជកាលព្រះ **កែវហ្វាចៅពញាញោម** (19) ។

## ២.៣- លទ្ធិបុគ្គលនិយម.-

នៅសម័យអង្គរ យើងបានឃើញថាចាប់តាំងពីស.វ.ទី ៩ ដល់ស.វ.ទី ១២ គេមានកស្តុតាងជាច្រើនដែលបង្ហាញថា ព្រះរាជាខ្មែរបានកាន់លទ្ធិបុគ្គលនិយមស្របពេលជាមួយនិងលទ្ធិទេវរាជ ។ នៅសម័យដែលយើងលើកយកមកសិក្សានេះ រាជពង្សាវតារផ្តល់កស្តុតាងថា លទ្ធិនេះនៅតែមានសកម្មភាពបន្តទៅទៀត ។ ប្រភពនេះបានអោយពត៌មានថា ព្រះ **ចន្ទរាជា** បានសាងព្រះវិហារមួយនៅក្នុងខេត្តលង្វែក រួច"ទ្រង់ត្រាស់អោយសាងព្រះពុទ្ធរូបឈើសួងព្រះអង្គ មួយព្រះអង្គ កំពស់ស្មើព្រះអង្គ ជាសណ្ឋានកណ្តាល ។ ទ្រង់អោយសាងព្រះពុទ្ធរូបឈើមួយព្រះអង្គទៀត សួងព្រះអគ្គមហេសីព្រះ **គគចតីស្រីនាងធីតា** កំពស់ស្មើព្រះអង្គសណ្ឋានឈរ ទ្រង់សាងព្រះពុទ្ធរូបឈើមួយព្រះអង្គទៀត សួងព្រះអង្គ **សម្តេចព្រះស្រីធ្មោធិក្យត្រី** ជាសម្តេចព្រះរាជបុត្រ កំពស់ស្មើព្រះអង្គសណ្ឋានឈរទៀត" (32) ។

ប្រភពរាជពង្សាវតារខ្មែរ បាននិយាយទៀតថា កាលដែល **សម្តេចចៅហ្វាជុំ ខំណាចណេទីនាវ៉ែសោភ័ណកែវ** ដែលត្រូវជាបិតាមាតាសម្តេចព្រះអគ្គមហេសី ស្រិធេព

www.budinst.gov.kh www.elibraryofcambodia.org

ធីតា ព្រះបរមរាជាទី ៤ "ទ្រង់ត្រាស់បង្គាប់អោយជាងយកថ្មល្អិតល្អ មកសាងជារូបសម្តេចចៅហ្វាជុំ ១ ចំណាចទេពីណាវីសោភ័ណវៃ ១ តំកល់រូបទាំង២នោះក្នុងសាលាមួយទុកអោយសម្តេចព្រះអគ្គមហេសគោរពរៀងមក» (33) ។

## ៣– សិល្បៈ –

សិល្បៈខ្មែរច្រើនមានទំនាក់ទំនងជិតស្និទ្ធជាមួយនឹងសាសនា ។ ដោយហេតុថានៅសម័យនោះ ខ្មែរមានជំនឿស៊ប់តែទៅលើព្រះពុទ្ធសាសនា សិល្បៈខ្មែរក៏មានលក្ខណៈទោរទន់ទៅតាមសាសនានោះដែរ ។

សេចក្តីដកស្រង់តទៅនេះ អាចបង្ហាញអោយឃើញនូវប្រធាននិងបច្ចេកទេសៈប្រើក្នុងវិស័យសិល្បៈស្ថាបត្យកម្មនិងចម្លាក់ក្នុងសម័យនោះ :

« អស់មុខមន្ត្រីមេការទាំងឡាយ កែនកូនជាងសាងព្រះមហាស្តូប ព្រះចេតិយធំនិងព្រះចេតិយតូចជាបរិវារ រចនាដោយថ្ម តកំដែងខ្វាក់ខ្វែង អោយជាច្រើនបែបច្រើនយ៉ាងសាងព្រះវិហារមានត្រីស្ងូលកំពូលប្រាំ ។ តាមកំផែងនិងព្រះលានព្រះអារាមនោះ សឹងឆ្លាក់ឆ្មៅជាភាពមនុស្ស គ្រុឌនាគ សត្វមហិង្សា គោក្របី និងក្បាច់ភ្ញីផ្កា វល្លិ រចនាវៃថ្លាប្រពៃ ហើយសាងព្រះពុទ្ធរូបបន្ទំនិងសណ្ឋិតជាច្រើនអង្គ មានសីមា និងរបៀងរោងទងក្លោងទ្វារកំពូលមុខព្រហ្មសុទ្ធសឹងឆ្លាក់ឆ្មៅដោយថ្ម កកំដែងខ្វាតខ្វែង ជុំវិញសឹងថ្មបាយអថ្មត្រាមក្រាលថ្មល្អិត ហើយមានរូបសិង្ហគោររាជសីហ៍ ដំរីយក្សដាក់គ្រប់ទ្វារ » (34) ។

ក្នុងវិស័យសិល្បៈដដែលនេះ នាងកញ្ញា Madeleine Giteau បានចាប់អារម្មណ៍យ៉ាងខ្លាំងលើព្រះពុទ្ធរូបទ្រង់គ្រឿងឆ្លាក់ពីឈើ ឬពីថ្មដែលមានតំកល់នៅក្នុងប្រាសាទអង្គរវត្តសព្វថ្ងៃ ។ នាងយល់ថាព្រះពុទ្ធរូបទាំងនោះអាចបង្ហាញអោយឃើញនូវរចនាបថខាងឡាយនៃសិល្បៈខ្មែរក្នុងសម័យក្រោយអង្គរ (35) ។

* *

www.budinst.gov.kh www.elibraryofcambodia.org

# ចំពូកទី១២

---

# ប្រទេសខ្មែរនៅសតវត្សទី១៧និងទី១៨: វិបត្តិក្នុងរាជវង្សខ្មែរ និងការជ្រៀតជ្រែករបស់យួន

មកដល់សតវត្សទី ១៧ ប្រទេសខ្មែរបានបើកទំព័រប្រវត្តិសាស្ត្រថ្មីមួយដែលពោរពេញទៅដោយមេរៀនផ្លូវចិត្ត សំរាប់អោយបច្ចាជនខ្មែរយកទៅត្រិះរិះពិចារណារកហេតុផល ហើយទាញយកការពិសោធន៍ពីសកម្មភាពរបស់ដូនតាខ្លួន ក្នុងបំណងធ្វើយ៉ាងណាកុំអោយធ្លាក់ទៅក្នុងរៀងចាស់ដដែលទៀត ។

## ក–ប្រតិកម្មប្រឆាំងសៀមនិងចំណងមេត្រីភាពជាមួយយួន.–

### ១–ព្រះបរមរាជាទី ៨ ស្រីសុរិយោពណ៌ (១៦០៣-១៦១៨).–

រួចមកហើយ យើងបានឃើញថា ប្រភពអឺរ៉ុបនិងប្រភពខ្មែរបានផ្តល់ពត៌មានប្លែកគ្នាបន្តិចអំពីការដែលព្រះ **ស្រីសុរិយោពណ៌** វិលត្រឡប់ចូលមាតុប្រទេសវិញ ។ ប៉ុន្តែរាជពង្សាវតារខ្មែរទាំងអស់បានមិយៈយស្រុបគ្នាថា ដែលព្រះ**ស្រីសុរិយោពណ៌**បានធ្វើមាតុភូមិនិវត្តន៍នោះ គឺដោយសារមោះសំណូមពរពីព្រះអយ្យការបស់ព្រះអង្គចំពោះព្រះចៅសៀម



www.budinst.gov.kh www.elibraryofcambodia.org

ក្នុងបំណងអោយស្តេចអង្គនេះបានមកគ្រប់គ្រងអាណាប្រជារាស្ត្រជាជំនួស **ព្រះកែវហ្វា ចៅពញាញោម** ដែលជាស្តេចមិនប្រកបដោយទសពិធរាជធម៌ ។

កាលដែលព្រះ **ស្រីសុរិយោពណ៌** យាងមកដល់ប្រទេសស្យាម ព្រះអង្គយាងទៅគង់នៅ **កោះស្លាកែត** ( ទល់មុខទីជ្រោយអំពិលសព្វថ្ងៃ ) ។ **សម្តេចព្រះទេពីក្សត្រី សម្តេចព្រះកែវហ្វា** និងព្រះរាជវង្សានុវង្សក៏បានយាងទៅគង់នៅមូលនៅទីនោះដែរ ។

ឯកសារខ្មែរខ្លះនិយាយថា ព្រះ**ស្រីសុរិយោពណ៌** ទ្រង់បានបញ្ជាអោយលើកទ័ពទៅបង្ក្រាបស្រុកតូចស្រុកធំ ខ្លះក៏ព្រមចុះចូលខ្លះក៏នៅ ។ ចំណែកឯ**កែវព្រះភ្លើង** ដែលបានបះបោរតាំងពីរាជ្យព្រះ**កែវហ្វាចៅពញាញោម**នោះ ត្រូវតេជោ **មាស** លើកទ័ពទៅចាប់បាន ។

តមក ព្រះ**ស្រីសុរិយោពណ៌** ទ្រង់អោយនាំសារទៅក្រុង**ស្រីអយុធ្យា** ទូលព្រះចៅសៀម សូមព្រះរាជបុត្រទាំងពីរ គឺព្រះ**ជ័យជេដ្ឋា** និងព្រះ **ឧទ័យ**អោយត្រឡប់មកប្រ-ទេសខ្មែរវិញ ។ ព្រះចៅសៀមក៏បានយល់ព្រមតាមសំណើនេះ ។

ព្រះ **ស្រីសុរិយោពណ៌** ទ្រង់បានបញ្ជាព្រះរាជបុត្រទាំងពីរអង្គអោយលើកទ័ពចេញប្រាមប្រាបអស់ស្រុកតូចធំដែលមិនទាន់ចុះចូល ។ គួរគប្បីពញ្ញាក់ថាការដែលស្រុកទេសធ្លាក់ទៅក្នុងស្ថានភាពវឹកវរដូច្នេះ គឺមកពីអំណាចកណ្តាលក្នុងរជ្ជកាលមុនៗមានភាពទន់ខ្សោយ ។ ម្ល៉ោះហើយ ពួកស្តេចត្រាញ់ក៏តាំងខ្លួនជាធំរៀងៗខ្លួន ដូចជា **ព្រះរាមបាធី ព្រះរាមត្រាំង ព្រះរាមក្បួងឃ្មុំ ព្រះរាមបាត្ត** ។

នៅឆ្នាំខាលសំរិទ្ធិស័ក **សម្តេចព្រះកែវហ្វា** ដែល **សម្តេចទេពីក្សត្រី** បានបន្ទយចេញពីការគ្រងរាជសម្បត្តិនោះ ដោយមានព្រះទ័យគុំគួន បានអោយសំគ្របក្សពួកមកបំរុងធ្វើគត់ព្រះ **ស្រីសុរិយោពណ៌** តែពុំបានសំរេចហើយត្រូវព្រះបិតុលាចាប់បានយកទៅប្រ-ហារជីវិតតាមទោសប្រពៃណី ។

នៅគ.ស. ១៦១៣ ព្រះ **ស្រីសុរិយោពណ៌** ទ្រង់បានទទួលប្រាព្ធាភិសេកឡើងសោយរាជសម្បត្តិដោយមានព្រះនាមសំរាប់រាជ្យថា **សម្តេចព្រះរាជឱង្ការព្រះស្រី**

www.budinst.gov.kh www.elibraryofcambodia.org

សុរិយោពណ៌បរមរាជា (បរមរាជាទី៨) ។ តាមឯកសារខ្លះថាព្រះអង្គមានព្រះនាមសំរាប់រាជ្យថា ព្រះបាទសម្តេចព្រះបរមរាជាធិរាជរាមាធិបតី (36) ។

ក្នុងរជ្ជកាលរបស់ព្រះអង្គ ព្រះបរមរាជាស្រីសុរិយោពណ៌ ទ្រង់ព្រះភូសាសៀមក្រោយ (អាវដាយ) បែបថៃ ហើយទ្រង់បញ្ញត្តិអោយបណ្តាមុខមន្ត្រីធំតូច នាយមហាត នាយពលធ្វើសៀគ្រោយពាក់ម៉ងបានរុំសំពត់សៃ្បថ្ងចកាលទៅក្រុងលង្វែកទេ រួចព្រះអង្គទ្រង់បញ្ញត្តិអោយខ្ចូលអោយធ្វើយថា ព្រះស្រីសពេជ្ញសម្តេចនរនាថ ហើយព្រះអង្គបញ្ញត្តិអោយបណ្តាខុនណាងអ្នកស្រែហៅថា ឪពុក អោយហៅសម្តេចព្រះអគ្គមហេសីថា ម៉ែ បណ្តាស្តេចក្រៅពីស្តេចទ្រង់រាជ្យថា ព្រះបាទអម្ចាស់ (36) ។

យើងឃើញថាព្រះ បរមរាជាស្រីសុរិយោពណ៌ ទ្រង់បានធ្វើសន្តិភាពអោយប្រទេសបានស្ងប់ទាបឡើងវិញ កំប៉ុន្តែប្រទេសខ្មែរត្រូវទទួលឥទ្ធិពលយ៉ាងខ្លាំងពីពួកសៀម ។ ប្រតិកម្មមួយក៏បានផ្ទុះឡើង ប្រឆាំងនឹងការទទួលយកទំនៀមទំលាប់សៀមមកបង្ខំអោយខ្មែរប្រើ ជាហេតុបណ្តាលអោយព្រះរាជាទ្រង់ដាក់រាជ្យនៅគ.ស. ១៦១៨ ថ្វាយទៅព្រះរាជបុត្រច្បងគឺព្រះ ជ័យជេដ្ឋា ។

## ១.១– ចំណាក់ចំនងជាមួយយួន.—

ប៉ុន្តែគួរគប្បីបញ្ជាក់ផងថា ទោះបីព្រះអង្គទ្រង់បានបញ្ចូលឥទ្ធិពលសៀមមកក្នុងប្រទេសខ្មែរក៏ដោយ ក៏ព្រះ បរមរាជាស្រីសុរិយោពណ៌ ទ្រង់បាននឹកគិតទៅដល់អនាគតរបស់ប្រទេសជាតិដែរ ។ ព្រះអង្គទ្រង់បានឈ្វេងយល់ថា ឥទ្ធិពលរបស់សៀមមកលើប្រទេសព្រះអង្គនោះមានទម្ងន់ខ្លាំងក្លាណាស់ ។ ម្ល៉ោះហើយ ដើម្បីរំដោះប្រទេសអោយរួចផុតពីក្រញាំឥទ្ធិពលសៀមនោះព្រះអង្គពុំបានធ្វើការទាក់ទងជាមួយនគរជាតិអឺរ៉ុបដូចព្រះរាជាមុនៗទៀតទេ តែព្រះអង្គបានទៅចងស្ពានមេត្រីជាមួយយួនម្តងវិញ ដោយទ្រង់មានបំណងយកឥទ្ធិពលយួននេះទៅទប់ទល់នឹងឥទ្ធិពលសៀម

គួរគប្បីជ្រាបថា ក្រោយពីបានរំដោះខ្លួនរួចផុតពីទឹមចិនអស់រយៈពេលជាងមួយ

www.budinst.gov.kh www.elibraryofcambodia.org

៣ពាន់ឆ្នាំមក ( ១១១ មុន គ.ស-គ.ស. ៩២៣ ) ស្តេចយួនក្នុងរាជវង្ស លី បានផ្តើមការវាយលុកប្រទេស ចាម្ប៉ា ចាប់ពីស.វ. ទី១១ តទៅ ។ នៅគ.ស. ១៤៧០ ស្តេចយួនព្រះនាម ឡេថាញ់តោន ( Lê Thanh Tôn ) ទ្រង់វាយយកបានរាជធានី វិជ័យ របស់ចាមដែលនៅពេលនោះមានពលទាហានស្លាប់ដល់ទៅ ៤០០០០ នាក់ ។ ជោគជ័យដ៏ធំសម្បើមនេះរបស់ជនជាតិយួនបានរុញច្រានត្រំប្រទល់ប្រទេស ចាម្ប៉ា ចុះទ្វាយមកទិសខាងត្បូងទៀតគឺមកដល់ជ្រោយ Varella ។ នៅគ.ស. ១៦០០ ប្រទេសយួនត្រូវបាត់បង់ឯកភាពរបស់ខ្លួន ៖ ទឹកដីត្រូវបែងចែកជាពីរ ខាងជើងជារបស់រាជវង្ស ឡេ (Lê) ដែលមានពួកស្តេចត្រាញ់ ទ្រិញ (Trinh) ជាអ្នកគាំទ្រ ខាងត្បូងត្រូវបានទៅក្នុងស្តេចត្រាញ់ ង្វៀន (Nguyên) ។ ប៉ុន្តែ ទោះបីមានវិបត្តិផ្ទៃក្នុងក៏ដោយ ក៏ពួក ង្វៀន បានបន្តការវាយដណ្តើមយកទឹកដីប្រទេស ចាម្ប៉ា ទាល់តែអស់រលីង ។ ក្នុងក្របខណ្ឌពង្រីកទឹកដីនេះ យួនបានវាយយក ៖

— ភូយេន (Phu-yên) នៅ គ.ស.១៦១១

— ខាញ់ ហ៊ា (Khanh-hoa) នៅ គ.ស.១៦៥១

— ប៊ិញ ធួន (Binh-thuân) នៅ គ.ស. ១៦៩៣

ដូច្នេះ យើងឃើញថានៅស.វ.ទី ១៧ នេះ យួនបានក្លាយជាមហាអំណាចមួយជាអ្នកនៅជិតខាងរបស់ខ្មែរយើង ។ គឺក្នុងកាលៈទេសៈនោះហើយដែលព្រះបរមរាជាស្រីសុរិយោពណ៌ បានទទួលសម្ពន្ធមេត្រីជាមួយយួនដោយស្តីដណ្តឹងបុត្រីស្តេចយួន ដើម្បីរៀបរាជាភិសេកជាមួយព្រះរាជបុត្រទ្រង់នាម ជ័យជេដ្ឋា ។ តាមរាជពង្សាវតារខ្មែរ ក្សត្រីយួនអង្គនេះមាននាមថា អង្គចូវ ហើយនេះជាព្រឹត្តិការណ៍មួយមានសារសំខាន់ខ្លាំងណាស់ផងតែគួរអោយស្តាយ ! ព្រោះឯកសារយួនពុំមានកត់ត្រារឿងនេះអោយបានច្បាស់លាស់សោះ ។ បើតាមអ្នកប្រវត្តិសាស្ត្រយួនម្នាក់ថា ក្នុងឯកសារមួយឈ្មោះ Liêt Truyên Tiên Biên ត្រង់វគ្គនិយាយពីក្សត្រីបាននិយាយថា ស្តេច ហ៊ីតុង (Hy-Tông) មានបុត្រី ៤ នាក់ ក្នុងចំណោមនោះបុត្រី ២ នាក់គឺនាង ង៉ុក លៀន (Ngoc Liên) និង ង៉ុក វ៉ាញ់

www.budinst.gov.kh www.elibraryofcambodia.org

(Ngoc Danh) គេឃើញមានកត់ត្រាច្បាស់លាស់ពីប្រវត្តិប្ដីនិងកូន ចំណែកឯបុត្រី ២ នាក់ទៀតគឺ **ង៉ុក វ៉ាន់** (Ngoc Van) និង **ង៉ុក ខ្វា** (Ngoc Khoa) គេមិនស្គាល់ច្បាស់ពីប្រវត្តិប្ដីនិងកូនយ៉ាងណាទេ ។ អ្នកប្រវត្តិសាស្ត្ររូបនោះបានចោទសួរទៅទីបញ្ចប់ថា បើដូច្នោះ តើនាងណាមួយត្រូវជាមហេសីរបស់**ជ័យជេដ្ឋាទី ២** ? (37) ។ ប៉ុន្តែបើតាមអ្នកនិពន្ធយួនម្នាក់ទៀត លោកអះអាងថា**ជ័យជេដ្ឋាទី២** បានរៀបរាជាភិសេកជាមួយនាង**ង៉ុក វ៉ាន់** ជាបុត្រីរបស់ស្ដេច**ង្វៀន សៃ វឿង** (Nguyên Sai Vuong) ដែលបានសោយរាជ្យពីគ.ស. ១៦១៣ ដល់ ១៦៣៥ (38) ។ ត្រង់នេះគួរគប្បីបញ្ជាក់ថា នៅតំបន់ **ធួន ហ៊ា** (Thuân hoa) នៅក្រុងវេសម័យនោះ មានស្ដេចមួយអង្គសោយរាជ្យពី១៦១៣ដល់១៦៣៥ពិតមែន ។ ស្ដេចអង្គនេះ នៅមាននាមមួយទៀតថា **ង្វៀន ភុក ង្វៀន** (Nguyên Phuc Nguyên) ហើយពេលឡើងសោយរាជ្យទ្រង់មានព្រះនាមថា **ហ៊ី តុង ហៀន វ៉ាន់ ហ៊ាង ដេ** (Hy - Tông Hiên Văn Hoang-dê) ។ បើដូច្នោះ មហេសីរបស់ **ជ័យជេដ្ឋា** គឺពិតជាបុត្រីរបស់ស្ដេចអង្គនេះហើយ តែយើងមិនហ៊ានសន្និដ្ឋានថា ត្រូវនឹងនាងណាមួយក្នុងចំណោមនាងទាំងពីរ គឺ **ង៉ុក វ៉ាន់** និង **ង៉ុក ខ្វា** ។

មានចំណុចមួយទៀតដែលគួរអោយបញ្ជាក់ដែរថា បើតាមឯកសារយួន(37)គឺ**ជ័យ-ជេដ្ឋា**អង្គឯងទេ ដែលបានទៅស្ដីដណ្ដឹងបុត្រីស្ដេចយួនដោយសង្ឃឹមថានឹងបានការគាំទ្រពីស្ដេចក្រុងវេដើម្បីទប់ទល់នឹងការគំរាមកំហែងរបស់សៀម ។ ការអះអាងនេះ ឃើញថាសមហេតុសមផលគួរជឿបានដែរ ព្រោះរាជាភិសេករវាងព្រះ**ជ័យជេដ្ឋា** និងក្សត្រីយួនបានប្រារព្ធធ្វើឡើងនៅគ.ស.១៦២០ គឺនៅពេលដែលព្រះអង្គទ្រង់បានឡើងសោយរាជ្យបាន២ឆ្នាំហើយ (១៦១៨) ។ ប្រភពដដែលបានបន្ថែមទៀតថា ដែលស្ដេចយួនព្រមលើកបុត្រីថ្វាយ**ជ័យជេដ្ឋា** ព្រោះព្រះអង្គបានគិតវែងឆ្ងាយណាស់ !

**១.២– ទំនាក់ទំនងជាមួយជនជាតិអឺរ៉ុប.-**

ចំពោះទំនាក់ទំនងជាមួយជនជាតិអឺរ៉ុប ខ្មែរបានស្គាល់ជនជាតិអង់គ្លេសជាលើកដំបូង

www.budinst.gov.kh www.elibraryofcambodia.org

នៅគ.ស. ១៦១២ ព្រោះនៅឆ្នាំនោះជនជាតិអង់គ្លេសទី ១ ឈ្មោះ Peter Floris បានធ្វើដំណើរតាមជើងទឹកទន្លេមេគង្គហើយបានមកដល់ក្រុងភ្នំពេញនៅវែកកដា ។ ក៏ប៉ុន្តែ រហូតមកដល់គ.ស. ១៦៥១ ទើបក្រុមហ៊ុនឈ្មោះ English East India Company (ក្រុមហ៊ុនអង់គ្លេសនៅប្រទេសឥណ្ឌាខាងកើត) បានយកចិត្តទុកដាក់ខ្លាំងក្នុងការធ្វើជំនួញ ជាមួយប្រទេសខ្មែរ (39) ។

## ២– ព្រះបាទជ័យជេដ្ឋាទី២ (១៦១៨-១៦២៨).-



ចេតិយនៅលើភ្នំព្រះរាជទ្រព្យ

(រូបថតផ្ទាល់ខ្លួន)

ព្រះ ជ័យជេដ្ឋា បានឡើងសោយរាជ្យនៅ គ.ស. ១៦១៨ ដោយមានព្រះនាមសំរាប់រាជ្យថា **សម្តេចព្រះរាជឱង្ការ ព្រះជ័យជេដ្ឋាធិរាជរាមាធិបតី** ។ អ្នកប្រវត្តិសាស្ត្រនិយមហៅព្រះអង្គថា **ព្រះជ័យជេដ្ឋាទី២** ។ ព្រះអនុជត្រូវបានតាំងជាមហាឧបរាជហើយទទួលព្រះនាមជាព្រះ **ឧទ័យបរមរាជា** ។ ឯព្រះបិតាលោកគង់នៅជាឧភយោរាជ ប៉ុន្តែ១ឆ្នាំក្រោយព្រះអង្គក៏សោយទីវង្គតទៅ ក្នុងព្រះជន្មាយុ ៦៤ វស្សានៅព្រះរាជវាំង **លង្វែក** ។

ព្រះបាទ **ជ័យជេដ្ឋាទី២**

www.budinst.gov.kh www.elibraryofcambodia.org

ទ្រង់បានបោះបង់ចោលនូវទំនៀមទំលាប់សៀម ហើយលើកយកទំនៀមទំលាប់ខ្មែរមកប្រើជាជំនួសវិញ ហើយដើម្បីបង្ហាញអោយសៀមឃើញថាព្រះអង្គមិនទទួលស្គាល់នូវអំណាចរបស់សៀមមកលើប្រទេសខ្មែរទេ ព្រះអង្គក៏លើករាជធានីពី **ល្វាឯម** ទៅតាំងនៅក្រុង **ឧដុង្គ** នៅគ.ស. ១៦២០ ។ នៅគ.ស. ១៦២៣ ព្រះអង្គទ្រង់បញ្ជាអោយសាងព្រះចេតិយធំឈ្មោះព្រះ **ចេតិយត្រៃត្រឹង** នៅលើភ្នំព្រះរាជទ្រព្យដើម្បីតំកល់ព្រះអដ្ឋិធាតុព្រះបិតា ។

ក្នុងរជ្ជកាលរបស់ព្រះអង្គ ព្រះបាទ **ជ័យជេដ្ឋាទី២** ទ្រង់បញ្ញត្តិអោយបណ្ដាមុខមន្ត្រីធំតូច និងបណ្ដានាយមហាត នាយពល និងទូលថ្វាយអោយថា **សម្ដេចព្រះនារាយណ៍នរនាថ** ។ ព្រះអង្គទ្រង់លើកអ្នក **អង្គចូវ** ព្រះរាជបុត្រីស្ដេចយួនអោយឡើងជាអគ្គមហេសីហៅ **សម្ដេចព្រះភគវតីព្រះស្រីនរក្សត្រី** ។

ក្នុងរជ្ជកាលរបស់ព្រះអង្គ មានការផ្ទៀងផ្ទាត់រៀបរៀងព្រះរាជក្រិត្យ ២៤ ក្រម មាន ក្រម **សុភាធិបតី** ក្រម **ឧសភរិយា** ក្រម **ចែកពល** ក្រម **ឧទេន** ក្រម **សុរបសង្ស** ក្រម **ពលទេព** ក្រម **ស្នូស្តី** ។ល។ (29) ។

កាលដែលមិនទាន់សោយរាជ្យ ព្រះជន្មបាន ២៦ វស្សា ព្រះ **ជ័យជេដ្ឋា** មានបុត្រ :

— នាម **ចៅពញាតូ** ជាមួយ **អ្នកម្នាងសុខ**

— នាម **ចៅពញានូ** ជាមួយ **អ្នកម្នាងធន**

លុះសោយរាជ្យបាន ២ ឆ្នាំ ព្រះអង្គមានបុត្រ :

— នាម **ចៅពញាចន្ទ** ជាមួយ **អ្នកម្នាង** លាវឈ្មោះ **ម៉ុស**

រាជពង្សាវតារខ្មែរខ្លះបាននិយាយថា ព្រះអង្គមានបុត្រី ២ អង្គទៀត :

— នាម **ចន្ទវតីក្សត្រី** ជាមួយ **អ្នកម្នាងនង**

— នាម **បុប្ផាវតី** ជាមួយអគ្គមហេសីយួន (?)

ចំណែកឯព្រះ **ឧទ័យបរមរាជា** មហាឧបរាជ ព្រះអង្គទ្រង់បញ្ញត្តិអោយបណ្ដាមុខមន្ត្រីទូលនិងថ្វាយថាព្រះ **ភូធរនរនាថ** ។ ស្ដេចមានម្នាង ៣ នាក់ហើយមានបុត្រ ៤ អង្គដូចតទៅ :

www.budinst.gov.kh www.elibraryofcambodia.org

— **អ្នកអង្គនន់** បុត្រជាមួយ **អ្នកម្នាងសន**

— **អ្នកអង្គស្ងួរ** ⎫
— **អ្នកអង្គតន់** ⎭ បុត្រជាមួយ **អ្នកម្នាងស្ងួស**

— **អ្នកអង្គអិម** បុត្រជាមួយ **អ្នកម្នាងឌិន** ។

### .១– ទំនាក់ទំនងជាមួយសៀម.-

ដោយព្រះបាទ **ជ័យជេដ្ឋាទី ២** ពុំព្រមទទួលស្គាល់អំណាចរបស់សៀមមកលើប្រទេសខ្មែរ ព្រះចៅសៀមក៏លើកទ័ពចូលវាយខ្មែរនៅ គ.ស ១៦២២ ។ ទ័ពសៀមបានលើមកដល់ភ្នំ **ចុង្គាង** (បរិបូណ៌) ព្រះអង្គនាំទ័ពទៅតស៊ូប្រឆាំងទឹកដីទ័ពខ្មាំង ។ សៀមបាក់ទ័ព ត្រូវខ្មែរចាប់បានជាឈ្លើយអស់ជាច្រើនហើយព្រះអង្គអោយហៅឈ្លើយទាំងនោះជា **សៀមចុង្គាង** ។ នៅ គ.ស. ១៦២៣ សៀមបានលើកទ័ពមកវាយខ្មែរម្តងទៀតក្រោមបញ្ជាការរបស់ព្រះចៅ **ស្រីធម្មរាជា** ។ លើកនេះ ទ័ពជើងទឹករបស់សៀមបានមកដល់ស្រុក **ពាម** ហើយបានពើបប្រយុទ្ធនឹងទ័ពរបស់ព្រះ **ឧទ័យ** ដែលចេញពីក្រុងឧដុង្គមានជ័យ ។ សៀមចាញ់វាក់ទ័ពជយទៅវិញអស់ទៀត ។ រាជពង្សាវតារខ្មែរទ្រង់បញ្ជាក់ថា ក្រោយមកព្រះចៅសៀមទ្រង់ចាត់អោយបុត្រនាមព្រះ **ជេដ្ឋា** លើកទ័ពតាមជើងទឹកមកវាយខ្មែរម្តងទៀត ។ ព្រះ **ឧទ័យ** ត្រូវចាត់អោយចេញទៅទល់ទៀត សៀមមិនហ៊ានវាយនិងលើកទ័ពដេញ ។ ព្រះ **ឧទ័យ** ទ្រង់សុំចូលវាយស្រុកសៀមតែព្រះ **ជ័យជេដ្ឋាទី ២** ទ្រង់មិនអនុញ្ញាត ។

### .២ – ទំនាក់ទំនងជាមួយយួន.—

សៀវភៅប្រវត្តិសាស្ត្រយួនបានបញ្ជាក់ថា ប្រទេសខ្មែរ (ចិនឡាប) ដែលស្ថិតនៅត្រង់វាលទំនាបខាងក្រោមនៃទន្លេមេគង្គ ជាប្រទេសដ៏មានសម្បូណ៌ទៅដោយផ្លូវទឹក ឯដីធ្លីស្រែចំការក៏មានច្រើនណាស់ដែរ ។ ចំណែកឯនៅប្រទេស **វៀតណាម** ឯណោះ ប្រ

www.budinst.gov.kh  www.elibraryofcambodia.org

ជារាស្ត្រត្រូវកើតប្រមុខៈនឹងទុរភិក្សជារឿយ ៗ ដោយស្រែចំការពុំបានផ្តល់ផលអោយគ្រប់គ្រាន់ ម្យ៉ាងទៀតនៅពេលនោះ ពួកស្តេចត្រាញ់ **ត្រិញ** និង **ង្វៀន** កំពុងតែវាយប្រហារគ្នា ម្ល៉ោះហើយមានជនជាតិយួនជាច្រើនបានលបលួចចូលនៅក្នុងទឹកដីខ្មែរត្រង់ **បារា** និង **ដូនណៃ** ដើម្បីកាប់ព្រៃយកដីធ្វើស្រែ (40) ។

នៅ គ.ស. ១៦២៣ គណៈបេសកកម្មទូតយួនមួយត្រូវបានបញ្ជូនមកក្រុង **ឧដុង្គ** ក្នុងគោលបំណងសូមព្រះរាជាខ្មែរអនុញ្ញាតអោយបង្កើតគ្រឹះស្ថានដំនូញនៅខាងត្បូងប្រទេសខ្មែរ គឺនៅត្រង់តំបន់ **ព្រៃនគរ** (ព្រៃនគរ) **កំពង់ក្របី** (១) ព្រមទាំងសូមអនុញ្ញាតអោយមានសិទ្ធិកាន់កាប់ក្រសួងគយនៅតំបន់នោះផង ។ ស្ថានការណ៍ក្នុងប្រទេស សម្ពន្ធមិត្តជាមួយក្រុងវេ ការយោគយល់ដល់អគ្គមហេសី ទាំងនេះហើយជាកត្តាជម្រុញអោយព្រះ **ជ័យជេដ្ឋាទី២** ទ្រង់អនុញ្ញាតយល់ព្រមតាមសេចក្តីស្នើសូមរបស់គេ ។ ចំពោះរឿងនេះ អ្នកប្រវត្តិសាស្ត្របរទេសខ្លះយល់ឃើញថា : " ជាការវាយដណ្តើមយកមណ្ឌលពាណិជ្ជកម្មមួយរបស់ខ្មែរដោយលាក់មុខ " (41) ។ ចាប់តាំងពីពេលនោះមក ហើយដោយមានការលើកទឹកចិត្តពីព្រះចៅក្រុងវេផង ជនជាតិយួនបានដឹកកូនជញ្ជូនចៅ បបួលគ្នាចូលនៅក្នុងទឹកដីខ្មែរ កាន់តែច្រើនឡើង ៗ ។ បន្ទាប់មកទៀត ដោយយកលេសថាដើម្បីជួយអាជ្ញាធរខ្មែររក្សាសន្តិសុខអោយមានប្រសិទ្ធិភាព ព្រះចៅក្រុង វេ ទ្រង់បានបញ្ជូនមេទ័ពម្នាក់អោយទៅឈរនៅតំបន់នោះទៀត ។

ចំពោះការដែលយួនលើកគ្នាចូលរស់នៅក្នុងទឹកដីខ្មែរជាលើកដំបូងនេះ មានរាជពង្សាវតារខ្មែរខ្លះនិយាយថាស្តេចយួនបានចាត់ទូតអោយមកសុំខ្ចីដីខ្មែរត្រង់**ព្រៃនគរ-កំពង់ក្របី** ដើម្បីហ្វឹកហាត់ទាហានធ្វើចម្បាំងជាមួយចិន ហើយនឹងបង្វិលសងមកខ្មែរវិញក្រោយរយៈពេល ៥ ឆ្នាំ ។

គួរគប្បីជ្រាបថាពួកយួនចំណូលថ្មីទាំងនោះ កាលដែលមកតាំងនៅក្នុងប្រទេសខ្មែរ

---

(១) គួរគប្បីជ្រាបថា ដែលហៅថា **ព្រៃនគរ** (ព្រៃដើមគរ) នៅពេលនោះគឺត្រូវនឹងតំបន់ **ជីឡឹង** សព្វថ្ងៃ ឯកន្លែងក្រុង **ព្រៃនគរ** សព្វថ្ងៃពីដើមហៅថា **កំពង់ក្របី** ។

www.budinst.gov.kh www.elibraryofcambodia.org

ប្រើនតែទៅរស់នៅត្រង់កន្លែងណាដែលមានដីជាតិល្អថ្ងៃជានៅតាមច្រាំងទន្លេ និងស្ទឹងទាំងឡាយ ដែលជាមូលហេតុបណ្តាលអោយជនជាតិខ្មែរសុខចិត្តលះបង់ចោលនូវទ្រព្យសម្បត្តិ មានស្រែចំការ ផ្ទះសំបែង ស្រុកភូមិ ដើម្បីជយខ្លួនទៅរស់នៅឯកន្លែងផ្សេង ព្រោះពុំអាចរស់នៅជាមួយពួកចំណូលថ្មីដែលមានទំនៀមទំលាប់ របៀបរស់នៅខុសប្លែកពីគ្នាពេក ។

នៅពេលដែលព្រះបាទ **ជ័យជេដ្ឋា** ទ្រង់សោយទីវង្គតទៅនៅ គ.ស. ១៦២៨ ភាគខាងពីព្រៃនគរ **បារា** និង **ដូនណៃ** (កំពង់ស្រកាត្រី) ទៅទល់និងអតីតណាចក្រ **ចាម្ប៉ា** មានសុទ្ធតែជនជាតិយួនមកនៅពាសពេញអស់ទៅហើយ ។

## ២.៣- ទំនាក់ទំនងជាមួយជនជាតិអឺរ៉ុប.-

ចាប់ពី ស.វ. ទី ១៧ តទៅ ខ្មែរបានទាក់ទងជាមួយជនជាតិអឺរ៉ុបថ្មីៗទៀត ជនជាតិ **ហូឡង់**នេះឯង ។

ក្រុមពីពួកព័រទុយក៏ល និង អេស្ប៉ាញដែលមានបំណងជំនួញក្នុងការផ្សាយសាសនា អាស៊ី ពួកហូឡង់ធ្វើសកម្មភាពតែក្នុងវិស័យជំនួញ ។ ចាប់ពីគ.ស.១៥៩៥ ពួកនេះបាន ធ្វើជាតិបក្ខការសឹកទៅកោះ**ជ្វា** ហើយបន្ទាប់មកបានដណ្តើមយកពីពួកព័រទុយហ្គាល់ អាណានិគមទាំងអស់លើកលែងតែMacao ចេញ ហើយបានបង្កើតគ្រឹះស្ថានជំនួញនៅប្រទេសឥណ្ឌា នៅកោះសេរីលង្កា នៅ Malacca នៅប្រទេសសៀម និងនៅប្រទេសជប៉ុន ។

នៅគ.ស.១៦២០ ពួកហូឡង់បានចូលមកធ្វើការទាក់ទងជាមួយខ្មែរជាលើកដំបូង : នៅថ្ងៃទី ២២ ខែ សីហា ឈ្មួញឈ្មោះ Jacob Gaerman ជិះកប៉ាល Galias បានមកដល់ ពាមបទុំ ហើយបានធ្វើដំណើរអស់រយៈពេល ៤ ខែ ទើបមកដល់ក្រុងភ្នំពេញ ។ បីឆ្នាំក្រោយមកទៀត ពួកនេះបានបង្កើតគ្រឹះស្ថានជំនួញជាលើកដំបូងនៅ **កំពង់ហ្លួង** ជិតរាជធានី **ឧដុង្គ** ។ ប៉ុន្តែ ឯកសារមួយទៀត (39) បាននិយាយថាការបង្កើត[illegible]ដំបូងនេះ

www.budinst.gov.kh www.elibraryofcambodia.org

គឺនៅគ.ស.១៦៣៧ទៅវិញដោយ **ក្រុមហ៊ុនឥណ្ឌាខាងកើត**(Vereenigde Oostindische Compagnie) នៅខាងជើង **ពញាឮ** បន្តិច ។ តាំងពីពេលនោះមក ពួកហុល្លង់តែងតែព្យាយាមរកលេសមួលបង្កាច់និងដាក់កំហុសលើពួកព័រទុយកាល់ ដោយមានជំនួយពីពួកជប៉ុន ។ ប៉ុន្តែទោះបីពួកហុល្លង់រិតទំយ៉ាងណាក៏ដោយ គឺគេមិនអាចកំចាត់ពួកចិនបានទេ ដែលនៅទីបំផុតទៅក្លាយជាឈ្មួញជើងឯកនៅតំបន់អាស៊ីអាគ្នេយ៍យើងនេះ ។

## ៣–ព្រះបាទស្រីធម្មរាជាទី ២ ឬព្រះរាជសំភារៈ ចៅពញាតូ (១៦២៩-១៦៣៤).–

កាលមានព្រះជន្ម២១វស្សា **ចៅពញាតូ** បានយាងទៅបួសនៅឯ **នគរវត្ត** ។ ព្រះបិតាទ្រង់បានទំនុកបំរុងផ្សំផ្គុំជាមួយបុត្រីនាម **ចន្ទវតី** អោយជាជាយាគំណាន់ព្រះទ័យ ទ្រង់គិតថានឹងបង្វែររាជសម្បត្តិថ្វាយនៅពេលណាដែលចាកសិក្ខាបទបក ។ ត្រង់ចំណុចនេះឯកសារខ្លះនិយាយថា បុត្រីដែលព្រះអង្គបានផ្សំផ្គុំអោយ **ចៅពញាតូ** នោះគឺ **បុប្ផាវតី** បុត្រីជាមួយ **អង្គទូទ** (?) ទៅវិញ ។

កាលដែលព្រះ **បាទជ័យជេដ្ឋា** សោយទិវង្គតទៅ ពួកនាម៉ឺនបានយាងព្រះអនុជរបស់ព្រះអង្គគឺព្រះ **ឧទ័យ** អោយឡើងសោយរាជសម្បត្តិ តែព្រះអង្គប្រកែកពុំព្រមសោះឡើយ ព្រះអង្គគ្រាន់តែទទួលព្រះឋានៈជាឧភយោរាជកាន់កាប់អំណាចបណ្ដោះអាសន្នទំរាំមានព្រះរាជាឡើងសោយរាជ្យ (១៦២៨-១៦២៩) ។ ជាអកុសល ព្រះ**ឧទ័យ** បានគួចព្រះហឫទ័យប្រតិព័ទ្ធលើរូបនាង **ចន្ទវតី** (ឬបុប្ផាវតី ?) ដែលត្រូវជាគូកំណាន់របស់ **ចៅពញាតូ** ទៅវិញ ។

ចំណែកឯ **ចៅពញាតូ** ដែលកំពុងតែបួសនៅ **នគរវត្ត** នោះ ទាល់តែមាននាម៉ឺនទៅសូមយាងអស់ច្រើនលើក ទើបព្រមចាកសិក្ខាបទមកទទួលរាជាភិសេកឡើងសោយរាជ្យស្នងព្រះបិតាដោយយកព្រះនាមជា**ព្រះបាទសម្ដេចព្រះស្រីធម្មរាជាធិរាជរាមាធិបតី** នៅរាជធានី **គោះឃ្លោក** (ខ្សាច់កណ្ដាល) ។

នៅគ.ស. ១៦៣៣ ព្រះបាទ **ធម្មរាជាទី ២** ទ្រង់បានលើកទ័ពទៅវាយលុកចូលក្រុង

www.budinst.gov.kh

www.elibraryofcambodia.org

**នគររាជសីមា** តែយកមិនបាន ហើយក៏កៀរគ្រួរខ្លះនាំចូលស្រុកខ្មែរវិញ ។ ក្នុងរជ្ជកាល របស់ព្រះអង្គ មានការតែងតាំងចិន ៤ នាក់ជាមន្ត្រីនិងការបង្ហាត់ចិនអោយទៅជាទាហានក្រុម រក្សាព្រះអង្គ ។

គួរគប្បីជ្រាបថាព្រះបាទ **ធម្មរាជាទី ២ ទៅពញាតូ** ជាក្សត្រមួយអង្គមានប្រាជ្ញា យក ព្រះទ័យទុកដាក់នឹងអក្សរសាស្ត្រ ។ ព្រះអង្គទ្រង់បានទុកស្នាព្រះហស្តជាច្រើនក្នុងវិស័យ នេះ ដូចជា :

— **រាជសីត្ថ "ច្បាប់រាជសំភារ"** (គ.ស. ១៦២២)
— **ហោមន្តមាស** (គ.ស. ១៦២៩)
— **កាព្យនិរាស** (គ.ស. ១៦៣០)
— **ហិនលក្ខណ៍សល** (គ.ស. ១៦៣០) (30)

ប៉ុន្តែព្រះអង្គពុំបានសោយរាជ្យអោយបានយូរអង្វែងដើម្បីផ្សព្វផ្សាយ និង ឧបត្ថម្ភវិស័យ អក្សរសាស្ត្រនេះអោយបានទូលំទូលាយនិងបានរឹងប៉ឹងទេ ព្រោះព្រះអង្គមានទំនាស់វិបត្តិជា មួយនឹងព្រះបិតុលាក្នុងរឿងស្នេហា ! យ៉ាងណាមិញ ភ្លើងកាមតណ្ហាបានដុតរោលព្រះ អង្គអោយចាប់ព្រះទ័យប្រតិព័ទ្ធ នាង **ចន្ទទតី (ឬ មុន្នាទតី ?)** ឡើងវិញ ។ គូសង្សារទាំង ពីរបានសរសេរលិខិតឆ្លើយឆ្លងគ្នា ។ នាង **ចន្ទទតី (ឬ មុន្នាទតី ?)** បានធ្វើឧបាយហែ កឋិនទៅ **នគរវត្ត** ដើម្បីបានឱកាសជួបគ្នា ។ ក្រោយមក នាងធ្វើឧបាយថាបានបន់ស្រន់ ព្រះពុទ្ធនៅ **វត្តព្រះវិហារសួគ៌** អោយព្រះភស្តាបានជាសះស្បើយ កាលដែលព្រះអង្គប្រ-ឈួន ដល់ពេលចេញដំណើរក៏ចូលទៅ**កោះឃ្លោក** ជួប ព្រះ**ធម្មរាជា**ទៀត ។ ពួកមន្ត្រីចាំ បាត់យូរពេក ត្រឡប់មកទូលព្រះ **ឧទ័យ** ព្រះអង្គលើកទ័ពទៅដោយមានពួកព័រទុយក៏ល ទៅជាមួយផង ។

ខាងព្រះ**ធម្មរាជា**ក៏លើកទ័ពចេញទទួលច្បាំង តែទន់ដៃជាងគេរត់ចូលបន្ទាយ បន្ទាយ ត្រូវគេវាយបែកទៀត ។ ព្រះ **ធម្មរាជា** ទ្រង់ភៀសព្រះអង្គតាមទូកទៅដល់ស្រុក **អញ្ចេះ** រត់ ទៅពួនលើចុងត្នោតហើយត្រូវពួកព័រទុយក៏លបាញ់ធ្លាក់មកដី តែមុននឹងសុគត(គ.ស.១៦៣៤)

www.budinst.gov.kh www.elibraryofcambodia.org

ទ្រង់បានសុំអនុញ្ញាតទុកពេលបារលើស៊ីករូតឆ្លាតខ្លះ ជំហូម្មាន ទុកអោយបច្ចាជនជ.នក្រោយ ល្មោភក្នុងកាមគណ្ហាដូចព្រះអង្គទៀត ។

ចំណែកឯនាង **ចន្ទធតី (ឬ ចុទ្ធធតី ?)** ត្រូវទទួលទោសប្រហារជីវិតបង់ ។

## ៥– ព្រះបាទអង្គធនរាជា ចៅពញានូ (១៦៣៥-១៦៣៩).–

**ចៅពញានូ** ជាព្រះរាជបុត្រព្រះបាទ**ជ័យជេដ្ឋាទី ២** ព្រះជន្មបាន៦៣វស្សា បានឡើងសោយរាជ្យសម្បត្តិស្នងព្រះរៀមនៅក្រុង **ឧដុង្គមានជ័យ** ដោយមានព្រះនាមសំរាប់រាជ្យថា **ព្រះបាទសម្ដេចព្រះអង្គធនរាជាធិរាជរាមាធិបតី** ។

នៅគ.ស.១៦៣៨ នៅស្រុក**រលាំងជ្រើល** មានការបះបោរ ព្រះអង្គអោយប្រាបប្រាបរាបទាបអស់ទៅវិញ ។

### ៥.១– ទំនាក់ទំនងជាមួយជនជាតិហុល្លង់.–

នៅគ.ស.១៦៣៥ ពួកហុល្លង់បានចាប់យកសំពៅរបស់ខ្មែរដែលផ្ទុកពេញដោយទំនិញក្នុងដែនទឹកMacassar ។ ព្រះ**អង្គធនរាជា**ទ្រង់បានតវ៉ា ពួកហុល្លង់ក៏បានលែងសំពៅនោះមកវិញ ។ នៅឆ្នាំបន្ទាប់ កប៉ាល់ហុល្លង់ពីរគ្រឿងមកពីក្រុង**បាតាវ្យ** (គឺក្រុង**ជាកាតា** សព្វថ្ងៃ) បាននាំសំបុត្ររបស់លោកទេសាភិបាលស្នើលក់កាំភ្លើងធំអោយខ្មែរ ។ ជាអកុសល កប៉ាល់មួយគ្រឿងឈ្មោះ Noordwych ត្រូវគេផ្ដាប់លើខ្សាច់ត្រង់មាត់ពាមទន្លេមេគង្គ ។ ព្រះរាជាទ្រង់បានបញ្ជាអោយរើបអូសយកកាំភ្លើងធំ ៣០ ដើម និងស្ពាន់ ៥០០ ហាបពីកប៉ាល់នោះ ។ នៅថ្ងៃទី ២៦ ខែមីនា ១៩៣៧ លោកទេសាភិបាលហុល្លង់នៅក្រុង **បាតាវ្យា** បានបញ្ជូនឈ្មួញឈ្មោះ Hendrik Hagenhaar ជាមួយនឹងកប៉ាល់ ៤ គ្រឿងទៀត មកក្នុងឋានៈជាទូតដើម្បីផ្សះផ្សាវិវាទខាងលើ ។ តែលុះមកដល់ទន្លេមេគង្គនៅថ្ងៃ ១១ ខែឧសភា លោក Hagenhaar បានជួបប្រទះនឹងកប៉ាល់ព័រទុយកាល់មួយគ្រឿង ហើយក៏បានរឹបអូសយកកប៉ាល់នោះទៅ ជាហេតុបណ្ដាលអោយព្រះរាជាស្ដីបន្ទោសលោក

www.budinst.gov.kh www.elibraryofcambodia.org

យ៉ាងខ្លាំងនៅពេលដែលលោកថ្វាយសារតាំងចំពោះព្រះអង្គ ។ នៅគ.ស.១៦៣៨ គណៈបេសកកម្មថ្មីមួយទៀតត្រូវបញ្ជូនមក **ឧដុង្គ** ក្រោមកិច្ចដឹកនាំរបស់លោក **Paulus Croocq** ហើយលោក **Johannès Van der Hagen** បានមកជំនួសលោក **Jan Galen** ជាមេគ្រឹះស្ថានហុល្លង់ ។ ពួកមកថ្មីនេះក៏ពុំបានទទួលផលល្អក្នុងកិច្ចការរបស់ខ្លួនដូចពួកមកមុនៗដែរ ។ ប៉ុន្តែ ពួកនេះបានធ្វើអោយព្រះ **ឧទ័យ** យកព្រះទ័យទុកដាក់យ៉ាងខ្លាំងក្នុងទំនាក់ទំនងពាណិជ្ជកម្មនិងនយោបាយជាមួយពួកហុល្លង់ ។ នៅគ.ស.១៦៣៨ព្រះអង្គទ្រង់បានអោយ **ក្រុមហ៊ុនឥណ្ឌាខាងកើត** ទូប្រាក់ និងលក់ម្រេចក្សណ៍ ឈើខ្លឹមចន្ទន៍ និងភ្លុកដំរី អោយពួកហុល្លង់ (១) ។

## ២–ទំនាក់ទំនងជាមួយយួន.–

រាជពង្សាវតារខ្មែរខ្លះបាននិយាយថា នៅ គ.ស. ១៦៣៨ (?) **ព្រះអង្គឧទ័យរាជា** ទ្រង់បានកៀនទារយកដី **ព្រៃនគរ-កំពង់ក្របី**មកវិញ ប៉ុន្តែអគ្គមហេសីយួនរបស់ **ព្រះជ័យជេដ្ឋាទី២** ទ្រង់បានធ្វើអន្តរាគមន៍សុំអោយពន្យាពេលអោយបានយូរបន្តិចទៀត ។

## ព្រះបាទបទុមរាជា អង្គនន់ ( ១៦៣៩-១៦៤១ ) .–

លុះព្រះ **អង្គឧទ័យរាជា** សោយទីវង្គតទៅនៅ គ.ស. ១៦៣៩ **ព្រះអង្គនន់** រាជបុត្របងព្រះ **ឧទ័យ** ព្រះជន្មបាន ២១ វស្សា ត្រូវបានលើកអោយឡើងសោយរាជ្យស្នងព្រះរៀមនៅរាជធានី **ឧដុង្គ** ដោយមានព្រះនាមសំរាប់រាជ្យថា **ព្រះបាទសម្តេចព្រះបរមរាជាធិរាជរាមាធិបតី** ។ ព្រះអង្គទ្រង់យកព្រះរាជបុត្រីសម្តេច **ព្រះជ័យជេដ្ឋាទី ២** ដែលត្រូវជាព្រះអនុជព្រះអយ្យកា ១ ជាព្រះអគ្គមហេសី លើកព្រះនាមហៅ **សម្តេចព្រះតគនពីព្រះបវរក្សត្រី** ( ឯកសារសៀមថាឈ្មោះ **អ្នកយាំ** ) ។ ព្រះអង្គទ្រង់មានបុត្រជាមួយអគ្គមហេសីនេះនាម **ស្រីជ័យជេដ្ឋ** ។ ឯព្រះបិតា គឺព្រះ **ឧទ័យ** ទ្រង់គង់នៅជាព្រះឧភយោរាជដដែល ។

នៅគ.ស. ១៦៤១ **ចៅពញាចន្ទ** ព្រះរាជបុត្រពៅព្រះ **ជ័យជេដ្ឋាទី ២** ដោយអន់

www.budinst.gov.kh www.elibraryofcambodia.org

ព្រះទ័យព្រោះមិនបានឡើងសោយរាជ្យ បានអោយបក្សពួកចូលលុកព្រះរាជវាំងធ្វើគត់បាន ទាំងសម្ដេចឧភយោរាជ និង ព្រះ **បទុមរាជា** ។

## ២– វិបត្តិក្នុងរាជវង្សខ្មែរ និង អន្តរាគមន៍របស់យួន.–

បទឧក្រិដ្ឋដែល **ចៅពញាចន្ទ** ទ្រង់បានប្រព្រឹត្តនោះ បណ្ដាលអោយមានវិបត្តិជាថ្មីទៀតក្នុងរាជវង្សខ្មែររហូតដល់មានចម្បាំងគ្នាឯងក្នុងស្រុក ហើយដែលជាឱកាសល្អអោយយួនលូកដៃចូលជ្រៀតជ្រែកក្នុងផ្ទៃក្នុងរបស់ខ្មែរជាលើកដំបូង ។

### ១– ព្រះបាទរាមាធិបតីទី ១ ចៅពញាចន្ទ (១៦៤១–១៦៥៩).–

ក្រោយពីបានធ្វើគត់ព្រះបិតុលានិងព្រះអនុជអយ្យកា ១ ហើយ **ចៅពញាចន្ទ** បុត្រពៅ **ព្រះជ័យជេដ្ឋាទី២** បានឡើងសោយរាជ្យសម្បត្តិនៅក្រុង **ឧដុង្គមានជ័យ** ដោយមានព្រះនាមសំរាប់រាជ្យថា **ព្រះបាទសម្ដេចព្រះរាមាធិបតី** នៅពេលដែលព្រះជន្មបាន២៣វស្សា ។

រាជពង្សាវតារខ្មែរបាននិយាយថា ថ្ងៃមួយព្រះអង្គយាងទៅក្រសាលនៅទន្លេធំ និង **ស្រីសន្ធរ** ដល់ពេលត្រឡប់មកវិញដល់ **តំបន់ឃ្លាំង** ទ្រង់ទតឃើញស្រីចាម (ជ្វា ?) ឈ្មោះនាង **ទំ:** (ឯកសារខ្លះថាឈ្មោះ Fatima ) ហើយដោយត្រូវពួកចាមដាក់ស្នេហ៍បន្ថែមផង ក៏ទ្រង់ប្រតិព័ទ្ធយ៉ាងខ្លាំងលើរូបនាង **ទំ:** ហើយលើកនាងជាស្នំឯកទៀតផង ប៉ុន្តែប្រពៃណីតម្រូវអោយព្រះអង្គកាន់ **សាសនាឥស្លាម** កាត់ចុងអង្គជាតិនិងយកព្រះនាមថាIbrahim ។ ដោយហេតុនោះហើយ ទើបមានឈ្មោះហៅថាព្រះ **រាមចូលសាសន៍** ។ ព្រះអង្គទ្រង់បានប្រោសប្រណីពួកចាមជ្វា លើកតំកើងអោយឡើងជានាម៉ឺនធំៗ ទ្រង់បានលើក **ថៃសុន** ( ព្រះបិតាក្មេក ) អោយឡើងជា **សម្ដេចបវរធេសពាជ** ។

### ១.១– វិវាទជាមួយពួកហុល្លង់.–

នៅពេលដែលបានឡើងសោយរាជ្យភ្លាម ព្រះ **រាមាធិបតី** ទ្រង់បានផ្ញើព្រះរាជសារ

www.budinst.gov.kh www.elibraryofcambodia.org

លិខិតទៅជូនលោកទេសាភិបាលហុល្លង់នៅ**បាតាវ្យា** ដើម្បីសុំធ្វើការទាក់ទងយ៉ាងជិតស្និទ្ធជាមួយនឹង **ក្រុមហ៊ុននៃប្រទេសឥណ្ឌាខាងកើត** ។ ជាការឆ្លើយតប លោកទេសាភិបាលបានបញ្ជូនលោក Cornelius Clain អោយមកប្រទេសខ្មែរនៅ គ.ស. ១៦៤២ ដើម្បីថ្វាយពរសរសើរចំពោះព្រះអង្គដែលទ្រង់មានជ័យជំនះលើពួកស្តេចដែលជ្រែករាជ្យ ( ព្រះឧទ័យនិងអង្គនន់ ) និងដើម្បីសូមអោយព្រះអង្គប្រុងប្រយ័ត្នចំពោះពួកព័រទុយកាល់កាន់សាសនាកាតូលិក ។

ឯកសារមួយទៀតបាននិយាយថា នៅ គ.ស. ១៦៤១ លោក Van Wuystoff បានធ្វើដំណើរតាមទន្លេមេគង្គទៅដល់ក្រុង **វៀងចន្ទ** ដោយឆ្លងកាត់តាមក្រុង **ភ្នំពេញ** ក្នុងដំណើរស្វែងរកទិញជ័រ កំញាន និងល័ក្ខ ។ បើតាមពតិមានដែលឈ្មួញហុល្លង់ឈ្មោះ Indijk បានផ្តល់ថា នៅសម័យនោះគេអាចទិញនៅភ្នំពេញជារៀងរាល់ឆ្នាំនូវស្បែកប្រើស ១០០០០០ ផ្ទាំង មាស ភ្លុកដំរី និងជ័រកំញាន ។ ចំណែកឯទំនិញដែលគេនាំចូលពីប្រទេសក្រៅមានផាអ.ៈ ស្ពាន់ ព័រសីឡែន និងកំរាលព្រំមកពីស្រុក Coromandel (39) ។

នៅខែកញ្ញា១៦៤៣ ឧបទ្ទវហេតុមួយបានកើតឡើង ។ លោក Pierre de Regemortes មេគ្រឹះស្ថានជំនួញហុល្លង់ បានតវ៉ាចំពោះព្រះរាជាពីការខូចខាតដែលក្រុមហ៊ុនលោកបានទទួលរងគ្រោះ ។ ដោយលោកនេះបានបញ្ចេញឫកពាកោងកាចពេក ពួកក្រុមរក្សាព្រះរាជាក៏បានសម្លាប់លោកនិងពួកបរិវាររបស់លោកទៅ ។ នៅពេលជាមួយគ្នា គ្រឹះស្ថានរបស់លោកក៏ត្រូវគេប្លន់របអូសយកទ្រព្យសម្បត្តិអស់ មនុស្ស ៣៦ នាក់ ត្រូវស្លាប់ហើយមនុស្សប្រហែល ៥០ នាក់ទៀតត្រូវចាប់យកទៅឃុំឃាំង ។

ដើម្បីជាការសងសឹក **ក្រុមប្រឹក្សាប្រទេសឥណ្ឌា** ( Conseil des Indes ) បានបញ្ជូនកងនាវាមួយនៅថ្ងៃ២៣ ខែមីនា ១៦៤៤ ក្រោមបញ្ជាការរបស់លោក Hendrik Harouze និងលោក Simon Jacobsz Domkens ។ កងនាវាដែលមានកប៉ាល់៥គ្រឿង និងទាហានទាំងអស់ ១៦០ នាក់ បានមកដល់ក្រុងចតុមុខនៅថ្ងៃ ៦ ខែកក្កដា ហើយស្ថិតនៅទីនោះរហូតដល់ថ្ងៃ ទី ២០ ខែ មករា ១៦៤៥ ដោយពុំបានទទួលសំណងសោហ៊ុយ

www.budinst.gov.kh www.elibraryofcambodia.org

ជូនផុលពីព្រះរាជាខ្មែរសោះ ។ ម្ល៉ោះហើយ មេបញ្ជាការក៏សំរេចថា ត្រូវតែបន្តដំណើររហូតដល់រាជធានី **ឧដុង្គ** ។ ពេលដែលពួកហូល្លង់ទៅដល់ ទ័ពខ្មែរបានយកសំរាស់ឫស្សីទៅឃាំងផ្លូវទឹកហើយយកកាំភ្លើងធំទៅភ្លង់ពីលើច្រាំងទាំងសងខាង ។ ការប្រយុទ្ធតទល់គ្នាក៏បានផ្ទុះឡើង ។ លោកមេបញ្ជាការត្រូវស្លាប់ ឯពួកពលទាហានហូល្លង់ក៏ស្លាប់អស់ជាច្រើន ។ ប៉ុន្តែកងនាវាបានទំពុះពារឧបសគ្គរត់រំដោះខ្លួនបាន ហើយនៅ គ.ស. ១៦៤៦-១៦៤៧ ពួកហូល្លង់បានធ្វើការចរចាសុំសន្តិភាពជាមួយខ្មែរ ។ ព្រះរាជាទ្រង់បានយល់ព្រមអោយដោះលែងពួកឈ្លើយហូល្លង់និងសងទៅវិញនូវទំនិញដែលបានរឹបអូស ។ នៅគ.ស. ១៦៥៥ កិច្ចព្រមព្រៀងមួយត្រូវបានសំរេចឡើងជាមួយ**ក្រុមហ៊ុនប្រទេសឥណ្ឌាខាងកើត** ដោយមានការជូនផុលសោហ៊ុយដល់គ្រឹះស្ថានជំនួញហូល្លង់ដែលត្រូវខូចខាតយ៉ាងដំណាំនោះ ។

## ១.២–ទំនាក់ទំនងជាមួយយួន.-

ព្រះ**រាមាធិបតីទី១** ទ្រង់បានតៀនទាយកដី**ព្រៃនគរ-កំពង់ក្របី**ពីយួនមកវិញ តែព្រះអគ្គមហេសីយួនរបស់ព្រះ**ជ័យជេដ្ឋា**បានធ្វើអន្តរាគមន៍ជាថ្មី ដោយសុំពន្យាពេលអោយបានយូរតទៅទៀត ។

នៅពេលដែលព្រះអង្គទ្រង់រាជ្យបាន ១៧ វស្សា គឺនៅគ.ស. ១៦៥៨ ព្រះ **អង្គសូរ** និងព្រះ **អង្គតន់** ដែលជារាជបុត្រព្រះ **ឧទ័យ** ហើយដែលបានគេចផុតពីឧក្រិដ្ឋកម្មពីមុននោះ ក្រោយពីបានចាត់មន្ត្រីអោយទៅបញ្ចុះបញ្ចូលរាស្ត្រជាសម្ងាត់ បានលើកទ័ពទៅច្បាំងជាមួយព្រះ**រាមាធិបតី** តែច្បាំងមិនឈ្នះ ក៏រត់ទៅពឹងពាក់និងអតីតអគ្គមហេសីយួនរបស់ព្រះ**ជ័យជេដ្ឋាទី ២** ។ ក្សត្រីយួននេះមានព្រះទ័យក្រេវក្រោធយ៉ាងខ្លាំងចំពោះព្រះ**រាមាធិបតី** ក៏បានទូន្មានស្តេចខ្មែរទាំងពីរអង្គអោយសុំជំនួយពីព្រះចៅក្រុង**វេ** ។

ត្រង់នេះ អ្នកប្រវត្តិសាស្ត្រយួនមានយោបល់ថាជាឱកាសមួយយ៉ាងប្រសើរដើម្បីអោយពួកស្តេច**ង្វៀង** ធ្វើអន្តរាគមន៍ ពង្រីកឥទ្ធិពលរបស់ខ្លួនលើប្រទេសខ្មែរដែលជួនកាគេបាន

www.budinst.gov.kh www.elibraryofcambodia.org

យកវិត្តទុកដាក់ជាយូរមកហើយ (37) ។ ស្តេច ថៃ តុង (Thai-tông) បានបញ្ជាអោយលើកទ័ព ៣០០០ នាក់ មកជួយតាមសំណូមពររបស់ស្តេចខ្មែរ ។ ទ័ពយួនលើកមកប្រយុទ្ធនឹងទ័ពខ្មែរនៅត្រង់ **បារា** ចាប់បានព្រះ **រាមាធិបតី** ដាក់ទ្រុងដែកនាំយកទៅឃុំទុកនៅ **ក្វាងប៊ិញ** (Quang Binh) ឯ**អង្គនិម** ជាបុត្រព្រះ **ឧទ័យ** ដែរតែចូលដៃខាងព្រះ **រាមាធិបតី** ត្រូវក្បៀសព្រះជន្មលើសមរភូមិនោះទៅ ។

ចំពោះព្រះ **រាមាធិបតី** ឯកសារខ្លះថាយួនឃុំព្រះអង្គទុករហូតដល់សុគត (36) ឯកសារខ្លះថាត្រូវលែងអោយមកវិញ យាងមកបានពាក់កណ្តាលផ្លូវប្រឈួនហើយសុគតនៅស្រុក **បត់ទិញ្ញៀន** ឯកសារខ្លះទៀតថាត្រូវលែងមកវិញ តែត្រូវលើកស្លួយសារអាករថ្វាយស្តេចយួននិងត្រូវការពារជនជាតិយួនដែលរស់នៅលើទឹកដីខ្មែរ (40) ។

លុះបានជ័យជំនះលើព្រះ **រាមាធិបតី** ហើយ ទ័ពយួនបែរមកច្បាំងនឹង **អង្គសូរ** និង **អង្គតន់** វិញ ។ ស្តេចទាំងពីរស៊ូច្បាំងឈ្នះ ដេញទ័ពយួនត្រឡប់ចុះទៅស្រុកវិញ ។

## ២ – ព្រះបរមរាជាទី៩ អង្គសូរ (១៦៥៩-១៦៧២).-

ក្រោយពីដេញទ័ពយួនអោយថយទៅវិញអស់ទៅ **អង្គសូរ** រាជបុត្រព្រះ **ឧទ័យ** បានឡើងគ្រងរាជ្យនៅ **ឧដុង្គមានជ័យ** ក្នុងជន្មាយុ ២៦ វស្សា ។

ព្រះអង្គទ្រង់លើក **អង្គឡី** ក្សត្រីជាព្រះអនុជ (មាតាដទៃ) ជាព្រះមេហេសី ។ ព្រះអង្គមានបម្រើម្នាង ២ ទៀត គឺ :

— **អ្នកម្នាងពៅ** មានបុត្រានាម **អ្នកអង្គជី** និង បុត្រីនាម **អង្គស្រីធីតា**

— **អ្នកម្នាងនៃ** មានបុត្រានាម **ចៅពញាសូរ** (ឯកសារខ្លះថាឈ្មោះ **អង្គស្ងួ**) និង បុត្រីនាម **អង្គអី**

លុះបានព្រះជន្ម ២៩ វស្សា ព្រះអង្គទ្រង់ធ្វើពិធីប្រាប្តាភិសេកឡើងសោយរាជសម្បត្តិដោយមានព្រះនាមសំរាប់រាជ្យថា **សម្តេចព្រះបរមរាជាធិរាជរាមាធិបតី** ។ ព្រះអង្គទ្រង់លើក **អង្គឡី** ជាអគ្គមហេសី ព្រះនាមហៅ **សម្តេចព្រះភគវតីព្រះវររាជក្សត្រី** ។

www.budinst.gov.kh www.elibraryofcambodia.org

នៅគ.ស. ១៦៦៧ គ្រឹះស្ថានជំនួញពួកហុល្លង់នៅ ... ឡូច ដែលបានបើកធ្វើសកម្មភាពរឿងវិញនោះ ត្រូវពួកចិននៅជិតខាងចូលប្លន់យកទ្រព្យសម្បត្តិអស់ ។ ទោះបីយ៉ាងនេះក៏ដោយ ក៏គ្រឹះស្ថាននោះនៅបន្តសកម្មភាពរបស់ខ្លួនតទៅទៀតយ៉ាងត្រដាបត្រដួស ក្រោមកិច្ចដឹកនាំរបស់លោក Johannès Besselman ។

គេដឹងថាគ្រឹះស្ថានជំនួញនោះត្រូវបិទជាស្ថាពរនៅ គ.ស. ១៦៨៦ ហើយចាប់ពីពេលនោះទៅ ទំនាស់រវាងពួកព័ទុយកាល់និងពួកហុល្លង់ក្នុងវិស័យជំនួញក៏ផុតរលត់អស់ទៅ ។

គ្រានោះ មានជនម្នាក់តាំងខ្លួនជាស្តេចឈ្មោះ **បាទីនេ** គិតជះក្តោបរាជ្យ ។ ព្រះអង្គទ្រង់បញ្ជាអោយលើកទ័ពទៅបង្ក្រាប ហើយចាប់បានយកមកប្រហារជីវិតចោល ហើយទ្រង់តាំង **អង្គតន់** ព្រះអនុជជាឧភយោរាជ ។

នៅ គ.ស. ១៦៧២ ព្រះអង្គទ្រង់សព្វព្រះហឫទ័យផ្សំផ្គុំបតីនាម **អង្គស្រីធីតា** និងក្មួយនាម **ស្រីជ័យជេដ្ឋ** ជាបុត្រព្រះ **អង្គនន់ ទី១** ។ ប៉ុន្តែជាអកុសល គឺបុត្រប្រសានិងក្មួយអង្គនេះបានបញ្ចូនបក្សពួកអោយចូលក្នុងរាជវាំង លុកធ្វើគត់ព្រះអង្គបានប៉ុន្មានខែក្រោយមក ។

ចំណែកឯព្រះឧភយោរាជ **អង្គតន់** ព្យាយាមចាញ់ក៏ភៀសព្រះអង្គទៅស្រុកយួនជាមួយក្មួយនាម **អង្គនន់** ( បុត្រអង្គអិម ) ។

## ៣–ព្រះបទុមរាជាទី ២ ស្រីជ័យជេដ្ឋ ( ១៦៧២-១៦៧៣ ).–

ព្រះ **ស្រីជ័យជេដ្ឋ** ព្រះជន្មបាន ៣៣ វស្សា បានឡើងសោយរាជ្យសម្បត្តិនៅក្រុងឧដុង្គមានជ័យ ដោយមានព្រះនាមសំរាប់រាជ្យថា **ព្រះបាទសម្តេចព្រះបទុមរាជាធិរាជរាមាធិបតី** ។ ព្រះអង្គយក **អង្គឡី** អគ្គមហេសី ព្រះ **អង្គសួរ** ហើយត្រូវជាព្រះមាតុច្ឆាជាអគ្គមហេសីរបស់ព្រះអង្គ ។

លុះសោយរាជ្យបាន ៥ ខែ សម្តេចព្រះ **តកនចក្រីព្រះចមក្សត្រី** ជាអគ្គមហេសីអោយពួកចាមអ្នកសម លបធ្វើគត់ព្រះអង្គបាន ។

www.budinst.gov.kh www.elibraryofcambodia.org

### ៤–ព្រះកែវហ្វាទី ២ អង្គជី ( ១៦៧៣-១៦៧៩ ).–

ព្រះ **អង្គជី** បុត្រព្រះ **បរមរាជាទី ៩ អង្គសួរ** ត្រូវបានលើកអោយសោយរាជ្យក្នុងព្រះជន្មាយុ ២១ វស្សា នៅក្រុង **ឧដុង្គមានជ័យ** ដោយមានព្រះនាមសំរាប់រាជថា **សម្តេចព្រះកែវហ្វា** ។

ព្រះអង្គមានម្នាងម្នាក់ឈ្មោះអ្នកម្នាង **ពៅ** ។ ពីកាលពុំទាន់សោយរាជ្យនោះអ្នកម្នាង **ពៅ** បានប្រសូតបុត្រា ១ អង្គនាម **ចៅពញាយ៉ង** (ឯកសារខ្លះហៅថាព្រះ **អង្គយ៉ង**) ។

នៅគ.ស. ១៦៧៣ គឺនៅពេលដែលព្រះអង្គឡើងសោយរាជ្យនោះ ព្រះឧភយោរាជ **អង្គតន់** និង **អង្គនន់** ដែលបានរត់ទៅពឹងយួនពីមុន បានលើកទ័ពយួន ១០០០០ នាក់ជាជំនួយរបស់ស្តេច **ថៃ តុង** (Thai Tông) ។ ព្រះ **កែវហ្វាអង្គជី** ដោយទ្រង់បារម្ភខ្លាចព្រះបិតុលា **អង្គតន់** ដណ្តើមយករាជសម្បត្តិ ក៏ទ្រង់លើកទ័ពចេញទទួលច្បាំងនៅភ្នំពេញ តែមិនចាញ់មិនឈ្នះ ។ ព្រះ **អង្គតន់** ក៏ថយទ័ពទៅនៅត្រើយ **ល្វាឯម** ក្រោយមកលើកទ័ពចូលវាយបែកបន្ទាយភ្នំពេញហើយ បំរុងលើកបន្តួសទៅវាយ **ឧដុង្គ** ទៀតតែប្រឈួនហើយសោយទិវង្គតទៅ ។

ព្រះ **កែវហ្វាអង្គជី** លើកទ័ពទៅច្បាំងទៀត យួនបាក់ទ័ពត្រឡប់ទៅស្រុកវិញអស់ទៅ ។ ប្រទេសពេលនោះត្រូវចែកជា ២ : ខាងលិចបានទៅព្រះ **កែវហ្វា** ខាងកើតបានទៅព្រះ **អង្គនន់** ដែលពួកមន្ត្រីថ្វាយព្រះនាមថា **សម្តេចព្រះបទុមរាជាមហាឧភយោរាជ** ។

ព្រះ **កែវហ្វា** លើកទ័ពទៅច្បាំងទៀត តែប្រឈួនហើយសុគត ។ ឯកសារខ្លះថាព្រះអង្គច្បាំងចាញ់យួន រត់ទៅសុគតនៅស្រុក **រូបាំគម្លីង** ខេត្ត **សំពោចចក** (ក្បែនវត្តគោកកាក) ។ ឯកសារយួនថាព្រះអង្គភៀសព្រះអង្គចូលព្រៃហើយត្រូវបក្សពួកធ្វើគត់ (37) ។

ព្រះ **អង្គស៊ូ** (ឬ **ចៅពញាសួរ**) ធ្វើចម្បាំងប្រឆាំងនិង **អង្គនន់** តទៅទៀត ។ ការប្រយុទ្ធគ្នាកើតឡើងនៅ **ពញាឮ** ។ ព្រះ **អង្គនន់** ឧភយោរាជទទួលបរាជ័យភៀសព្រះអង្គទៅស្រុកយួនម្តងទៀត ។ ក្នុងដំណើរនោះ អ្នកម្នាង **ឯម** ជាកូនចិន **ចុងតុន** បានប្រសូត

www.budinst.gov.kh www.elibraryofcambodia.org

**ឃ្លុំឈាមៈអង្គអិម** (នាមដូចព្រះអយ្យកោ) ។

គួរគប្បីបញ្ជាក់ថា ឯកសារយួនច្រើននិយាយថានៅគ.ស. ១៦៧៤ ព្រះ **អង្គឌី** (Nac Ong Dai) បានទៅសុំជំនួយមកសៀមមកប្បាំងនឹង **អង្គនន់** (Nac Ong Nôn) (37-40) ប៉ុន្តែឯកសារខ្មែរទាំងអស់ពុំបាននិយាយពីជំនួយទ័ពសៀមនោះសោះ ។ បើមានគឺ **អង្គស៊ូ** វិញទេជាអ្នកសុំជំនួយពីក្រុង **ស្រីអយុធ្យា** ក្នុងការបន្តចម្បាំងជាមួយនឹង **អង្គនន់** ។ ម្យ៉ាងទៀត ឯកសារយួនបាននិយាយថាព្រះ **អង្គស៊ូ** (Nac Ong Thu) បានចុះចូលនឹងយួន ហើយដោយសារព្រះអង្គជាវង្សស្តេចពេញច្បាប់ក៏ត្រូវបានលើកអោយសោយរាជ្យ ចំណែកឯ **អង្គនន់** ត្រូវបានតាំងជាឧបរាជអោយឈរត្រួត **ព្រៃនគរ** ហើយត្រូវលើកសួយថ្វាយព្រះអង្គរៀងរាល់ឆ្នាំ (40) ។

## គ–ការបាត់បង់ទឹកដីកម្ពុជាក្រោម.–

### ១–ព្រះបាទជ័យជេដ្ឋាទី ៣ អង្គស៊ូឬចៅពញាស៊ូរ ( រជ្ជកាលទី ១: ១៦៧៥-១៦៨៨ ).–

លុះវាយកំចាត់ទ័ពយួនអោយថយទៅវិញអស់ ព្រះ **អង្គស៊ូ** ( ឬចៅពញាស៊ូរ) ដែលមានព្រះជន្ម ១៦ វស្សា បានឡើងគ្រងរាជ្យស្នងព្រះរៀមនៅក្រុង **ឧដុង្គមានជ័យ** ដោយមានព្រះនាមថា **សម្តេចព្រះស្រីជ័យជេដ្ឋា** ។ ព្រះអង្គទ្រង់លើក **អង្គលី** ( អង្គអី ? ) ព្រះអនុជរួមបិតា ( ឯកសារខ្លះថាជាព្រះមាតុច្ឆា) (42) ជាអគ្គមហេសី ។

គួរគប្បីជ្រាបថា នៅ គ.ស. ១៦៧៩ មាននាម៉ឺនចិនឈ្មោះ **យឿង ង៉ាន ឌិច** ( Duong Ngan Dich ) និង **ត្រឹង ធឿង ស្វៀង** (Trân Thuong Xuyên) រត់មកពីខេត្ត **ក្វាង ទុង-ក្វាងស៊ី** ព្រោះពេលនោះពួក **ម៉ង់ស៊ូ** ( Mandchous ) វាយយកបានប្រទេសចិនពីរាជវង្ស **មិញ** ( Minh ) ។ ដោយពុំព្រមចំណុះពួកបរទេសឈ្នានពានទឹកដី ពួកចិនទាំងនោះបាននាំគ្នា ៣០០០ នាក់ នឹងសំពៅ ៥០ មកសុំជ្រកកោននឹងស្តេចយួន ។ ស្តេច **ថៃ តុង** ( Thai Tông )ទ្រង់បានបញ្ជូនជនភៀសខ្លួននោះអោយ


www.budinst.gov.kh www.elibraryofcambodia.org

ទៅនៅក្នុងប្រទេសខ្មែរនៅត្រង់តំបន់ **ឃាំងិញ** ( ទុកញ៉ាំងិន ? ) ។ ក្រោយមកពួកនោះបានបំបែកគ្នាទៅនៅត្រង់ **ដូនណៃ** ខ្លះ **ត្រង់មេសរ** ខ្លះ ប្រកបរបរធ្វើស្រែចំការ បង្កើតក្រុង មានឈ្មួញបរទេសចេញចូលលក់ដូរយ៉ាងច្រើន គឺឈ្មួញជាតិអឺរ៉ុប ឈ្មួញជប៉ុន និងឈ្មួញជ្វា ។

គួរគប្បីជ្រាបថា នៅពេលជំណាលគ្នាជាមួយនិងជនជាតិចិនភៀសខ្លួនខាងលើនេះ មានចិនម្នាក់ទៀតឈ្មោះ **ម៉ាក គីវ** ( Mac Cuu ) មានកំណើតនៅខេត្ត **ក្វាង តុង** ជាឈ្មួញមានឈ្មោះល្បី ធ្លាប់ធ្វើសកម្មភាពជំនួញនៅប្រទេសហ្វីលីពីននិងនៅក្រុងបាតាវៀ នៅពេលដែលចិនឡើងចាញ់ពួក **ម៉ាន់ស៊ូ** លោកមិនព្រមប្រកាន់យកទំនៀមទំលាប់បរទេសមានការក្រងសក់ជាដើម ក៏រត់មកជ្រកកោននឹងស្តេចខ្មែរ ហើយត្រូវបានតែងតាំងជាមន្ត្រីឈរត្រួតតំបន់ឆ្នេរល្បងសមុទ្រសៀម ។ ដោយឃើញផ្ទៃក្នុងរបស់ខ្មែរមានភាពច្របូកច្របល់ និងដោយឃើញឈ្មួញបរទេសចេញចូលច្រើន គាត់ក៏បើកក្បាលបៀយកគុង ។ ម្យ៉ាងទៀត ដោយជីកបានកំណប់មួយ គាត់ក៏ក្លាយទៅជាអ្នកមានស្តុកស្តម្ភ ។ គាត់បានសង់បន្ទាយនិងក្រុងនៅមាត់សមុទ្រ ហើយប្រមូលរាស្ត្រអោយទៅនៅត្រង់ **ពាម កោះត្រល់ តំពាត កំពង់សោម ត្រពាំងស ពឹកខ្មៅ** ។ នៅ គ.ស. ១៦៨៧-១៦៨៨ សៀមលើកទ័ពចូលវាយលុកតំបន់ **ពាម** ចាប់បាន **ម៉ាកគីវ** យកទៅប្រទេសសៀម តែក្រោយមកគាត់បានលួចរត់ត្រឡប់មក **ពាម** បានវិញនៅប្រមាណ គ.ស. ១៧០០ (37) ។

នៅ គ.ស. ១៦៨២ ព្រះ **អនុជន** ដែលបានភៀសព្រះអង្គទៅស្រុកយួននោះ ទ្រង់បានប្រមែប្រមូលពួកចិនដែលជាចំណុកលថ្មីនៅ **ដូនណៃ-ឃាំងិញ** ផ្សំគ្នាជាមួយទ័ពយួនខ្លះលើកទៅវាយព្រះ **ជ័យជេដ្ឋា** ទៀត ដំបូងវាយយកបានខេត្ត **ព្រះត្រពាំង បាសាក់** ហើយលើកបន្តួសដល់ **ភ្នំពេញ-ឧដុង្គ** ។ កាលណោះព្រះ **ជ័យជេដ្ឋា** កំពុងតែគង់នៅវាំង **ក្រុងគ្រើច** ទ្រង់កែនទ័ពទៅច្បាំងឈ្នះ ទ័ពចិនក៏ថយទៅនៅ **កោះតែងអស់** ប៉ុន្តែពួកនោះបានចាប់យកព្រះមាតាព្រះអង្គទៅឃុំទុកនៅ **ព្រៃវាយចខ្នារ** ក្រោយមកបាន **ពញាមាស** ទៅរំដោះបានមកវិញ ។

www.budinst.gov.kh www.elibraryofcambodia.org

នៅ គ.ស. ១៦៨៣ ព្រះ **ជ័យជេដ្ឋា** ទ្រង់យាងទៅគង់នៅ **ឧដុង្គមានជ័យ** វិញ ។

នៅគ.ស. ១៦៨៤ ព្រះ**អង្គនន់** ត្រឡប់មកពីស្រុកយួន មកតាំងបន្ទាយនៅ**ស្រីសន្ធរ** ហើយលើកទ័ពចំរុះ ខ្មែរ-ចិន ទៅវាយក្រុងភ្នំពេញ តែត្រូវបរាជ័យថយចូលបន្ទាយវិញ ។

នៅគ.ស. ១៦៨៨ ព្រះ**ជ័យជេដ្ឋា** ទ្រង់ប្រឈួនដោយជំងឺពិសក្ដៅ (ឯកសារខ្លះថា កើតអុតធំ) ក៏ប្រគល់រាជសម្បត្តិថ្វាយព្រះមាតា ។

## ២– **រជ្ជកាលអ្នកម្នាងចន្ទ (១៦៨៨).-**

ព្រះមាតាទ្រង់បានសោយរាជ្យជំនួសបាន៣ខែ ។ លុះព្រះ **ជ័យជេដ្ឋា** ទ្រង់បានជាសះស្បើយហើយ ទេពទ្រង់ព្រះផ្នួសបាន៧ថ្ងៃហើយលាមក ឡើងសោយរាជ្យវិញ ។

## ៣– **ព្រះជ័យជេដ្ឋាទី ៣ (រជ្ជកាលទី២ : ១៦៨៨-១៦៩៥).-**

នៅគ.ស. ១៦៨៩ នាម៉ឺនឈ្មោះ **ចៅពញានូ** និងចិនឈ្មោះ **តាន់ចុងអៀ** ដោយតួចចិត្តមិនបានបុណ្យស័ក្តិ ក៏រត់ទៅចូលខាង **អង្គនន់** ព្រះអង្គអោយលើកទ័ពមកច្បាំង តាំងបន្ទាយនៅ**ព្រៃឈ្មោះចក្រ** ។ ប៉ុន្តែ មន្ត្រីទាំងពីរត្រូវចាប់បានហើយយកទៅប្រហារជីវិតបង់ ។

នៅឆ្នាំដដែល ព្រះ**ជ័យជេដ្ឋា** ដែលបានគ្រងរាជ្យអស់រយៈពេល ១៣ ឆ្នាំមកហើយ ក៏ទ្រង់ធ្វើរាជពិធីប្រាប្ដាភិសេក ហើយយកព្រះនាមសំរាប់រាជ្យថា **សម្ដេចព្រះជ័យជេដ្ឋាបរមសុរិន្ទ្រាធិរាជរាមាឥស្សូរ** លើក **អង្គលី** (អង្គអី?) ជាអគ្គមហេសី ហៅថា **សម្ដេចព្រះភគវតីសិរីចក្រពត្តិមហាក្សត្រី** ។ ពេលនោះ ព្រះ**អង្គនន់** បានភៀសទៅសុំជំនួយទ័ពយួនមកច្បាំងនឹងព្រះអង្គទៀត ។ ទ័ពយួនពីរម៉ឺនទាក់បានលើកមកដល់ក្រុងភ្នំពេញ តែត្រូវបរាជ័យថយទៅស្រុកវិញអស់ ។ ចំណែកឯព្រះ**អង្គនន់** ទ្រង់រត់ចូលបន្ទាយ **ស្រីសន្ធរ** ការពារខ្លួន ។ ក្រោយមកដោយឈឺព្រះទ័យព្រោះបរាជ័យច្រើនដងពេក ក៏សុគតទៅក្នុងព្រះជន្មាយុ ៣៧ វស្សា ។

ចំពោះប្រតិបត្តិការសឹករបស់យួនលើកនោះ ឯកសារយួនបានផ្ដល់ភស្តុតាងថា ដោយយួនវាយសន្ធាប់ខ្លាំងពេក ព្រះ**អង្គសូ** ( Nac Thu ) ទ្រង់បានថយចូលការពារក្នុងបន្ទាយ ។ ព្រះអង្គទ្រង់បានបញ្ជាអោយNac Sa(?) នាំគ្រឿងបណ្ណាការទៅជូនមេទ័ពយួនឈ្មោះ **ម៉ាយ**

www.budinst.gov.kh www.elibraryofcambodia.org

វ៉ាន់ ឡុង ( Mai Van Long ) តែរាជទូតនោះត្រូវចាប់ឃុំជាឈ្លើយ ។ ដោយហេតុនោះ ព្រះអង្គបានបញ្ជាស្ត្រីរូបនោះម្នាក់ឈ្មោះ **Chiêm Dao Luât (?)** ជាអ្នកមានវោហារថ្វីមាត់ អោយយកវត្ថុមានតម្លៃដូចជាមាស ប្រាក់ជាដើមទៅជូនមេទ័ពយួនទៀត ។ មេទ័ពនោះនៅតែតឿនអោយព្រះអង្គលើកស្លួយសារអាករទៅថ្វាយ ។ ព្រះអង្គបានបញ្ជាស្ត្រីដដែលនោះអោយយកមាសប្រាក់ទៅស្លូកបាំទ់ថែមទៀតនិងសុំអោយរង់ចាំ ។ មេទ័ព Van Long ជឿពាក្យសន្យា មិនព្រមលើកទ័ពចូលវាយសោះ ។ មេទ័ពម្នាក់ទៀតឈ្មោះ **ង្វៀន ថាំង សឺន** ( Nguyên Thang Son ) ថ្វាយដំណឹងទៅស្តេចយួន ។ ព្រះអង្គទ្រង់ខ្ញាល់ខ្លាំង ចាត់អោយមេទ័ព **ង្វៀន ហ៊ឺន ហាវ** ( Nguyên Huu Hao) ទៅជំនួស ។ មេទ័ពនោះបានលើកទ័ពទៅបោះជំរំនៅ Bich-dôi (?) នៅ គ.ស. ១៦៩០ ។ ពេលនោះស្តេចយួនបញ្ជូនទូតអោយមកប្រាប់ថា : « ប្រសិនបើ **អង្គស៊ូ** ( Nac Thu ) ចង់រួចទោស ត្រូវលើកស្លួយមានដំរីឈ្មោល៥០ មាស ៥០០តម្លឹង ប្រាក់ ២០០០តម្លឹង កុយរមាស ៥០ ថ្វាយយ៉ាងប្រញាប់ បើពុំនោះទេត្រូវលើកទ័ពចូលវាយលុកក្រុង » ។ ព្រះ **អង្គស៊ូ** (Nac Thu ) ទ្រង់បានបញ្ជាអោយយកដំរីតូច ២០ ក្បាល មាស ១០០ តម្លឹង ប្រាក់៥០០ តម្លឹងទៅជូន **ង្វៀន ហ៊ឺន ហាវ** ។ មេទ័ពយួនភាគច្រើនយល់ថាព្រះ **អង្គស៊ូ** ( Nac Thu) មិនស្មោះត្រង់ សុំចូលវាយលុក តែព្រះអង្គបានបញ្ជាអោយនាង Dao Luât (?) ទៅអង្វរករសុំពន្យាពេលទៀត ។ មេទ័ព **ង្វៀន ហ៊ឺន ហាវ** យល់ថាយួនមិនបាច់ច្បាំងដណ្ដើមក៏ស្តេចខ្មែរព្រមចំណុះទៅហើយ ដូច្នេះមិនបាច់វាយលុកធ្វើអ្វី ។ ចាប់ពីពេលនោះមកពួកមេទ័ពយួនបែកបាក់គ្នា ។ ព្រះ **អង្គស៊ូ** ( Nac Thu ) ទ្រង់បញ្ជាអោយនាង Dao Luât (?) យកដង្វាយមានដំរីតូច ១០ ក្បាល កុយរមាស ៦ មាស ៥០តម្លឹង ប្រាក់ ១០០ តម្លឹងទៅជូនជាបន្ថែមទៀត ។ ដោយហេតុនោះ ទោះបីពួកសេនាសុំវាយលុកយ៉ាងណាក៏ដោយក៏ **ង្វៀន ហ៊ឺន ហាវ** ដកទ័ពថយទៅនៅត្រង់ **ឆាទា** ។ ស្តេចយួនខ្ញាល់ខ្លាំង ទ្រង់ដកហូតបុណ្យសក្តិពីមន្ត្រីរូបនោះ ។

ឯកសារយួនដដែលបានបញ្ជាក់ទៀតថា ប្រតិបត្តិការសឹកលើកនោះឃើញជាចាចទទួល

www.budinst.gov.kh www.elibraryofcambodia.org

ផលល្អដោយព្រះ **អង្គស៊ូ** (Nac Thu) ព្រមចំណុះនិងព្រមលើកស្លួយសារអាករថ្វាយ ៗ ជនវៀតណាមចូលនៅក្នុងទឹកដីខ្មែរកាន់តែច្រើនឡើង ៗ ទ័ពយួនយកដីនោះ (**បៀនហ៊ា-ឃាំនិញ**) ចែកជាតំបន់ ហើយចាត់មន្ត្រីអោយឈរត្រួតត្រាតែក្រោមដូវការនោះហើយ (37) ។

នៅ គ.ស. ១៦៩០ ព្រះ **ជ័យជេដ្ឋា** ទ្រង់មានបុត្រជាមួយ **អង្គលី** (អង្គអី ?) នាម**ធម្មរាជា** លើក**អង្គយ៉ង** បុត្រព្រះ **អង្គជី** អោយនាមថា**ឧត្ដិយរាជា** ហើយផ្សំផ្គុំនិងព្រះ **សុជាតិក្សត្រី** ( បុត្រីព្រះអង្គនន់ ) ជាជាយា ៗ ព្រះឧទ័យរាជាមានបុត្រនាម **អង្គតន់**ដែលតមកទៀតមាននាមថា **អង្គឧង** ៗ

លុះស្រុកបានសន្តិភាពឡើងវិញហើយ ព្រះ **ជ័យជេដ្ឋា** ទ្រង់បញ្ជាអោយសើរើច្បាប់សំរាប់រដ្ឋហើយរៀបចំឡើងវិញ ដោយមានការបន្ធូរបន្ថយទណ្ឌកម្មដែលមានលក្ខណៈធ្ងន់ហួសប្រមាណ និងការបំបាត់ចោលនូវទោសប្រហារជីវិតបង់ជន ៗ ម្យ៉ាងទៀត ព្រះអង្គក៏ទ្រង់បានរៀបចំអោយមានរូបមន្តសំរាប់ធ្វើសច្ចាប្រណិធានខាងនយោបាយនិងខាងតុលាការ ៗ

នៅគ.ស. ១៦៩២ ស្ដេចចាមនាម **បាត្រាញ់** (Ba Tranh) មិនព្រមលើកស្លួយសារអាករថ្វាយស្ដេចយួន ៗ ស្ដេច **ង្វៀន ភុក ជូ** (Nguyên phuc Chu) បញ្ជាអោយមេទ័ព **ង្វៀន ហ៊ីវ គិញ** (Nguyên huu Kinh) លើកទ័ពទៅវាយ ហើយចាមបាន ៗ រាជវង្សានុវង្សចាមនៅ **ផានរិច** (Phan-ri) **ផានរ៉ាង** (Phan-rang) ដោយមានបរិវារ៥០០០នាក់បានភៀសចូលមកសុំជ្រកកោននឹងព្រះ **ជ័យជេដ្ឋា** ៗ ព្រះអង្គក៏ទ្រង់សន្ដោសអោយទៅនៅ**ត្បូងឃ្មុំ** **ស្ទឹងត្រង់** **ព្រៃឈរ** **ព្រៃក្របាស** ៗ

នៅគ.ស. ១៦៩៥ ព្រះអង្គទ្រង់បង្វែររាជសម្បត្តិអោយទៅព្រះភាគិនេយ្យ (ក្មួយ) គឺព្រះ **ឧទ័យរាជា** (បុត្រព្រះអង្គជី) ៗ

## ព្រះបាទនាមាធិបតីទី ២ អង្គយ៉ង (គ.ស. ១៦៩៥-១៦៩៦).-

ព្រះ**ឧទ័យរាជា** កាលមានព្រះជន្ម ២១ វស្សា ទ្រង់បានទទួលរាជសម្បត្តិពីព្រះបិតុលានៅក្រុង **ឧដុង្គមានជ័យ** ទ្រង់មានព្រះនាមថា **ព្រះបាទសម្ដេចព្រះនារាយណ៍រាមាធិបតី ព្រះឧទ័យរាជាបរមបពិត្រ** ។ ព្រះអង្គទ្រង់លើកព្រះ **សុជាតិវតី** ជា-

www.budinst.gov.kh www.elibraryofcambodia.org

អគ្គមហេសី ។ ព្រះអង្គឡើងសោយរាជ្យបានតែ ១០ ខែ ទ្រង់អាពាធ ហើយសោយទីវង្គតទៅ ។

## ព្រះបាទជ័យជេដ្ឋាទី ៣ (រជ្ជកាលទី ៣ : ១៦៩៦-១៦៩៩).—

កាលដែលដាក់រាជ្យថ្វាយទៅព្រះ **ឧទ័យរាជា** នោះ ព្រះបាទ **ជ័យជេដ្ឋាទី៣** បានចេញទ្រង់ផ្នួសបាន ៥ ថ្ងៃ រួចលាផ្នួសមកវិញ ។ លុះភាគិនេយ្យសោយទីវង្គតទៅ ព្រះអង្គឡើងសោយរាជ្យជាលើកទី ៣ ។

នៅគ.ស. ១៦៩៧ ដោយមានព្រះបំណងប្រមែប្រមូលរាជវង្សានុវង្ស ព្រះអង្គទ្រង់បានបញ្ជានាម៉ឺនអោយលើកគ្រឿងបណ្ណាការទៅថ្វាយស្ដេចយួន ដើម្បីសុំព្រះ **អង្គអិម** មកវិញ ។ ព្រះអង្គទ្រង់សព្វព្រះទ័យលើក **អង្គអិម** ជា **ព្រះកែវហ្វា** ហើយទ្រង់លើកបុត្រីព្រះអង្គព្រះនាម **សម្ដេចព្រះមហាក្សត្រី** អោយជាទេពីទៀត ។ ក្រោយមក **ព្រះកែវហ្វា** មានបុត្រនាម **អង្គជី** (សម្ដេចព្រះសត្ថា) ។

នៅគ.ស ១៦៩៩ **ឧកញ៉ានរិន្ទអិម** ជាកូន **ឧកញ៉ាមហាសេនាមិញ** ចូលចិត្តខ្វល់ញុះញង់មន្ត្រីឯទៀត ហើយមិនគោរពខ្លាចព្រះចេស្ដាផង ។ ព្រះរាជាទ្រង់ជេរបន្ទោសប្រដៅទូន្មានកុំអោយប្រព្រឹត្តអាក្រក់ទៀត ។ មន្ត្រីរូបនោះនឹកខ្មាសព្រះស្នំ រកឧបាយ-កលក្បត់ ធ្វើពុតជាឈឺ ថ្វាយត្រាលាផារចេញពីរាជការ រួចទៅធ្វើជំនួញនៅស្រុកក្រោម ជួបនឹងមន្ត្រីយួនក៏និយាយញុះញង់ថា ស្ដេចខ្មែរមិនប្រកបដោយធម៌ ហើយយកសៀមជាមិត្តគិតវាយយួន ។ ម្ល៉ោះហើយ មន្ត្រីរូបនោះក៏សុំអង្វរអោយយួនជួយទំនុកបំរុងខ្លួនជាជំនួយកងទ័ពដើម្បីលើកទៅវាយព្រះរាជា ។

ស្ដេចយួនព្រះនាម **ហៀន តុង** ( Hiên-tông ) អោយលើកទ័ព ៤០០០០ នាក់ និងទូក ៥០០ ( ឯកសារខ្លះថាតែ ២០០០០ នាក់ - 42 ) ទៅរហូតដល់បឹងទន្លេសាប ។ ពេលនោះ ព្រះ **ជ័យជេដ្ឋា** និងពួកបរិវារភៀសទៅនៅពោធិសាត់ ហើយកែនទ័ពប្រយុទ្ធនឹងយួនវិញ ។ ទ័ពខ្មែរត្រូវចែកជា ២ កង :- ១ ស្ថិតនៅក្រោមបញ្ជាការរបស់ព្រះ **ធម្ម**

www.budinst.gov.kh www.elibraryofcambodia.org

១៨៦ ត្រូវយាងសុំត្រ ១ ទៀតទៅក្រោមបញ្ជាការរបស់ព្រះ អង្គអិម ព្រះភាគិនេយ្យ ទ័ពទាំង ២ គន ដើងគោគមិនដើងទឹកលើកទៅប្រសព្វគ្នានៅកំពង់ឆ្នាំង វាយផ្តួលហើយ ក្រញ ប្រានទ័ពយួនអោយថយពីស្រុកខ្មែរតាមទន្លេមេគង្គ (42) ប៉ុន្តែវាពុំព្រមត្រឡប់ទៅស្រុក យួនវិញទេ បែរជាក្រាញនៅក្នុងដីខ្មែរត្រង់ ព្រៃនគរ កំពង់ស្រកាត្រី បាសាក់



www.budinst.gov.kh www.elibraryofcambodia.org

**ឧកញ៉ាំឧទិន្ទនិម** បានសន្យាថាទុកជាផ្ទុរទឹកជំនួយចំពោះយួនសំរាប់លោកវាយនគរផាត... (ស្ទូមមើលរជនទី) ។

ចាប់តពេលនោះមក ស្តេច **ហៀន តុង** បានបញ្ជាអោយលោក **ង្វៀង ហ៊ីុង គិញ** ចូលមករៀបចំទឹកដីរបស់ខ្មែរដែលយួនទើបយកជាកម្មសិទ្ធិរបស់គេនោះ ។ លោកក៏យកស្រុក **ដូនណៃ** បង្កើតជាស្រុក **ភឿក ឡុង** (Phuoc-long) យកដី **ប៉ៀងនា** បង្កើតជាបន្ទាយ **ត្រឹង បៀន** ( Trân biên ) យកដី **ព្រៃនគរ** បង្កើតជាស្រុក **តឹង ប៊ិញ** ( Tân-binh ) យកដី **យ៉ាំឌិញ** ( ឧកញ៉ាឌិន ? ) បង្កើតបន្ទាយ **ភៀន ត្រឹង** ( Phiên trân ) ។ រួចស្តេចយួនបញ្ជាអោយប្រមែប្រមូលរាស្ត្រពី **ក្វាង ប៊ិញ** ( Quang Binh) អោយចូលមករស់នៅលើទឹកដីថ្មី បង្កើតជាភូមិ ជាស្រុក និងផ្ការដី ធ្វើស្រែធ្វើចំការ ។ កាលណោះ ជនជាតិចិនក៏មានចំនួនកើនឡើងកាន់តែច្រើនហើយ យួនក៏បង្កើតស្រុកភូមិអោយពួកនោះរួចចាប់ផ្តើមធ្វើនយោបាយសមានកម្ម : ជនជាតិចិនដែលនៅត្រង់ដី **ត្រឹង បៀន** និង **ភៀន ត្រឹង** គេតម្រូវអោយចូលសញ្ជាតិយួនទាំងអស់ (37-40) ។

គួរគប្បីបញ្ជាក់ថា មន្ត្រីយួនទាំងប៉ុន្មានដែលមកឈរនៅត្រង់តំបន់ខាងលើនោះ ត្រូវឡើងទៅមេទ័ពម្នាក់ដែលកាន់កាប់អំណាចខាងយោធាផង និងអំណាចខាងរដ្ឋបាលផង ហើយដែលមានបញ្ជាការដ្ឋានតាំងនៅ **ព្រៃនគរ** ។

ចំណែកឯទឹកដីខ្មែរនៅត្រង់ **មេសរ** យួនបានដាក់អំណាចត្រួតត្រា តែនៅត្រូវផ្លូវការនៅឡើយ ។

នៅដំណាច់គ.ស. ១៦៩៩ ព្រះ **ជ័យជេដ្ឋា** ទ្រង់បង្វែររាជសម្បត្តិថ្វាយទៅព្រះ **កែវហ្វាអង្គអិម** ព្រះរាជបុត្រប្រសាដែលទ្រង់បានច្បាំងឈ្នះយួន ហើយចាប់បានទាំង **ឧកញ៉ាឧទិន្ទនិម** ទៀតផង ។

## – ព្រះកែវហ្វាទី ៣ អង្គអិម (១៦៩៩-១៧០០).-

ព្រះ **កែវហ្វាអង្គអិម** ឡើងសោយរាជ្យស្នងព្រះបិតុលា គង់នៅ **លង្វែកសាំងតាក់** នៅ

www.budinst.gov.kh www.elibraryofcambodia.org

ពោធិសាត់ ។ ចំណែកឯព្រះ **ជ័យជេដ្ឋា** កាលជាក់រាជ្យនោះ ព្រះអង្គចេញទ្រង់ផ្នួសនៅក្នុង **ឧត្តពោធិវិហារបុណ្យ**បាន៣ថ្ងៃ ក៏លាផ្នួស ទើបសម្ដេចព្រះ **កែវហ្វា** លើករាជសម្បត្តិថ្វាយព្រះអង្គ ព្រះអង្គទ្រង់ទទួលសោយរាជសម្បត្តិវិញ ។ ឯកសារខ្លះនិយាយថា ដោយយល់ថាព្រះបិតាក្មេកមានគុណទើបព្រះ **កែវហ្វា** ថ្វាយរាជសម្បត្តិព្រះអង្គវិញ ប៉ុន្តែឯកសារខ្លះទៀតនិយាយថាដោយព្រះអង្គគ្មានសមត្ថភាពគ្រប់គ្រងរដ្ឋ ទើបព្រះបិតាក្មេកយករាជ្យមកវិញ (9) ។

## ៧– ព្រះជ័យជេដ្ឋាទី ៣ (រជ្ជកាលទី ៤ : ១៧០០–១៧០២).-

ក្នុងរជ្ជកាលទី ៤ នេះ មានការបះបោររបស់មន្ត្រីម្នាក់ឈ្មោះ **គិម** ដែលមានយួនគាំទ្រ ។ ដំបូង ព្រះអង្គត្រូវភៀសទៅពោធិសាត់ជាមួយពួកបរិវារ ក្រោយមកមានជ័យជំនះហើយចាប់បានមេបះបោរនោះទៀត (9) ។

ឯកសារយួនមួយនិយាយថានៅគ.ស. ១៧០០ មេទ័ពជាតិចិនឈ្មោះ **ត្រឹន ធឿង ស្វៀន** (Trân Thuong Xuyên) ដែលបានបំរើស្ដេចយួននោះ បានឲ្យដំណឹងថាខ្មែរច្រើនលើក (ប្រហែលគាំទ្រមន្ត្រីឈ្មោះគិមនោះឬ?)បានលើកទ័ពមកដល់បន្ទាយ Bich-dôi (?) និងភ្នំពេញ ។ **អង្គស៊ូ** (Nac Thu) ដកថយ បន្ទាយត្រូវវាយបែក ពួកសេនាទាហានសុំចុះចាញ់ មេទ័ព **ង្វៀន ហ៊ឺន គិញ** ចូលបន្ទាយលួងលោមប្រជារាស្ត្រ ។ ក្រោយមក **អង្គស៊ូ** (Nac Thu) ក៏មកសុំចំណុះទៀត ។ យួនក៏ដកថយទៅវិញអស់ (37) ។ ចំពោះព្រឹត្តិការណ៍បែបនេះ តើការពិតស្ថិតនៅត្រង់ណា ? ឯកសារខ្មែរមិនឃើញនិយាយសោះ ។

## ៨– ព្រះបាទស្រីធម្មរាជាទី ៣ (១៧០២–១៧០៣).-

នៅគ.ស. ១៧០២ ព្រះបាទ **ជ័យជេដ្ឋាទី៣** ដោយឃើញព្រះរាជបុត្រនាម **ធម្មរាជា** ដែលមានព្រះជន្មតែ ១២ វស្សាមានឫកពាសមរម្យ ក៏បន្ទោររាជ្យថ្វាយ ប៉ុន្តែមិនបានធ្វើពិធីរាជាភិសេកទេព្រោះមានវ័យនៅក្មេងពេក ។

www.budinst.gov.kh www.elibraryofcambodia.org

គ្រានោះ មានសំរែម្នាក់ឈ្មោះ **តះប្រេហ្សង** នៅស្រុក **គុឡា** (ភូមា ?) បានបះប្រទាំង ព្រះរាជា ។ ដោយមានការថ្វាយយោបល់ពីមន្ត្រីព្រះអង្គទ្រង់ពញ្ញាអោយលើកទ័ពទៅបង្ក្រាប សំរែនោះបាននៅចុងខេត្តពោធិសាត់ ហើយយកទៅបញ្ចូលជាពលរក្សាប្រាសាទនគរវត្ត ។

នៅ គ.ស. ១៧០៣ ព្រះរាជាយាងពីពោធិសាត់មកគង់នៅរាជធានី **ឧដុង្គ** វិញ ។ លុះគ្រងរាជ្យបាន ១ ឆ្នាំ ព្រះអង្គទ្រង់លើករាជ្យថ្វាយទៅព្រះបិតាវិញ ។

## ៩– ព្រះបាទជ័យជេដ្ឋាទី ៣ ( រជ្ជកាលទី៥: ១៧០៣–១៧០៦ ).–

នៅ គ.ស. ១៧០៤ រាជវង្សានុវង្សលាវមួយអង្គដោយបរិវារ ៥០០០ នាក់បានភៀស មកសុំជ្រកកោនពីព្រះរាជាខ្មែរ ។ ព្រះអង្គទ្រង់សព្វព្រះទ័យទទួលអោយទៅរស់នៅក្នុង ខេត្ត **បាទី** នៅជិតភូមិលាវដែលជាឈ្លើយខ្មែរតាំងពីសម័យលង្វែកម៉្លេះ ។ ឯហេតុដែល នាំអោយមានការភៀសខ្លួននោះ មកពីកាលណោះនៅរាជាណាចក្រ **ទៀមចន្ទ** មាន កើតចម្បាំងគ្នាឯងក្នុងស្រុកតាំងពី គ.ស. ១៧០០ ម៉្លេះ ។ ទេសាភិបាលក្រុង Na-Khône ឈ្មោះ Nan Tharat បានបះដណ្តើមយករាជសម្បត្តិសោយ បណ្តាល អោយមានការរើករក្នុងផ្ទៃប្រទេស ។

លុះព្រះរាជបុត្រមានព្រះជន្ម ១៦ វស្សាហើយ ព្រះរាជាដាក់រាជ្យថ្វាយម្តងទៀត ។

## ១០– ព្រះបាទធម្មរាជាទី ៣ ( រជ្ជកាលទី២: ១៧០៦–១៧០៩ ).–

ព្រះអង្គធ្វើពិធីអភិសេកឡើងសោយរាជ្យ ដោយមានព្រះនាមសំរាប់រាជ្យថា **ព្រះស្រី ធម្មរាជាធិរាជរាមាធិបតីបរមបពិត្រ** ។ ឯព្រះបិតាដែលដាក់រាជ្យនោះទ្រង់មានឋានៈ ជាក្សត្រិយ៍ **ឧភយោរាជ** ។

នៅ គ.ស. ១៧០៦ ព្រះម៉ែនាង **ស្រីបុប្ផា** ប្រសូតបុត្រនាម **អង្គអិម** ។

នៅ គ.ស. ១៧០៧ ព្រះ **អង្គឯម** មានបុត្រនាម **អង្គស្ងួន** ក្រោយមកមាននាម ជា **ឧទ័យរាជា** ។ ចំណែកឯព្រះម្នាង **ជាតិក្សត្រី** មានបុត្រនាម **អង្គចន្ទ** ( ឯកសារ

www.budinst.gov.kh www.elibraryofcambodia.org

ទ្រង់ហៅ: ចៅពញាចន្ទ ) ក្រោយមកមាននាមហៅថា ធម្មរាជា និងព្រះ កែវហ្វា ។

នៅគ.ស.១៧០៧ដដែល ដោយឃើញថាផ្ទៃក្នុងរបស់ខ្មែរនៅតែមានភាពច្របូកច្របល់ដដែល ចិនឈ្មោះម៉ាគគីវបានលើកដង្វាយទៅថ្វាយសំដែងភក្តីភាពចំពោះស្តេចយៀន ហើយទូលសុំធ្វើចៅហ្វាយខេត្តពាម ។ ស្តេចហៀន តុខទ្រង់យល់ព្រមតាមសំណើនោះ ។ ដូច្នេះ ចាប់ពីគ.ស. ១៧០៧ ភូមិភាគ ពាម ក៏បានក្លាយទៅជាសាមន្តរដ្ឋរបស់យួន ។ ពេលនោះ មានជនជាតិយួនបានចូលរស់នៅរាយប៉ាយលើទឹកដីខ្មែរ ។ ស្តេចហៀន តុខ ទ្រង់ចាត់អោយសេនាទៅប្រមែប្រមូលពួកនោះ ចែកដីធ្លីអោយដើម្បីបង្កើតភូមិគ្រាម លើកលែងមិនអោយបំពេញកិច្ចការខាងកំណែនផ្សេង ៗ ខាងយោធា ហើយមិនបាច់បង់ពន្ធក្នុងរយៈពេល ៣ ឆ្នាំ ។

នៅគ.ស. ១៧០៩ ព្រះមិនាង ស្រីធុជ្ញា ប្រសូតបុត្រនាម អង្គស្ងួន ។ នាឆ្នាំនោះព្រះ ធម្មរាជា ដោយមានព្រះបំណងធ្វើការត្រួតពិនិត្យពួកលាវដែលបានភៀសខ្លួនមកនៅក្នុងខេត្ត បាទី នោះ ទ្រង់បញ្ជាអោយប្រមូលពួកនោះទៅរស់នៅមួលគ្នាឯ កោះរាម ព្រៃ ៣ តែពួកនោះមិនយល់ព្រម បែរជាបះបោរប្រឆាំងនឹងព្រះរាជបញ្ជា ។ ព្រះរាជាទ្រង់បង្គាប់អោយលើកទ័ពទៅបង្ក្រាប បំបែកពួកនោះជា ៣ ក្រុម :

- ១ ក្រុមរត់ទៅនៅព្រៃលើ
- ១ ក្រុមរត់ទៅស្រុកក្រោម
- ១ ក្រុមរត់ទៅចូលព្រះ កែវហ្វាអង្គឹម ដែលត្រូវដាក់រាជ្យនៅ គ.ស. ១៧០០ នោះ ។ ស្តេចអង្គនេះទំនងជាមានគំនុំនឹងព្រះបិតុលា (ជ័យជេដ្ឋាទី៣) ក្នុងការដែលព្រះអង្គទ្រង់បានយករាជសម្បត្តិទៅវិញនោះ បានចូលដៃជាមួយស្តេចមួយអង្គទៀតនាមសុគន្ធបទ ហើយបំបះបំបោរពួកលាវដែលត្រូវបានយួនផ្តល់ជំនួយទ័ព២០០០០ នាក់ ។ ម្យ៉ាងទៀត ព្រះ អង្គឹម ទ្រង់ចាត់អោយទៅបញ្ចុះបញ្ចូលរាស្ត្រព្រៃលើ មាន គួយ សំរែ បានពល ១០០០០ នាក់ទៀត លើកទៅវាយយកបានខេត្តខាងកើតរួចទ្រង់ទន្ទ្រានយកទ័ពទៅឡោមព័ទ្ធវាំង ឧដុង្គ ( គ.ស.១៧១០ ) ។ ក្រោយពីតស៊ូអស់រយៈពេល៣ខែ ព្រះធម្មរាជា

www.budinst.gov.kh www.elibraryofcambodia.org

បានភៀសព្រះអង្គទៅប្រទេសសៀមក្នុងពេលរាត្រីជាមួយនឹងព្រះ **អង្គឥង** (បុត្រព្រះឧទ័យរាជា អង្គយ៉ង) និងព្រះរាជបុត្រព្រះអង្គ គឺ**អង្គអិម** ។

ដូច្នេះ នេះជាលើកទី ២ ហើយដែលមានស្ដេចខ្មែរបានរត់ទៅពឹងពាក់អោយសៀមជួយយកអាសា ។ ស្ដេចទី ១ គឺ**ចៅពញាចន្ទ** ឬ **ចន្ទរាជា** ។

## ១១– ព្រះកែវហ្វ៉ាទី ៣ អង្គអិម (រជ្ជកាលទី ២ : ១៧១០–១៧២២).-

លុះព្រះ **ធម្មរាជា** ភៀសចេញទៅបាត់ហើយ មន្ត្រីទាំងឡាយក៏អញ្ជើញព្រះ**អង្គអិម** ឡើងគ្រងរាជ្យស្នងព្រះអនុជ ។ ប៉ុន្តែ ៤ ឆ្នាំក្រោយមកទៀតទើបព្រះអង្គធ្វើពិធីអភិសេក ដោយមានព្រះនាមសំរាប់រាជ្យថា **ព្រះអង្គអិមសម្ដេចព្រះកែវហ្វ៉ា** ។

នៅគ.ស. ១៧១៤ ព្រះចៅក្រុង **ស្រីអយុធ្យា** ទ្រង់ចាត់អោយមន្ត្រី ២ នាក់គឺ **ចៅពញាពលទេព** និង **ពញាសស្វាធតី** ជាមួយនឹងកងទ័ព ១៥ ០០០ នាក់នាំស្ដេចទាំង ៣ អង្គមកចរចាស្ពានមេត្រី ។ ពេលយាត្រាមកដល់ក្រុងបាត់ដំបង **សម្ដេចព្រះកែវហ្វ៉ា** ព្រះអង្គមិនព្រមទទួលជាស្ពានមេត្រី ក៏ត្រឡប់ទៅក្រុង **អយុធ្យា** វិញ ។

បន្ទាប់ពីនោះ **ព្រះកែវហ្វ៉ាអង្គអិម** ទ្រង់បានប្រគល់រាជសម្បត្តិអោយសម្ដេចព្រះអគ្គមហេសី ហើយចេញទ្រង់ផ្នួសបាន៣ថ្ងៃ រួចព្រះអង្គលាផ្នួសវិញ ។

នៅគ.ស. ១៧១៥ ដោយមានការគាំទ្រពីព្រះចៅសៀមផង ព្រះ**អង្គឥង**ត្រូវចាត់អោយលើកទ័ពចូលមកដល់ខេត្តពោធិ៍សាត់ ដែលមានប្រជារាស្ត្រភាគច្រើននៅស្រឡាញ់រាប់អានព្រះ **ធម្មរាជា** នៅឡើយ ។ លុះទ្រង់ទទួលពត៌មានថារាស្ត្រនៅពោធិ៍សាត់បះបោរនាំងព្រះអង្គហើយ **ព្រះកែវហ្វ៉ាអង្គអិម** ទ្រង់បញ្ជាអោយទ័ពយួនលើកទៅវាយ ។ ព្រះ**អង្គឥង** ត្រូវរបួសថយទៅនៅឫស្សីសាញ រង់ចាំជំនួយទ័ពមកពីប្រទេសសៀម ។

ពីគ.ស. ១៧១៩ ដល់ ១៧២២ ព្រះចៅសៀមទ្រង់បញ្ជាអោយលើកទ័ពជើងទឹក ៥០០០ នាក់ មកវាយខេត្ត **ពាម** និងទ័ពជើងគោក ១០០.០០ នាក់នាំព្រះ **ធម្មរាជា** និងព្រះរាជបុត្រត្រឡប់ចូលប្រទេសខ្មែរម្ដងទៀត ។ ទ័ពជើងទឹករបស់សៀមត្រូវមេទ័ពជាតិចិន

www.budinst.gov.kh www.elibraryofcambodia.org

ឈ្មោះ **មាំក គីន** វាយអោយថយទៅវិញ ប៉ុន្តែទ័ពជើងគោកបានជំរុលទៅដល់ក្រុងឧដុង្គ ។

ដោយឃើញស្ថានភាពដុនដាបពេកហើយ ហើយក្រោយពិពិគ្រោះជាមួយពួកមន្ត្រី **សម្តេចកែវហ្វា** ទ្រង់ចាត់មន្ត្រីជាន់ខ្ពស់ម្នាក់ទៅធ្វើការចរចាជាមួយមេទ័ពសៀម សុំចងស្ពានមេត្រីហើយព្រមនាំរាជសារជំបារមាសឡើងសៀមតាមទំនៀម ។ ដោយឃើញថាព្រះកែវហ្វា ព្រមផ្តល់អត្ថប្រយោជន៍ច្រើនដល់ជាតិគេ សៀមក៏យល់ព្រមហើយនាំស្តេចខ្មែរអភ័ព្វទាំង ៣ ត្រឡប់ចូលស្រុកសៀមវិញអស់ ។

## ១២–ព្រះបាទសត្ថាទី ២ អង្គជី (រជ្ជកាលទី ១ : ១៧២២-១៧២៩).–

នៅគ.ស.១៧២២ ព្រះ **កែវហ្វា អង្គអិម** ទ្រង់ប្រគល់រាជសម្បត្តិអោយរាជបុត្រនាម **អង្គជី** ។ ព្រះអង្គមាននាមសំរាប់រាជ្យថា **សម្តេចព្រះសត្ថា** សោយរាជ្យនៅក្រុងឧដុង្គលើក **សម្តេចព្រះស្រីសុជាតា** ( បុត្រីព្រះជ័យជេដ្ឋា ) ជាអគ្គមហេសី ។

ពេលនោះ ប្រជាជននៅនាងផ្អែកបះបោរប្រឆាំងនិងព្រះអង្គ ព្រះអង្គទ្រង់អោយលើកទ័ពទៅបង្ក្រាបរាបទាបបានវិញ ។

នៅ គ.ស. ១៧២៩ **ព្រះសត្ថា** ទ្រង់លើករាជសម្បត្តិថ្វាយទៅព្រះបិតាវិញ ។ ព្រះអង្គក៏ព្រមទទួលឡើងសោយរាជ្យជាលើកទី៣ ។

## ១៣– ព្រះកែវហ្វាទី ៣ អង្គអិម ( រជ្ជកាលទី៣ : ១៧២៩ ).–

ព្រះអង្គសោយរាជ្យបានតែ ៧ ខែ ហើយមានព្រះនាមសំរាប់រាជ្យថា **ព្រះបាទសម្តេចស្តេចព្រះជ័យជេដ្ឋាធិរាជរាមាឥស្សរអំពូលលោកីយត្រៃក្រែតានាថ** ។ នៅដំណាច់ គ.ស. ១៧២៩ ព្រះអង្គទ្រង់បង្វែររាជ្យអោយព្រះរាជបុត្រសាជាថ្មីម្តងទៀត ។

## ១៤– ព្រះបាទសត្ថាទី២ អង្គជី (រជ្ជកាលទី ២ : ១៧២៩-១៧៣៧).—

ព្រះអង្គមាននាមសំរាប់រាជ្យថា **ព្រះបាទសម្តេចស្តេចព្រះរាជាឱង្ការព្រះបរមរាជាធិរាជរាមាធិបតី** ។ ព្រះបិតាទ្រង់ស្ថិតនៅជាឧភយោរាជ ។

www.budinst.gov.kh www.elibraryofcambodia.org

នៅ គ.ស ១៧៣០ មានលាវម្នាក់នៅ **ប្រសូត ជាតិ** តាំងខ្លួនជាអ្នកមានបុណ្យ ធម្មិកជន ៗ មានខ្មែរជាច្រើនជឿតាម លាវនោះក៏លើកទៅវាយយួនរហូតដល់ **ព្រៃនគរ** ៗ ស្ដេច **ទុក តុង** (Tuc Tông) បញ្ជាអោយមេទ័ពឈ្មោះ **ទ្រឿង គឿក វិញ** (Truong-phuoc Vinh) លើកទ័ពទៅបង្ក្រាប (37) ៗ ពួកនោះចាក់ទ័ព ថយចូលស្រុកខ្មែរវិញ តែបានសម្លាប់រង្គាលជនជាតិយួនទាំងឡាយដែលខ្លួនបានជួបប្រទះ ៗ លុះទ្រង់ជ្រាបពីឧប្បត្តិហេតុខាងលើនោះ **ព្រះសត្ថា** ទ្រង់បញ្ជាអោយលើកទ័ពទៅបង្ក្រាបអោយរាបទាបវិញអស់ ៗ ប៉ុន្តែនៅឆ្នាំក្រោយ ( គ.ស. ១៧៣១ ) យួនបានលើកទ័ពមកសងសឹកខ្មែររហូតដល់ក្រុងភ្នំពេញ ៗ **ព្រះសត្ថា** ទ្រង់ថយទ័ពទៅនៅ **ពាមស្រែគ្រង** ( ស្រីសឈរ ) សិន ៗ លុះកែនទ័ពបានគ្រប់ល្មមហើយ ព្រះអង្គទ្រង់លើកមកវាយយួន យួនថយទៅវិញអស់ ៗ

ក្រោយមក ស្ដេចយួនបញ្ជាអោយលើកទ័ពមកច្រើនជាងមុនទៀត ៗ **ព្រះសត្ថា** ទ្រង់ថយទៅគង់នៅ **ពាមក្រសោ** ( អាសន្ទុក ) កែនទ័ពរួចលើកទៅប្រយុទ្ធនឹងយួន ៗ ខ្មែរមានជ័យជំនះទៀត ៗ

ក្រោយពីនោះ **ព្រះសត្ថា** និងរាជវង្សានុវង្សយាងទៅគង់នៅលង្វែកវិញ ៗ

ចំពោះព្រឹត្តិការណ៍ខាងលើ ឯកសារយួន (37) បាននិយាយថា **ព្រះសត្ថា** ដោយខ្លាចមានទោសកំហុសធ្លាក់មកលើព្រះអង្គ ក៏បានថយទៅ **សឺន បូ** (Son-bô?) ហើយទ្រង់ផ្ញើសារលិខិតទៅមេទ័ពយួនជាសុំអោយពន្យារពេលដើម្បីព្រះអង្គបង្ក្រាបជនបះបោរ ៗ ប៉ុន្តែពួកបះបោរនៅតែបន្តសកម្មភាពសម្លាប់យួនដដែល ៗ មេទ័ពយួនឈ្មោះ **ទ្រឿង គឿក វិញ** បានបន្ទោស**ព្រះសត្ថា**ថាចូលដៃនឹងពួកបះបោរ ៗ ព្រះអង្គភិតភ័យខ្លាំង ទ្រង់ថយទៅ**សឺន បូ ( ? )** ទ្រង់បញ្ជាអោយយកវត្ថុមានតម្លៃទៅសូកប៉ាន់ដើម្បីទុកពេលអោយព្រះអង្គបង្ក្រាបពួកបះបោរ ៗ ទ័ពយួនវាយលុកចូលដល់ Lô-viet (អង្គរវត្ត) ព្រះ**សត្ថា**ទ្រង់ប្រើឧបាយសម្លាប់បានពួកលាវបះបោរ រួចចេញសារភាពទូលទោសនោះចំពោះទ័ពយួន ៗ ទ័ពយួនក៏ដកថយវិញអស់ទៅ ៗ

www.budinst.gov.kh www.elibraryofcambodia.org

ប្រកបយួនដដែលបានញាក់ថា ក្រោយពីមានជ័យជំនះក្នុងការបង្ក្រាបពួកបះបោរនោះហើយ ស្ដេចយួននាម **ទុក តុង** (Tuc-tông) តម្រូវអោយ **ព្រះសត្ថា** លើកអោយយួន ២ ខេត្ត គឺ **ខេត្តមេសរ** និង **លង់ហោរ** ( គ.ស. ១៧៣២ ) ដោយយកលេសថា ដើម្បីការពារជនជាតិយួនដែលបានទៅរស់នៅជាច្រើននៅត្រង់តំបន់នោះហើយ (42)។

ដូច្នេះ ជនជាតិយួនបានចូលដល់ទន្លេមេគង្គហើយក្នុងដំណើរសំរុកមកទិសខាងត្បូងរបស់ខ្លួន ។ នៅក្នុង **ខេត្តលង់ហោរ** យួនបានបង្កើតបន្ទាយ **ឡុង ហោ** (Long-hô)។ ចំណែកឯ **មេសរ** នៅរក្សាលក្ខន្តិកៈចាស់ដដែល ។

ចំណែកឯព្រះ **ធម្មរាជា** កាលដែលយាងទៅគង់នៅឯក្រុង **អយុធ្យា** ឯណោះ មានម្ចាស់សៀមឈ្មោះ **ម៉មរ៉ត** ហើយមានបុត្រា ២ អង្គនិងបុត្រី ១ អង្គ គឺ :

— **អង្គហ៊ីង**

— **អង្គជួង**

— **អង្គស្រោតត្រ្យត្រី**

នៅ គ.ស. ១៧៣៥ ព្រះអង្គទ្រង់ប្រទានដល់ព្រះរាជបុត្រ **អង្គអិម** នូវនាម **ធម្មរាជា** ដូចព្រះអង្គដែរ ។ បន្ទាប់មក ព្រះ**ធម្មរាជា** បុត្រទ្រង់បានសូមអនុញ្ញាតពីព្រះចៅសៀមអោយព្រះអង្គបានវិលត្រឡប់ចូលមាតុភូមិវិញដើម្បីគិតការផែនដី ។ លុះព្រះចៅសៀមទ្រង់បានយល់ព្រមតាមសំនើរហើយ ព្រះអង្គក៏យាងទៅគង់ត្រង់តំបន់ **នគររាជសីមា** បញ្ជូនទូតទៅចរចាសុំចងស្ពានមេត្រីជាមួយ **ព្រះសត្ថា** តែពុំបានផលអ្វីសោះ ព្រះអង្គក៏គង់នៅ **នគររាជសីមា** នោះសិនទៅ ។

គួរគប្បីជ្រាបថានៅ គ.ស. ១៧៣៥ ដដែលនោះ ចិនឈ្មោះ **ម៉ាក គីវ** (ម.ក.ឃ) ត្រួតតំបន់មាត់សមុទ្រខ្មែរបានទទួលមរណភាព ។ ស្ដេចយួននាម **ទុក តុង** (Tuc-tông) ទ្រង់លើកអោយកូនលោកឈ្មោះ **ម៉ាក ធៀន ធូ** (Mac Thiên Tu) ដែលមានម្ដាយជាតិយួនឡើងកាន់តំណែងជាជំនួសឪពុក ។ កាលណោះ តំបន់ **ពាម** បានក្លាយទៅជាតំបន់ពាណិជ្ជកម្មមួយយ៉ាងសំខាន់ ។ ដោយហេតុនោះ ស្ដេចយួនទ្រង់ប្រទានអោយ

www.budinst.gov.kh www.elibraryofcambodia.org

សំពៅធំ ៣ គ្រឿងសំរាប់ទាក់ទងជាមួយចិនបារាំងស ។ មន្ត្រីថ្មីរូបនោះ ក៏បានកែនទំព សង់បន្ទាយ សង់ជ្រារ សង់ក្រុង ៗ ក្ដាប់ល់បរទេសចេញចូលធ្វើជំនួញកាន់តែច្រើនឡើង ៗ ចំណែកស្លាកក៏បានបញ្ជូនទំនិញចេញទៅលក់ដល់ប្រទេសជប៉ុនឯណោះ (37) ។

នៅ គ.ស. ១៧៣៦ ព្រះសត្ថាទ្រង់មានព្រះទ័យសង្ស័យលើរូបអគ្គមហេសីផ្ទាល់របស់ព្រះអង្គគឺ **សម្ដេចព្រះស្រីសុជាតា** និងក្សត្របីអង្គគឺ : **អង្គស្ងួន** (បុត្រព្រះអង្គទង ដែលភៀសទៅសៀម) **អង្គស្ងួន** និង **អង្គចន្ទ** (បុត្ររបស់ព្រះធម្មរាជាទី ៣ ដែលភៀសទៅសៀម (ថាមានគំនិតក្បត់ចំពោះព្រះអង្គ ទើបព្រះអង្គយាងទៅស្ថិតនៅក្រុងភ្នំពេញ ហើយបញ្ជាអោយមនុស្សមកព័ទ្ធដើម្បីធ្វើគត់ស្ដេចទាំង ៤ អង្គនោះ ។ ប៉ុន្តែក្សត្រាទាំង ៣ អង្គ បានប្រមូលរាស្ត្រនៅក្រុងលង្វែកហើយលើកមកប្រយុទ្ធនឹង **ព្រះសត្ថា** ហើយមានជ័យជំនះ ។ **ព្រះសត្ថា** ទ្រង់ភៀសព្រះអង្គទៅប្រទេសយួនជាមួយនឹងព្រះអនុជពៅនាម **អង្គអិម** (ឯកសារខ្លះថាអង្គអ៊ុង) នៅ គ.ស ១៧៣៧ ។

បន្ទាប់ពីនោះ ក្សត្រទាំង ៣ អង្គទ្រង់បានចាត់ចែងការពារដោយទប់ទល់នឹងការវិលត្រឡប់មកវិញរបស់ព្រះ **សត្ថា** ដែលគេជឿជាក់ថាមុខជាមានទ័ពយួនមកជាមិនខាន ។ ម្ល៉ោះហើយ ព្រះ**អង្គស្ងួន** យាងទៅគង់នៅ **បាភ្នំ** ត្រើយខាងកើត ឯព្រះ **អង្គចន្ទ** យាងទៅគង់នៅត្រើយខាងលិច ដើម្បីចាំកាំងផ្លូវទ័ពយួនដែលនឹងលើកមកតាមផ្លូវទឹក ។

នៅពេលជាមួយគ្នានោះ ព្រះ **ធម្មរាជា** បុត្រ (អង្គអិម) ទ្រង់កែនពួកអ្នកស្រុកភ្នំនៅតំបន់ **នគររាជ** ហើយលើកមកយកខេត្ត **នគរវត្ត** បានយ៉ាងងាយ ។ ចំណែកឯព្រះ ចៅសៀម លុះអូទ្រង់ជ្រាបពីស្ថានការណ៍នៅស្រុកខ្មែរហើយ ទ្រង់បានអនុញ្ញាតអោយព្រះ **ធម្មរាជា** (បិតា) ត្រឡប់មកវិញ មកឡើងគោកនៅត្រង់ **កំពត** ជាមួយទ័ព ៣៦០០នាក់ និងអនុញ្ញាតអោយព្រះ **អង្គឯង** លើកទ័ព ២០០០ នាក់ទ្ទោះទៅ **នគររាជ** ជាទីកន្លែងដែលព្រះអង្គកែនទ័ពបាន ៨០០ នាក់ ជាបន្ថែមហើយលើកទៅជួយព្រះ **ធម្មរាជា** (បុត្រ) នៅ **នគរវត្ត** ។ លុះបានជួបជុំគ្នាហើយ ក្សត្រទាំងពីរទ្រង់បានលើកចេញជា ២ ផ្លូវ មួយអង្គយាងតាមបឹងទន្លេសាប មួយអង្គយាងតាមផ្លូវគោក ហើយទៅជួបគ្នានៅ **សំរោងសែន** ក្នុងខេត្ត **កំពង់លែង** ។

www.budinst.gov.kh www.elibraryofcambodia.org

លុះទ្រង់ជ្រាបពត៌មាននោះហើយ ព្រះស្រីសុជាតា (អគ្គមហេសីព្រះសត្ថា) ដែលជាអ្នកផ្ដួចផ្ដើមគំនិតរំលំព្រះស្វាមីនោះ ទ្រង់បានទាក់ទងជាមួយស្ដេចខ្មែរដែលទើបតែយាងមកពីស្រុកសៀម ។ ក្រោយពីបានធ្វើការចរចាគ្នាហើយ ក្សត្រទាំងនោះទ្រង់បានព្រមព្រៀងគ្នាថាត្រូវតែលើករាជសម្បត្តិថ្វាយទៅព្រះស្រីធម្មរាជាទី ៣ វិញ ។

១៥– ព្រះបាទធម្មរាជាទី ៣ (រជ្ជកាលទី ៣ : ១៧៣៨-១៧៤៧).-

ព្រះអង្គទ្រង់ទទួលព្រះនាមសំរាប់រាជ្យថា ព្រះជ័យជេដ្ឋាធិរាជរាមាធិបតី ។ រាជធានីតាំងនៅឧដុង្គ ។ ព្រះអង្គទ្រង់យកអ្នកនាងជាតិក្សត្រី ជាព្រះអគ្គមហេសីព្រះនាមថា សម្ដេចព្រះជាតិក្សត្រី ។

ឯកសារយួនមួយបាននិយាយថា លុះបានឡើងសោយរាជ្យហើយព្រះធម្មរាជាទី ៣ (Nac Thâm) ទ្រង់បានបញ្ជារាជទូតអោយនាំគ្រឿងបណ្ណាការទៅថ្វាយស្ដេច ឌុក គុខ ស្ដេចអង្គនេះទ្រង់បានយល់ព្រម ។ ចំណែកឯព្រះសត្ថាទី ២ (Nac Tha) ដែលភៀសទៅនៅស្រុកយួននោះ បានស្ដេចយួនទុកអោយនៅជ្រកកោននៅយ៉ាឌិញ រង់ចាំឱកាសល្អ ហើយបានគង់នៅទីនោះអស់ជាង ១០ ឆ្នាំ (37) ។

ពេលដែល ម៉ាក តឹច ទទួលមរណភាពហើយ ព្រះធម្មរាជាទី ៣ ទ្រង់គិតថាមិនមានលទ្ធភាពដណ្ដើមយកដីពាមបកវិញ ក៏លើកទ័ពទៅវាយនៅគ.ស. ១៧៣៩ ប៉ុន្តែត្រូវម៉ាក ធៀន ទី ជាកូនរុញច្រានមកវិញ (37) ។

ចំណែកព្រះអង្គឧង ឡើងជាមហាឧភយោរាជ ហើយក្រោយមកទ្រង់ទទួលព្រះនាមថា សម្ដេចព្រះរាមាធិបតី ។ ព្រះអង្គស្ងួន ឧទ័យរាជា បានឡើងជាមហាឧបរាជ ។ ព្រះធម្មរាជាទី ៣ ទ្រង់ផ្សំផ្គុំព្រះរាជបុត្រ អង្គអិម (ធម្មរាជា) ជាមួយបុត្រីព្រះអង្គគឺអ្នកអង្គមែន នាមសម្ដេចព្រះឯកក្សត្រី ។ ព្រះអង្គថ្វាយព្រះនាមព្រះ អង្គអិម ថាសម្ដេចព្រះកែវហ្វា ហើយទ្រង់ផ្សំផ្គុំជាមួយ អ្នកអង្គបុស (បុត្រីព្រះមហាឧភយោរាជ) ដែលទ្រង់មានព្រះនាមថាសម្ដេចព្រះអនុជាតិក្សត្រី ។ នៅគ.ស.១៧៣៩ ក្សត្រីអង្គនេះមានបុត្រនាម

www.budinst.gov.kh . www.elibraryofcambodia.org

ព្រះអង្គធម ។ ព្រះឧបរាជយកព្រះអនុជព្រះ សត្ថាទី ២ នាម អង្គពៅ ជាមហេសី ហើយមានបុត្រនាម អង្គតន់ ។ ព្រះឧបរាជមានម្នាងម្នាក់ទៀត គឺ អ្នកម្នាងរស់ មានបុត្រនាម អង្គជ៉ាច និងបុត្រីនាម អង្គម៉ី ។

នៅគ.ស. ១៧៤០ ព្រះរាជបុត្រនាម អង្គស្ងួនសម្តេចព្រះស្រីជ័យជេដ្ឋ មានបុត្រ ២ អង្គ នាមអង្គនន់ និង អង្គឌី ។ ពីរឆ្នាំក្រោយមក ព្រះ អង្គនន់ ទ្រង់មាននាមថាព្រះរាមាធិបតី ។

នៅគ.ស. ១៧៤៣ សម្តេចព្រះកែវហ្វា អង្គចន្ទ ទ្រង់អាពាធហើយសុគត ។ នាឆ្នាំដដែល ព្រះរាជាទ្រង់ប្រទានអោយព្រះរាជបុត្រអង្គហ៊ីង នូវព្រះនាមថាព្រះសីសុរិយោពណ៌ ហើយទ្រង់ផ្សំផ្គុំនឹងព្រះ អនុជាតិក្សត្រី (អតីតអគ្គមហេសីព្រះកែវហ្វា) ។ ឯព្រះ អង្គដួង ទ្រង់បានទទួលព្រះនាមថា ព្រះកែវហ្វា ។ ម្នាងរបស់ព្រះអង្គនាមអ្នកម្នាង ណា (បុត្រីឧកញ៉ាមាន់) មានបុត្រីនាម អង្គលី ។

នៅ គ.ស. ១៧៤៥ អ្នកម្នាងណា មហេសី ព្រះកែវហ្វាអង្គដួង បានប្រសូតបុត្រនាម អង្គធម្ម ។

ព្រះធម្មរាជាទី ៣ ទ្រង់អាពាធហើយសោយទិវង្គតនៅ គ.ស. ១៧៤៧ ។

## ៦–ព្រះបាទធម្មរាជាទី ៤ អង្គអិម (១៧៤៧).–

ព្រះអង្គបានឡើងសោយរាជ្យស្នងព្រះបិតា តែបានតែ ១ ឆ្នាំ ក៏ត្រូវព្រះអនុជនាម អង្គហ៊ីង (ប្រសូតនៅស្រុកសៀម) អោយបក្សពួកធ្វើគត់ ។ ពួកនាម៉ឺននិងព្រាហ្មណ៍បុរោហិតមិនពេញចិត្តនឹងអំពើនក្រិដ្ឋនេះ បានលើកព្រះ អង្គធម មហានកុមារាជអោយឡើងសោយរាជ្យ ។

## ៧– ព្រះរាមាធិបតីទី ៣ អង្គធម ( រជ្ជកាលទី ១ ៖ ១៧៤៧-១៧៤៨ ).–

នៅ គ.ស. ១៧៤៧ នេះទៀត លោក ង្វៀនទេឿនគុក ចៅហ្វាយស្រុកខេត្តបាសាក់

www.budinst.gov.kh www.elibraryofcambodia.org

ដែលត្រូវយួនវាយបះតែរំលោភលើអំណាចនិងលើទឹកដីរបស់លោក ក៏បានលើកទ័ពទៅប្រយុទ្ធនឹងពួកនោះ ។ ជ័យជំនះបានមកខាងខ្មែរ ពួកយួនក៏រត់ទៅជ្រកនៅកោះ **តាហុង** នៅក្នុងទន្លេមេគង្គ ។

នៅគ.ស.១៧៤៨ ដោយយកលេសថាដើម្បីបង្ក្រាបខ្មែរបះបោរដែលមាន **ឧកញ៉ានរេន្ទ្រគុក** ( យួនហៅ Sô-liên-tôc ) ជាអ្នកដឹកនាំនោះ ព្រះចៅក្រុងវេទ្រង់បញ្ជាអោយមេទ័ពឈ្មោះ **ង្វៀន ហ៊ុច យន** ( Nguyên Huu Doan ) លើកទ័ពយួនដោយមានព្រះ **សត្ថាទី២** ចូលរួមផង មកច្បាំងឈ្នះ **ឧកញ៉ានរេន្ទ្រគុក** ដុតបំផ្លាញសំពៅរបស់លោកនៅ **មេសរ** ហើយលើកទ័ពឆ្ពោះទៅផែលក្រុងភ្នំពេញ ។ ហ្លួងបញ្ជាអោយ **ចៅហ្វាឯក** ( យួនហៅ Châu Thuy Yêt ) លើកទ័ពចេញទៅតទល់នឹងយួននៅត្រង់ **ទ្រាំងចំរេះ** ។

ទ័ពខ្មែរទន់ដៃជាងត្រូវដកថយ យួនដេញតាមដល់ **ឧដុង្គ** ។ ហ្លួង ព្រះឧបរាជ និង ព្រះ **អង្គស្ងួន** ( ស្រីជ័យជេដ្ឋ ) គៀសព្រះអង្គទៅប្រទេសសៀម ។

## ១៨– ព្រះសត្ថាទី ២ អង្គឌី ( រជ្ជកាលទី ៣ : ១៧៤៩ ).—

ឯកសារយួនថា ស្តេចយួនលើកអោយព្រះ **សត្ថាទី ២** ឡើងសោយរាជ្យនៅ **ឧដុង្គ** ។ ការពិត គឺពួកមេទ័ពយួនជាអ្នកកាន់អំណាច : អំណាចហូតយកពន្ធដា អំណាចតែងតាំងនឹងផ្លាស់ប្តូរចៅហ្វាយស្រុកខ្មែរ និងយកច្បាប់រដ្ឋបាលនៅក្រុង **ឆេ** មកអនុវត្តនៅស្រុកខ្មែរ ។

កាលណោះ មន្ត្រីខ្មែរម្នាក់គឺ **ឧកញ៉ាក្រឡាហោមឌិត** មានការឈឺចាប់យ៉ាងខ្លាំងចំពោះការត្រួតត្រារបស់បរទេស បានកែនទ័ពនៅខេត្តពោធិសាត់ហើយលើកទៅប្រយុទ្ធនឹងយួននៅត្រង់កំពល **ស្រាបអន្លាម** ។ ទ័ពយួនទទួលបរាជ័យដកថយទៅវិញ នាំទាំង **ព្រះសត្ថាទី ២** និងក្សត្រាខ្លះទៀត ត្រឡប់ទៅស្រុកយួនវិញ ។ ព្រះ **សត្ថា** ទ្រង់អាពាធហើយសុគតនៅកណ្តាលផ្លូវ ។

ចំណែកឯលោក **ឧកញ៉ាក្រឡាហោមឌិត** និងលោកចៅហ្វាយស្រុកខេត្ត ពោធិ៍-សាត់បានរៀបចំប្រទេសអោយមានសន្តិភាពឡើងវិញ ។ រួចលោកចាត់អោយសេនាបតីទៅ

www.budinst.gov.kh www.elibraryofcambodia.org

ស្រុកសៀមសូមយាដហ្លួនត្រឡប់មកវិញ ។ ព្រះចៅសៀមទ្រង់អនុញ្ញាតអោយតែព្រះអង្គស្ងួន មកមុន ឯហ្លួនធិនិងឧបរាជឧទ័យរាជា ត្រូវឃាត់ទុកសិន ។

១៩ **ព្រះបាទស្រីជ័យជេដ្ឋ អង្គស្ងួន** (១៧៤៩-១៧៥៥).—

ព្រះ **អង្គស្ងួន** បានឡើងសោយរាជ្យនៅ **ឧដុង្គ** ដោយមានព្រះនាមសំរាប់រាជ្យថា **ព្រះបាទសម្តេចព្រះរាជាឱង្ការព្រះស្រីជ័យជេដ្ឋាធិរាជបរមបពិត្រ** ។

ដើម្បីតបស្នងសង្គុណចំពោះលោក **ឧកញ៉ាសួគន៏** ចៅហ្វាយស្រុកពោធិ៍សាត់ដែលបានជួយកំចាត់ខ្មាំងសត្រូវនោះ ព្រះរាជាទ្រង់សព្វព្រះទ័យលើកលោកឡើងជាចៅហ្វា-**ធឡះ** ។ ការតែងតាំងថ្មីនេះធ្វើអោយមន្ត្រីឯទៀតមិនពេញចិត្ត ខូលមូលបង្កាច់ផាចង់ក្បត់ ។ ម្ល៉ោះហើយព្រះរាជាក៏ជឿតាម រួចបញ្ជាអោយពួកទាមផ្កាទៅសំឡាប់ ។ លោក **ឧកញ៉ាសួគន៏** ដឹងខ្លួនទាន់ ក៏ភៀសទៅស្រុកសៀមបាត់ទៅ (១៧៥០) ។

នៅ គ.ស. ១៧៥១ ព្រះចៅសៀមទ្រង់សព្វព្រះទ័យបើកអោយស្តេចខ្មែរដែលភៀសទៅកាល គ.ស. ១៧៤៨ នោះអោយត្រឡប់ចូលស្រុកវិញ ។ ហ្លួនធិនិរាជវង្សានុវង្សនោះមកដល់ខេត្ត **ក្រង** ក៏ឈប់នៅទីនោះសិនព្រោះនៅ គ.ស. ១៧៥២ មានមន្ត្រីឈ្មោះ **ខ្សែត្រូឯក** គិតយករាជ្យអោយព្រះ **អង្គតន់** រាជបុត្រព្រះឧបរាជ **ឧទ័យរាជា** ។ លោកបានយកអ្នកសិល្បឈ្មោះ **ស្នួស** ធ្វើជាមេទ័ព តែត្រូវហ្លួនទៅខេត្តក្រងធ្វើកលចាប់បាន **ខ្សែត្រូឯក** យកទៅសម្លាប់ចោល ។ ក្រោយមកអ្នកសិល្ប **ស្នួស** កូន **ខ្សែត្រូឯក** និងមេម្នាក់ទៀតឈ្មោះ **អង្គលីរាជ** ត្រូវចាប់បានហើយត្រូវប្រហារជីវិតបង់ទាំងអស់ ។

នៅគ.ស. ១៧៥៣ ព្រះឧបរាជ **ឧទ័យរាជា** ដែលចូលបួសនៅ **នគរវត្ត** កាលយាងមកស្រុកសៀម ក៏សុគតនៅឆ្នាំនោះ ។ ព្រះរាជបុត្រព្រះអង្គនាម **អង្គតន់** ទ្រង់យកព្រះនាមថា **ឧទ័យរាជា** ដូចព្រះបិតា ។ ឯ **អង្គហ៊ីង** បានឡើងជាមហាឧបរាជ ។

២០ —**ព្រះបាទរាមាធិបតីទី ៣ អង្គតន** (រជ្ជកាលទី២ : ១៧៥៦-១៧៥៧).-

ព្រះបាទ **ស្រីជ័យជេដ្ឋ អង្គស្ងួន** សោយទីវង្គតនៅគ.ស. ១៧៥៥ ក្រោយ ព្រះមហា

www.budinst.gov.kh www.elibraryofcambodia.org

**ឧភយោរាជ អង្គធន** ត្រូវបានពួកមន្ត្រីនិងព្រាហ្មណ៍បុរោហិតលើកអោយឡើងសោយរាជ្យ នៅគ.ស. ១៧៥៦ ។

វិវាទរវាងព្រះឧបរាជ **អង្គហ៊ីង** និងព្រះ **ឧទ័យរាជា** បានកើតឡើង ។ ព្រះ**ឧទ័យរាជា** ទ្រង់ភៀសទៅនៅស្រុក **ពាម** ក្រោយមកទៅនៅខេត្ត**ព្រះត្រពាំង** ។ គ្រានោះ **ម៉ាក ធៀនទី** កូន **ម៉ាកគីវ** បានជួយកែនទ័ពហើយប្រគល់អោយមន្ត្រី៣ នាក់លើកឆ្ពោះទៅ **ឧដុង្គ** ចំណែកឯព្រះ **ឧទ័យរាជា** បានលើកទ័ពដើរទឹកតាមទន្លេមេគង្គ ។ មកដល់ភ្នំ-ពេញ ព្រះអង្គទ្រង់បានទទួលដំណឹងថាទ័ពព្រះអង្គបានវាយឈ្នះព្រះឧបរាជ ហើយព្រះឧបរាជក៏ភៀសទៅនៅខេត្ត**ព្រៃក្ដី** ហើយ ។ ព្រះ **ឧទ័យរាជា** ទ្រង់អោយលើកទ័ពដេញតាមចាប់បានព្រះឧបរាជហើយធ្វើគត់ទៅ ។ រួច ទ្រង់អោយចាប់ **អង្គស្ងួន** ជាអនុជ **អង្គហ៊ីង** ហើយដែលរត់ទៅបួស យកទៅផ្សឹកហើយសម្លាប់ចោលទៀត ។ ចំណែកឯ **អង្គនន់**និង **អង្គឌី** (បុត្រអង្គស្ងួន) ត្រូវបានលើកលែងទោសព្រោះនៅក្មេងពេក ។

ពេលនោះ ព្រះអនុជ **ជាតិក្សត្រី** អតីតអគ្គមហេសីព្រះឧបរាជកែនទ័ពច្បាំងនឹងព្រះ**ឧទ័យរាជា** នៅ **តំបន់តាគោ** តែត្រូវបរាជ័យ ។ ដោយហេតុនោះ ហ្វូង (អង្គទង) អគ្គ-មហេសីព្រះឧបរាជនិងក្សត្រខ្លះភៀសទៅគង់នៅពោធិសាត់ ។ នៅគ.ស. ១៧៥៧ ហ្វូង ទ្រង់សោយទិវង្គតនៅទីនោះ ។ ព្រះ **ឧទ័យរាជា** ទ្រង់បានបញ្ជាអោយលើកទ័ពទៅចាប់អគ្គមហេសីព្រះឧបរាជនិងបុត្រនាម **អង្គធន** នៅ **ឫស្សីសាញ** យកប្រហារជីវិតបង់ទាំងពីរអង្គ ។ ឯ **អង្គនន់** និង **អង្គឌី** ដែលភៀសទៅនៅ **តំបន់ស្វាយ** ក៏ត្រូវបញ្ជាអោយចាប់ដែរ ។ នៅតាមផ្លូវ មានមន្ត្រីខ្លះបានពង្រត់ **អង្គនន់** ទៅស្រុកសៀម ឯ **អង្គឌី** ត្រូវនាំទៅ **ឧដុង្គ** ហើយត្រូវធ្វើគត់ ។

គួរគប្បីជ្រាបថា នៅគ.ស. ១៧៥៧ មុនពេលដែលសោយទិវង្គតទៅ ព្រះ**អង្គធន មហាធិបតី** ទ្រង់បានយល់ព្រមលះបង់អោយយួននូវ**ខេត្តផ្សារដែក** **ស្រុក ២ នៃខេត្តលង់ហោរ** (យួនហៅ Tâm Don និង Xuy Lap) និង**ខេត្តពាក់ថ្លុក** ។ មូលហេតុបណ្ដាលមកពីយួនបានបង្កើតអោយមានចលាចលនៅក្នុងខេត្តខ្មែរគឺ **ខេត្តព្រាំង ខេត្ត-**

www.budinst.gov.kh www.elibraryofcambodia.org

បន្ទាយមាស និងខេត្ត ព្រៃនគរ ដែលជាកម្លាំងគៀបសង្កត់មកលើរាជការខ្មែរដែលកំពុងតែជួបប្រទះនូវស្ថានការណ៍លំបាក ព្រោះតែមានវិបត្តិជាទម្ងន់ក្នុងរាជវង្ស (9) (សូមមើលផែនទី) ។

•

២១– ព្រះបាទនារាយណ៍រាជាទី ២ អង្គតន់ (១៧៥៨–១៧៧៥).-

ព្រះឧបរាជ អង្គឥន្ទរាជា បានឡើងសោយរាជ្យនៅ ឧដុង្គ ដោយមានព្រះនាមសំរាប់រាជ្យថា ព្រះបាទសម្តេចស្តេចព្រះរាជាឱង្ការព្រះនារាយណ៍រាជាធិរាជ រាមាធិបតី ព្រះស្រីសុរិយោពណ៌ ។

លុះបានឡើងសោយរាជ្យនៅគ.ស. ១៧៥៨ ស្តេចអង្គនេះទ្រង់បានលើកអោយស្តេចយួននាម ថេ តុង (Thê-tông) នូវដីពីរខេត្តគឺខេត្ត ព្រះត្រពាំង និងខេត្ត ឃ្លាំង ជាសគុណចំពោះជំនួយផ្សេងៗដែលយួនបានផ្តល់អោយក្នុងជម្លោះរវាងរាជវង្សានុវង្សខ្មែរ (42) (សូមមើលផែនទី) ។

*

* *

ក្រោយពីក្រុង លង្វែក ត្រូវបែកបាក់ដោយការវាយលុករបស់សៀម ទឹកដីខ្មែរមួយភាគធំនៅឯទាយភ្នំដងរែកត្រូវបាត់បង់ជាស្ថាពរ ។ ប៉ុណ្ណឹងហើយ អ្នកដឹកនាំជាតិនៅតែមិនទាន់ចេះទាញមេរៀនពីការបែកបាក់សាមគ្គីរវាងគ្នាឯងនៅឡើយ ។ ជម្លោះដណ្តើមអំណាចដណ្តើមរាជសម្បត្តិមានតែកើនឡើងរ៉ាំរ៉ៃ តែរីកធំឡើងជាហេតុបណ្តាលអោយអ្នកជិតខាង ជាពិសេសជាតិយួនដែលបានក្លាយជាមហាអំណាចមួយក្រោយពីបានច្បាំងឈ្នះប្រទេសចាម្ប៉ានោះ មានឱកាសនិងមានលេសដើម្បីធ្វើអន្តរាគមន៍លូកដៃចូលកកូរផ្ទៃក្នុងរបស់ខ្មែរតាមតែអំពើចិត្ត ។

www.budinst.gov.kh www.libraryofcambodia.org

អ្នកដឹកនាំជាតិក្នុងសម័យនោះ ពុំបានយកចិត្តទុកដាក់ចំពោះវាសនាប្រទេសជាតិ ចំពោះជីវភាពរបស់ប្រជារាស្ត្រ គឺថាពុំបានគិតដល់ប្រយោជន៍រួមទេ តែគិតធ្វើយ៉ាងណាអោយតែបានអំណាច បានយសសក្តិ បានរាជបល្ល័ង្ក បានស្នេហា បានប្រយោជន៍ផ្ទាល់ខ្លួនតែប៉ុណ្ណោះ ។ ម្ល៉ោះហើយ ក្នុងការធ្វើអោយសំរេចបំណងរៀងៗខ្លួន គេមិននិយមសម្រុះសម្រួលផ្សះផ្សារាជវង្សានុវង្សទេ គេសុខចិត្តកែនរាស្ត្រអោយបង្ហូរឈាមគ្នា រួចរត់ទៅពឹងពាក់បរទេសជិតខាងអោយគេជួយគាំទ្រ អោយគេជួយជំនួយជាទ័ពយកមកជិះជាន់ស្រុកទេសខ្លួន យកមកកាប់សម្លាប់តែជាតិឯង ។

នៅទីបំផុត ខ្មែរទាំងសងខាងត្រូវទ្រុឌទ្រោមអស់ថាមពលតែរៀងខ្លួន ប្រយោជន៍ត្រូវបានទៅអ្នកជិតខាងដែលគេតែងតែទារយកសគុណពីជំនួយរបស់គេគ្រប់ប្រភេទក្នុងការជួយគាំទ្រស្តេចខ្មែរដែលកើតវិវាទនឹងគ្នា ។ ដោយហេតុនោះ ស្តេចខ្លះដូចជា **អង្គនិមតែងហ្វ៊ានី** ៣ សុខចិត្តដាក់ប្រទេសចំណុះសៀម អោយតែសៀមទុកអោយព្រះអង្គបានសោយរាជ្យហើយនាំស្តេចជាគូបដិបក្ខត្រឡប់ទៅស្រុកវិញ ឬ **សត្ថាទី២អង្គឌី** សុខចិត្តយល់ព្រមអោយពួកយួនមកតាំងអំណាចត្រួតត្រាលើស្រុកខ្មែរអោយតែពួកនេះព្រមទទួលស្គាល់ព្រះអង្គជាព្រះមហាក្សត្រខ្មែរ និងស្តេចខ្លះទៀតបានយល់ព្រមលះបង់ទឹកដីអោយបរទេសដូចជាករណីរបស់ **នាណយណ៍រាជាអង្គតន់** ជាដើម ។

ក្នុងរយៈពេលតែ ១៣៥ ឆ្នាំសោះ គឺចាប់ពីគ.ស. ១៦២៣ ដល់ ១៧៥៨ ខ្មែរត្រូវបាត់បង់ទឹកដីកម្ពុជាក្រោមទាំងមូលដែលមានទំហំផ្ទៃប្រមាណជា ៦០ ០០០ គ.ម.ក្រឡា ។

ក្នុងការដណ្តើមយកទឹកដីខាងលើនេះ គេសង្កេតឃើញថាយួនបានអនុវត្តវិធី៣ យ៉ាង៖

— **វិធីទូត ឬ សន្តិវិធី** ៖ វិធីនេះគេបានយកមកអនុវត្តមុនគេបង្អស់ ព្រោះពេលនោះទោះបីយួនខ្លាំងឈ្នះចាមហើយតែនៅមិនទាន់លេបអស់ទឹកដីចាមនៅឡើយ ។ ស្តេចយួនបានបញ្ជូនទូតអោយមក សូមអនុញ្ញាតពីស្តេចខ្មែរអោយរាស្ត្រយួនចូលរកស៊ីក្នុងទឹកដីខ្មែរ ។ នេះជាវិធីមួយដែលយួនពុំបានប្រើជាមួយចាមទេព្រោះជាមួយចាមគេបានបញ្ជូនទ័ពមកឈ្លានពានសិនទើបបញ្ជូនរាស្ត្រមកតាមក្រោយ ។

www.budinst.gov.kh www.elibraryofcambodia.org

— **វិធីយោធា** : យួនបានប្រើវិធីនេះដោយផ្តល់ជំនួយជាទ័ពដើម្បីជួយ វង្សានុវង្សស្តេច ឬមន្ត្រីណាដែលបានរត់ទៅពឹងអោយគេជួយ (ករណីរបស់ឧកញ៉ាធិរាជាអ៊ិមនៅគ.ស.១៦៨៩)ឬដោយយកលេសថាការពារជនជាតិគេមករស់នៅលើដីខ្មែរក៏លើកទ័ព[illegible]ទឹកដីខ្មែរ (ឧ.ការបះបោរប្រឆាំងយួនក្នុងគ.ស.១៧៣០) ។

— **វិធីចិត្តសាស្ត្រ** : យួនប្រើវិធីនេះដោយធ្វើការបំផុសបំបោរបង្កើត ចល អោយមានអសន្តិសុខ គឺធ្វើយ៉ាងណាអោយរាជការខ្មែរទ្រាំមិនបានត្រូវលះបង់ទឹកដីអោយគេទៀត ។ វិធីនេះ យួនក៏មានប្រើក្នុងការទទួលស្គាល់ឬលើកស្តេចខ្មែរអង្គណាមួយអោយឡើងសោយរាជ្យ (ឧ.ករណីព្រះនារាយណ៍រាជាអង្គតន់ ) ។

គួរកត់សំគាល់ម្យ៉ាងទៀតថា ជនជាតិយួនគេបានសរសេរក្នុងសៀវភៅប្រវត្តិសាស្ត្ររបស់គេថា : " ការបញ្ចូលទឹកដីជាផ្លូវការក្នុងដែនទឹប្រទេសគេ និងការដាក់អាជ្ញាធរអោយគ្រប់គ្រងច្រើនតែបានប្រព្រឹត្តក្រោយពេលដែល ជនជាតិយួនបានទៅនៅកុះករនៅលើទឹកដីនោះហើយ ។ ជនជាតិយួនជាមនុស្សឧស្សាហ៍ ព្យាយាមក្នុងការរកស៊ី ហើយម្យ៉ាងទៀតដោយមានវប្បធម៌ មានទំនៀមទំលាប់ខុសគ្នាផង បានជាកន្លែងណាដែលមានជនជាតិយួនទៅនៅហើយ ជនជាតិខ្មែរក៏បោះបង់ចោលទីនោះដើម្បីទៅរស់នៅកន្លែងដទៃវិញ ។ មានកន្លែងខ្លះ មានខ្មែរនិងយួននៅលាយឡំគ្នាដែរ ។ កាលណាមានជនជាតិយួនទៅរស់នៅកន្លែងណាបានច្រើនគ្នាហើយ ពួកស្តេច **ង្វៀន** ក៏រកមធ្យោបាយដណ្តើមយកទឹកដីកន្លែងនោះជាផ្លូវការ និងដាក់អាជ្ញាធរអោយនៅគ្រប់គ្រងទៅ " (37) ។

www.budinst.gov.kh  www.elibraryofcambodia.org

| លេខរជ្ជកាល | នាមសំរាប់រាជ្យ នាមផ្ទាល់ | កាលកំណត់រជ្ជកាល | រាជធានី | រាជវង្ស |
|---|---|---|---|---|
| ១ | បរមរាជាទី ៨ ស្រីសុរិយោពណ៌ | ១៦០៣ - ១៦១៨ | កោះស្លាកែត ល្វាឯម | បុត្រព្រះបរមរាជាទី ៤ |
| ២ | ជ័យជេដ្ឋាទី ២ | ១៦១៨ - ១៦២៨ | ឧដុង្គ | បុត្រស្តេច ១ |
| ៣ | ធម្មរាជាទី ២ ឬរាជសំភារ ចៅពញាតូ | ១៦២៩ - ១៦៣៤ | កោះឃ្លោក | បុត្រស្តេច ២ |
| ៤ | អង្គទងរាជា ចៅពញានូ | ១៦៣៥ - ១៦៣៩ | ឧដុង្គ | បុត្រស្តេច ២ |
| ៥ | បទុមរាជាទី ១ អង្គនន់ | ១៦៣៩ - ១៦៤០ | ឧដុង្គ | បុត្រព្រះឧទ័យ |
| ៦ | រាមាធិបតីទី ១ ចៅពញាចន្ទ | ១៦៤០ - ១៦៥៩ | ឧដុង្គ | បុត្រស្តេច ២ |
| ៧ | បរមរាជាទី ៩ អង្គសូរ | ១៦៥៩ - ១៦៧២ | ឧដុង្គ | បុត្រព្រះឧទ័យ |
| ៨ | បទុមរាជាទី ២ ស្រីជ័យជេដ្ឋ | ១៦៧២ - ១៦៧៣ | ឧដុង្គ | បុត្រស្តេច ៥ |
| ៩ | កែវហ្វាទី ២ អង្គជី | ១៦៧៣ - ១៦៧៥ | ឧដុង្គ | បុត្រស្តេច ៧ |
| ១០[១] | ជ័យជេដ្ឋាទី៣ អង្គស៊ូ ឬចៅពញាសូរ | ១៦៧៥ - ១៦៨៨ (រជ្ជកាលទី ១) | ឧដុង្គ ទួលទំព្រីង | បុត្រស្តេច ៧ |

www.budinst.gov.kh www.elibraryofcambodia.org

| លេខរជ្ជកាល | នាមសំរាប់រាជ្យ នាមផ្ទាល់ | កាលកំណត់រជ្ជកាល | រាជធានី | រាជវង្ស |
|---|---|---|---|---|
| ១៦ | អ្នកម្នាងថៃ | ១៦៨៨ (៣ ខែ) | ឧដុង្គ | មាតាស្តេច ១០ |
| ១០[២] | ជ័យជេដ្ឋាទី ៣ | ១៦៨៨-១៦៩៥ (រជ្ជកាលទី ២) | ឧដុង្គ | បុត្រស្តេច ៧ |
| ១៧ | រាមាធិបតីទី ២ ឧទ័យរាជា អង្គយ៉ង | ១៦៩៥-១៦៩៦ | ឧដុង្គ | បុត្រស្តេច ៩ |
| ១០[៣] | ជ័យជេដ្ឋាទី ៣ | ១៦៩៦-១៦៩៩ (រជ្ជកាលទី ៣) | ឧដុង្គ | បុត្រស្តេច ៧ |
| ១៣[១] | កែវហ្វាទី ៣ អង្គឹម | ១៦៩៩-១៧០០ (រជ្ជកាលទី ១) | វាំងភាក់ ពោធិសាត់ | បុត្រអង្គនន់ |
| ១០[៤] | ជ័យជេដ្ឋាទី ៣ | ១៧០០-១៧០២ (រជ្ជកាលទី៤) | ឧដុង្គ | បុត្រស្តេច ៧ |
| ១៤[១] | ធម្មរាជាទី ៣ | ១៧០២-១៧០៣ (រជ្ជកាលទី ១) | ពោធិសាត់ ឧដុង្គ | បុត្រស្តេច ១០ |
| ១០[៥] | ជ័យជេដ្ឋាទី ៣ | ១៧០៣-១៧០៦ (រជ្ជកាលទី ៥) | ឧដុង្គ | បុត្រស្តេច ៧ |
| ១៤[២] | ធម្មរាជាទី ៣ | ១៧០៦-១៧០៩ (រជ្ជកាលទី២) | ឧដុង្គ | បុត្រស្តេច ១០ |
| ១៣[២] | កែវហ្វាទី ៣ អង្គឹម | ១៧១០-១៧២២ (រជ្ជកាលទី ២) | ឧដុង្គ | បុត្រអង្គនន់ |

www.budinst.gov.kh www.elibraryofcambodia.org

| លេខរជ្ជកាល | នាមសំរាប់ពង្ស នាមផ្ទាល់ | កាលកំណត់រជ្ជកាល | រាជធានី | ពង្សវង្ស |
|---|---|---|---|---|
| ១៥$^{១}$ | សត្ថាទី ២ អង្គជី | ១៧២២-១៧២៩ (រជ្ជកាលទី ១) | ឧដុង្គ | បុត្រស្តេច ១៣ |
| ១៣$^{៣}$ | កែវហ្វាទី៣-ជ័យជេដ្ឋា អង្គអិម | ១៧២៩ (៧ខែ) (រជ្ជកាលទី ៣) | ឧដុង្គ | បុត្រអង្គធន់ |
| ១៥$^{២}$ | សត្ថាទី២-បរមរាជា អង្គជី | ១៧២៩-១៧៣៧ (រជ្ជកាលទី ២) | ឧដុង្គ លង្វែក | បុត្រស្តេច ១៣ |
| ១៤$^{៣}$ | ធម្មរាជាទី៣-ជ័យជេដ្ឋា | ១៧៣៨-១៧៤៧ (រជ្ជកាលទី៣) | ឧដុង្គ | បុត្រស្តេច ១០ |
| ១៦ | ធម្មរាជាទី ៤ អង្គអិម | ១៧៤៧ (១ឆ្នាំ) | ឧដុង្គ | បុត្រស្តេច ១៤ |
| ១៧$^{១}$ | រាមាធិបតីទី ៣ អង្គទង | ១៧៤៧-១៧៤៩ (រជ្ជកាលទី ១) | ឧដុង្គ | បុត្រស្តេច ១២ |
| ១៥$^{៣}$ | ព្រះសត្ថាទី ២ អង្គជី | ១៧៤៩ (រជ្ជកាលទី ៣) | ឧដុង្គ | បុត្រស្តេច ១៣ |
| ១៨ | ស្រីជ័យជេដ្ឋ អង្គស្ងួន | ១៧៤៩-១៧៥៥ | ឧដុង្គ | បុត្រស្តេច ១៤ |
| ១៧$^{២}$ | រាមាធិបតីទី ៣ អង្គទង | ១៧៥៦-១៧៥៧ (រជ្ជកាលទី ២) | ឧដុង្គ ពោធិសាត់ | បុត្រស្តេច ១២ |
| ១៩ | នារាយណ៍រាជាទី២ ឧទ័យរាជា អង្គតន់ | ១៧៥៨-១៧៧៥ | ឧដុង្គ | ចៅស្តេច ១៧ |

សេចក្តីសង្ខេប.— លេខតូចដែលដាក់ក្បែរហើយនៅខាងស្តាំលើនៃលេខធំជាលេខសំគាល់ទីនៃ

www.budinst.gov.kh www.elibraryofcambodia.org

## ចំពូកទី១៣

# ការប្រណាំងប្រជែងរវាងសៀម និង យួន ដើម្បីត្រួតត្រាប្រទេសខ្មែរ (ស.វ.ទី១៨ និង ទី១៩)

លុះឃើញយួនដណ្តើមយកបានទឹកដីរបស់ខ្មែរបានជាច្រើន សៀមដែលបានចាត់ទុកជាប្រទេសខ្មែរជាសាមន្តរដ្ឋរបស់គេតាំងពីយូរយារណាស់មកហើយនោះ ក៏បានរិះរកមធ្យោបាយដើម្បីទប់ទល់នឹងការឈ្លានពានរបស់យួន ៗ ដូច្នេះ ការប្រណាំងប្រជែងមួយក៏បានកើតឡើងរវាងយួននិងសៀមក្នុងការត្រួតត្រាប្រទេសខ្មែរ ៗ

## ក- ឥទ្ធិពលដ៏ខ្លាំងក្លារបស់យួន .-

ក្នុងដំណាក់ការដំបូងនេះ ឥទ្ធិពលរបស់យួនមានសភាពខ្លាំងក្លាជាងឥទ្ធិពលរបស់សៀម ព្រោះជាព្រះ **ឧទ័យរាជាអង្គតន់** កាលដែលបានកំចាត់គូសត្រូវរបស់ព្រះអង្គអស់ហើយ ត្រូវបានស្តេចយួនទំនុកបំរុងស្គាល់អោយឡើងសោយរាជ្យនៅក្រុង **ឧដុង្គមានជ័យ** និងបានលើកអោយយួនទទួលដីពីរខេត្ត ជាហេតុបណ្តាលអោយកម្ពុជាក្រោមទាំងមូលត្រូវធ្លាក់ទៅក្នុងការគ្រប់គ្រងរបស់រាជការយួន ៗ

### ១- ព្រះបាទនារាយណ៍រាជាទី ២ អង្គតន់ (១៧៥៨ - ១៧៧៥) .—

នៅគ.ស. ១៧៦០ ព្រះអង្គទ្រង់តាំង **អ្នកម្លាងខង** អោយហៅជាអ្នកម៉ែនាង **ហញា**

www.budinst.gov.kh www.elibraryofcambodia.org

បុប្ផាទេវី ។

នៅគ.ស. ១៧៦៣ ក្រោយពីបានប្រគល់កិច្ចការរដ្ឋអោយមន្ត្រីធំ ៗ កាន់ហើយ ព្រះអង្គទ្រង់ចេញសាងផ្នួសបាន ៣ ខែ លុះចាកសិក្ខាបទមក ទ្រង់ត្រឡប់មកសោយរាជ្យវិញ ។

ពីរឆ្នាំក្រោយមក អ្នកម៉ែនាង **មាលាបុប្ផាទេវី** ទ្រង់ប្រសូតបុត្រីនាម **អ្នកអង្គមិញ** ដែលត្រូវលើកជាអគ្គមហេសីស្ដាំមាននាមហៅថា **សម្ដេចព្រះភគវតីព្រះឯកក្សត្រីស្រីឧត្ដមក្ខត្តិយវង្សរាជវរលក្ខណ៍** ។ នៅឆ្នាំបន្ទាប់មកទៀត អ្នកម៉ែនាងម៉ែន (កូនស្រីលោកឧកញ៉ាបវរនាយកស្វ) បានប្រសូតបុត្រីនាម **អង្គអី** ។ ចំណែកឯ **អ្នកអង្គអី** បុត្រីព្រះកែវហ្វាអង្គជួន ត្រូវលើកជាអគ្គមហេសីឆ្វេង ហើយមានបុត្រីនាម **អង្គពៅ** ។ ព្រះអគ្គមហេសីឆ្វេងនេះមាននាមហៅថា **សម្ដេចព្រះភគវតីព្រះស្រីសុជាតាមហាក្សត្រី** ។

នៅជំណាច់គ.ស. ១៧៦៧ ស្ដេចភូមានាម **អាឡោងផះយ៉ា** (Alaungpaya) បានលើកទ័ពចូលវាយរាជធានី **អយុធ្យា** ម្ដងទៀត ទ្រង់ចាប់យកព្រះចៅ**ឯកទស្សរថ**ទៅបាន ។ ឯព្រះរាជបុត្រនាម **ចុលជាស៊ីសាំង** លើកទ័ពចេញច្បាំងចាញ់ភូមា ទ្រង់ភៀសព្រះអង្គចូលនៅក្នុងប្រទេសខ្មែរហើយក្រោយមកសុគតនៅទីនេះ ។

ក្នុងឱកាសដែលស្រុកទេសកំពុងតែកើតចលាចល ចិនម្នាក់ដែលមានម្ដាយជាតិជាសៀមនិងឪពុកគឺចិនហៃហុង ឈ្មោះ **ពញ៉ាតាក** បានតែនទ័ពវាយកំចាត់ភូមាអោយរត់ទៅវិញអស់ ហើយតាំងខ្លួនជាស្ដេចក្នុងក្រុង **ស្រីអយុធ្យា** មានព្រះនាមជាព្រះចៅ**តាកស៊ីន**។

និយាយពីព្រះ **អង្គនន់** កាលដែលភូមាវាយបែកក្រុង **អយុធ្យា** នោះទ្រង់បានថយទៅគង់នៅ **បស្ចិមបុរី** រួចត្រឡប់ទៅពឹងព្រះចៅ **តាកស៊ីន** ទៀត ។

នៅគ.ស.១៧៦៨ ព្រះចៅ **តាកស៊ីន** ទ្រង់បញ្ជារាជទូតអោយនាំសុភអក្សរមកទូលព្រះរាជាខ្មែរអោយទ្រង់លើកស្នួយជាផ្កាមាសផ្កាប្រាក់ទៅថ្វាយព្រះអង្គជាផ្លូវព្រះរាជមេត្រី តែព្រះរាជាខ្មែរពុំយល់ព្រមធ្វើតាមព្រោះព្រះចៅ **តាកស៊ីន** មិនមែនជាក្សត្រ ។ លុះទ្រង់ជ្រាបដំណឹងនេះហើយ ព្រះចៅ **តាកស៊ីន** ទ្រង់ខ្ញាល់ខ្លាំង ទើបទ្រង់ត្រាស់អោយព្រះចៅ**យមរាជ**សាំងញ្ញា លើកទ័ពមកដល់នគរវត្តក្នុងបំណងយកព្រះ **អង្គនន់** អោយឡើងសោយរាជ្យ



www.budinst.gov.kh www.elibraryofcambodia.org

ធនៅប្រទេសខ្មែរ ។ ព្រះរាជាខ្មែរទ្រង់ត្រាស់បញ្ជាក្រឡាហោម **ម៉ឺន** អោយលើកទ័ពចេញទៅ តស៊ូ តែក្រឡាហោម **ម៉ឺន** ត្រូវស្លាប់ក្នុងសមរភូមិ (36) ។ គ្រង់នេះរាជពង្សាវតារខ្មែរថា ទោះបីមេទ័ពខ្មែរត្រូវបាត់បង់ជីវិតក៏ដោយ ក៏ទ័ពខ្មែរត្រូវបានជ័យជំនះដេញសៀមអោយថយទៅវិញអស់ ។

នៅគ.ស.១៧៦៩ ព្រះរាជាទ្រង់មេត្តាអ្នកអង្គធម្ម ជារាជបុត្រព្រះកែវហ្វាអង្គដួង ក៏លើកឡើងជាសម្តេចព្រះមហាឧបរាជ ។

គ្រានោះ ឈ្មោះ **ម៉ាក់ តោន** ( ឯកសារសៀមថាឈ្មោះសម្តេចព្រះសោទ័គ ) ជាទេសាភិបាលចិនឈរនៅគ្រង **តាម** បានកែនទ័ពចេញទៅវាយសៀមដល់ **ចន្ទបុរី** តែត្រូវវាយថយមក**តាម**វិញអស់ ។

ដើម្បីជាការសងសឹកចិត្តនឹងបំណងយកប្រទេសខ្មែរជាចំណុះផង ព្រះចៅ **តាកស៊ីន** ទ្រង់បញ្ជាអោយលើកទ័ពមកជា ២ ផ្លូវ : ទ័ពជើងគោកចូលតាមខាងជើងស្ថិតក្រោមបញ្ជាការឧកញ៉ាយមរាជ ឯទ័ពជើងទឹកស្ថិតក្រោមបញ្ជាការរបស់ព្រះចៅ **តាកស៊ីន** ហើយដែលមានព្រះ**អង្គនន់**អមផង បានលើកឆ្ពោះមក**តាម** ។ **ម៉ាក់ តោន** បានរិតខំការពារគ្រន់ណាស់ដែរ តែដោយទន់ដៃជាង ត្រូវទ័ពសៀមដេញតាមរហូតដល់**ទឹកខ្មៅ** ។

លុះទ្រង់ជ្រាបដំណឹងនេះហើយ ព្រះរាជាខ្មែរទ្រង់នាំរាជវង្សានុវង្សភៀសទៅស្រុកយួន ។ ខ្មែរនិងសៀមច្បាំងគ្នាតទៅទៀត ហើយនៅទីបំផុតសៀមដកថយទៅ**តាម**វិញអស់ ទុកអោយព្រះ**អង្គនន់** គង់នៅ**កំពត** និងទាហាន ៥០០ នាក់ ។ ក្នុងចម្បាំងលើកនេះ ខាងព្រះ**អង្គតន់** ទំនងជាមានការគាំទ្រពីទ័ពយួន ព្រោះឯកសារយួនបានសរសេរថា : «នៅឆ្នាំ ១៧៧២ (?) ខែ ៦ ស្តេច**ឡៀង** បានបញ្ជាមេទ័ពឈ្មោះ **ឡៀង គីវ ដាម**( Nguyên Cuu Dam) អោយលើកទ័ពជើងទឹកទៅវាយសៀមនៅភ្នំពេញ ទ័ពសៀបដកថយទៅតាម ចំណែកឯ **អង្គនន់**ទ្រង់ភៀសទៅកំពត» (40) ។

លុះសៀមថយទៅវិញអស់ហើយ ព្រះ**អង្គតន់**យាងត្រឡប់មកសោយរាជ្យវិញ តែទ្រង់ទៅគង់នៅ**ព្រែកមាត់គណ្ដាល** ។ រាជការយួនក៏បញ្ជូនមន្ត្រីជាន់ខ្ពស់ម្នាក់អោយមក

www.budinst.gov.kh www.elibraryofcambodia.org

នៅថែរក្សា ចាំជួយសំរេចកិច្ចការផែនដីដែលយួនហៅថា**បាវហោ** (Bảo-hộ) បានសេចក្តីថាប្រទេសខ្មែរបានធ្លាក់ទៅនៅក្រោមអំណាចគ្រប់គ្រងរបស់យួនម្តងទៀតហើយ ។

នៅគ.ស.១៧៧២ ព្រះ**អង្គតន់**ទ្រង់យាងទៅគង់នៅ**ព្រែកពាក់ព្រ័ត** ។ ព្រះអង្គទ្រង់ព្រះចិន្តាមេត្តាករុណាបណ្តាអាណាប្រជានុរាស្ត្រ ដែលរងទុក្ខវេទនាដោយសារសង្គ្រាមរ៉ាំរ៉ៃ ក៏ទ្រង់បញ្ជាអោយព្រះ **កែវហ្វាអង្គជួន** ទៅចរចាចងស្ពានមេត្រីជាមួយព្រះចៅ **តាកស៊ីន** តែព្រះចៅ**តាកស៊ីន**មិនជឿអោយចាប់ឃុំឃាំង ក្រោយមកព្រះ **អង្គជួន** សូមអនុញ្ញាតអោយមាតា ភរិយានិងបុត្រចូលទៅដល់ក្រុង **អយុធ្យា** ទើបព្រះចៅ**តាកស៊ីន**ជឿថាស្មោះត្រង់ពិតក៏អោយលើកលែងទោស ។

នៅគ.ស. ១៧៧៣ អ្នកម្នាងរបស់ព្រះ **អង្គតន់** នាម**ទៃ** ប្រសូតបុត្រនាម**អង្គអេង** ។ ហើយឆ្នាំក្រោយមកព្រះអង្គយាងទៅគង់នៅ**កោះចិន** ហើយអោយទ័ពយួនថយទៅស្រុកវិញ ។ នៅទីបំផុត ព្រះអង្គយាងត្រឡប់ចូលរាជធានី**ឧដុង្គ**វិញ ហើយក្រោយពីពិគ្រោះជាមួយមន្ត្រីធំៗហើយ ទ្រង់សំរេចព្រះទ័យដាក់រាជ្យថ្វាយទៅព្រះ**អង្គនន់**នៅគ.ស.១៧៧៥ ដើម្បីចៀសវាងកុំអោយមានការបង្ហូរឈាមគ្នាឯងតទៅទៀត ។ ចំណែកឯព្រះអង្គទ្រង់ស្ថិតនៅជាមហាឧភយោរាជវិញ ។

## ២– ព្រះរាមរាជា អង្គនន់ (១៧៧៥-១៧៧៩).-

ព្រះ**អង្គនន់**ទ្រង់អភិសេកឡើងសោយរាជ្យនៅ **ឧដុង្គមានជ័យ** ដោយមានព្រះនាមសំរាប់រាជ្យថា **ព្រះបាទសម្តេចស្តេចព្រះរាមរាជាធិរាជបរមបពិត្រ** ។

លុះទ្រង់ឡើងគ្រប់គ្រងរដ្ឋហើយ ហើយដោយគិតរើបំរះមិនព្រមចំណុះយួនតទៅទៀត នៅគ.ស. ១៧៧៦ ព្រះ**រាមរាជា**ទ្រង់បញ្ជាអោយជាងសិតកាំភ្លើងបញ្ឆេះ ក៏ចាំសេរកាប់ឈើធ្វើបន្ទាយនៅក្រុងភ្នំពេញ និងនៅមុខកំពូល ។

និយាយពីនៅស្រុកយួនឯណោះ មានការបះបោរប្រឆាំងនិងវង្សនុយភាំងពី គ.ស. ១៧៧៣ ។ យ៉ាងណាមិញ មានបងប្អូន៣ នាក់នៅភូមិ **តី សឺន** (Tây Sơn) ឈ្មោះ

www.budinst.gov.kh www.elibraryofcambodia.org

ង្វៀន ញ៉ាក (Nguyên Nhac) ង្វៀន លឺ (Nguyên Lu) និងង្វៀន ហ៊េ (Nguyên Huê) បានរួមកម្លាំងជាមួយពួកអ្នកស្រុកភ្នំ លើកទ័ពឆ្ពោះទៅក្រុងគ្វី ញើន (Qui Nhon) មូលហេតុនៃការបះបោររបស់ពួកតី សឺននេះ គឺបណ្តាលមកពីរាជសុសិទ្ធឈ្មោះទ្រឿង ភុក លន (Truong Phuc Loan) បានប្រើអំណាចជិះជាន់ប្រជារាស្ត្រខ្លាំងពេក ។ នៅ គ.ស. ១៧៧៥ ស្តេចឌិញ វឿង (Dinh Vuong) បានភៀសព្រះអង្គទៅនៅស្រុកក្រោម ប៉ុន្តែត្រូវពួកបះបោរចាប់បានហើយធ្វើគុតនៅគ.ស. ១៧៧៧ ។ ចំណែកឯក្មួយរបស់ព្រះអង្គឈ្មោះ ង្វៀន ភុក អាញ់ (Nguyên Phuc Anh) បានភៀសព្រះអង្គទៅគង់នៅកោះត្រល់ រួចទៅនៅប្រទេសសៀមនៅគ.ស. ១៧៨៤ ។

ក្នុងគ្រានោះ លោកទេសាភិបាលយួនដែលឈរនៅព្រៃនគរ បានរត់ទៅសុំជំនួយទ័ពពីព្រះរាមរាជា ដើម្បីទៅបង្ក្រាបពួកបះបោរតែព្រះអង្គពុំយល់ព្រម ។ ម៉្លោះហើយ លោកទេសាភិបាលនោះក៏លើកទ័ពយួនចូលមកប្រទេសខ្មែរ ឡើងទៅដល់ក្រុងភ្នំពេញ ច្បាំងនឹងទ័ពខ្មែរ តែមិនចាញ់មិនឈ្នះក៏ដកថយទៅវិញអស់ទៅ ។

នៅ គ.ស. ១៧៧៧ លោកឧកញ៉ាធិបុលរាជ ទាមស្វ៊ ដោយមិនចូលចិត្តនឹងព្រះអង្គនន់ បានញុះញង់ព្រះឧបរាជអង្គធម្មថាព្រះអង្គនន់ចង់ប្រទូស្តនៃព្រះឧបរាជមិនខាន ។ ម៉្លោះហើយ ដោយភ័យខ្លាចក្រែងមានទោសកំហុស លោកឧកញ៉ាធិបុលរាជបានទៅទូលញុះញង់ព្រះអង្គនន់ថាព្រះឧបរាជចង់ក្បត់ដណ្តើមរាជ្យ ព្រះអង្គក៏ព្រមជឿតាមហើយទ្រង់បញ្ជាអោយធ្វើគុតព្រះឧបរាជបានក្នុងពេលលេងចត្រង្គ ដោយមានលោកឧកញ៉ាស្រីអគ្គរាជចូលដៃផង ។ ប៉ុន្មានថ្ងៃក្រោយមក ព្រះមហាឧភយោរាជក៏សោយទិវង្គតទៅតំពប់ហ្លួងទៀតដោយព្រះអង្គព្រួយព្រះទ័យពេក ។

នៅ គ.ស.១៧៧៨ ព្រះចៅ តាក ស៊ីន ទ្រង់បញ្ជាអោយឧកញ៉ាចក្រីនិងឧកញ៉ាសួរសីហ៍លើកទ័ព១០០០០នាក់ទៅវាយលាវនៅវៀងចន្ទ ។ ទ័ពនោះបានធ្វើដំណើរកាត់តាមស្រុកខ្មែរ លុះទៅដល់បន្ទាយពេជ្រមេទ័ពបានធៀងទៅឧដុង្គទូលព្រះរាមរាជាសូមជួយកងទ័ពនិងស្បៀងអាហារ ។ ព្រះរាមរាជាទ្រង់យល់ព្រមតាម ហើយទ្រង់បញ្ជាអោយកែនទ័ពបាន

www.budinst.gov.kh www.elibraryofcambodia.org

ក្រោយ ១០០០០ នាក់ប្រគល់អោយមេទ័ពទាំងពីរព្រមទាំងមានស្បៀងជាអង្ករគប់គ្រាន់ទៀតផង ។

ទ័ពខ្មែរលើកទៅជាពីរផ្លូវ ១ តាមជើងគោក មួយទៀតតាមជើងទឹក ។ កាលណោះ គេបានកែនពួកស្រី ៗ នៅខេត្ត**កំពង់ស្វាយ**អោយបុកអង្ករកិនស្រូវដើម្បីបញ្ជូនទៅអោយកងទ័ព ។ ដំណឹងនេះឮទៅដល់ពួកទាហានដែលគេបង្ខំអោយទៅច្បាំងនឹងលាវ ពួកនោះក៏រត់មករកប្រពន្ធកូនវិញ ។ **ព្រះអង្គនន់**ទ្រង់បញ្ជាអោយរកចាប់បញ្ជូនមកវិញ ប៉ុន្តែពួកនោះរួមគ្នាប្រឆាំងនឹងព្រះអង្គវិញ រហូតដល់កាប់សម្លាប់ពួកឧកញ៉ាហ្លួងទៀតផង ។

រាជពង្សាវតារបាននិយាយថា ព្រះ ร.ជាទ្រង់បានចោទចៅហ្វាយស្រុកខេត្ត**បារាយណ៍**និងខេត្ត**ព្រៃក្ដី**ដែលត្រូវជាបងប្អូននឹងចៅហ្វាយស្រុកខេត្ត **កំពង់ស្វាយ** ថាឃុបឃិតផ្សំគំនិតនឹងគ្នាព្រោះមិនបានថ្វាយដំណឹងទាំងនេះអោយទាន់ពេលវេលា ។ ម្ល៉ោះហើយ ចៅហ្វាយស្រុកខេត្ត**ព្រៃក្ដី ឧកញ៉ាមន្ត្រីស្នេហាសួរ**ត្រូវកាត់ទោសប្រហារជីវិត ចៅហ្វាយស្រុក**បារាយណ៍ ឧកញ៉ាសេនាទាងហ្លួងពាង**ត្រូវវាយ៥០រំពាត់និងត្រូវហូតងារ ឯចៅហ្វាយស្រុក**កំពង់ស្វាយ ឧកញ៉ាតេជោតែន**គ្រាន់តែត្រូវស្ដីប្រដៅ ទ្រង់អោយនៅដដែល រួចទ្រង់ព្រោសអោយត្រឡប់ទៅស្រុកវិញ ។

ឆ្នាំបន្ទាប់មក នៅគ.ស.១៧៧៩ មន្ត្រីទាំងពីរជាបងប្អូននឹកតូចចិត្តនឹងព្រះរាជាដែលបានកាត់ទោសប្រហារជីវិតប្អូនលោកនោះ បានបំបះបំបោររាស្ត្រអោយប្រឆាំងនឹងស្ដេច ។ ស្ដេចអោយ**ចៅហ្វាមូ**នៅស្រុកបាសាក់លើកទ័ពទៅបង្ក្រាបនៅកំពង់ស្វាយ តែនៅទីបំផុតលោកបានចូលដៃជាមួយប្អូនលោកទាំងពីរប្រឆាំងនឹងស្ដេចវិញទៀត ។

ព្រះ**រាមរាជា**ទ្រង់លើកទ័ពទៅបង្ក្រាបផ្ទាល់ព្រះអង្គ ។ នៅពេលនោះ **ឧកញ៉ាវិបុលរាជស្វី**ក៏បានចូលដៃជាមួយពួកបះបោរទៀត ។ មន្ត្រីរូបនេះបានទាំងចាប់យកព្រះ**អង្គអេង**ដែលមានព្រះជន្មទើបបាន ៦ វស្សា និងអោយធ្វើគត់បុត្រទាំង ៤ របស់ព្រះរាជា ។

លុះទ្រង់ជ្រាបដំណឹងនោះ ព្រះរាជាទ្រង់ប្រញាប់លើកទ័ពត្រឡប់មកវិញជួបនឹងទ័ព


www.budinst.gov.kh www.elibraryofcambodia.org

ចំរុះខ្មែរ-យួនទៅកំពង់ឆ្នាំង ។ ទាំងសងខាងបានប្រយុទ្ធគ្នាអស់ពេលយ៉ាងយូរតែមិនចាញ់មិនឈ្នះ ។ ព្រះរាជាដកថយទៅនៅជិត**ភ្នំគំរែង ខេត្តក្រគរ** ។

**ចៅហ្វាមូ**ជ័ងការណ៍ លើកទ័ពទៅចាប់បានព្រះរាជាយកទៅកើតគត់នៅត្រង់**បឹងខ្យង** នៅខាងត្បូងជិតរាជធានី រួចឡើងកាន់អំណាចគ្រប់គ្រងរដ្ឋនៅគ.ស.១៧៧៩ តាំងខ្លួនឡើងឈ្មោះថា **ចៅហ្វាទឡ្ហៈ មហាឧបពិត្រ** ។ **ឧកញ៉ាធិបុលរាជស្វ៊ី** ឡើងជា**ឧកញ៉ាក្រឡាហោម** ។ **ឧកញ៉ាសែនទ្យោតចហ្វាពាង** ឡើងជា**ឧកញ៉ាចក្រី** ។ រីឯ**ឧកញ៉ាអធិទឡ្ហាប៉ុក**ដែលថែរក្សាព្រះ**អង្គអេង**ឡើងជា**ឧកញ៉ាវាំង** ។

## ខ-ឥទ្ធិពលដ៏ខ្លាំងក្លារបស់សៀម.–

### ១-ព្រះបាទនារាយណ៍រាជាទី៣ អង្គអេង (១៧៧៩-១៧៩៦).–

នៅដំណាច់ឆ្នាំ១៧៧៩ ពួកមន្ត្រីនិងព្រាហ្មណ៍បុរោហិតបានលើករាជសម្បត្តិថ្វាយព្រះ**អង្គអេង**ដែលមានព្រះជន្មទើបបាន៧វស្សា ប៉ុន្តែកិច្ចការផែនដីនៅលើកណ្ដាប់ដៃ**ចៅហ្វាមូ**ទាំងអស់ ។

ដើម្បីចៀសវាងនូវអំពើក្បត់ផ្សេងៗ **ចៅហ្វាមូ** ចាត់**ឧកញ៉ាយមរាជបែន**អោយទៅនៅខេត្តកំពង់ស្វាយជាមួយប្អូនលោកគឺ**ឧកញ៉ាតេជោឌែន** ។ ចំណែកឯមន្ត្រីផ្សេងៗទៀត ក៏លោកបានចាត់វិធានការដូចគ្នានេះដែរ ។

លុះទ្រង់ជ្រាបដំណឹងខាងលើនេះហើយ ព្រះចៅសៀមទ្រង់បញ្ជាព្រះ**អង្គដួង**ដែលត្រូវឃាត់ទុកពីមុននោះ អោយត្រឡប់ចូលប្រទេសខ្មែរធ្វើយ៉ាងណាសុំអោយបាន**ឧកញ៉ាយមរាជបែន**ជាមន្ត្រីចាស់របស់ព្រះបិតាព្រះ**អង្គអេង**ដើម្បីនាំទៅស្រុកសៀម ។ **ចៅហ្វាមូ** ក្រោយពីប្រឹក្សានឹង**ឧកញ៉ាក្រឡាហោមស្វ៊ី** ក៏ព្រមប្រគល់**ឧកញ៉ាបែន**អោយទៅព្រះចៅសៀម ។ មន្ត្រីរូបនេះត្រូវស្ដីបន្ទោសយ៉ាងខ្លាំងពីបទចូលដៃនឹងយួននិងពីឃាតកម្មលើរូបព្រះ**ឧទ័យរាជា** ហើយថែមទាំងត្រូវយកទៅដាក់គុកទៀតផង ។

www.budinst.gov.kh www.elibraryofcambodia.org

នៅគ.ស.១៧៨០ ដោយនឹកសង្ស័យថាពួកមន្ត្រីដែលគ្រប់គ្រងរដ្ឋនៅប្រទេសខ្មែរមុខជាចូលដៃនឹងយួនមិនខាន ព្រះចៅសៀមក៏ទ្រង់បញ្ជាអោយលើកទ័ព២០០០០នាក់ចូលជា៣ផ្លូវ ៖

– កងទ័ពមួយស្ថិតក្រោមបញ្ជាការរបស់ព្រះរាជបុត្រនាម **ចៅណាយ** លើកឆ្ពោះត្រង់មក**ឧដុង្គ**តែម្តង ។

– កងទី ២ ស្ថិតក្រោមបញ្ជាការរបស់**ឧកញ៉ាចក្រី**លើកមកបោះជំរំនៅចាំត្រង់តំបន់អង្គរ ។

– កងទី ៣ ស្ថិតក្រោមបញ្ជាការរបស់ **ឧកញ៉ាសូរសីហ៍** លើកចូលលុកយកខេត្តកំពង់ស្វាយ ។

នៅចំពោះមុខការឈ្លានពាននេះ **ចៅហ្វាមូ** បានកែនទ័ព ពង្រឹងបន្ទាយ នាំព្រះ**អង្គអេង** ទៅគង់នៅភ្នំពេញ ហើយចាត់បំរើអោយទៅសុំជំនួយទាហានពីយួន ។ ស្តេច **ង្វៀង ភុក អាញ់** (Nguyên phuc Anh) បញ្ជាមេទ័ព២នាក់គឺ **ង្វៀង ហ៊ឺុន ថ្វាយ** (Nguyên huu Thoai) និង **ហូ វ៉ាន់ ឡឹង** (Hô văn Lân) នាំទ័ព ៣០០០ នាក់មកជួយ (40) ។

ក្នុងពេលដែលសៀម និងយួនកំពុងតែច្បាំងគ្នានៅលើទឹកដីខ្មែរ ព្រះចៅសៀម **តាកស៊ីន** ទ្រង់កើតវិកលចរិត ។ មេទ័ពសៀមទាំងពីរដែលកំពុងតែធ្វើប្រតិបត្តិការសឹកនៅប្រទេសខ្មែរ ក៏ប្រញាប់ប្រញាល់លើកទ័ពចូលស្រុកវិញ នាំយកទាំងព្រះរាជបុត្រនាម **ចៅណាយ** ទៅជាមួយផង ។ ព្រះចៅ **តាកស៊ីន** និងព្រះរាជបុត្រត្រូវចាប់ឃុំឃាំងហើយក្រោយមកត្រូវយកទៅធ្វើគត់(គ.ស.១៧៨២) ។ **ឧកញ៉ាចក្រី** ក៏តាំងខ្លួនជាព្រះរាជាមានព្រះនាមថា **សម្តេចព្រះពុទ្ធយ៉តហ្វាចូឡាលោក** ឯ**ឧកញ៉ាសូរសីហ៍**បានតាំងជាឧបរាជ ។

លុះសៀមថយទ័ពទៅអស់ហើយ យួនបានសុំទ័ពខ្មែរអោយជួយកំចាត់ពួក **តិសឺន** តែចាញ់ពួកនោះ (ឯកសារយួនគ្មាននិយាយ) ។ ស្តេចយួន **ង្វៀង ភុក អាញ់** រត់ទៅពឹងសៀម (១៧៨៤) ស្តេចសៀមអោយលើកទ័ព ២០ ០០០ នាក់ និង សំពៅ ៣០០ មកជួយច្បាំង

www.budinst.gov.kh www.elibraryofcambodia.org

ទៀតតែនៅតែចាញ់ពួក **តីសឺន** ។ នៅទីបំផុត ទ្រង់បានសុំជំនួយពីបារាំងវិញ ។

ក្នុងគ.ស. ១៧៨២ នៅឯប្រទេសខ្មែរឯណោះជម្លោះបានកើតឡើងរវាង **ចៅហ្វាមូ** **ឧកញ៉ាចក្រីពាង** និង **សម្ដេចចៅពញាស៊ូ** ។ **សម្ដេចចៅពញាស៊ូ** បានចាត់មនុស្សអោយទៅហៅ **ឧកញ៉ាបែន** មកវិញ ។ នៅគ.ស. ១៧៨៥ **ឧកញ៉ាបែន** បានស្ដេចសៀមអនុញ្ញាតអោយត្រឡប់ចូលប្រទេសវិញ ។ **សម្ដេចចៅពញាស៊ូ** សុំអោយ **ឧកញ៉ាបែន** បានទៅនៅជាមួយលោក ។ ក្នុងពេលជប់លៀងមួយ បក្សពួករបស់លោកបានសម្លាប់បក្សពួកខាង **ចៅហ្វាមូ** និង **ឧកញ៉ាចក្រីពាង** ។ ឯមន្ត្រីទាំងពីរជាបងប្អូនត្រូវចាប់បានហើយយកទៅប្រហារជីវិតបង់ ។

**សម្ដេចចៅពញាស៊ូ** លើកខ្លួនជាធំ គិតកំចាត់ **ឧកញ៉ាបែន** ទៀតតែ **ឧកញ៉ាបែន** ដឹងខ្លួនហើយកំចាត់ **សម្ដេចពញាស៊ូ** បានមុន ហើយតាំងខ្លួនជា **សម្ដេចចៅហ្វាទឡ្ហៈ** ។ តែទោះបីមានជ័យជំនះយ៉ាងនេះហើយក៏ដោយ ក៏បក្សពួក **សម្ដេចចៅពញាស៊ូ** បានលើកគ្នាទៅ **ឧដុង្គ** ជាហេតុបណ្ដាលអោយ **ចៅហ្វាបែន** ភៀសទៅប្រទេសសៀមនាំទាំងព្រះ **អង្គអេង** និងក្សត្រីទាំង ៣ អង្គទៅជាមួយផង ។

**ចៅហ្វាបែន** ត្រូវបានព្រះចៅសៀមទ្រង់ប្រទានបានន្តរសក្ដិជា **ចៅពញាអភ័យធីបែសនិសេសសង្គ្រាមរាមនរិន្ទបតី** ។

នៅ គ.ស. ១៧៩១ អ្នកម្នាង **អ្នូត** មានបុត្រនាមព្រះ **អង្គចន្ទ** ហើយបីឆ្នាំក្រោយមកមានបុត្រមួយអង្គទៀតនាម **អង្គស្ងួន** ។ អ្នកម្នាងម្នាក់ទៀតមានបុត្រនាម **អង្គអិម** ។ អ្នកម្នាង **កែ** មានបុត្រនាម **អង្គតិម** ( គ.ស. ១៧៩៣ ) ។

នៅ គ.ស. ១៧៩៤ ព្រះ **អង្គអេង** ត្រូវបានព្រះចៅសៀមអភិសេកនៅ **បាងកក** ដោយមានព្រះនាមហៅថាសម្ដេចព្រះ **នារាយណ៍រាជាធិរាជរាមាធិបតី** ។ ឯ ឧកញ៉ាក្រឡាហោម **ប៉ុក** ដែលបានភៀសទៅជាមួយព្រះ **អង្គអេង** ដែរនោះ ត្រូវបានតាំងជា **ចៅហ្វាទឡ្ហៈ** ជាជំនួស **ចៅហ្វាទឡ្ហៈបែន** ដែលបានតាំងជាស្ដេចត្រាញ់ឈរត្រួតខេត្តបាត់ដំបង ។

លុះបានអភិសេកនិងតែងតាំងគ្រប់សព្វហើយ ព្រះចៅសៀមទ្រង់បញ្ជាអោយ ចៅ

www.budinst.gov.kh www.elibraryofcambodia.org

**ចៅពញាអភ័យធីបែសបែន** លើកទ័ពនាំព្រះ **អង្គអេង** យាងមកសោយរាជ្យនៅប្រទេសខ្មែរ វិញត្រឡប់ទៅឈរត្រួតខេត្តបាត់ដំបងវិញ តែត្រូវឡើងផ្ទាល់ទៅព្រះចៅសៀម ។ ចំណែក ចៅហ្វាយខេត្ត **អង្គរ** ត្រូវស្ថិតនៅក្រោមអំណាចរបស់ **ចៅពញាអភ័យធីបែសបែន** ។ ដូច្នេះ ចាប់តាំងពី គ.ស ១៧៩៥ មក ខេត្ត **បាត់ដំបង** និងខេត្ត **អង្គរ** ត្រូវបាត់ទៅសៀម ដោយសន្តិវិធី ។ ចំពោះការបាត់បង់ទឹកដីនេះ អ្នកប្រវត្តិសាស្ត្រខ្លះបានចោទសួរថា តើ មានកិច្ចព្រមព្រៀងសម្ងាត់អ្វីមួយរវាងព្រះមហាក្សត្រទាំងពីរដែរឬទេ ? តើនេះជាគុណថ្លាធំចំពោះស្តេចសៀមដែលបានទទួលស្គាល់ស្តេចខ្មែរ ហើយលើកអោយឡើងសោយរាជ្យឬយ៉ាងណា? (42) ។ ចំពោះរឿងដដែលនេះ ឯកសារសៀមមួយបានសរសេរថា: "ចំណែក **ចៅពញាអភ័យធីបែស** ( ចៅហ្វាបែន ) បានថែរក្សាប្រទេសកម្ពុជារៀបរយល្អ តែជាពួករបស់ព្រះ **រាមរាជា** ( អង្គនន់ ) ក្រែងមិនស្និទ្ធស្នាលជាមួយ **សម្តេចព្រះនារាយណ៍** ( អង្គអេង ) និង **ចៅហ្វាធឡុះ** ( ចៅហ្វាប៉ុក ) ទើបទ្រង់សុំស្រុក **សៀមរាប** និងស្រុក **បាត់ដំបង** អោយ **ចៅពញាអភ័យធីបែស** គ្រប់គ្រងឡើងដល់ថៃដោយត្រង់ ។ ខេត្តនេះទើបធ្លាក់នៅក្រោមអំណាចថៃរហូតដល់រជ្ជកាលទី ៥ " (36) ។

រាជពង្សាវតារខ្មែរមួយ បានផ្តល់ពត៌មានមានន័យប្រហាក់ប្រហែលនឹងពត៌មានរបស់ឯកសារសៀមដែរ: "ឧកញ៉ា **បែន** គិតថា បើនៅបំរើព្រះ **នារាយណ៍រាជាអង្គអេង** ត្រូវសំគះចៅហ្វា **ប៉ុក** ឧកញ៉ាបែន និង **អង្គដួង** នាំអោយខូចកិត្តិយស គិតថយទៅ **បាត់ដំបង** ឡើងផ្ទាល់ទៅសៀមវិញ ។ ព្រះរាជាក៏ទ្រង់អនុញ្ញាតអោយទៅ ទៅហើយទូលស្តេចសៀម សុំខេត្ត **បាត់ដំបង មហានគរ** ឡើងផ្ទាល់សៀមជារង្វាន់ ។ ស្តេចសៀមធ្វើសុភអក្សរមកពីដេញទើបព្រះ **អង្គអេង** ព្រមថ្វាយ តែព្រមថ្វាយសំរាប់តែផែនដីព្រះគុណយំកហ្វាមួយទេ ( គ.ស. ១៧៩៥ ) (43) ។

នៅ គ.ស. ១៧៩៦ អ្នកម្នាងរស់ បានប្រសូតបុត្រនាម **អង្គដួង** ។ ទន្ទឹមដែល ព្រះ **នារាយណ៍រាជាអង្គអេង** ទ្រង់អាពាធហើយសោយទិវង្គត ។

www.budinst.gov.kh www.elibraryofcambodia.org

## ២– ចៅហ្វាប៉ុក (១៧៩៦-១៨០៥).—

លុះទ្រង់ជ្រាបពត៌មានខាងលើហើយ ព្រះចៅសៀមទ្រង់បញ្ជាអោយចៅហ្វាប៉ុក លើកព្រះ អង្គចន្ទ ដែលមានព្រះជន្មទើបបាន ៥ វស្សាអោយឡើងគ្រងរាជ្យ ហើយអោយ លោកទទួលមើលខុសត្រូវក្នុងកិច្ចការរដ្ឋសិន ។

នៅគ.ស. ១៧៩៤ សៀមច្បាំងនឹងភូមា ។ ចៅហ្វាប៉ុក បាននាំកងទ័ពទៅជួយច្បាំង ឈ្នះភូមា ចាប់បានឈ្លើយជាច្រើននាំចូលប្រទេសខ្មែរអោយទៅតាំងនៅត្រង់តំបន់ ប៉ៃលិន ក្នុងខេត្ត បាត់ដំបង ។

នៅគ.ស. ១៨០០ ដោយទទួលបញ្ជាពីស្តេចសៀម ចៅហ្វាប៉ុក បានបញ្ជូនទ័ព ទៅជួយ ង្វៀង គុក អាញ់ ដើម្បីកំចាត់ពួក តី សឺន ។ ទាហានណាមិនព្រមច្បាំងត្រូវ ប្រហារជីវិតបង់ ជាហេតុនាំអោយរាស្ត្រខ្មែរក្តៅក្រហាយខ្លាំង ។ លុះបានជ័យជំនះលើ ពួកតី សឺនហើយ ង្វៀង គុក អាញ់ ឡើងសោយរាជ្យមាននាមថា យ៉ាឡុង (Gia-long) ហើយបានផ្ញើសងមកខ្មែរវិញនូវកាំភ្លើងធំ ២ ដើមដែលយួនបានរឹបយកកាលធ្វើសង្គ្រាមជាមួយ ព្រះ អង្គនន់ (ព្រះរាមរាជា) ។

នៅគ.ស. ១៨០៥ ព្រះអង្គចន្ទ ទ្រង់យាងទៅប្រទេសសៀមដោយមានចៅហ្វាប៉ុក ដង្ហែទៅផង តែលោកបានស្លាប់នៅទីនោះក្នុងជន្មាយុ ៦៥ ឆ្នាំ ។

## គ– យួនមានឥទ្ធិពលខ្លាំងឡើងវិញ.–

## ១– ព្រះបាទឧទ័យរាជា អង្គចន្ទ (១៨០៦-១៨៣៤).-

នៅខែសីហាគ.ស.១៨០៦ ព្រះអង្គចន្ទដែលមានព្រះជន្មទើបបាន ១៥ វស្សាបាន អភិសេកនៅក្រុងបឹងគគ ដោយមានព្រះនាមស៊ុំរាប់រាជ្យថា ព្រះបាទសម្តេចព្រះឧទ័យ រាជាធិរាជរាមាធិបតីព្រះស្រីសុរិយោពណ៌ ។ រួចហើយ ព្រះអង្គទ្រង់យាងត្រឡប់



www.budinst.gov.kh www.elibraryofcambodia.org

មកសោយរាជ្យនៅក្រុង**ឧដុង្គ**វិញ ។ បីខែក្រោយមក **ចៅពញាអភ័យធិបែសរ៍បែន** បានយកកូនស្រីឈ្មោះ**ទេព**មកថ្វាយជាម្នាង ។

បន្ទាប់មក ព្រះ **ឧទ័យរាជា** ទ្រង់អោយនាំគ្រឿងបណ្ណាការទៅថ្វាយស្តេចសៀម សុំយាងក្សត្រាក្សត្រីខ្លះមកវិញ ។ ស្តេចសៀមអោយតែព្រះមាតា និង រាជបុត្រី **អង្គពៅ** ត្រឡប់មកវិញ (១៨០៧) ។

នៅគ.ស.១៨០៩ អ្នកម្នាង **ទេព** ប្រសូតបុត្រីនាម **អង្គប៉ែន** ។ នៅឆ្នាំដដែលព្រះចៅសៀមសោយទីវង្គត ហើយព្រះរាជបុត្រច្បងឡើងសោយរាជ្យស្នង ។ ឯ **ចៅពញាអភ័យធិបែសរ៍បែន** ក៏ទទួលមរណភាពជំណាលគ្នានោះដែរ ។ កូនលោកគឺ **ឧកញ៉ា និបុលរាជបែន** ត្រូវបានព្រះចៅសៀមតែងតាំងអោយកាន់តំណែងជាជំនួសឪពុកលោក ។

ព្រះ**អង្គចន្ទ**ទ្រង់បានចាត់អោយព្រះអនុជនិងមន្ត្រីខ្លះទៅចូលរួមក្នុងពិធីបុណ្យសពស្តេចសៀម ។ ព្រះចៅសៀមដែលឡើងសោយរាជ្យស្នងបិតាទ្រង់សព្វព្រះទ័យតាំងព្រះ **អង្គស្ងួន** ជាឧភយោរាជ និងតាំងព្រះ **អង្គអិម** ជាឧបរាជ ។

ក្រោយមក វិវាទបានកើតឡើងរវាងព្រះ **អង្គចន្ទ** និងព្រះអនុជជាឧភយោរាជ ។ បុព្វហេតុទំនងជាបណ្តាលមកពីស្តេចសៀមពុំបានសួរយោបល់ពីព្រះអង្គក្នុងការតែងតាំងគេ ។ ព្រះឧភយោរាជនិងគ្រួសារទ្រង់បានភៀសទៅនៅពោធិ៍សាត់ ។ ព្រះរាជាទ្រង់បានសូមសម្តេចព្រះសង្ឃរាជនិងចាត់មន្ត្រីអោយសូមយាងមកវិញតែឥតប្រយោជន៍ ។ ដោយហេតុខ្លាចក្រែងមានចម្បាំងគ្នាឯងក្នុងស្រុកកើតឡើង ព្រះអង្គក៏ទ្រង់ចាត់អោយទៅសុំទ័ពយួនមកបង្ការ ។ ទ័ពនេះបានមកហើយទៅបោះនៅត្រង់**កោះចិន** ។

ប្រហែលជាចាប់ពីពេលនោះ ព្រះអង្គទ្រង់បានទិតជិតមកខាងយួន ទ្រង់ទុកដាក់ប្រទេសខ្មែរជាសាមន្តរដ្ឋ ហើយលើកសួយសារអាករទៅថ្វាយស្តេច**យ៉ាឡុង** ៣ ឆ្នាំម្តង ។

ចំណែកឯព្រះចៅសៀមទ្រង់មិនពេញព្រះទ័យចំពោះអំពើរបស់ព្រះ **អង្គចន្ទ** ដែលបានងាកទៅរកយួនជាមិត្តនោះវិញ ។ ម្ល៉ោះហើយ ក៏ទ្រង់បញ្ជូនទ័ពអោយចូលប្រទេសខ្មែរជា ៣ ផ្លូវ ។

ទ័ពចំរុះ ខ្មែរ-យួន ច្បាំងនិងទ័ពសៀម ។ ដោយឃើញស្ថានការណ៍មានសភាពកាន់តែធ្ងន់ ព្រះ **អង្គចន្ទ** និងព្រះអនុជទាំងពីរគឺ **អង្គអិម** និង **អង្គដួង** ដកថយទៅកាន់នៅ **តិចចូវ**( Tân châu ) ។ នៅពេលយប់ ព្រះឧបរាជ **អង្គអិម** និង **អង្គដួង** នាំព្រះមាតានិងបណ្តាខ្ញុំរត់ទៅប្រទេសសៀមជាមួយ **អង្គស្ងួន** ។

នៅ គ.ស. ១៨១៣ ក្រោយពីបានធ្វើការសំរុះសំរួលជាមួយសៀមខ្លះហើយ ស្តេច **យ៉ាឡុង** ទ្រង់បានបញ្ជាអោយលោក **ឡេ វ៉ាន់ យៀត** ( Lê Van Duyêt ) ហែព្រះ **អង្គចន្ទ** អោយត្រឡប់មកសោយរាជ្យនៅប្រទេសខ្មែរវិញ ។ ពេលទ័ពយួនមកដល់ ពួកមេទ័ពសៀមបែរជាស្រឡាំងកាំង ដកទ័ពថយទៅវិញ ហើយមានមេទ័ពខ្លះមកថ្វាយស័ក្តិសាធុការចំពោះព្រះអង្គថែមទៀតផង ។

ឯកសារសៀមក្តី (36) រាជពង្សាវតារខ្មែរក្តី បាននិយាយស្របគ្នាថា ទោះបីព្រះអង្គស្និទ្ធស្នាលនឹងយួនជាងក៏ដោយ ក៏ព្រះ **អង្គចន្ទ** បាននាំគ្រឿងបណ្ណាការទៅថ្វាយស្តេចសៀមក្នុងឋានៈជាប្រទេសរាជ ។

នៅគ.ស.១៨១៤ សៀមលើកទ័ពចូលម្តងទៀត តែពុំមែនមកកំចាត់យួនដូចពេលមុនៗទេ គឺមកដណ្តើមយកទឹកដីខ្មែរដោយត្រង់ៗតែម្តង ៈ ដូច្នេះទឹកដីខ្មែរបី ខេត្តទៀតត្រូវបានទៅសៀមចាប់តាំងពីពេលនោះទៅគឺ **មូលប្រៃ** **ទន្លេរពៅ** និង **ស្ទឹងត្រែង** (សូមមើលផែនទី) ។ បើតាមលោក Moura(42) ការបាត់បង់ទឹកដីខាងលើនេះ គឺបណ្តាលមកពីចៅហ្វាយស្រុកខេត្ត **កំពង់ស្វាយ** ឈ្មោះ **ម៉ឹង** បានទៅអះអាងប្រាប់ព្រះចៅសៀមថាប្រជារាស្ត្រក្នុងខេត្តទាំងប៉ុន្មាននោះ បានសុំអោយទទួលអោយខ្លួនបាននៅក្រោមអំណាចគ្រប់គ្រងរបស់សៀម ។

ឯកសារយួនមួយបានសរសេរថា លោក **ឡេ វ៉ាន់ យៀត** ទេសាភិបាលនៅ **យ៉ាឌិញ** បានទូលសូមអនុញ្ញាតពីស្តេចយួនអោយសង់បន្ទាយនៅភ្នំពេញនិងនៅ **ឡាឡែម** (ល្វាឯម) ។ លុះបន្ទាយទាំងនោះសង់រួចស្រេចហើយ ស្តេចយួន **ថេ តោ** ( Thê tô ) គឺស្តេច **យ៉ា ឡុង** បានបញ្ជាអោយមេទ័ព **ង្វៀង វ៉ាន់ ធុយ** ( Nguyên-văn-Thuy )

www.budinst.gov.kh www.elibraryofcambodia.org

ប្រមាណ ១០០០ នាក់ទៅតាំងអាណាព្យាបាលភាពលើប្រទេសចិនឡាប (ប្រទេសខ្មែរ) ។

ចំណែកឯទេសាភិបាលយួនឈរនៅកម្ពុជាក្រោមមានអំណាចសំរេចរាជការគ្រប់បែប យ៉ាងលើប្រទេសខ្មែរ គឺទាំងខាងរដ្ឋបាលនិងទាំងខាងយោធា (42) ។

រាជពង្សាវតារខ្មែរបានបញ្ជាក់បន្ថែមទៀតថា **អុង តា គុន** (គឺ ឡេ វ៉ាន់ យៀត) សាងវាំងថ្មីមួយនៅខាងត្បូង **ទន្លេឧណ្ណាលោម** ហៅថា **ព្រះរាជវាំងតំផែងកែវ** ហើយយាងព្រះ**ឧទ័យរាជា** អោយមកគង់ក្នុងវាំងថ្មីនេះ ។ ម៉្យាងទៀត លោកបានអោយលើកដីសង់**ជំណាក់ព្រះបារមី**មួយនៅជ្រោយចង្វារ តែងរាល់ថ្ងៃ ១ រោច ១៥ កើតអោយអស់មន្ត្រីយួនខ្មែរទៅសំពះរំលឹកគុណស្តេចយួន ។ ពេលនោះ ទាំងព្រះ**ឧទ័យរាជា** ទាំងនាម៉ឺនសព្វមុខមន្ត្រីសុទ្ធតែស្លៀកខោពាក់អាវផ្លូតឈ្នួតក្បាលតាមបែបយួនទាំងអស់ ។

នៅគ.ស. ១៨១៥ អ្នកម្នាង **គ្រុមាប់** មានបុត្រីនាម **អង្គម៉ី** ។

នៅឆ្នាំដដែល ស្តេចយួនទ្រង់ចាត់អោយសង់បន្ទាយនៅ **មាត់ជ្រូក** និងជីកព្រែកពីរនៅក្នុងទឹកដីយួន :

— ព្រែកមួយ ហៅថាព្រែក **វិញតេ** (Vinh-tế) មានប្រវេង ៥៣ គ.ម. ត្រូវតភ្ជាប់មាត់ជ្រូកទៅនឹងសមុទ្រនៅតំបន់ពាម ។

— ព្រែកមួយទៀត ហៅថា **វិញអាន** (Vinh-an) មានប្រវែង ១៤ គ.ម. ទទឹង ២៤ ម. ត្រូវតភ្ជាប់ទន្លេធំទៅនឹងទន្លេបាសាក់ ។

រាជពង្សាវតារខ្មែរបានបញ្ជាក់ថា ក្នុងការជីកព្រែកទាំងពីរខាងលើនេះ ប្រជារាស្ត្រខ្មែរត្រូវគេកេនទៅ ហើយត្រូវយួនធ្វើបាបគ្មានត្រាប្រណីរាប់តិចសោះឡើយ ។ **រឿងតំពប់តែអុង** ដែលយួនវាយកខ្មែរកប់ទាំងរស់យកក្បាលធ្វើជើងក្រានដាំតែបានកើតឡើងនៅពេលនោះដែរ ។ ឯកសារខ្មែរមួយទៀតបានសរសេរទាក់ទងនឹងរឿងនេះដែរថា "ក្រុមយួនទាហានបរទេសខ្មែរ ជាគួលីកំណែងនេះប្រៀបបាននឹងឋាននរក ។ មួយថ្ងៃៗធ្វើការតាំងពីព្រលឹមរហូតដល់ល្ងាចយប់ ឥតមានសំរាកឡើយ ទឹកសំរាប់ជីកមានកឿងលាយភក់ បាយស៊ីទៅ

www.budinst.gov.kh www.elibraryofcambodia.org

ហើយពោះ បណ្ដាលអោយកើតរោគ យួនភ័យ សំគងថែមទៀត ដោយចោទថាខ្មែរខ្ជិល ខ្មែរធ្វើពុត ខ្មែរយឺត ។ នៅពេលដែលយួនបើកទឹកបង្ហូរចូលព្រែក យួនឥតប្រាប់ខ្មែរទេ បណ្ដាលអោយកម្មករកំណែនខ្មែរដែលរត់មិនទាន់លិចលង់ក្នុងព្រែកស្លាប់ជាច្រើន ។ ចំពោះអំពើព្រៃផ្សៃ អមនុស្សធម៌របស់យួន ព្រះ**អង្គចន្ទ**ឥតបានតវ៉ាអ្វីឡើយ មានតែមន្ត្រីម្នាក់បានរចញមុខការពារ ។ យួនដឹងក៏ចាប់មន្ត្រីនោះទៅសំលាប់ចោល ។ ក្រោយពីកែនខ្មែរអោយទៅជីកព្រែក យួនទៅបានបង្ខំខ្មែរអោយកាប់ព្រៃឈើអោយគេថែមទៀត ។ ដំបូង គេប្រើគោ ក្របី រទេះសំរាប់អូសឈើ តែដល់សត្វស្លាប់អស់ទៅដោយកាប់ឈើច្រើនពេក គេក៏ប្រើមនុស្សអោយអូសវិញ ។ អំពើអមនុស្សធម៌នេះបណ្ដាលអោយប្រជារាស្ត្រខ្មែរ ព្រះសង្ឃខ្មែរទ្រាំពុំបាន ក៏នាំគ្នាកាប់សំលាប់យួនអស់ជាច្រើន ។ តែយួនសងសឹកខ្មែរវិញយ៉ាងសាហាវជាទីបំផុត (18) ។

នៅ គ.ស ១៨២០ មានភិក្ខុ១ អង្គនាម **កែគង់** បួសនៅវត្តសំបូរក្នុងខេត្តភ្នំពេញ បានតាំងខ្លួនជាអ្នកសិល្ប៍ក្លូវិសេស ទៅបញ្ចុះបញ្ចូលអស់រាស្ត្រនៅខេត្ត **បាភ្នំ** រួចទៅរួបរួមនឹង **សម្ដេចចៅពញាតី ឧកញ៉ានរេន្ទ្រគង់** និងនាយ **កែវព្រាល** លើកទ័ពទៅកាប់សម្លាប់យួនអស់ជាច្រើន ។ ពេលនោះ **អុចតាគុន ឡេ វ៉ាន់ យៀត** នៅ **ព្រៃនគរ** ប្រើអោយនាំពល ៣០០០ នាក់លើកដល់ភ្នំពេញ ហើយបង្ហូសទៅបោះនៅ **កោះស្លូតិន** ទើបសម្ដេច **ព្រះឧត្ដិយរាជា** ទ្រង់បញ្ជាអោយលើកទ័ពទៅជាបន្ថែម ហើយចាប់បានភិក្ខុ **កែគង់** យកទៅសម្លាប់ ។ ចំណែកឯ **សម្ដេចចៅពញាតី ឧកញ៉ានរេន្ទ្រគង់** នឹងនាយ **កែវព្រាល** ត្រូវចាប់បានបញ្ជូនទៅ **ព្រៃនគរ** ហើយក្រោយមកត្រូវប្រហារជីវិតបង់ដែរ ។ រាជពង្សាវតារបានបញ្ជាក់ថា ឧប្បត្តិហេតុនេះកើតមកពីការវិវាទរវាងនាម៉ឺនខ្មែរនិងនាម៉ឺនយួន ។

នៅ គ.ស. ១៨២១ ម្នាងម្នាក់នៃ **អង្គដួង** បានប្រសូតបុត្រីនាម **មុំ** ។ នៅឆ្នាំក្រោយ អ្នកម្នាង **យស** របស់ព្រះ **អង្គចន្ទ** មានបុត្រីនាម **អង្គពៅ** ។

នៅ គ.ស ១៨២៩ អ្នកម្នាង **ប៉ែន** ( ប្អូនអ្នកម្នាងក្រចាប់ ) មានបុត្រីនាម **អង្គស្ងួន** ។

នៅ គ.ស. ១៨៣២ សៀមលើកទ័ពមកតាមផ្លូវបាត់ដំបង ពោធិសាត់ ហើយមក

www.budinst.gov.kh www.elibraryofcambodia.org

រហូតដល់កំពង់ឆ្នាំង ។ ទ័ពខ្មែរស្ថិតនៅក្រោមបញ្ជាការរបស់ឧក្រី **ឡុង** បានប្រយុទ្ធជាមួយទ័ពសៀមនៅ **មិចពោធិ** តែនៅទីបំផុតខ្មែរទន់ដៃជាង បាក់ទ័ព ហើយឧក្រី **ឡុង** ក៏ភៀសទៅនៅខេត្តបាភ្នំ ។ បរាជ័យរបស់ខ្មែរលើកនេះជាហេតុបណ្តាលអោយព្រះ**ឧទ័យរាជា** ភៀសទៅស្រុកក្រោមម្តងទៀត ហើយទៅគង់នៅ **លង់ហោរ** ។ ទ័ពសៀមដែលមាន **ពញាបឌិនតេជោ** ជាមេបញ្ជាការបាននាំព្រះ **អង្គអិម** មហាឧបរាជ និងព្រះ**អង្គដួង** មកទុកអោយគង់នៅភ្នំពេញ ហើយលើកបន្តសទៅប្រយុទ្ធជាមួយយួននៅ **ចាត់ជ្រូក** វាយឈ្នះយកបានបន្ទាយនេះ ។

នៅពេលនោះ នកញ៉ាឧក្រី **ឡុង** ដែលបានភៀសទៅបាភ្នំនោះ បានទៅកែនទ័ពហើយវាយឈ្នះទ័ពសៀមដែលចូលទៅក្រោយខាងកើត ។

ចំណែកឯ **ពញាបឌិនតេជោ** ដែលវាយឈ្នះយួននៅចាត់ជ្រូកនោះបានជម្រុលទៅដល់ **លង់ហោរ** តែត្រូវទទួលបរាជ័យក្នុងចម្បាំងជើងទឹកជាមួយយួន ។

សៀមលើកទ័ពថយទៅវិញអស់ ។ លុះទ្រង់ជ្រាបដំណឹងនេះ ព្រះ **អង្គអិម** និងព្រះ**អង្គដួង** ក៏យាងភៀសទាំងពីរអង្គទៅខេត្តបាត់ដំបង ។

លុះសៀមដកទ័ពថយទៅវិញអស់ហើយ យួននាំព្រះ **ឧទ័យរាជា** ត្រឡប់មកសោយរាជ្យនៅភ្នំពេញវិញ ។ ឧក្រី **ឡុង** ត្រូវបានតាំងជា**ចៅហ្វាទឡ្ហៈ** ។

យួនបានសង់បន្ទាយតាក្លាប នៅជិតក្រុងភ្នំពេញ ហើយចាត់មេទ័ពឈ្មោះ**ទ្រឿង មិញ យ៉ាំង** (Truong minh Giang) និងមន្ត្រីឈ្មោះ **លេ ដាយ កឿង** ( Lê dai-Cuong ) អោយឃ្លាំមើលត្រួតប្រទេសខ្មែរ ។

ព្រះ **ឧទ័យរាជា** ទ្រង់សោយទិវង្គតនៅគ.ស. ១៨៣៤ ដោយរោគរាគក្នុងព្រះជន្ម ៤៤ ព្រះវស្សា ។

## ២–ក្សត្រីអង្គមី ( គ.ស. ១៨៣៤ - ១៨៤០ ).–

ព្រះចៅ **មិញ ម៉ាំង** (Minh mang) ដែលជារាជបុត្រសោយរាជ្យស្នងព្រះចៅ**យ៉ា-**



www.budinst.gov.kh www.elibraryofcambodia.org

ឡុង ទ្រង់បានបញ្ជូន អុង តាំ ហ៉ង អោយនាំគ្រឿងបណ្ណាការឡើងមកជួយការបុណ្យ
បរមសព ។ រាជទូតរូបនេះនៅមានបេសកកម្មម្យ៉ាងទៀត គឺការជ្រើសរើសក្សត្រអោយ
ឡើងសោយរាជសម្បត្តិស្នងព្រះ **ឧទ័យរាជា អង្គចន្ទ** ។ តាមពិតលោកបានទទួលបញ្ជា
ជាស្រេចពីព្រះចៅ **មិញ ម៉ាង** ថាត្រូវជ្រើសរើសក្សត្រអង្គណាអោយឡើងកាន់អំណាច
ហើយ ដូចមានសេចក្តីបញ្ជាក់ពីព្រះរាជពង្សាវតារថា **អុង តាំ ហ៉ង** បាននាំទាំងព្រះនាម
មកថ្វាយរៀបអភិសេកអ្នក **អង្គ មី** ជាព្រះរាជបុត្រីបន្ទាប់អោយគ្រប់គ្រងក្រុងកម្ពុជាធិបតី ។
ប៉ុន្តែ ដើម្បីជាការបិទបាំងកុំអោយអ្នកផងស្គាល់ព្រះរាជបំណងព្រះចៅយួន លោកបានធ្វើ
ការប្រឹក្សាសួរយោបល់នៃមន្ត្រីខ្មែរ ដោយ បានបញ្ជាក់ថាត្រូវចៀសវាងកុំលើកក្សត្រទាំង
ឡាយដែលបានភៀសទៅខាងសៀម មានព្រះ **អង្គអិម** មហាឧបរាជនិងព្រះ **អង្គឌួង** ជា
ដើម នងត្រូវចៀសវាងកុំលើកក្សត្រី **អង្គប៉ែន** ព្រោះព្រះមាតាជាអ្នកស្និទ្ធស្នាលនឹងសៀម
ទៀត(42) ។

ដោយហេតុនោះ ក្សត្រី **អង្គ មី** ជាបុត្រីបន្ទាប់នៃព្រះ **ឧទ័យរាជាអង្គចន្ទ** ត្រូវលើក
អោយឡើងគ្រងរាជ្យ ក្នុងព្រះជន្ម ២១ វស្សា នៅ**កោះស្លាកែត** ដោយមានព្រះនាមហៅ
តាមយួនថា **បា គុង ចៅ** (ba công chua) ប៉ុន្តែបើតាមឯកសារយួនថា មានព្រះនាមថា
**ង៉ុក វ៉ឹង គុង ជួ** (Ngoc Vân công chua) ហើយមានព្រះឋានៈត្រឹមតែជា **ក្វឹង ជួ** (quân
chua) គឺស្មើនឹងចៅហ្វាយខេត្តម្នាក់ប៉ុណ្ណោះ ។ ចំណែកឯក្សត្រី **អង្គពៅ** ត្រូវលើកជា
ឧបរាជិនី និងក្សត្រី **អង្គស្ងួន** ត្រូវលើកជាកែវហ្វា (40-44) ។

ចំពោះការជ្រើសរើសក្សត្រីមួយអង្គអោយឡើងគ្រងរាជ្យនេះ លោក Adhémard
Leclère បានសរសេរថា : "ការជ្រើសតាំងនេះពុំបានធ្វើអោយអាណាប្រជានុរាស្ត្រងឿង
ឆ្ងល់ពេកទេ ព្រោះថាបើគេពុំដែលនឹកឃើញថាស្ត្រីម្នាក់អាចត្រូវបានលើកអោយឡើង
សោយរាជ្យនៅប្រទេសកម្ពុជា ក៏គេធ្លាប់បានឃើញជាញឹកញយដងដែរថា មានព្រះរាជាខ្លះ
ដោយជក់ព្រះទ័យខ្លាំងនឹងការសាងផ្នួស ទ្រង់បានប្រគល់អំណាចទៅអោយព្រះអគ្គមហេសី
ឬព្រះមាតាដែរ" (44) ។

www.budinst.gov.kh www.elibraryofcambodia.org




www.budinst.gov.kh www.elibraryofcambodia.org

ឯកសារផ្សេងៗបានបញ្ជាក់អោយឃើញថា ក្នុងរជ្ជកាលរបស់ព្រះអង្គ **ក្សត្រីអង្គមី** ពុំមាន អំណាចអ្វីជាដុំឡើយ ហើយយួនបានចាត់ចែងការគ្រប់បែបយ៉ាងដើម្បីអោយខ្មែរក្លាយទៅជាយួន ជាហេតុបណ្តាលអោយអាណាប្រជានុរាស្រ្តបានដល់នូវសេចក្តីទុក្ខវេទនាឥតស្រាកស្រាន្ត ។

ជាដំបូង ប្រទេសខ្មែរត្រូវគេផ្លាស់អោយមានឈ្មោះហៅថា **ត្រឹន តី ថាញ់** (Trân-tây-thành) (១) ហើយត្រូវចែកជា ៣២ **ភូ** (phu) (២) និង ២ **ហ្វៀន** huyên) (៣) ។ នៅប្រទេសខ្មែរទាំងមូលមានមេទ័ពម្នាក់និងមន្ត្រីយួនជាច្រើននាក់ទៀតជាអ្នកមើលការខុសត្រូវក្នុងកិច្ចការរដ្ឋទាំងឡាយ ។ នៅកន្លែងណាដែលជាចំណុចយុទ្ធសាស្រ្តនោះ មានចាត់អោយមានជាបន្ថែមនូវមន្ត្រីដែលយួនហៅថា **ទៀន ភូ** (tuyên-phu) និង **អាន ភូ** (an-phu) (៤) ដើម្បីការពារថែមទៀត (40) ។

ឈ្មោះទីទាំងឡាយ គឺតាំងពីឈ្មោះមនុស្សរហូតដល់ឈ្មោះក្រុង ខេត្ត ស្រុក ភូមិ សុទ្ធតែត្រូវផ្លាស់ប្តូរអោយមានសូរសៀងជាយួនទាំងអស់ (44-46) :

— **ក្សត្រីអង្គ មី** . . . . . **ង៉ុក វ៉ឹន កុង ជួ** (Ngoc Vân công-chua)

— **ចៅហ្វា ឡុង** . . . . . **ត្រា ឡុង** (Tra Long)

— **ភ្នំពេញ** . . . . . **ណាម វ៉ាង** (Nam Vang ,

---

(១) **ត្រឹន** (trân) = មណ្ឌលរដ្ឋបាលមួយក្នុងសម័យបុរាណរបស់យួន

**តី** (tây) = ខាងលិច

**ថាញ់** (thành) = បន្ទាយ

ដូច្នេះ **ត្រឹន តី ថាញ់** មានន័យថា មណ្ឌលរដ្ឋបាលមួយជាបន្ទាយនៅទិសខាងលិច ។

(២) **ភូ** ស្មើនឹងខេត្តមួយ

(៣) **ហ្វៀន** ស្មើនឹងស្រុកមួយ

(៤) សត្ថិស្មើចៅហ្វាយខេត្ត ?



www.budinst.gov.kh www.elibraryofcambodia.org

— បន្ទាយដៀវ . . . . . គបិច ( Go Bich )

— ល្វាឯម . . . . . ឡាឡេម (La lêm)

— ឃ្លាំង . . . . . ជាក់ គូណាម (Bac Co Nam)

— សំពៅលូន . . . . . ឡុង ដោន (Long tôn)

— បន្ទាយមាស . . . . . សាយ ម៉ាត (Sai mat)

— តំបូក . . . . . កឹង វ៉ត (Cân vot)

— បាសាក់ . . . . . ប៉ាថាក់ (Ba thac)

— ព្រះត្រពាំង . . . . . ត្រាវិញ (Travinh)

— ពាមបន្ទាយមាស . . . . . ហាទៀន (Hatiên)

— ស្រុកឃ្លាំង . . . . . សុកត្រាំង (Soctrang) ។ល។

រាជពង្សាវតារខ្មែរបានបញ្ជាក់ថា កាលណោះ **អុង តា គុន** ជាធំនៅថែរក្សាស្រុកភ្នំពេញ បានធ្វើអោយនាម៉ឺនសព្វមុខមន្ត្រីខ្មែរមានការក្តៅក្រហាយដោយបង្ខំអោយស្លៀកពាក់ទៅតាម អោយផ្ទួតក្បាលនិងអោយមានងារស័ក្តិហៅតាមបែបយួនទាំងអស់ ។ ម្យ៉ាងទៀតចៅហ្វាយស្រុកនៃខេត្តខ្មែរទាំងអស់សុទ្ធតែមានមន្ត្រីយួននៅអមដើម្បីចាំត្រួតពិនិត្យ និងឃ្លាំមើលសកម្មភាពជាអចិន្ត្រៃយ៍ ។

អាណាប្រជានុរាស្ត្រត្រូវបង្ខំអោយបង់ពន្ធជាទម្ងន់ ត្រូវកែនចាប់ប្រើអោយធ្វើស្រែកាប់ចំការខ្លះ បំពេញកិច្ចការសាធារណៈខ្លះដូចជាសង់បន្ទាយ លើកផ្លូវពីភ្នំពេញទៅខេត្តទ្រាំងបន្ទាយមាស ។ នៅតាមបណ្តោយផ្លូវនោះគេត្រូវអោយសង់រោងមានមនុស្សប្រចាំការ ៣ នាក់គ្រប់ដំណាក់ដែលយួនហៅថា **ត្រាម** ( tram ,

ចំណែកឯព្រះពុទ្ធសាសនា ក៏ត្រូវរាជការយួនធ្វើទុក្ខបុកម្នេញយ៉ាងខ្លាំង ។ វត្តអារាមត្រូវរុះរើ ព្រះពុទ្ធរូបត្រូវវាយកំទេច ។ នៅឯស្រុកក្រោម ស្តេច **មិញ ម៉ាង** បានបង្ខំអោយព្រះសង្ឃខ្មែរប្រព្រឹត្តដូចលោកសង្ឃយួនផ្នែកមហាយាន គឺត្រូវគេអោយសក់ទុកចិញ្ចើម មិនឆាន់សាច់ ស្លៀកខោពាក់អាវដាយកត្រង់តណិ ឈាមជ្រុក ...ពេលសូត្រធម៌ត្រូវមានវាយៈ

www.budinst.gov.kh www.elibraryofcambodia.org

ត្រជោកជង (45-47) ។ គឺនៅក្នុងក្របខ័ណ្ឌប្រឆាំងនឹងការបំបាត់ទំនៀមទំលាប់ប្រពៃណីខ្មែរនេះហើយ ដែលលោកចៅហ្វាយស្រុកខេត្តព្រះត្រពាំងនាមចៅហ្វាយ **គុយ** សុខចិត្តធ្វើពលិកម្មបូជាជីវិតដើម្បីថែរក្សាកេរមត៌កពីដូនតាតទៅទៀត ។

នៅឯកម្ពុជាលើ ក៏មានមន្ត្រីជាច្រើនបានប្រឆាំងចំពោះការជិះជាន់របស់យួន ខ្លះក៏ត្រូវចាប់បានហើយយកទៅប្រហារជីវិត ខ្លះទៀតក៏រត់រួចចូលទៅខាងសៀម ។

នៅគ.ស.១៨៤០ ស្តេច **មិញ ម៉ាង** ទ្រង់បញ្ជាមន្ត្រីជាន់ខ្ពស់ពីរនាក់ទៀត គឺ **ឡេ-វ៉ាន់ ឌឹក** (Lê văn Duc) និង **យន អ៊ុន** (Doan Uân) អោយមកជួយ **ត្រឿង មិញ យ៉ាង** ក្នុងការគ្រប់គ្រងប្រទេសខ្មែរ ជាពិសេសក្នុងការត្រួតពិនិត្យពាណិជ្ជកម្ម ការគិតពន្ធដារនិងការវាស់វែងដីស្រែ (40) ។

នៅឆ្នាំដដែលនោះ ដើម្បីចៀសវាងនូវការបះបោរដែលអាចកើតមានឡើង **ត្រឿង មិញ យ៉ាង** បានប្រើឧបាយបញ្ជាអោយមន្ត្រីជំនិតនាំសារទៅថ្វាយព្រះ **អង្គអិម** មហាឧបរាជ ដែលព្រះចៅសៀមនាម **ណាំងក្លាវ** ទ្រង់ប្រោសអោយទៅគង់នៅបាត់ដំបង ជាសូមយាងព្រះអង្គចូលសោយរាជ្យនៅប្រទេសកម្ពុជា ។ លុះឮដូច្នោះហើយ ព្រះមហាឧបរាជក៏ជឿ តាមទ្រង់បញ្ជាអោយមន្ត្រីខ្លួនបក្រាប់ជាព្រះអនុជ **អង្គដួង** ចង់រត់ចូលក្រុងកម្ពុជាដើម្បីឡើងសោយរាជ្យ ។ ពេលនោះ ព្រះចៅសៀមទ្រង់បានបញ្ជាអោយគេនាំព្រះ **អង្គដួង** ត្រឡប់ចូលក្រុង **បាងកក** វិញ ។

ចំណែកឯព្រះមហាឧបរាជទ្រង់បានធ្វើដំណើរមកដល់ភ្នំពេញ ។ **ត្រឿង មិញ យ៉ាង** បានបញ្ជាអោយនាំបង្ខំសយកទៅដល់ក្រុង **វេ** ។

បន្ទាប់ពីនោះ **ត្រឿង មិញ យ៉ាង** បានប្រើកលល្បិចទៀតជាសូមអញ្ជើញមន្ត្រីជាន់ខ្ពស់របស់ខ្មែរមានចៅហ្វា **ឡុង** ជាដើមអោយទៅក្រុង **វេ** ជាដើម្បីពិភាក្សាពីកិច្ចការរដ្ឋជាមួយព្រះចៅយួននិងព្រះមហាឧបរាជ ។

លុះពួកមន្ត្រីចេញដំណើរទៅអស់ហើយ **ត្រឿង មិញ យ៉ាង** បានបញ្ជាអោយគេចាប់ក្សត្រីទាំង ៤ បញ្ជូនទៅស្រុកក្រោមទៀត ។ លុះទៅដល់ **សង់ហោរ** ក៏សំរាកចៅហ្វាយ

www.budinst.gov.kh www.elibraryofcambodia.org

ទេត្តនេះអោយតែក្សត្រី ៣ អង្គ គឺ**អង្គម៉ី** **អង្គពៅ** និង **អង្គស្ងួន** បណ្ដើរតែដល់វៀង **នគរ** ចំណែកឯ **អង្គម៉ែន** ត្រូវយកទៅផ្ទង់ទឹកចោលដោយត្រូវចោទថាជន់ថាវិបាការត់ទៅស្រុកសៀម ។

អំពើទាំងប៉ុន្មានដែលយួនបានប្រព្រឹត្តនេះពុំបានចាត់ស្ងាត់ទេ ។ អស់នាម៉ឺនសព្វមន្ត្រី ចៅហ្វាយស្រុកខេត្ត និងអស់បណ្ដារាស្ត្រកើតក្ដីក្ដៅក្រហាយទឹងទឹងយួន ព្រោះដឹងថាភាពបំរុងនឹងរំលាយស្រុកខ្មែរអោយសាបសូន្យ ម៉្លោះហើយបានស្រុះចិត្តគ្នាបះឡើងជាទ័ព លើកទៅកាប់សម្លាប់យួនអស់ជាច្រើន ។ យួនរត់មកផ្ដុំគ្នានៅភ្នំពេញ ។

នាម៉ឺននិងរាស្ត្រខ្មែរជំនុំពិភាក្សាគ្នាហើយ មូលមតិគ្នាចាត់ឧកញ៉ាវិបុលរាជ **ឡុង** និងឧកញ៉ាសួគ៌ាលោក **មុក** អោយចូលទៅស្រុកសៀមទូលព្រះចៅ **ណាំងក្លាវ** សូមយាង **ព្រះអង្គដួង** មកគ្រប់គ្រងក្រុងកម្ពុជា ។ ព្រះចៅសៀមក៏ទ្រង់យល់ព្រមតាមសំណូមពរ ហើយចាត់ **ពញាបតិនតេជោ** លើកទ័ពនាំព្រះ **អង្គដួង** ចូលមកស្រុកខ្មែរវិញ ។

ស្ដេចយួនឃើញស្ថានការណ៍ដូច្នោះ ទ្រង់ចាត់អោយលើកទ័ពនាំព្រះមហាឧបរាជ និងក្សត្រាក្សត្រីខ្មែរមកវិញ តែរាស្ត្រខ្មែរមិនជឿយួនទៀត យួនក៏នាំព្រះមហាឧបរាជទៅគង់នៅមាត់ជ្រូកសិន ។

## ឃ- សៀមនិងយួនស្រុះស្រួលគ្នាដើម្បីត្រួតត្រាខ្មែរ.-

### ១- ព្រះហរិរក្សរាមាឥស្សរាធិបតីអង្គដួង (គ.ស. ១៨៤០ - ១៨៥៩).-

ព្រះ **អង្គដួង** ព្រះរាជបុត្រពៅនៃព្រះបាទ **នារាយណ៍រាជាធី ៣ អង្គអេង** ត្រូវបាននាម៉ឺនសព្វមុខមន្ត្រីនិង **ពញាបតិនតេជោ** យាងអោយឡើងគ្រងរាជសម្បត្តិ ។ ព្រះអង្គទៅគង់នៅ **នាំង ឃ្លាំងស្បែក** ដែលរាស្ត្របានសាងថ្វាយនៅជិត **ពញាឮ** ។ ឯ**ពញាបតិនតេជោ** ក៏ស្ថិតនៅក្នុងប្រទេសខ្មែរសិនដើម្បីចាំជួយធ្វើអន្តរាគមន៍អោយបានទាន់ពេលវេលា **បើមានការចាំបាច់** ។



www.budinst.gov.kh www.elibraryofcambodia.org



ព្រះបាទមហារិរក្សរាមាឥស្សរាធិបតីអង្គដួង

(រូបស្រង់ពីទស្សនាវដ្ដី Le Sangkum លេខ៤ ខែវិច្ឆិកា ១៩៦៥)

ឯកសារយួនបាននិយាយថា នៅពេលនោះ នៅប្រទេស **ចឹងឡាប** (ប្រទេសខ្មែរ) ពួកអ្នកស្រុករួមគ្នានិងពួកសៀមបានធ្វើការប្រយុទ្ធយ៉ាងខ្លាំងក្លា ៗ ទ័ពយួនទប់មិនជាប់ ជាហេតុនាំអោយរាជការយួនមានសេចក្ដីព្រួយបារម្ភយ៉ាងខ្លាំង ៗ ម៉្លោះហើយនៅខាងដើមរជ្ជកាលស្ដេច **ធៀវត្រី** (១៨៤១) នាម៉ឺនឈ្មោះ **តា ក្វាង គី** (Ta quang Cu) បានទូលសុំបោះបង់ចោលប្រទេស **ចឹងឡាប** ដកថយទៅចាំទប់ទល់នៅ **មាត់ជ្រូក** វិញ ៗ ស្ដេចយួនទ្រង់ដៀតាម ហើយបញ្ជាអោយលោក **ទ្រឿង-មិញ យ៉ាង** ដកទ័ពចេញពីស្រុកខ្មែរ ៗ លុះមកដល់ **មាត់ជ្រូក** លោកឈឺចិត្តពេក ធ្លាក់ឈឺហើយទទួលមរណភាពទៅ (10) ។

ប្រគល់យួនដដែលនេះបាននិយាយថា ក្នុងពេលដំណាលគ្នានោះនៅស្រុកក្រោមមានការតស៊ូរបស់លោក **ឡឹម សោម** និងព្រះសង្ឃ ៗ ចំពោះរឿងនេះ ឯកសារខ្លះទៀតបានបញ្ជាក់ថា លោក **ឡឹមសោម** ឬ **ធេស្សាសោម** បានកទ័ពនៅស្រុក **ចាបគ្លើង** ក្នុងខេត្ត **ព្រះត្រពាំង** ក្នុងបំណងសងសឹកជួសចៅហ្វាយ **គុយ** និងដេញកំចាត់ពួកសត្រូវអោយចេញផុតពីទឹកដីដូនតារបស់លោក ៗ ដោយមានសេនា **ឯកប្រុញ** និង **ម៉ឺនសោម**

www.budinst.gov.kh www.elibraryofcambodia.org

ជួយយាំងសកម្មផង លោកបានលើកទ័ពទៅដល់ **ខ្ជោះជ្ជួខ** សម្លាប់បានយួនជាច្រើន តែនៅទីបំផុតលោកត្រូវទទួលបរាជ័យដោយទ័ពជំនួយរបស់យួនលើកមកពីទេត្តខាងកើត ។ លោកត្រូវចាប់ដាក់ទ្រុង នាំយកទៅក្រុង **ផេ** ហើយត្រូវប្រហារជីវិតតាមបញ្ជាស្ដេច **ធៀវទ្រី** (Thiêu-tri) ។

លុះមេទ័ពឈ្មោះ **ង្វៀង ធៀន ឡឹម** (Nguyên tiên Lâm) និង **ង្វៀង គុង ទ្រី** (Nguyên công Tru) បានបង្ក្រាបការតស៊ូរបស់លោក **ញ៉ឹមសោម** នៅស្រុកក្រោមហើយ សៀមបានលើកទ័ពជើងទឹកមកចុះត្រង់ **តំពត** ហើយការប្រយុទ្ធគ្នាជាមួយទ័ពយួន បានប្រព្រឹត្តទៅនៅ **ពាម** ។ នៅទីបំផុត សៀមដកទ័ពថយទៅវិញអស់ ។ ប៉ុន្តែទ័ពសៀមដែលនៅសល់ក្នុងស្រុកខ្មែរ និងទ័ពយួនដែលនៅក្នុងស្រុកក្រោះបះចះតែប្រយុទ្ធគ្នាជាបន្តទៅទៀតរហូតដល់ឆ្នាំ ១៨៤៥ ។ នៅឆ្នាំនោះ ស្ដេច **ធៀវទ្រី** បានបញ្ជាអោយលើកទ័ពធំចូលវាយសៀម យកបាន **ភ្នំពេញ** ហើយលើកបន្លូសទៅព័ទ្ធក្រុង **ឧដុង្គ** ថែមទៀត។ ខាងខ្មែរ-សៀមសុំចរចារកសន្តិភាព យួនមិនព្រម ។ តែមិនយូរប៉ុន្មាន យួនខ្វះឯងបានសុំចរចាម្ដងវិញ ។

ការចរចាបានប្រព្រឹត្តទៅនៅភូមិ **ពោធិបីដើម**: យួននិងសៀមថា ចង់ទំនុកបំរុងប្រទេសខ្មែរនិងស្ដេចខ្មែរដូចគ្នា ជាត្រូវអភិសេកព្រះ **អង្គដួង** អោយឡើងសោយរាជ្យដោយតំណាងប្រទេសទាំងពីរ សៀមរុះបន្ទាយយួន យួនរុះបន្ទាយសៀម ។ សៀមបានដោះលែងមេទ័ពនិងទាហានយួនជាឈ្លើយ ឯយួនត្រូវដោះលែងក្សត្រា ក្សត្រីខ្មែរមកវិញ ។

រហូតដល់ គ.ស. ១៨៤៧ ទើបព្រះ **អង្គដួង** ត្រូវបានអភិសេកអោយឡើងសោយរាជ្យនៅ **ឧដុង្គ** ដោយមានព្រះនាមសំរាប់រាជ្យថា ព្រះ **ហរិរក្សរាមាឥស្សរាធិបតី** ។ នៅឆ្នាំក្រោយ **ពញាបមិនគេជោ** បានលាព្រះអង្គត្រឡប់ចូលក្រុង **ប៉ិចគត** វិញ ។

គួរគប្បីជ្រាបថា នៅពេលឡើងសោយរាជ្យព្រះ **អង្គដួង** ទ្រង់គួចព្រះទ័យខ្លាំងណាស់ចំពោះការបាត់បង់ទឹកដីជាច្រើនដែលត្រូវយួននិងសៀមប្រវញ្ចយកដោយខុសច្បាប់ ។ ទឹកដីខ្មែរពីដើមមានវិសាលភាពធំទូលាយ ឥឡូវនេះត្រូវរួញតូចជាអតិបរិមា ប៉ុន្តែព្រះ **អង្គដួង**

www.budinst.gov.kh www.elibraryofcambodia.org

ពុំហ៊ានលើកយកបញ្ហានោះមកទេ ឬគាំអ្វីជាមួយយួននិងសៀមឡើយ ពីព្រោះអ្នកដឹកខាងទាំងពីរនេះមិនចូលចិត្តអោយលើកយករឿងទឹកដីនេះមកពិភាក្សាឡើងវិញទេ ។ គេយល់ថាទឹកដីទាំងប៉ុន្មានដែលគេបានកាន់កាប់នោះ គឺសុទ្ធតែជាកម្មសិទ្ធិស្របច្បាប់របស់គេទាំងអស់រួចហើយ ។

នៅគ.ស. ១៨៥៤ ដោយអត់ទ្រាំពុំបាននឹងអំពើរលោភទន្ទ្រានយកទឹកដីពីសំណាក់ជនជាតិយួនដែលរស់នៅក្នុងកម្ពុជាក្រោម **ព្រះអង្គឌួង**ទ្រង់បានសំរេចព្រះទ័យថាត្រូវតែសុំជំនួយនិងការការពារពីមហាអំណាចអឺរ៉ុបណាមួយ ។ ដោយហេតុនោះ ព្រះអង្គទ្រង់បានបញ្ជូនដោយសម្ងាត់នូវមន្ត្រីខ្មែរម្នាក់កាន់សាសនាកាតូលិកអោយទៅ **សិង្ហបុរី** ដើម្បីយកព្រះសារលិខិតរបស់ព្រះអង្គសរសេរជាភាសា បារាំងដោយសង្ឃ **Miche** យកទៅថ្វាយព្រះចៅ **Napoléon** ទី ៣ តាមរយៈលោកកុងស៊ុលបារាំងប្រចាំនៅទីនោះ ។ ជាមួយគ្នានោះ **ព្រះអង្គឌួង** ទ្រង់បានផ្ញើរគ្រឿងបណ្ណាការខ្លះទៅថ្វាយព្រះចៅប្រទេសបារាំង មានភ្លុកដំរី កុយរមាស រត្ន ស្ក និងម្រេចជាដើម ។ លោកកុងស៊ុលបារាំងបានសន្យាថានឹងនាំព្រះសារលិខិតនិងជូនថ្វាយទៅក្រុងប៉ារីស ។

នៅគ.ស. ១៨៥៥ លោករាជទូត **de Montigny** ត្រូវបានចាត់អោយបំពេញបេសកកម្មជាច្រើននៅតំបន់ចិននិងនៅប្រទេសចិន ។ លោកបានទទួលបញ្ជាពីព្រះចៅ **Napoléon** អោយធ្វើសន្ធិសញ្ញាមិត្តភាពនិងខាងជំនួញជាមួយខ្មែរ ប៉ុន្តែការធ្វេសប្រហែសរបស់រាជទូតរូបនេះបានធ្វើអោយព្រះចៅសៀមទ្រង់ជ្រាបពីបំណងរបស់ប្រទេសបារាំង ជាហេតុបណ្តាលអោយសន្ធិសញ្ញារវាងខ្មែរនិងបារាំងពុំបានសំរេចទៅវិញ ។ ម្យ៉ាងទៀត លោក**de Montigny** ពុំបានអញ្ជើញទៅជួបនឹងព្រះរាជាខ្មែរទេ លោកគ្រាន់តែបញ្ជាអោយបព្វជិត **Hertrest** ដែលឈរនៅកំពតទៅគាល់ព្រះអង្គ ។ ដោយទ្រង់មិនពេញព្រះទ័យនឹងអាកប្បកិរិយារបស់លោក **Montigny** ផង និងដោយខ្លាចមានការធ្វើទុក្ខបុកម្នេញពីសំណាក់សៀមផង **ព្រះអង្គឌួង**ក៏ទ្រង់លះបង់ចោលនូវព្រះបំណងសុំការការពារពីប្រទេសបារាំង ។

ក្នុងព្រះសារលិខិតទី២ ព្រះអង្គទ្រង់បានរំលឹកដល់ព្រះចៅ **Napoléon** ថា ទឹកដីដែលយួន

www.budinst.gov.kh www.elibraryofcambodia.org

បានយកហើយដែលស្ថិតនៅចន្លោះត្រើយខាងលិចនៃព្រែកព្រៃនគរនិង ពាម តិកទាំងកោះ ក្របាំ និង កោះត្រឡាច ពិតជាដីរបស់ខ្មែរ ។ ចំពោះព្រះសារលិខិតទី២ នេះ ប្រទេសបារាំងពុំបានឆ្លើយតបអ្វីសោះឡើយ ។

នៅ គ.ស.១៨៥៦ ដោយព្រះអង្គមានវ័យកាន់តែជរាហើយដោយនឹកគិតទៅដល់អនាគតនៃប្រទេសជាតិ ព្រះអង្គឌួងទ្រង់សូមព្រះចៅសៀមអោយតែងតាំងព្រះរាជបុត្រច្បងនាម អង្គវតី ជាមហាឧបរាជនិងព្រះរាជបុត្របន្ទាប់នាម ស៊ីសុវត្ថិ ជាព្រះកែវហ្វា និងសូមអោយបានវិលចូលក្រុងកម្ពុជាដើម្បីជួយបំពេញរាជការផង ។

ទន្ទាំងដែល យួននៅស្រុកក្រោមបានសង់បន្ទាយនៅបាយឆៅនៅឃ្លាំងនិងនៅសិច្ចហោដើម្បីពង្រឹងជំហររបស់ខ្លួននៅក្នុងខេត្តខាងលិច ។ វាបានរំលោភលើអំណាចរបស់ចៅហ្វាយស្រុក សុខ ជាហេតុបណ្តាលអោយខ្មែរក្រោកឡើងក្រោមបញ្ជាការរបស់សេនាសឹម លើកទៅប្រយុទ្ធនឹងយួនដោយមានជ័យជំនះ នៅតំបន់ធំទប់និងកំពង់ត្រប់ ។ ពេលនោះព្រះអង្គឌួងទ្រង់អោយសង់បន្ទាយនិងលើកទ័ពទៅចាំនៅព្រំដែន ។ យួនឃើញដូច្នោះក៏លើកទ័ពទៅរាំងដើម្បីបិទកុំអោយខ្មែរខាង..និងខ្មែរខាងក្រោមទាក់ទងគ្នាបាន ។

និយាយពីនៅស្រុកយួនឯណោះ ក្នុងរជ្ជកាលរបស់ស្តេច ទឺឌឹក (Tu-duc) និងក្នុងរជ្ជកាលមុនៗ មានការធ្វើទុក្ខបុកម្នេញលើរូបអ្នកផ្សាយសាសនា ជាហេតុនាំអោយបារាំងធ្វើអន្តរាគមន៍យកលេសថា ដើម្បីការពារជនទាំងនោះនៅគ.ស ១៨៥៨ ។ គឺនៅក្នុងស្ថានភាពថ្មីនេះហើយដែលព្រះ អង្គឌួង បានទាក់ទងសារជាថ្មីជាមួយជនជាតិបារាំង ។ តាមរាជពង្សាវតារខ្មែរ ថាព្រះអង្គទ្រង់បានជួលទ័ពបារាំងអោយជួយវាយយក ព្រៃនគរ គិតជាឈ្នួល ៥០០ណែនប្រាក់ ។ ក្នុងពេលជំណាលគ្នានោះ ពួកចាមជ្វានៅខេត្ត ត្បូងឃ្មុំ បានបះបោរទាំងនិងចៅហ្វាយស្រុកខេត្តនេះក្រោមការដឹកនាំរបស់មេ ៣ នាក់គឺ តួន ហ៊ីម តួន ស៊ី និង តួនអ៊ិត ។ ព្រះអង្គឌួង ទ្រង់លើកទ័ពទៅបង្ក្រាប មេម្នាក់ត្រូវស្លាប់ ២ នាក់ទៀតបានរត់រួចចូលទៅនៅទីមាត់ជ្រូក ។

រាជពង្សាវតារខ្មែរថានៅគ.ស ១៨៥៨ នោះ លោកមេទ័ព Doudart de Lagrée-



www.budinst.gov.kh www.elibraryofcambodia.org

បានលើកទ័ពទៅវាយ **ព្រៃនគរ** ឯព្រះ **អង្គឌួង** ទ្រង់បញ្ជាអោយលោកឧកញ៉ារាជាសេដ្ឋី **កែប** លើកទ័ពទៅវាយ **ត្រាំខ្យួច បាសាក់ ព្រះត្រពាំង ក្រមួនស មាត់ជ្រូក** ។ ចំណែកឯពួកចាមជ្វាដែលរត់ទៅ **មាត់ជ្រូក** ចូលទៅបំបះរាស្ត្រលើកទៅវាយ **ឧដុង្គ** តែត្រូវព្រះឧបរាជនិងព្រះកែវហ្វាចាប់បានពួកមេដឹកនាំហើយបាក់ទ័ពរត់ខ្ចាត់ខ្ចាយទៅវិញអស់ ។

និយាយពីទ័ពរបស់ឧកញ៉ា **កែប** ដែលលើកទៅវាយយួនឯស្រុកក្រោមនោះ ឃើញថាមានជោគជ័យហើយចេះតែជម្រុលទៅមុខ ប៉ុន្តែនៅពេលដែលព្រះរាជាសោយទិវង្គតទៅ (១៨៥៩) ហើយដោយមានការរើករើននៅឯរាជធានី **ឧដុង្គ** លោកក៏ដកទ័ពថយចូលស្រុកវិញអស់ ។ ឯកសារខ្លះបានបញ្ជាក់ថាការដែលលោកឧកញ៉ា **កែប** បានលើកទ័ពចូលវាយស្រុកក្រោមនោះ គឺដើម្បីទៅបង្ក្រាបពួកចាមជ្វាបះបោររត់ទៅទីនោះហើយដែលរាជការយួនមិនព្រមចាប់ប្រគល់មកអោយខ្មែរវិញ (42) ។

## ២ — ស្នាព្រះហស្តព្រះអង្គឌួង.—

**ព្រះបាទហរិរក្សរាមាឥស្សរាធិបតីអង្គឌួង** ជាព្រះរាជាមួយអង្គដែលប្រកបដោយទសពិធរាជធម៌ ។ ព្រះអង្គទ្រង់យកព្រះទ័យទុកដាក់រៀបចំអោយមានសន្តិភាពក្នុងប្រទេស និងអោយមានរបៀបរៀបរយក្នុងរាជការ ។ យ៉ាងណាមិញ ការបែកបាក់សាមគ្គីរវាងខ្មែរ និងចម្បាំងឈ្លានពានរបស់បរទេសជាហេតុនាំអោយប្រទេសរើបប្រទះនឹងមហន្តរាយៈ ភូមិស្រុកត្រូវដុតបំផ្លាញ ស្រែចំការត្រូវបោះបង់ចោល ផ្លូវថ្នល់ត្រូវបំផ្លិចបំផ្លាញដោយវិនាសកម្ម និងដោយទឹកជំនន់ ស្ពានភាគច្រើនត្រូវខូចខាត ។ អសន្តិសុខកើតមានសព្វពេញផ្ទៃប្រទេស ព្រោះរាស្ត្រដែលអត់ឃ្លានបានក្លាយទៅជាចោរលួចចោរប្លន់ កាប់សំលាប់ឥតត្រាប្រណី សកម្មភាពខាងជំនួញឥតមានទាល់តែសោះ ។

គឺនៅក្នុងស្ថានភាពដុនដាបបែបហ្នឹងហើយដែលព្រះ **អង្គឌួង** ទ្រង់បានឡើងគ្រងរាជ្យ ។ ព្រះអង្គទ្រង់បានខិតខំរៀបចំប្រទេសជាតិឡើងវិញ និងលើកតម្កើងជីវភាពប្រជារាស្ត្រ ។ រាជធានី **ឧដុង្គ** ត្រូវបានស្ថាបនាឡើងវិញ ។ ចំនួនខេត្តក្នុងព្រះរាជាណាចក្រ

www.budinst.gov.kh www.elibraryofcambodia.org

ត្រូវបន្ថយ ។ ខេត្តនិមួយៗ មានទំហំផ្ទៃប្រហាក់ប្រហែលគ្នា ហើយត្រូវបែងចែកជាស្រុក ។

ពីគ.ស. ១៨៥១ ដល់ ១៨៥៣ ព្រះអង្គបញ្ជាអោយលើកផ្លូវមួយពី **ឧដុង្គ** ទៅ **កំពត** ដែរ ជាកំពង់ផែសមុទ្រតែមួយរបស់ខ្មែរ ព្រោះកំពង់ផែ ព្រៃនគរ ត្រូវបានទៅយួនជាស្ថាពរទេ ហើយ ។ នៅគ.ស. ១៨៥២ ព្រះអង្គទ្រង់អោយលើកផ្លូវមួយទៀតភ្ជាប់រាជធានី **ឧដុង្គ** ទៅ **កំពង់ហ្លួង** ជាកំពង់ផែសំខាន់មួយទៀតរបស់ខ្មែរក្នុងសម័យនោះ ។

ក្នុងរជ្ជកាលរបស់ព្រះ **អង្គដួង** ព្រះអង្គបញ្ជាកុំអោយមានការតម្លើងនិងការបង្កើតពន្ធថ្មី និងជៀសវាងកុំកេនរាស្ត្រអោយបំពេញកិច្ចការសាធារណៈក្នុងរដូវធ្វើស្រែចំការ ។ ព្រះអង្គមានព្រះទ័យអាណិតអាសូរចំពោះរាស្ត្រដែលរងទុក្ខវេទនា ។ ម្ល៉េះហើយបានជា នៅពេលដែលកើតជម្ងឺរាតត្បាត ព្រះអង្គទ្រង់យាងដោយផ្ទាល់ទៅចែកស្បៀងអាហារ និងសំលៀកបំពាក់អោយរាស្ត្រក្រីក្រ ។

ម្យ៉ាងទៀត ព្រះអង្គទ្រង់ហាមមិនអោយបរបាញ់សត្វ និងមិនអោយចាប់ត្រីដោយប្រើព្រួលវាំងពេញព្រែកទេ ។ ព្រះអង្គស្ដីបន្ទោសនិងដាក់ទណ្ឌកម្មយ៉ាងធ្ងន់លើពួកជនប្រមឹក ជនជក់អាភៀន និងជនប្រព្រឹត្តល្បែងស៊ីសង ទ្រង់បង្ក្រាបដោយតឹងរ៉ឹងនូវអំពើចងការប្រាក់ដោយយកការច្រើនហួសប្រមាណ ហើយក្នុងការខ្ចីបុលគ្នា ទ្រង់តម្រូវអោយមានកិច្ចព្រមព្រៀងគ្នាជាលាយលក្ខណ៍អក្សរ រវាងមេបំណុលនិងកូនបំណុល ។ ជាពិសេសទៅទៀត ព្រះអង្គទ្រង់បានបរិច្ចាគព្រះរាជទ្រព្យផ្ទាល់ដើម្បីលោះពួកមនុស្សខ្ញុំគេអោយបានរួចខ្លួនវិញអស់ជាច្រើន ។

ក្នុងវិស័យសេដ្ឋកិច្ចនិងហេរញ្ញវត្ថុ ព្រះអង្គទ្រង់បានបោះប្រាក់រៀលមូល ម្ខាងមានរូបប្រាសាទ **អង្គរវត្ត** ម្ខាងទៀតមានរូប **សត្វហង្ស** សំរាប់ប្រើប្រាស់ក្នុងព្រះរាជាណាចក្រ និងទ្រង់បានទាក់ទាញឈ្មួញចិន និងឥណ្ឌា អោយចូលធ្វើពាណិជ្ជកម្មក្នុងប្រទេសខ្មែរទៀតផង ។

ឯពន្ធដារត្រូវបានដាក់អោយទាបតាមរបបកាសីុ ជាហេតុអោយរាជការមានលទ្ធភាពរៀបចំថវិកាមួយដែលមានតុល្យភាព ។

www.budinst.gov.kh www.elibraryofcambodia.org





**ប្រាក់បោះក្នុងរជ្ជកាលព្រះបាទមហារាជាឥស្សរាធិបតី អង្គដួង**

(រូបស្រង់ចេញពីទស្សនាវដ្ដី Le Sangkum លេខ ៤ ខែវិច្ឆិកា ១៩៦៥)

ក្នុងវិស័យវប្បធម៌ ព្រះអង្គទ្រង់បានបង្កើតសាលាតាមវត្តជាច្រើន ទ្រង់បានលើកទឹកចិត្តពួកអ្នកប្រាជ្ញបណ្ឌិតកវី ហើយទ្រង់បានផ្ដល់នូវលុយកាក់និងមធ្យោបាយផ្សេង ១ ដល់ជនណាដែលចង់ធ្វើការសិក្សា ស្វែងរកចំណេះវិជ្ជា ៗ ព្រះអង្គទ្រង់សព្វព្រះទ័យធ្វើការពិភាក្សាជាមួយព្រះសង្ឃពីបញ្ហាសាសនា និងអក្សរសាស្ត្រ និងទ្រង់បានបរិច្ចាគព្រះរាជទ្រព្យផ្ដល់ចំពោះព្រះសង្ឃ សំរាប់កសាងវត្តអារាម និងចំណាយផ្សេង ១ តាមព្រះពុទ្ធបញ្ញត្តិ ៗ

នៅទីបញ្ចប់នេះ គួរគប្បីបញ្ជាក់ដែរថា ព្រះ**អង្គដួង** ជាអ្នកនិពន្ធមួយរូបយ៉ាងឆ្នើមដែរ ៗ ស្នាព្រះហស្តរបស់ព្រះអង្គក្នុងវិស័យអក្សរសិល្ប៍គឺ :

- **ចម្បាំងចោរ** (គ. ស. ១៨១០)
- **រឿងកាកី** (គ. ស. ១៨១៥)
- **ច្បាប់ស្រី** (គ. ស. ១៨៣៧) (៣០) ៗ

*

*   *

www.budinst.gov.kh   www.elibraryofcambodia.org

# ចំពូកទី ១៤

# ប្រទេសខ្មែរក្រោមអាណាព្យាបាលភាពបារាំង (ស.វ.ទី១៩ និងទី២០)

## ក-ហេតុអ្វីបានជាមានអាណាព្យាបាលភាពបារាំង?

### ១- ព្រះបាទនរោត្តម (១៨៥៩-១៩០៤).-



**ព្រះបាទនរោត្តម**

(រូបស្រង់ចេញពីទស្សនាវដ្តី Le Sangkum លេខ ៥ ខែធ្នូ ១៩៦៥)

នៅពេលដែលព្រះបាទហរិរក្សរាមាឥស្សរាធិបតីសោយទិវង្គតទៅ ពួកមន្ត្រីនិងព្រាហ្មណ៍បុរោហិត បានលើកព្រះរាជបុត្រច្បងនាម**អង្គច្រឡឹង** ឬ **អង្គវតី** អោយឡើងគ្រងរាជ្យស្នងព្រះបិតានៅរាជធានី**ឧដុង្គ** ។

កិច្ចការដែលព្រះអង្គត្រូវបំពេញជាដំបូង គឺការថ្វាយដំណឹងទៅព្រះចៅសៀម ពីការជ្រើសរើសអោយព្រះអង្គឡើងគ្រងរាជ្យ ។ ព្រះចៅសៀមបានបញ្ជូនមន្ត្រីម្នាក់មករាជធានី **ឧដុង្គ** ដើម្បីបញ្ជាក់ពីការយល់ព្រមរបស់ព្រះអង្គ និងដើម្បីចូលរួមក្នុងព្រះរាជពិធីបុណ្យសពព្រះ**អង្គដួង**ផង ។ នៅពេលជាមួយគ្នានោះ ព្រះអង្គ**ស៊ីវត្ថា** ព្រះរាជបុត្រទី ៣ របស់ព្រះ**អង្គដួង** ក៏បានយោះត្រឡប់



www.budinst.gov.kh www.elibraryofcambodia.org

ចូលស្រុកវិញដែរ ។

## ២– ការតស៊ូរបស់ខ្មែរនៅកម្ពុជាក្រោម.–

គួរកត់សំគាល់ថា នៅខាងដើមរជ្ជកាលនៃព្រះបាទ **នរោត្តម** ខ្មែរនៅកម្ពុជាក្រោម បានបន្តការតស៊ូរបស់ខ្លួនប្រឆាំងនឹងអំពើឈ្លានពានរបស់យួនទៀត ។

នៅគ.ស. ១៨៥៩ ពួកយួនបានរៀបចំគំរោងការថ្មីហើយបានទាក់ទាញពួកចាមដែលកៀសទៅនៅ**មាត់ជ្រូក**អោយចូលខាងខ្លួន ។ ដូច្នេះខ្មែរនៅកម្ពុជាក្រោមត្រូវតស៊ូជាថ្មីទៀត ៖ លោកសេនា **ស្នួស** និងបក្សពួករបស់លោកបានក្រោកឡើងប្រយុទ្ធនឹងយួននៅ **មហាទប់** និង **ចុងមល្លូក** ក្នុងខេត្ត **ឃ្លាំង** ។ ក្នុងរយះពេល ៣ ឆ្នាំនៃការតស៊ូ ខាងខ្មែរតែងបានទទួលជោគជ័យជានិច្ច ប៉ុន្តែជាអកុសល ! នៅទីបំផុតលោកសេនា **ស្នួស** ត្រូវទទួលមរណភាពដោយថ្នាំបំពុលរបស់ពួកចាមដែលចុះចូលខាងយួន ។

នៅឆ្នាំបន្ទាប់មកទៀត គឺនៅ គ.ស. ១៨៦០ មានបងប្អូនពីរនាក់ ឈ្មោះសេនា **ឌា** និងសេនា**មន** បានក្រោកឡើងប្រឆាំងនឹងយួនទៀតនៅ **លំពួយ** ក្នុងខេត្ត **ឃ្លាំង** ដដែលៗ ដំបូងទ័ពខ្មែរទន់ដៃជាត្រូវដកថយចូលទៅខេត្ត **ពលលាវ** នៅត្រង់តំបន់**ត្រាខា** ។ ក្រោយមកក៏មានជោគជ័យវិញ ហើយដេញតាមកំចាត់ទ័ពយួនរហូតដល់តាម **ពលលាវ** ។ ប៉ុន្តែនៅទីនោះយួនមានទ័ពជំនួយមកជួយ ហើយលោកសេនា **ឌា** ក៏ត្រូវទទួលមរណភាពទៀត ដោយត្រូវគ្រាប់កាំភ្លើងរបស់ថ្វាបាញ់ ។ សពរបស់លោកត្រូវបានដឹកនាំយកទៅកប់នៅក្បែរវត្ត **ខ្វែងបប៉ែល** ក្នុងភូមិ **ហ៊ុង ហ្វូយ** (Hung-hôi) សព្វថ្ងៃ ។

## ៣– ការបះបោររបស់ព្រះអង្គស៊ីវត្ថា. (១៨៦១-១៨៦៧).–

លោក Moura បានសរសេរថា ៖ ទោះបីព្រះបាទ **នរោត្តម** ទ្រង់បានទទួលរាក់ទាក់ និងជួយទំនុកបំរុងយ៉ាងណាក៏ដោយ ក៏ព្រះអង្គមិនអាចបំបាត់អោយអស់នូវការច្រណែនរបស់ព្រះអនុជរបស់ព្រះអង្គដែរ ។ ដោយពុំមានហេតុផលអ្វីអោយសុខរម្យឡើង **ព្រះអង្គស៊ីវត្ថា**


www.budinst.gov.kh www.elibraryofcambodia.org

ឃុំនិគមថា ព្រះវៀមព្រះអង្គទាំងពីរគឺ **នរោត្តម** និង **ស៊ីសុវត្ថិ** មិនត្រូវមានសិទ្ធិឡើងសោយរាជសម្បត្តិដែលត្រូវតែបានទៅព្រះអង្គជាដាច់ខាត ។ ម្ល៉ោះហើយ ព្រះអង្គក៏បញ្ចេញអាកប្បកិរិយារឹងរូស មិនគោរព មិនស្ដាប់បង្គាប់ព្រះវៀម មិនឡើងគាល់ព្រះវៀម ហើយនៅទីបំផុតបានគេចចាត់ពីរាជធានីតែម្ដង ( គ.ស. ១៨៦១ ) ។

ចម្បាំងគ្នាឯងក្នុងស្រុកបានកើតឡើងជាថ្មីទៀត ។ តែមិនបានយូរប៉ុន្មានព្រះ **អង្គស៊ីវត្ថា** បានភៀសព្រះអង្គទៅប្រទេសសៀមជាមួយព្រះអនុជនាម **សិរីវង្ស** ។ ទោះបីព្រះអង្គភៀសទៅហើយក៏ចម្បាំងនៅមិនទាន់ចប់ ព្រោះបក្សពួករបស់ព្រះអង្គគឺស្នង **សួរ** និង **គំហែងយុដ្ឋា** ( ឯកសារខ្លះថាឈ្មោះ **មនោរែត** ) បានបន្តសកម្មភាពទៅទៀត ។ មេដឹកនាំទាំងពីរនេះបានទៅបំបះបំបោររាស្ត្រនៅតំបន់បាភ្នំ-ស្វាយរៀង ឯពួកចៅហ្វាយខេត្តសឹងចុះចូលទាំងអស់ ។

ពួកបះបោរបានលើកទៅវាយយកបានក្រុង **ភ្នំពេញ** ។ ពេលនោះ ដោយគ្មានទ័ពគ្រប់គ្រាន់ព្រះបាទ **នរោត្តម** ទ្រង់ភៀសព្រះអង្គទៅគង់នៅ **បាត់ដំបង**សិន ។ រាជធានី **ឧដុង្គ** ត្រូវយកបានទៀត ប៉ុន្តែពួកចាមជ្វាដែលបានរត់ទៅមាត់ជ្រូកពីមុនបានសុំសម្ដេច **នរោត្តម** ធ្វើការរាជការថ្វាយ ហើយបានប្រយុទ្ធនឹងពួកបះបោរវិញ ។

ពេលនោះ ព្រះចៅសៀមទ្រង់អោយយាងសម្ដេច **នរោត្តម** ទៅ **បាងកក** ។

ការប្រយុទ្ធគ្នាបានបន្តទៅទៀតនៅត្រើយខាងកើត ។ ជោគជ័យត្រូវបានទៅខាងទ័ពព្រះ **នរោត្តម** ដែលបានយាងត្រឡប់ចូលប្រទេសវិញនៅខែមីនា ១៨៦២ ដោយមានការគាំទ្រពីព្រះចៅសៀម ។ នៅខែតុលាឆ្នាំដដែល **យុដ្ឋា** ( មនោរែត? ) ត្រូវគេសម្លាប់បាន ស្នង **សួរ** ត្រូវរបួសបានភៀសទៅស្រុកក្រោម ទៅពឹងមេទ័ពបារាំងនៅរោងដីរ៉ា បារាំងក៏ចាប់យកទៅដាក់ក្នុងកោះ ។ ដូច្នេះ វិបត្តិក្នុងរាជវង្សក៏ត្រូវដោះស្រាយបានចប់ពីពេលនោះមក ។

**សន្និសញ្ញា ថ្ងៃទី ១១ សីហា ១៨៦៣.—**

www.budinst.gov.kh  www.elibraryofcambodia.org

សន្ធិសញ្ញានេះ បានបើកអោយបារាំងមកតាំងអាណាព្យាបាលភាពលើប្រទេសខ្មែរជាលើកដំបូង ។ គំណាំងអំណាចរបស់បារាំងនេះបានចោទជាចំណោទមួយចំពោះអ្នកប្រវត្តិសាស្ត្រដែលតែងតែចោទសួរថា តើស្តេចខ្មែរគឺសម្តេច **នរោត្តម** ទ្រង់បានហៅបារាំងអោយមកគ្រប់គ្រងស្រុកខ្មែរ ឬក៏បារាំងបានមកបង្ខំអោយព្រះអង្គទទួលយកអាណាព្យាបាលភាពរបស់បារាំង ?

បើតាមឯកសារសៀម (៥ - 49) គេបានអះអាងថាបារាំងបានបង្ខំអោយសម្តេច **នរោត្តម** ធ្វើសន្ធិសញ្ញាដាក់ប្រទេសខ្មែរក្រោមអាណាព្យាបាលភាពបារាំង ប៉ុន្តែខាងបារាំងបានប្រកែកថា ពុំបានធ្វើការកៀបសង្កត់អ្វីមួយក្នុងរឿងនោះទេ ព្រោះថាប្រទេសកម្ពុជា ជាប្រទេសឯករាជ្យហើយមានសិទ្ធិធ្វើការចរចាតាមប្រយោជន៍របស់ខ្លួន (48) ។

ដូច្នេះ តើការពិតស្ថិតនៅត្រង់ណា ? យើងនឹងសាកល្បងធ្វើការវិនិច្ឆ័យដោយផ្អែកទៅលើព្រឹត្តិការណ៍ដែលបានកើតឡើង ។

រួចមកហើយ យើងបានឃើញថា ព្រះ **មហាវិរក្សត្រមហាឥស្សរាធិបតីអង្គឌួង** ទ្រង់មានបំណងចងស្ពានមេត្រីជាមួយមហាអំណាចអឺរ៉ុបណាមួយមានបារាំងជាដើម ដោយព្រះអង្គមានសង្ឃឹមថា នឹងយកមហិទ្ធិឫទ្ធិរបស់មហាអំណាចនោះមករំដោះប្រទេសព្រះអង្គអោយរួចពីក្រញាំរបស់យួននិងសៀម ប៉ុន្តែកាលណោះបារាំងពុំបានធ្វើអោយព្រះអង្គសំរេចព្រះបំណងបានឡើយ ។

ក្រោយមក ដោយយកលេសថា ស្តេចយួនធ្វើទុក្ខបុកម្នេញលើរូបអ្នកផ្សាយសាសនាជាតិបារាំង ក៏បារាំងបានវាយយកកំពង់ផែ Tourane នៅថ្ងៃទី ១ ខែ កញ្ញា ១៨៥៨ រួចវាយយកបានបន្ទាយ **ព្រៃនគរ** នៅថ្ងៃទី ១៧ ខែ កុម្ភៈ ១៨៥៩ ទៀត ។ តាមសន្ធិសញ្ញាចុះថ្ងៃទី៥ កក្កដា ១៨៦២ ស្តេច **ទឺឌឹក** បានទទួលជាកម្មសិទ្ធិរបស់បារាំងនូវខេត្ត **បៀនហ៊ា-យ៉ាឌិញ-ឌិញទឿង** (មេសរ) និង **កោះត្រឡាច** ដែលយួនបានប្រវញ្ចយកពីខ្មែរពីមុនមក ។ លុះបានចូលមកនៅជាអ្នកជិតខាងរបស់ខ្មែរលើដែនដី **កូសាំងស៊ីន**(Cochinchine) ហើយទើបបារាំងចាប់អារម្មណ៍យ៉ាងខ្លាំងមកលើប្រទេសខ្មែរ ។ រាជការអាណានិគមនិយម

www.budinst.gov.kh www.elibraryofcambodia.org

បារាំងថៀថា ទន្លេមេគង្គជាផ្លូវទឹកមួយសំខាន់អាចអោយគេធ្វើការជ្រៀតចូលទៅក្នុងប្រទេសចិនខាងត្បូងបាន ហើយម្យ៉ាងទៀត គេត្រូវរកមធ្យោបាយកំចាត់អោយអស់នូវគ្រោះថ្នាក់ទាំងឡាយដែលគំរាមកំហែងលើអាណានិគមថ្មីរបស់គេ ជាពិសេសគ្រោះថ្នាក់មកពីប្រទេសសៀម ដែលនៅខាងក្រោយនោះមានអធិរាជាណាចក្ររបស់ពួកអង់គ្លេសថែមទៀត ។

គេបានដឹងថា នៅគ.ស.១៨៦១ ក្រោយពីបានវាយបែកបន្ទាយ **ព្រៃនគរ** លោកឧត្តមនាវី Charner បានបញ្ជូននាយទាហានម្នាក់អោយទៅ **ឧដុង្គ** ដើម្បីធ្វើការទាក់ទងនឹងព្រះរាជាខ្មែរ ដើម្បីទូលប្រាប់ពីជោគជ័យរបស់បារាំងលើទ័ពយួន ពីបំណងរបស់បារាំងចង់តាំងនៅនៅ **កូសាំងស៊ីន** និងពីសេចក្តីសង្ឃឹមថានឹងអាចទាក់ទងជាមិត្តភាពជាមួយខ្មែរ ។

ក្រោយមក នៅគ.ស.១៨៦២ លោកឧត្តមនាវីត្រី Bonard ទេសាភិបាលនៃដែនដី **កូសាំងស៊ីន** បានធ្វើដំណើរមកប្រទេសខ្មែរដោយមានបំណងចង់ស្គាល់ច្បាស់ពីស្ថានភាពប្រទេសនេះ ជាពិសេសពីពួកមន្ត្រីជាបរិវារនៅក្រុង **ឧដុង្គ** ពីសារសំខាន់ក្នុងវិស័យកសិកម្ម និ...ពាណិជ្ជកម្ម ពីទំនាក់ទំនងជាមួយប្រទេសសៀម ។ល។ លោកទេសាភិបាលក៏បាន ...នោះសុំចូលគាល់សម្តេច **នរោត្តម** ដែលបានទទួលលោកយ៉ាងរាក់ទាក់.... លោកបានទៅទស្សនាប្រាសាទបុរាណនៅតំបន់ **អង្គរ** ហើយធ្វើដំណើរតាមដងទន្លេមេគង្គឡើងរហូតដល់ល្បាក់ទឹក (42) ។

លុះត្រឡប់ទៅ **ព្រៃនគរ** វិញ លោកបានផ្ញើកំណត់មួយទៅជូនលោក Chasseloup Laubat រដ្ឋមន្ត្រីក្រសួងទ័ពជើងទឹកនិងអាណានិគម និយាយពីសិទ្ធិរបស់ប្រទេសបារាំងមកលើប្រទេសខ្មែរ ។ បើតាមលោក ប្រទេសបារាំងមានសិទ្ធិលូកដៃចូលក្នុងកិច្ចការផ្ទៃក្នុងរបស់ខ្មែរ ព្រោះប្រទេសនេះបានទទួលមតិកជាសិទ្ធិអធិរាជភាព (droits de suzeraineté) ពីប្រទេសអាណ្ណាមលើប្រទេសខ្មែរ ដោយមធ្យោបាយរៀបចំរួមពីការបញ្ចូលដែនដី **កូសាំងស៊ីន** ជាកម្មសិទ្ធិរបស់បារាំង ។ ម្យ៉ាងទៀត លោកទេសាភិបាល Bonard ក៏បាន ...គំនិតមានដល់លោក Chasseloup Laubat ពីការប្រាថ្នារបស់សៀមមកលើប្រទេសខ្មែរ ... លោកបានសន្និដ្ឋានលើការចាំបាច់របស់ប្រទេសបារាំងត្រូវតែគាំពារឯករាជ្យភាពនៃប្រ-


www.budinst.gov.kh www.elibraryofcambodia.org

ទេសនេះ ដែលមានទាក់ទងទៅនឹងសន្តិសុខនៃដែនដីកូសាំងស៊ីន ។

នៅឆ្នាំបន្ទាប់មកទៀត (១៨៦៣) ក្រោយពីត្រូវបានតែងតាំងជាទេសាភិបាលនៃដែនដីកូសាំងស៊ីនហើយ លោកឧត្តមនាវី de la Grandière បានបញ្ជាអោយលោកអនុនាវីឯក Doudart de Lagrée ធ្វើដំណើរតាមកប៉ាល់ឈ្មោះ **យ៉ាំងនិញ** មកធ្វើសង្កេតការណ៍ផ្សេង ៗ នៅប្រទេសខ្មែរ ដើម្បីផ្តល់ពត៌មានដ៏ជាក់លាក់ដល់លោកទេសាភិបាល ។

លទ្ធផលនៃបេសកកម្មចុងក្រោយនេះបានបង្ហាញអោយឃើញថា សម្តេច **នរោត្តម** ទ្រង់មានការចង់ព្រះទ័យល្អទៅលើប្រទេសបារាំង ។ ហើយទោះបីមានបញ្ជាដ៏ស្ងាត់ស្ងៀមពីលោក Chasseloup Laubat ដែលប្រុងនឹងទុកប្រទេសខ្មែរទុកជាប្រទេសទ្រនាប់មួយរវាងប្រទេសសៀម ដែលទទួលការគាំទ្រពីអង់គ្លេស និងដែនដីកូសាំងស៊ីនជាអាណានិគមរបស់បារាំងក៏ដោយ ក៏លោកទេសាភិបាល de la Grandière បានធ្វើដំណើរទៅក្រុង **ឧដុង្គ** នៅខែសីហា ១៨៦៣ ។ បើតាមលោក Moura គឺការជ្រៀតជ្រែករបស់សៀមក្នុងកិច្ចការផ្ទៃក្នុងរបស់ខ្មែរនោះហើយដែលជាមូលហេតុញុាំងលោកទេសាភិបាលអោយទៅគាល់ព្រះរាជាខ្មែរក្នុងពេលនោះ ព្រោះបារាំងបានសង្កេតឃើញថាគឺតំណាងសៀមនៅអមព្រះរាជាខ្មែរនោះទេ ជាព្រះរាជាខ្មែរពិតប្រាកដ ។ ដូច្នេះ គឺដើម្បីកំចាត់អោយអស់នូវឥទ្ធិពលសម្ងាត់ទាំងឡាយរបស់សៀមដែលអាចគំរាមកំហែងដល់ផលប្រយោជន៍របស់បារាំងនៅឥណ្ឌូចិន ដើម្បីបង្កើតអោយមានសន្តិសុខនៅព្រំដែននៃអាណានិគមថ្មី និងដើម្បីត្រួតពិនិត្យមើលនូវដែនដីខាងក្នុងមួយដែលផ្តល់ប្រយោជន៍ច្រើន ដែលបារាំងបានតាំងអាណាព្យាបាលភាពរបស់ខ្លួនលើប្រទេសខ្មែរ ។ លោកទេសាភិបាល de la Grandière បានទូលហេតុផលទាំងនោះយ៉ាងសព្វគ្រប់ដល់ព្រះរាជាខ្មែរ ហើយសូមព្រះអង្គព្រមដាក់ប្រទេសខ្មែរអោយបារាំងជួយការពារ ។ សម្តេច Miche ទ្រង់បានថ្វាយនូវគំនិតផ្សេងៗទៀតផង ហើយទ្រង់បានធ្វើការពិភាក្សាជាមួយព្រះរាជាខ្មែរ ហើយនៅថ្ងៃ១១ សីហា ១៨៦៣ លោក de la Grandière បានចុះហត្ថលេខាក្នុងនាមលោកផ្ទាល់ លើសន្ធិសញ្ញាមិត្តភាព ការការពារ និងពាណិជ្ជកម្មមួយជាមួយព្រះអង្គ **នរោត្តម** ដែលបានទទួលយល់ព្រមដោយមានការញញើតញញើមយ៉ាងច្រើន (4 )

ដូច្នេះ យើងឃើញថា ព្រះបាទ **នរោត្តម** ពុំបានហៅបារាំងអោយមកតាំងអាណាព្យាបាលលើប្រទេសខ្មែរទេ ហើយព្រះអង្គទ្រង់បានទទួលយកសន្ធិសញ្ញាថ្ងៃ ១១ ខែសីហា ១៨៦៣ នោះ គឺទំនងជាមានការ **គៀបសង្កត់ដោយមិត្តភាព** ពីសំណាក់លោកទេសាភិបាល de la Grandière ជាមិនខាន ។ ភស្តុតាងមួយដ៏ជាក់ស្តែងក្នុងរឿងនេះ គឺសារលិខិតមួយដែលព្រះអង្គទ្រង់បានផ្ញើទៅឲ្យព្រះចៅសៀម ក្រោយពេលដែលព្រះអង្គបានឡាយព្រះហស្តលេខាលើសន្ធិសញ្ញាខាងលើ ។ ក្នុងសារលិខិតនោះ ព្រះអង្គទ្រង់បានត្អូញត្អែរថា ព្រះអង្គត្រូវគេបង្ខំអោយធ្វើសន្ធិសញ្ញាជាមួយបារាំង ។

តើមានអ្វីខ្លះជាខសំខាន់ក្នុងសន្ធិសញ្ញាចុះថ្ងៃ ទី ១១ ខែ សីហា ១៨៦៣ ?

ក្នុងមាត្រាទី១ មានសេចក្តីចែងថា ព្រះចៅអធិរាជនៃជនជាតិបារាំងនឹងផ្តល់នូវការការពារដល់ព្រះរាជាខ្មែរ ។ ក្នុងមាត្រាបន្តបន្ទាប់មកទៀតមានចែងថា ព្រះចៅនៃជនជាតិបារាំងនឹងតែងតាំងរេស៊ីដង់ម្នាក់ដែលមានឋានៈជាមន្ត្រីជាន់ខ្ពស់អោយនៅអមព្រះរាជាខ្មែរ ឯព្រះរាជាខ្មែរនឹងតែងតាំងរេស៊ីដង់ខ្មែរម្នាក់អោយនៅអមលោកទេសាភិបាលនៃដែនដីកូសាំងស៊ីនវិញ ។ ប៉ុន្តែ បើមានការតែងតាំងកុងស៊ុលដទៃ ក្រៅពីប្រទេសបារាំង នោះត្រូវអោយមានការយល់ព្រមពីលោកទេសាភិបាលកូសាំងស៊ីនផងដែរ ។

ជនជាតិបារាំងដែលមករស់នៅលើទឹកដីខ្មែរក្តី ជនជាតិខ្មែរដែលទៅរស់នៅក្នុងអធិរាជាណាចក្របារាំងក្តី សុទ្ធតែមានសេរីភាពពេញលេញក្នុងការទៅមក និងក្នុងការរស់នៅ អោយតែជនទាំងនោះបានទៅសុំចុះឈ្មោះសុំច្បាប់អនុញ្ញាតពីរេស៊ីដង់របស់ខ្លួន ។ លោករេស៊ីដង់បារាំងមានសិទ្ធិជំនុំជំរះវិវាទដែលបានកើតឡើងរវាងជនជាតិបារាំង និងជនជាតិអឺរ៉ុបដទៃទៀត ។ ក្នុងករណីមានជម្លោះរវាងជនជាតិបារាំងនិងជនជាតិខ្មែរវិញនោះ នឹងមានមន្ត្រីខ្មែរម្នាក់នៅអមលោករេស៊ីដង់បារាំងក្នុងការជំនុំជំរះ ។

កប៉ាល់របស់បារាំងមានសេរីភាពពេញលេញក្នុងការធ្វើជំនួញក្នុងដែនទឹកខ្មែរ ដោយឥតបង់ពន្ធគយអ្វីទាំងអស់ លើកលែងតែពន្ធលើអាភៀនចេញ ។ ឯកប៉ាល់ខ្មែរវិញក៏មានសិទ្ធិគ្រប់គ្រាន់ក្នុងការធ្វើជំនួញក្នុងកំពង់ផែទាំងឡាយនៃដែនកូសាំងស៊ីនវិញដែរ ។

www.budinst.gov.kh www.elibraryofcambodia.org

រដ្ឋាភិបាលខ្មែរត្រូវសន្យាថា ការពារពួកអ្នកផ្សាយសាសនា ពួកអ្នកប្រាជ្ញបារាំង និង ជនជាតិបារាំងជាទូទៅដែលរស់នៅឬដែលធ្វើជំនួញក្នុងទឹកដីខ្មែរ ។ ចំណែកឯជនជាតិខ្មែរ ដែលរស់នៅឬធ្វើជំនួញក្នុងទឹកដីជាកម្មសិទ្ធិរបស់បារាំង . ក៏នឹងត្រូវបានទេសាភិបាលនៃទឹកដីនោះការពារវិញដែរ ។

ព្រះចៅអធិរាជនៃជនជាតិបារាំងសន្យាថានឹងរៀបចំអោយប្រទេសកម្ពុជាបានស្ថិតក្នុងសន្តិភាពនិងរបៀបរៀបរយ និងការពារចំពោះការវាយលុកទាំងឡាយមកពីខាងក្រៅនឹងជួយខ្មែរក្នុងការហូតពន្ធគយ និងផ្តល់គ្រប់ភាពងាយស្រួលក្នុងការធ្វើគមនាគមន៍ជាមួយនឹងសមុទ្រ ។

ជាថ្នូរវិញ ប្រទេសកម្ពុជាព្រមអោយជាសម្បទានដល់ប្រទេសបារាំងនូវដីម្តុំត្រង់ជ្រោយចង្វា ដើម្បីស្ថាបនាឃ្លាំងផ្ទុកធ្យូង .ឃ្លាំងសំរាប់ផ្តល់ស្បៀងដល់កប៉ាល់បារាំង និងបន្ទាយសំរាប់អោយទាហាននៅ ។ ពិសេសទៅទៀត ដើម្បីជាការដឹងគុណចំពោះប្រទេសបារាំងដែលបានផ្តល់នូវការការពារដល់ប្រទេសកម្ពុជា ខ្មែរត្រូវបើកសិទ្ធិអោយបារាំងកាប់ឈើក្នុងព្រៃទាំងឡាយក្នុងព្រះរាជាណាចក្រ ដើម្បីយកទៅស្ថាបនាកប៉ាល់ ។

សរុបសេចក្តីមក យើងឃើញថាទោះបីខាងភាគីខ្មែរចាញ់ប្រៀបខាងភាគីបារាំងខ្លះក៏ដោយ ក៏មានមតិភាគច្រើនយល់ឃើញថាខ្មែរអាចទទួលយកសន្ធិសញ្ញាថ្ងៃ ១១ ខែ សីហា ១៨៦៣ ព្រោះបារាំងពុំបានដកហូតអំណាចពីព្រះរាជាខ្មែរនៅឡើយ ។ ប៉ុន្តែ ទោះបីបារាំងបានសន្យាថានឹងការពារប្រទេសកម្ពុជាប្រឆាំងនឹងអំពើវាយលុកពីក្រៅក៏ដោយ ក៏ព្រះបាទ**នរោត្តម** ទ្រង់បានធ្វើសន្ធិសញ្ញាសម្ងាត់មួយជាមួយព្រះចៅសៀមចុះថ្ងៃទី ១ ខែ ធ្នូ ១៨៦៣ ដោយទទួលស្គាល់ថាប្រទេសកម្ពុជាជាសាមន្តរដ្ឋរបស់សៀមដដែល និងដោយព្រមលះបង់អោយប្រទេសសៀមនូវខេត្តបាត់ដំបង អង្គរ មង្គលបុរី ស៊ីសុផុន កំពង់ស្វាយ និងពោធិសាត់ (48) ។ គួរគប្បីជ្រាបថាសន្ធិសញ្ញាសម្ងាត់នេះបានធ្វើឡើងក្នុងពេលដែលសន្ធិសញ្ញា ថ្ងៃ ១១ ខែ សីហា ១៨៦៣ ត្រូវផ្ញើទៅប្រទេសបារាំងសុំសច្ចាប័នពីព្រះចៅ Napoléon ទី៣ ។ ប៉ុន្តែ លុះបានទទួលសន្ធិសញ្ញាដែលមានសច្ចាប័នពីព្រះចៅ Napoléon

www.budinst.gov.kh

www.elibraryofcambodia.org

ទិញហើយ លោកទេសាភិបាលនៅកូសាំងស៊ីនបានគម្រាមអោយ ព្រះចៅសៀមបញ្ជូនគ្រឿងសំរាប់រាជ្យមក **ឧដុង្គ** យ៉ាងឆាប់រហ័សដើម្បីធ្វើពិធីអភិសេកព្រះបាទ **នរោត្តម** នៅថ្ងៃទី៣ ខែមិថុនា ១៨៦៤ ។ បន្ទាប់ពីនោះ រាជទូតសៀមត្រូវចាកចេញពីក្រុង **ឧដុង្គ** ហើយព្រះចៅសៀមក៏អស់អំណាចគ្រប់គ្រងមកលើប្រទេសខ្មែរចាប់តាំងពីពេលនោះដែរ ។

**- ការតស៊ូរបស់លោកអាចារ្យស្វា និង លោកពោធិកំបោរ.-**

នោះបើសន្ធិសញ្ញាថ្ងៃ ១១ ខែ សីហា ១៨៦៣ ដែលស្ថិតលើបដិការ (réciprocité) ក្នុងការផ្តល់ប្រយោជន៍អោយគ្នាទៅវិញទៅមកក៏ដោយ ក៏មានអ្នកស្នេហាជាតិបានក្រោកឡើងកាន់អាវុធប្រឆាំងនឹងការប៉ុនប៉ងរបស់បារាំងក្នុងការត្រួតត្រាប្រទេសខ្មែរដែរ ។

គេគប្បីជ្រាបថា បើតាមឯកសារបារាំង ឬតាមទស្សនៈរបស់អ្នកប្រវត្តិសាស្ត្របារាំងភាគច្រើន គេពុំបានចាត់ទុកថាលោក **អាចារ្យស្វា** និងលោក **ពោធិកំបោរ** ជាវីរជនស្នេហាជាតិទេ តែគេនិយមទុកថាជាមេចោរ ជាជនបោកប្រាស់ (51) ជាមនុស្សខ្មាំងទៅវិញ (9) ។

មានអ្នកប្រវត្តិសាស្ត្រខ្លះទៀតបានយល់ឃើញថាការតស៊ូរបស់លោក **អាចារ្យស្វា** និង **ពោធិកំបោរ** គឺបណ្តាលមកពីជម្លោះរាជវង្សវិញ ព្រោះគេបានឃើញថាលោក **អាចារ្យស្វា** បានតាំងខ្លួនលោកជា **អង្គតិម** ដែលត្រូវជារាជបុត្ររបស់ព្រះ **អង្គអិម** ឯ **ពោធិកំបោរ** បានតាំងខ្លួនជាចៅរបស់ព្រះ **អង្គចន្ទ** ។ ប៉ុន្តែ មានមតិខ្លះយល់ថាការតាំងខ្លួនដូច្នេះគឺគ្មានបំណងអ្វីក្រៅពីទាក់ទាញអោយប្រជារាស្ត្រចុះចូលអោយបានច្រើន គឺជាធ្វើស្របទៅតាមចិត្តគំនិតរបស់ខ្មែរក្នុងសម័យនោះដែលនៅគោរពបូជាស្តេចថាជាអាទិទេពនៅឡើយ(48) ។

បើតាមឯកសារខ្មែរ (52) និងតាមពាក្យដំណាលតៗ មក លោក **អាចារ្យស្វា** នេះ ធ្លាប់ជាបរិវាររបស់នាម៉ឺនម្នាក់នៅរាជធានីឧដុង្គ ។ លុះបារាំងមកតាំងអាណាព្យាបាលភាពលើប្រទេសខ្មែរ នៅគ.ស. ១៨៦៤ លោក **អាចារ្យស្វា** បានភៀសទៅកំពត រួចវាយយកបាន **ខេត្ត ត្រាំង** ហើយលើកឆ្ពោះមកក្រុង **ភ្នំពេញ** ទៀត ។ ប៉ុន្តែ លោកត្រូវវាយថយចូលទៅនៅក្នុងខេត្ត **មាត់ជ្រូក** ។ តាមសំណូមពររបស់លោក Doudart de Lagrée លោក


www.budinst.gov.kh www.elibraryofcambodia.org

Roze ជាទេសាភិបាលនៃកូសាំងស៊ីន បានធ្វើអន្តរាគមន៍ដោយសុំអោយអាជ្ញាធរយួនប្រគល់ខ្លួនលោក **អាចារ្យស្វា** អោយទៅបារាំង ។ ក្រោយមកលោក Doudart de Lagrée និងលោកអនុសេនីយឯក Obry បានធ្វើប្រតិបត្តិការសឹកដេញតាមចាប់លោកបាននៅថ្ងៃទី ១៩ ខែសីហា ១៨៦៦ ។ លោកត្រូវបារាំងនិរទេសយកទៅដាក់នៅកោះត្រឡាច រួចនៅកោះ la Réunion ហើយនៅទីបំផុតនៅកោះ Antilles ។

ចំណែកឯលោក **ពោធិកំបោរ** ជាព្រះសង្ឃមួយអង្គមានដើមកំណើតនៅខេត្ត **រោងដំរី** ។ នៅគ.ស. ១៨៦៥ លោកទេសាភិបាល de la Grandière និងលោក Roze បានផ្តល់មធ្យោបាយជាលុយកាក់អោយលោករស់នៅ **ព្រៃនគរ** ទំនងជាដើម្បីស្រួលឃ្លាំមើលសកម្មភាពរបស់លោកតែប៉ុណ្ណោះ ។ នៅខែឧសភា ១៨៦៦ លោកបានភៀសខ្លួនទៅក្នុងខេត្ត **រោងដំរី** ហើយកទ័ពនៅទីនោះ ។ នៅខែក្រោយ មេទាហានបារាំងពីរនាក់ត្រូវអ្នកស្នេហាជាតិខ្មែរសម្លាប់ ។ ទ័ពបារាំងនៅព្រៃនគរបានលើកទៅបំរុងនឹងកំចាត់លោក ។ លោកក៏ចូលទៅក្នុងប្រទេសខ្មែរ ហើយនៅខែធ្នូ ១៨៦៦ លោកបានលើកទ័ពឆ្ពោះទៅរាជធានី **ឧដុង្គ** និង **ភ្នំពេញ** ។ បារាំងបានសុំជំនួយទ័ពពីក្រសួងទ័ពជើងទឹកនិងអាណានិគម ហើយធ្វើអន្តរាគមន៍ការពារក្រុងទាំងពីរនេះ ។ ប៉ុន្តែនៅខែមករា ១៨៦៧ ស្ថានភាពសឹកនិងនយោបាយនៅប្រទេសខ្មែរកាន់តែតឹងតែងឡើង ៈ រាស្ត្រក្រោកឈរប្រឆាំងបារាំងគ្រប់ទីកន្លែង ។

នៅថ្ងៃទី ៩ ខែមករា ១៨៦៧ បារាំងសុំជំនួយទ័ពនិងថវិកាថែមទៀត ។ នៅខែកុម្ភៈ និងមិនាឆ្នាំដដែល ទ័ពបារាំងភ័យឈ្នះទ័ពលោក **ពោធិកំបោរ** នៅ **ឧដុង្គ** ។ លោកដកថយទៅនៅខេត្ត **កំពង់ស្វាយ** តែបារាំងដេញតាមចាប់លោក លោកក៏ថយទៅខាងជើងទៀត ។

គួរគប្បីជ្រាបថា នៅខែមិថុនា ១៨៦៧ ខេត្តទាំង ៣ គឺ **លង់ហោរ** **មាត់ជ្រូក** និង **ពាម** ដែលយួនបានយកពីខ្មែរនោះ ត្រូវបារាំងភ័យយកបញ្ចូលជាអាណានិគមកូសាំងស៊ីនរបស់ខ្លួនទៀត ព្រោះខេត្តទាំង ៣ នោះជាទីតាំងរបស់ពួកយួនដែលប្រឆាំងបារាំង និងជួយគាំទ្រពួកអ្នកស្នេហាជាតិខ្មែរក្នុងការប្រឆាំងបារាំងដូចខ្លួនដែរ ។ នៅពេលនោះលោក **ពោ**

www.budinst.gov.kh www.elibraryofcambodia.org

**ភិរម្យ** បានធ្វើសកម្មភាពជាថ្មីនៅខាងជើងខេត្ត **សៀមរាប** និងនៅតំបន់ **បាត់ដំបង** ។ ប៉ុន្តែលោកត្រូវចំពោះរបស់ព្រះ **កែវហ្វា ស៊ីសុវត្ថិ** ព្រាងបានអោយភៀសទៅទិសប្រទេសលាវ ហើយគេសម្លាប់លោកបានក្នុងពេលភៀសខ្លួននោះនៅថ្ងៃទី ៣០ វិច្ឆិកា ១៨៦៧ ។ មានឯកសារខ្លះថាលោកត្រូវគេសម្លាប់នៅខេត្ត (70) ហើយគឺរាស្ត្រដែលនៀយណាយទឹងការជិះជាន់របស់លោកនេះឯងដែលបានសម្លាប់លោក (9) ។

គួរគប្បីជ្រាបម្យ៉ាងទៀតថា នៅពេលជំណាល ៗ គ្នានោះគឺនៅថ្ងៃ ១៥ កក្កដា ១៨៦៧ ព្រះចៅសៀមនិងព្រះចៅអធិរាជនៃជនជាតិបារាំងបានធ្វើសន្ធិសញ្ញាមួយជាមួយគ្នា ។ តាមរយៈសន្ធិសញ្ញានេះ ព្រះចៅសៀមទ្រង់ទទួលស្គាល់ជានិរន្តរ៍អាណាព្យាបាលភាពរបស់បារាំងមកលើប្រទេសកម្ពុជា ។ ចំណែកខាងបារាំងបានសន្យាថា មិនភ្ជាប់យកប្រទេសនេះទៅបញ្ចូលជាមួយអាណានិគមកូសាំងស៊ីនរបស់ខ្លួន ហើយត្រូវទទួលស្គាល់ថាខេត្ត **បាត់ដំបង អង្គរ និង ស៊ីសុផុន** ជាកម្មសិទ្ធិរបស់សៀមជាស្ថាពរ ។

គឺនៅឆ្នាំ ១៨៦៧ ដដែលនេះដែរដែលព្រះបាទនរោត្តមទ្រង់បានលើករាជធានីពី **ឧដុង្គ** ទៅតាំងនៅក្រុង **ភ្នំពេញ** វិញ ។

## ៦—**សកម្មភាពប្រឆាំងលើកដំបូង** .—

នៅគ.ស. ១៨៧០ ព្រះ **កែវហ្វា ស៊ីសុវត្ថិ** ព្រះអនុជព្រះបាទ **នរោត្តម** បានយាងពី **ព្រៃនគរ** ចូលប្រទេសខ្មែរវិញ ហើយត្រូវបានតាំងជាមហាឧបរាជ ។

នៅគ.ស. ១៨៧៦ ព្រះ **អង្គស៊ីវត្ថា** ដែលភៀសទៅសៀមពីមុនបានត្រឡប់ចូលស្រុកវិញ ហើយបំបះបំបោររាស្ត្រម្តងទៀតនៅត្រង់ **បាត្តំ ទំនួល ព្រៃវែង** ។ តាមរាជពង្សាវតារខ្មែរថា នេះជាឧបាយកលថ្មីមួយទៀតរបស់សៀមដែលបានគិតថា បើបានបារាំងទំនុកបំរុងយូរទៅមុខជាខាងវារយកទឹកដីដែលសៀមបានយករួចហើយ ទើបសៀមអោយព្រះអង្គស៊ីវត្ថា មកច្បាំងដណ្តើមរាជ្យ ។ លើកនេះទៀត ព្រះមហាឧបរាជ **ស៊ីសុវត្ថិ** ត្រូវចាត់អោយចេញបង្ក្រាបបានរាបទាបវិញដោយមានជំនួយពីទ័ពបារាំងផង ។

www.budinst.gov.kh  www.elibraryofcambodia.org

លុះបានសន្តិភាពឡើងវិញ ហើយក្រោយពីបានធ្វើទស្សនកិច្ចទៅក្រុងខ្លះដូចជា **ហុង-កុង ម៉ាកាវ កង់តុង និង ម៉ានីល** (១៨៧២) ដើម្បីទ្រង់ជ្រាបពីវឌ្ឍនភាពក្នុងវិស័យសេដ្ឋកិច្ចនិងសង្គមកិច្ច នៅភូមិភាគអាស៊ីអាគ្នេយ៍ ដោយសារបច្ចេកទេសរបស់អ្នកគ្រប់គ្រង ពួកឈ្មួញនិងពួកអ្នកជំនាញខាងហិរញ្ញវត្ថុជាតិអឺរ៉ុប និងក្រោយពីបានធ្វើការចរចាជាច្រើនលើកជាមួយអ្នកតំណាងប្រទេសបារាំង ទើបព្រះបាទ **នរោត្តម** ទ្រង់បានសំរេចព្រះទ័យថាត្រូវតែធ្វើការកែទំរង់តាមព្រះរាជបញ្ញត្តិចុះថ្ងៃទី ១៥ ខែមករា ១៨៧៧ ដើម្បីអោយប្រទេសជាតិបានចំរើនលូតលាស់ទាន់សម័យនិងគេ ។

## – បញ្ញត្តិទាក់ទងនឹងរាជវង្សានុវង្ស :

បញ្ញត្តិនេះបានសំរេចលប់ចោលនូវឋានៈជាឧភយោរាជ ឧបរាជ និងវររាជិនីព្រមទាំងមន្ត្រីទាំង ៣ សំរាប់នៃក្សត្រទាំង៣នេះ ក្រោយពេលដែលក្សត្រក្នុងឋានៈនេះសោយទិវង្គតទៅ ។ ប្រាក់បៀវត្សនៃក្សត្រា-ក្សត្រីក្នុងរាជវង្សានុវង្សត្រូវបានតម្លើងដើម្បីអោយក្សត្រទាំងនោះអាចមានជីវភាពរស់នៅដោយសមរម្យផង ។ ឯប្រាក់ចំណូលមួយភាគធំត្រូវយកទៅចាយក្នុងកិច្ចការជាប្រយោជន៍រួមវិញ ។

ព្រះមហាក្សត្រិយ៍ទ្រង់គង់នៅជាម្ចាស់នៃដីទាំងឡាយក្នុងព្រះរាជាណាចក្រ ប៉ុន្តែព្រះអង្គទ្រង់បានសន្យាថា នឹងពន្យាររយៈពេលនៃការជួលដីសំរាប់ធ្វើស្រែចំការអោយបានវែងជាងមុន ។

## – បញ្ញត្តិទាក់ទងនឹងរដ្ឋាភិបាល :

ក. ការបង្កើត **ក្រុមប្រឹក្សា** មួយដែលមានមន្ត្រីជាន់ខ្ពស់៥នាក់ (រដ្ឋមន្ត្រី) ដែលអាចដឹកនាំការងាររដ្ឋ ដោយគ្មានវត្តមានរបស់ព្រះរាជា ។ ក្រុមប្រឹក្សានេះត្រូវទទួលភារៈត្រួតពិនិត្យលើការអនុវត្តច្បាប់ សិក្សាពីការកែទំរង់ចាំបាច់ដែលត្រូវធ្វើនិងពិនិត្យមើលនូវកិច្ចការទាំងឡាយរបស់រដ្ឋាភិបាល និងជនទាំងឡាយណាដែលចង់ធ្វើអាជីវកម្មអ្វីមួយក្នុង

www.budinst.gov.kh www.elibraryofcambodia.org

– **បញ្ញត្តិធាក់ទងនឹងរដ្ឋបាល :**

ទឹកដីខ្មែរទាំងមូលត្រូវបែងចែកជា **មណ្ឌលរដ្ឋបាល** ធំ ១ ប្រាំ តាមចំនួននៃរដ្ឋមន្ត្រីទាំងប្រាំ ដែលត្រូវគ្រប់គ្រងមណ្ឌលនិមួយ ៗ ។ ចំនួនខេត្តត្រូវបន្ថែមពី ៥៧ មកនៅត្រឹម ៥០វិញ ។ អំពើពុករលួយ ពួកនាម៉ឺនត្រូវទទួលប្រាក់បៀវត្សដែលមានកំរិតជាក់លាក់ ហើយត្រូវហាមឃាត់មិនអោយធ្វើជំនួញ ។ ពួកឧកញ៉ាបុរាណដែលមានការៈទៅគ្រងមើលខេត្តនានាត្រូវលប់ចោល ព្រោះពួកនេះបានទាញយកផល ប្រយោជន៍ពីព្រះរាជាផងនិងពីប្រជារាស្ត្រផង(53) ។ ម្យ៉ាងទៀត ប្រជារាស្ត្រមានសិទ្ធិជ្រើសរើស **មេស្រុក មេឃុំ និង ចំគង់**របស់ខ្លួន ។

– **បញ្ញត្តិធាក់ទងនឹងពន្ធដា :**

គេបានលប់ចោលនូវរបបទារពន្ធតាមការស៊ីឈ្នួលរើក តែងតែការស៊ីទាំងអាកៀននិងស្រាអាចេញ ។ ម្យ៉ាងទៀតពន្ធមួយចំនួនក៏ត្រូវគេលប់ចោលដែរ ជាពិសេសពន្ធលើល្បែងស៊ីសងដែលត្រូវហាមឃាត់ក្នុងសម័យនោះ ។ កំណែនអោយធ្វើការជូនរដ្ឋត្រូវរក្សាទុកនៅដដែល ប៉ុន្តែថេរវេលាត្រូវបន្ថយមកនៅត្រឹម ៩០ ថ្ងៃក្នុង ១ ឆ្នាំ ហើយដែលគេអាចយកប្រាក់ទៅលោះបាន ។ ពន្ធលើផលិតផលកសិកម្មខ្លះដូចជា ម្លូ ម្រេច ស្ករ ត្រូវបានបន្ធូរបន្ថយ (53) ។

– **បញ្ញត្តិធាក់ទងនឹងតុលាការ :**

មានការគ្រោងបង្កើតនូវតុលាការជាន់ខ្ពស់មួយដែលមានមុខងារជាសាលាឧទ្ធរណ៍ ។ ពួកមន្ត្រីដែលទទួលសំណូកពីគូក្តីត្រូវទទួលទណ្ឌកម្មជាខ្លួន ប្រាក់ពិន័យលែងបានទៅចៅក្រមទៀតហើយ ។ មន្ត្រីប្រគេទនេះត្រូវទទួលប្រាក់បៀវត្សដែលមានកំរិតជាក់លាក់ថែមទៀត ។ ជីវភាពរបស់ពួកជនជាប់គុកត្រូវបានរៀបចំអោយបានប្រសើរជាងមុន ។



www.budinst.gov.kh www.elibraryofcambodia.org

— បញ្ញត្តិដាក់ឧបនិខទាសភាព:

ពួកទាសាទាសីដែលត្រូវទៅនៅបំរើម្ចាស់បំណុលអស់មួយជីវិតពីមុននោះ អាចលោះខ្លួនអោយរួចពីខ្ញុំគេបាន ។ ការលក់ដូរពួកមនុស្សព្រៃនិងកូនក្មេងត្រូវហាមឃាត់ ។

ក្រោយពីបញ្ញត្តិចុះថ្ងៃទី ១៥ ខែមករា ១៨៧៧ នេះ ៗ គួរកត់សំគាល់ថានៅមានអនុសញ្ញាមួយចុះថ្ងៃទី ២៨ ខែមករា ឆ្នាំដដែល ហើយដែលធ្វើឡើងរវាងព្រះបាទ **នរោត្តម** និងលោកទេសាភិបាលកូសាំងស៊ីន ។ អនុសញ្ញានេះ បានបើកអំណាចយ៉ាងទូលាយថែមទៀតដល់តំណាងប្រទេសបារាំងនៅអមព្រះរាជាខ្មែរ ដោយអនុញ្ញាតអោយលោកចូលរួមក្នុងកិច្ចប្រជុំទាំងឡាយរបស់គណៈរដ្ឋមន្ត្រី ដើម្បីផ្តល់យោបល់ផ្សេងៗបាន ។ ក្នុងករណីណាដែលមានបញ្ហាសំខាន់ៗត្រូវដោះស្រាយនោះ វត្តមានរបស់តំណាងប្រទេសបារាំងជាការចាំបាច់ៗ

## ៧— អនុសញ្ញាថ្ងៃទី ១៧ មិថុនា ១៨៨៤ និងផលវិបាក.—

គួរគប្បីជ្រាបថាគំរោងនៃការកែទំរង់ទាំងប៉ុន្មានដូចបានរៀបរាប់រួចមកហើយ ពុំបានទទួលជោគជ័យទាំងអស់ទេ ។ ផ្ទុយទៅវិញការអនុវត្តត្រូវជួបប្រទះនឹងឧបសគ្គជាច្រើន បណ្ដាលមកពីប្រតិកម្មមិនអនុគ្រោះពីសំណាក់ពួកមន្ត្រីជាច្រើននិងពួកមេបំណុល ។

រដ្ឋាភិបាលបារាំងដោយបានទទួលរបាយការណ៍រាំរៀះ ក៏មានការមន្ទិលសង្ស័យទៅលើព្រះសុធន្ទះរបស់ព្រះរាជា ។ នៅពេលនោះលោក Jules Ferry ដែលកាន់តំណែងជានាយករដ្ឋមន្ត្រី បានសំរេចថាត្រូវតែតាំងអាណាព្យាបាលភាពពិតប្រាកដលើប្រទេសខ្មែរ ជាជំនួសការការពារដែលមានតាំងពីមុនមក ។ លោកបានប្រគល់បន្ទុកនេះអោយទៅលោក Charles Thomson ទេសាភិបាលដែនកូសាំងស៊ីន (9) ។

ឯកសារជាច្រើន ជាពិសេសសៀវភៅរបស់លោក Paul Collard បានបញ្ជាក់ថា ការតាំងអាណាព្យាបាលភាពរបស់បារាំងនៅលើកនេះគឺធ្វើដោយបង្ខិតបង្ខំ ដោយគំរាមកំហែងយ៉ាងជាក់ស្តែងតែម្តង ។

យ៉ាងណាមិញ លោក Charles Thomson បានយកកប៉ាល់ចំបាំងទៅឡោមព័ទ្ធ

www.budinst.gov.kh www.elibraryofcambodia.org

វិញ បានលុកលួលក្នុងក្រឡាបន្ទំក្នុងពេលដែលព្រះរាជាកំពុងតែផ្ទំ ហើយបង្ខំអោយព្រះអង្គទ្រង់ព្រះហស្តលេខាលើអនុសញ្ញាមួយដែលបានដកហូតអំណាចទាំងអស់របស់ព្រះអង្គ នៅថ្ងៃទី ១៧ ខែ មិថុនា ១៨៨៤ ។

មាត្រាទី ១ បានបង្ខំអោយព្រះរាជាទទួលស្គាល់ជាមុននូវ **ការកែទំរង់** ទាំងឡាយខាងផ្នែករដ្ឋបាល ផ្នែកតុលាការ ផ្នែកហិរញ្ញវត្ថុ និងផ្នែកពាណិជ្ជកម្ម ដែលសាធារណរដ្ឋបារាំងយល់ថាគួរតែធ្វើក្នុងអនាគតកាល ។

មាត្រាទី ៣ ចែងថា ក្នុងការគ្រប់គ្រងខេត្តនិងក្រសួងនានាមន្ត្រីខ្មែរត្រូវស្ថិតនៅក្រោមការត្រួតពិនិត្យរបស់អាជ្ញាធរបារាំង ។ ចំណែកឯក្រសួងគយ ក្រសួងពន្ធដា ក្រសួងសាធារណការ និងក្រសួងឯទៀតដែលមានប្រើសេ្វករត្រូវបានបារាំងកាន់កាប់ផ្ទាល់តែម្តង ។

មាត្រាទី៤ និងទី ៥ ចែងថារដ្ឋាភិបាលបារាំងអាចតែងតាំង **រេស៊ីដង់** និង **រេស៊ីដង់រង** អោយត្រួតពិនិត្យមន្ត្រីខ្មែរនៅតាមទីរួមខេត្ត និងនៅគ្រប់ទីកន្លែងណាដែលគេយល់ថាគួរជាក់ ។ មន្ត្រីបារាំងទាំងនោះស្ថិតនៅក្រោមឱវាទរបស់ **រេស៊ីដង់ជាន់ខ្ពស់** ម្នាក់ដែលអាចសុំគ្រៀសវនាការជាមួយព្រះរាជាបានជានិច្ច ។

មាត្រា ៦ ចែងថាចំណាយទាំងឡាយរបស់រដ្ឋការខ្មែរ និងរបស់រដ្ឋការអាណាព្យាបាលបារាំងជាបន្ទុករបស់ប្រទេសកម្ពុជា ។

មាត្រា ៧ ចែងថាអំណើះតទៅព្រះរាជាត្រូវទទួលប្រាក់បៀវត្សដែលមានកំរិតជាក់លាក់ ហើយមិនអាចខ្ចីប្រាក់ដោយគ្មានការយល់ព្រមពីរដ្ឋាភិបាលបារាំងឡើយ ។

មាត្រា ៩ ចែងថាដីធ្លីក្នុងព្រះរាជាណាចក្រទាំងមូលពីដើមជាកម្មសិទ្ធិផ្តាច់មុខរបស់ព្រះរាជា ឥឡូវពួកអាជ្ញាធរបារាំងនិងខ្មែរអាចរៀបចំអោយមានកម្មសិទ្ធិឯកជនខាងដីធ្លីនេះបាន ។

មាត្រា ១០ ចែងថាក្រុងភ្នំពេញត្រូវគ្រប់គ្រងដោយមន្ត្រីបារាំងម្នាក់ អមដោយក្រុមប្រឹក្សាមួយមានសមាជិកជាតិបារាំង៦នាក់ ជនបរទេស៤នាក់និងខ្មែរ៣នាក់ ។

សេចក្តីជាទសំខាន់ដែលបានលាតត្រដាងក្នុងមាត្រាទាំងប៉ុន្មានខាងលើនេះបានបង្ហាញអោយឃើញថា រដ្ឋការបារាំងបានកាន់កាប់អំណាចសឹងទាំងស្រុងក្នុងការគ្រប់គ្រងប្រទេស

www.budinst.gov.kh www.elibraryofcambodia.org

កម្ពុជា ។ ម្យ៉ាងទៀត ទោះបីត្រូវគេបង្ខំអោយទទួលយក **អនុសញ្ញា ថ្ងៃទី ១៧ ខែមិថុនា ១៨៨៤** ក៏ដោយ ក៏ព្រះបាទ **នរោត្តម** ទ្រង់បានរកមធ្យោបាយដើម្បីរំដោះប្រទេសព្រះអង្គ អោយរួចពីការត្រួតត្រាផ្ទាល់របស់បរទេសវិញដែរ ។

ចំពោះរឿងនេះ លោក Paul Collard បានសរសេរថា : "គ្រាន់តែសការរបស់បារាំងបានអោយសច្ចាប័នលើអនុសញ្ញា ហើយគ្រាន់តែសច្ចាប័ននោះបានថ្វាយដល់ព្រះរាជាក្រាបក្រាម ក៏ប៉ុន្តែបារាំងត្រូវភ័យលុកនៅគ្រប់ទិសទី ។ នៅថ្ងៃទី ៦ ឧសភា ១៨៨៥ រាជធានីត្រូវវាយលុកដោយពួកខ្មាំង ៥០០០នាក់ប្រដាប់ដោយព្រួញនិងកាំភ្លើងបាញ់ថ្ម..." ។

ដូច្នេះ យើងឃើញថា **អនុសញ្ញា ថ្ងៃទី ១៧ ខែ មិថុនា ១៨៨៤** បានបណ្តាលអោយមានប្រតិកម្មយ៉ាងខ្លាំងក្លាពីសំណាក់ប្រជារាស្ត្រខ្មែរ ហើយពួកមន្ត្រីបារាំងភាគច្រើនបានយល់ថាតែព្រះបាទ **នរោត្តម** នេះហើយជាអ្នកដឹកនាំចលនាតស៊ូប្រឆាំងបារាំងនេះឯង ។ លោក Paul Collard បានសរសេរថា : "មុនអ្វីទាំងអស់ ព្រះអង្គ (ព្រះបាទនរោត្តម) នឹងផ្តើមធ្វើសង្គ្រាម ព្រោះព្រះអង្គមិនទាន់អស់សង្ឃឹមទេ ។ ក៏ប៉ុន្តែដោយឡប់ស្មារតីបណ្តាលមកពីអត្ថបទនៃអនុសញ្ញាដែលបានបង្ហាញចំពោះព្រះអង្គនូវអាកប្បកិរិយារឹងប៉ឹងរបស់យើង (របស់បារាំង) ព្រះអង្គទ្រង់បានរៃធ្វើយ៉ាងណាកុំអោយសង្គ្រាមនេះផ្តល់គ្រោះថ្នាក់ដល់ព្រះអង្គគឺធ្វើយ៉ាងណាអោយមានលក្ខណៈជាការបះបោររបស់ប្រជារាស្ត្រទៅវិញ ហើយដែលគេមិនអាចដាក់ទោសទៅលើព្រះអង្គបាន ។ កិច្ចការដ៏លំបាកនោះ ព្រះអង្គទ្រង់បានបំពេញដោយការប៉ិនប្រសប់ជាទីបំផុត ។ ព្រះអង្គទ្រង់បានដឹកនាំការធ្វើសង្គ្រាមដោយគេមិនអាចចាប់កស្តុតាងបានដោយដាក់ស្តែងម្តងណាឡើយ ។ ផ្ទុយទៅវិញ ដរាបណាសង្គ្រាមនៅតែបន្តវែងឆ្ងាយទៅទៀត ដរាបនោះព្រះអង្គកាន់តែមិនត្រូវបាត់បង់កិត្តិយស ។ ដូចដែលព្រះអង្គទ្រង់សព្វព្រះទ័យ ប្រជារាស្ត្រដែលបានបញ្ចុះបញ្ចូលដោយពួកមេដឹកនាំបានធ្វើអោយសង្គ្រាមនោះមានលក្ខណៈជាការតស៊ូរបស់ជាតិទាំងមូល" ( **Avant tout il allumera la guerre : car il ne désespère pas. Toutefois, affolé par le texte de la Convention qui lui révèle l'énergie de notre attitude, il s'arrangera de telle sorte**

www.budinst.gov.kh www.elibraryofcambodia.org

que cette guerre soit pour lui sans péril, qu'elle ait l'apparence d'une insurrection, d'un soulèvement populaire et qu'il soit impossible de l'en rendre responsable. Cette entreprise si difficile à conduire, il la mène à bien avec une rare habileté, admirablement servi par ce tempérament asiatique qui déroute souvent les plus adroits. Il dirige la campagne sans qu'on puisse jamais le prendre en flagrant délit. Au contraire, plus les hostilités se prolongent, moins il risque de se compromettre. Ainsi qu'il l'a voulu le peuple, travaillé et endoctriné par ceux pui entretiennent le mouvement, donne à cette guerre toute la physionomie d'une révolte nationale) (50).

ចំពោះរឿងនេះ ជនជាតិបារាំងម្នាក់ទៀតគឺលោក André Migot បានសរសេរថា: "មិនដល់មួយឆ្នាំក្រោយពីការចុះហត្ថលេខាលើសន្ធិសញ្ញា ១៨៨៤ មានការបះបោរយ៉ាងខ្លាំងក្លាបានផ្ទុះឡើងដើម្បីប្រឆាំងនឹងខសំខាន់នៃសន្ធិសញ្ញានេះ ។ គេច្រើនតែចាត់ទុកថាការបះបោរដែលបណ្តាលអោយមានការបង្ហូរឈាមនៅប្រទេសកម្ពុជា ជាស្នាដៃរបស់ពួកស្តេច ឬពួកអ្នកផ្សងព្រេងល្មោភអំណាច ឬរបស់ពួកខ្មាំងដែលមានចិត្ត ថ្វីមជាចោរទៅវិញ ។ តាមការពិត នេះគឺជាការបះបោររបស់អ្នកស្នេហាជាតិខ្មែរក្នុងគោលបំណងរំដោះប្រទេសជាតិរបស់ខ្លួនអោយរួចពីនឹមបរទេស ឬក៏ជាការតស៊ូតាមរបៀបចំបាំងឈ្លបដែលមានការរៀបចំយ៉ាងទូលំទូលាយ ហើយដែលមានការគាំទ្រពីសំណាក់ព្រះស្តេចនិងព្រះសង្ឃ ។ ពិតមែនហើយថានៅគ្រាដំបូងគុំមានទំនាក់ទំនងជិតស្និទ្ធរវាងរាជវង្សានុវង្សនិងប្រជារាស្ត្រជាអ្នកប្រយុទ្ធ ប៉ុន្តែគេដឹងច្បាស់ថាព្រះបាទនរោត្តមទ្រង់បានខិតខំគាំទ្រនូវចលនាតស៊ូ ហើយជនជាតិបារាំងក៏តែងតែជឿជាក់ថាគឺព្រះអង្គនេះហើយជាអ្នកមេគំនិត ។ ទោះបីការបះបោរត្រូវទទួលបរាជ័យក៏ដោយ ក៏ការបះបោរនោះបានពង្រឹងវិហាររបស់ព្រះរាជាដែលអាចទាមទារយកពីជនជាតិបារាំងនូវសម្បទានខ្លះ: " (Moins d'un an après la signature du traité de 1884, de graves soulèvements avaient éclaté pour protester contre les termes du traité. On a souvent présenté les révoltes qui ensanglantèrent le Cambodge comme le fait de princes ou d'aventuriers avides du pouvoir, de «rebelles» plus ou moins assimilés à des bandits. En réalité il s'agissait d'un soulèvement de patriotes cambodgiens ayant pour but



www.budinst.gov.kh www.elibraryofcambodia.org

la libération de leur pays du joug de l'étranger, d'une lutte de guérillas organisée sur une vaste échelle, soutenue par des princes ou des bonzes bouddhistes. Bien qu'il n'y ait pas eu au début de contact direct entre la famille royale et le peuple combattant, il est bien évident que le roi Norodom faisait ce qu'il pouvait pour soutenir le mouvement, et les Français restèrent toujours persuadés qu'il en était l'instigateur. Si l'insurrection fut vaincue, elle n'en réussit pas moins à épauler le roi qui, grâce à elle, réussit à arracher aux Français un certain nombre de concessions)(50).

ការតស៊ូរបស់អ្នកស្នេហាជាតិខ្មែរមានរយៈពេលប្លែប្រាំមួយខែ ( ពីខែវិច្ឆិកា ១៨៨៤ ដល់ខែមករា ១៨៨៧ ) ហើយបានប្រព្រឹត្តទៅទូទាំងប្រទេស ។ បារាំងត្រូវលើកទ័ពទៅតស៊ូនិងអ្នកស្នេហាជាតិនៅគ្រប់ទិសទី ។ នៅក្នុងទីក្រុងដែលមានទាហានការពារយ៉ាងមាំទាំ គេឃើញមានការធ្វើឃាតយ៉ាងច្រើន ជាហេតុនាំអោយទាហានធ្លាក់ទឹកចិត្តយ៉ាងខ្លាំង ។ ទ័ពបារាំងត្រូវទទួលការខូចខាតយ៉ាងធំណាំ ព្រោះត្រូវទប់ទល់នឹងការវាយប្រហាររបស់អ្នកស្នេហាជាតិខ្មែរផង ត្រូវស្លាប់ដោយជម្ងឺនិងធាតុអាកាសផង ។

ក្រោយពីលោក Jules Ferry ចេញចាកពីនាកនយោបាយទៅ រដ្ឋាភិបាលបារាំងបានស្គាល់នូវការភ័ន្តច្រឡំរបស់ខ្លួន ដោយសារការផ្តល់ពត៌មានពីលោក Piquet ជារេស៊ីដង់ស៊ុបេរីយ៉េរ ។ បារាំងបានប្រគល់អំណាចទៅអោយព្រះរាជាវិញ ទុកអោយមានតែរេស៊ីដង់ស៊ុបេរីយ៉េរម្នាក់នៅអមព្រះអង្គ ។ កិច្ចការរដ្ឋត្រូវបានប្រគល់ទៅអោយមន្ត្រីខ្មែរកាន់កាប់វិញ ។ នៅតាមខេត្ត នៅមានតែរេស៊ីដង់បារាំង ៤ នាក់ប៉ុណ្ណោះ ( នៅកំពត ក្រចេះ កំពង់ធំ និងពោធិសាត់ ) ដែលបានទទួលបញ្ជាថាមិនត្រូវទៅជ្រៀតជ្រែកក្នុងកិច្ចការរបស់អ្នកស្រុក ហើយត្រូវគោរពទំនៀមទំលាប់ប្រពៃណីនិងសាសនារបស់អ្នកស្រុកថែមទៀត ។ ការកែទំរង់ទាំងឡាយដែលលោករេស៊ីដង់ស៊ុបេរីយ៉េរបានស្នើ ត្រូវបានទទួលសេចក្តីយល់ព្រមពីព្រះមហាក្សត្រិយ៍សិនទើបអាចយកទៅអនុវត្តបាន ។

លុះព្រះរាជាទ្រង់បានយល់ព្រមតាមនយោបាយថ្មីរបស់បារាំងនៅប្រទេសខ្មែរហើយ សន្តិភាពក៏មានឡើងវិញ ដោយព្រះអង្គទ្រង់បានយាងទៅជួបពួកមេដឹកនាំការតស៊ូទាំងអ



www.budinst.gov.kh www.elibraryofcambodia.org

មេក្ត ក្រែតធិច ហើយទ្រង់បានបញ្ជាក់ច្បាប់ថា រដ្ឋការបារាំងបានប្រគល់អំណាចអោយខ្មែរវិញ ។ ដូច្នេះ ការតស៊ូរបស់អ្នកស្នេហាជាតិក៏ត្រូវបញ្ចប់ត្រឹមពេលនោះដែរ ។ គួរគប្បីក្រាបជា ពួកមេដឹកនាំសំខាន់ ៗ នៅពេលនោះមានជាអាទិ៍ :

- **ឧកញ៉ា ឧត្តមយោធិបតី** នៅហ្វាយស្រុកសំរោងទង
- **ឧកញ៉ាឧទ្យាឧត្តមធិត** នៅហ្វាយស្រុកក្តុំស្រួច
- **និម្មុលពជ៍គែម** នៅគងពិសី
- **ឧទ្យាអគ្គរាជញ៉ឹក** នៅកណ្ដាលស្ទឹង
- **និម្មុលសង្គ្រាមស** នៅស្អាង
- **ចក្រីមាំ** នៅបាទី

ចំណែកឯ **ក្រឡាហោមគង់** និង **ពិស្ណុលោកឈួន** មិនបានអញ្ជើញទៅជួបជុំក្នុងពេលនោះទេ លោកគ្រាន់តែបានចាត់តំណាងអោយទៅទូលសុំធ្វើសវនាការជាមួយព្រះរាជា នៅថ្ងៃក្រោយ ៗ គេដឹងថា លុះស្រុកបានសន្តិភាពហើយ លោក **ពិស្ណុលោកឈួន** ត្រូវគេលួចធ្វើឃាត ឯលោក **ក្រឡាហោមគង់** ត្រូវបារាំងអោយនាម៉ឺនខ្មែរម្នាក់បញ្ឆោតអោយឡើងមើលកប៉ាល់វា ហើយត្រូវចាប់ចងផ្ដោបនឹងបំពង់កាំភ្លើងកប៉ាល់ រហូតដល់ក្ស័យជីវិតទៅ (54) ។

## ៨-បញ្ហាដែនដីភូសាំងស៊ីននិងបញ្ហាព្រំដែន.-

នៅគ.ស.១៨៦៤ ព្រះបាទ **នរោត្តម** ដោយមានលោក Doudart de Lagrée អមផង បានយាងទៅជួបលោកទេសាភិបាល de la Grandière នៅក្រុងព្រៃនគរ ហើយបានធ្វើសំណូមពរចំពោះលោកទេសាភិបាលសូមអោយប្រទេសបារាំងបង្វិលសងមកខ្មែរវិញនូវខេត្តទាំង៣ គឺ **លង់ហោរ** (លង់ហោរ ព្រះត្រពាំង ផ្សារដែក) **មាត់ជ្រូក** (មាត់ជ្រូក បារាព្រែកឫស្សី យ៉ាំង) និង **ពាម** (ពាមក្រមួនស ពលលាវ) ដែលស្ថិតនៅក្នុងការកាន់កាប់របស់យួននៅឡើយតាមសន្ធិសញ្ញា ១៨៦២ ។ ព្រះអង្គទ្រង់បានទទួលភាពក...ឡោតិរឿ

www.budinst.gov.kh www.elibraryofcambodia.org

នេះ ហើយក៏យាងត្រឡប់ចូលរាជធានី **ឧដុង្គ** វិញ ...ដោយទ្រង់មានសង្ស័យថាទឹកដីដែលបាត់បង់នោះមិនត្រូវបានបញ្ចូលជាទឹកដីខ្មែរដូចដើមវិញមិនខាន ។ ក៏ប៉ុន្តែ នៅគ.ស.១៨៦៧ ដោយហេតុថាខេត្តទាំងបីនោះជាកន្លែងដែលយួនធ្វើសកម្មភាពប្រឆាំងបារាំង លោកទេសាភិបាលកូសាំងស៊ីនក៏ភ័យយកបញ្ចូលជាអាណានិគមរបស់លោកតទៀតទៅ ដោយភ្លេចនឹកដល់ពាក្យសន្យារបស់លោកចំពោះព្រះបាទ **នរោត្តម** (55) ។

ដូច្នេះ ចាប់តាំងពីគ.ស ១៨៦៧ ទឹកដីកម្ពុជាក្រោមទាំងមូលបានក្លាយទៅជាអាណានិគមរបស់បារាំង ។ ចំណែកឯកម្ពុជាលើមានលក្ខន្តិកៈជាប្រទេសអាណាព្យាបាល ។ ម៉្លោះហើយ អាជ្ញាធរបារាំងនៅកូសាំងស៊ីនតែងតែធ្វើការកែប្រែបន្ទាត់ព្រំដែនតាមទំនើងចិត្តខ្លួនរវាងប្រទេសទាំងពីរដែលមានរបបខុសគ្នាដោយសំអាងលើហេតុផលខាងរដ្ឋបាល ឬ ខាងសេដ្ឋកិច្ច ។ គេបានសង្កេតឃើញថា ការកែប្រែទាំងនោះសុទ្ធតែធ្វើអោយចំណេញទឹកដីទៅខាងកូសាំងស៊ីនជានិច្ច ដោយមិនអើពើដល់ការតវ៉ារបស់ព្រះរាជាខ្មែរ ឬដោយមិនស្នើសូរព្រះយោបល់ផងទេ (56) ។

ចាប់ពីឆ្នាំ ១៨៩៣ ដល់ ឆ្នាំ ១៩១៤ ប្រទេសខ្មែរត្រូវបាត់បង់ទឹកដីអស់ថែមមួយភាគទៀត ដោយហេតុតែបារាំងបានប្រវញ្ចយកទៅបញ្ចូលក្នុងអាណានិគមកូសាំងស៊ីន ឬ ក្នុងប្រទេសអាណ្ណាមទៅវិញ (57) ។

នៅគ.ស. ១៨៩៨ លោករេស៊ីដង់ស៊ុបេរីយ័រនៃប្រទេសលាវបានដកហូតយកពីខេត្តស្ទឹងត្រែងនូវដី ១ ដុំដើម្បីបង្កើតជាស្នងការដ្ឋាន Darlac ដែលក្រោយមកត្រូវគេយកទៅបញ្ចូលក្នុងប្រទេស **អណ្ណាម** នៅគ.ស. ១៩២៤ ។ នៅគ.ស. ១៨៩៣ អនុក្រិត្យ(arrêté) របស់លោកទេសាភិបាលកូសាំងស៊ីនបានបញ្ចូលស្រុកខ្មែរពីរ គឺ **គឺទអាញ់** (Cau Anh) និង **ថាញ់ អាញ់** (Thanh Anh) នៅឯខាង **ឡុក និញ** (Loc Ninh) និងស្រុកទៀតពីរគឺ **ឡុកនិញ** និង **ភឿកឡេ** (Phuoc Lê) ទៅក្នុងវៀង (ស្រុក) **កាន់ឡេ** (Can Lê) ក្នុងបំណងដើម្បីកែនមនុស្សទៅស្ថាបនាផ្លូវពី **បៀនហ៊ា** ទៅ **ក្រចេះ** ។ ផែនទីដែលបោះពុម្ពមុនឆ្នាំ ១៩០៣ សុទ្ធតែដាក់ថាស្រុក **ឡុក និញ** និង **ភឿក ឡេ** ជាទឹកដីខ្មែរទាំងអស់

www.budinst.gov.kh www.elibraryofcambodia.org

លុះដល់ឆ្នាំ១៩២៥ ទើបមានអនុក្រឹត្យមួយរបស់លោកអគ្គទេសាភិបាលសំរេចបញ្ចូលស្រុកពីរនោះក្នុងដែនដីកូសាំងស៊ីន ។

ខាងផ្នែក **ខេត្តជីរី** លិខិតផ្លូវការជាច្រើនបានបញ្ជាក់ពីការដកហូតយកដីខ្មែរទៅបញ្ចូលក្នុងដែនកូសាំងស៊ីន គឺស្រុក **ខើចបាដែង មិចម្រុំ ស្រុកត្រាញ់** និងដីស្ថិតនៅត្រង់ចន្លោះនៃទន្លេ **វាយគោ** (Vaico) ទាំងពីរ ។

ខាងផ្នែក **ពាម** បារាំងបានយកឃុំពីរគឺ**កោះចន្លុះ** និង **សាគី** នៅ គ.ស. ១៨៩៣ ដើម្បីយកទៅបញ្ចូលក្នុងដែនកូសាំងស៊ីនទៀត ។ មានអនុក្រឹត្យមួយរបស់លោកអគ្គទេសាភិបាលធ្វើនៅឆ្នាំ ១៩១៤ បានបញ្ជាក់ពីរឿងនេះ ។

ចំពោះកោះទាំងឡាយវិញ អាជ្ញាធរបារាំងនៅកូសាំងស៊ីនក៏ដូចជាអាជ្ញាធរបារាំងនៅប្រទេសកម្ពុជាសុទ្ធតែបានទាមទារទុកជាកម្មសិទ្ធិតែរៀងៗខ្លួន ។ តាមផ្លូវច្បាប់ គេឃើញមានសារាចរមួយរបស់លោកអគ្គទេសាភិបាល Brévié ចុះថ្ងៃទី ៣១ ខែ មករា១៩៣៩ ដែលបានចែងថា : “ កោះទាំងឡាយដែលស្ថិតនៅខាងជើងបន្ទាត់មួយកែងនឹងឆ្នេរសមុទ្រត្រង់ចំណុចព្រំដែនរវាងប្រទេសកម្ពុជានិងកូសាំងស៊ីន នឹងត្រូវគ្រប់គ្រងដោយប្រទេសកម្ពុជា ។ អាជ្ញាធរអាណាព្យាបាលនឹងរាប់រងជាពិសេសនូវបញ្ហាប៉ូលីសលើ កោះទាំងនោះ ។

ចំណែកឯកោះទាំងឡាយដែលស្ថិតនៅខាងត្បូងបន្ទាត់នោះ គិតទាំង **កោះត្រល់** ទាំងមូលផង នឹងត្រូវគ្រប់គ្រងដោយអាជ្ញាធរដែនកូសាំងស៊ីន ” (56) ។

ដូច្នេះ យើងឃើញថាព្រំដែនរវាងប្រទេសកម្ពុជា និង ដែនដីកូសាំងស៊ីនមានលក្ខណៈជាព្រំដែនរដ្ឋបាលច្រើនជាងព្រំដែននយោបាយ ។ ខ្មែរត្រូវបាត់បង់ទឹកដីទទេៗ ព្រមទាំងកោះទុះមាន **កោះត្រល់** ជាដើម មកតែពីចិត្តលោភលន់របស់បារាំងតែប៉ុណ្ណោះ ។

www.budinst.gov.kh www.elibraryofcambodia.org

ចាប់តាំងពី គ.ស. ១៨៨៧តទៅ ប្រទេសខ្មែរបានស្ថិតនៅក្នុងសន្តិភាព ប៉ុន្តែមិនដែលត្រូវបារាំងទេះម្តងម្តុំ យកទៅបញ្ចូលឯណេះ ឬ ឯណោះតាមតែអំពើចិត្តរបស់ខ្លួន ។

ព្រះបាទ **នរោត្តម** ទ្រង់បានសោយទីវង្គត នៅថ្ងៃ ទី ២៤ ខែ មេសា ១៩០៤ ដោយរោគថ្លាម នៅវេលាម៉ោង ៣ ល្ងាច ។ ព្រះអង្គទ្រង់មានមរណនាមថា **សុវណ្ណកោដ្ឋ** ។

## ៦– បារាំងបានធ្វើអ្វីខ្លះជាប្រយោជន៍ដល់ខ្មែរ ?

### ១– ព្រះបាទស៊ីសុវត្ថិ ( ១៩០៤–១៩២៧ ) .–

នាថ្ងៃ ២៤ មេសា ដដែលនោះ វេលាម៉ោង ៣ និង ២០នាទីល្ងាច **ក្រុមប្រឹក្សារាជបល្ល័ង្ក** ( Conseil de la Couronne ) ដែលមានគណៈរដ្ឋមន្ត្រី និងមន្ត្រីជាន់ខ្ពស់ទាំងបព្វជិត និងទាំងគ្រហស្ថបានបើកសម័យប្រជុំក្រោមអធិបតីភាពនៃលោករេស៊ីដង់ស៊ុបេរីយ័រដើម្បី ជ្រើសរើសព្រះមហាក្សត្រិយ៍ថ្មីទៅតាមប្រពៃណីខ្មែរ ។ ដោយហេតុថាព្រះបាទ **នរោត្តម** ពុំសូវស្និទ្ធស្នាលនឹងបារាំង ព្រះរាជបុត្ររបស់ព្រះអង្គពុំត្រូវបានជ្រើសរើសអោយឡើងសោយរាជ្យស្នងព្រះបិតាទេ ។ ពេលនោះ **ក្រុមប្រឹក្សារាជបល្ល័ង្ក** ដែលមានលោករេស៊ីដង់ស៊ុបេរីយ័រជាអធិបតីនោះ បានសំរេចជ្រើសរើសព្រះមហាឧបរាជ **ស៊ីសុវត្ថិ** ជាព្រះអនុជព្រះបាទ **នរោត្តម** អោយឡើងសោយរាជ្យវិញ (58) ។

បើតាមលោក Paul Collard ព្រះបាទ **ស៊ីសុវត្ថិ** ជាបុគ្គលដែលគួរអោយស្រឡាញ់ជាទីបំផុត ជាមនុស្សដែលមានចិត្តទូលាយនិងចិត្តមេត្តាជាទីបំផុតក្នុងចំណោមខ្មែរទាំងឡាយ (58) ។ ព្រះអង្គទ្រង់បានខិតខំទាំងកម្លាំងព្រះទ័យនិងទាំងកម្លាំងព្រះកាយដើម្បីធ្វើអោយមានសន្តិភាពនិងធ្វើអោយប្រជារាស្ត្របានសម្បូណ៌សប្បាយ ។

លុះបានឡើងសោយរាជ្យភ្លាម ព្រះអង្គទ្រង់បានប្រកាសអោយប្រើនូវព្រះរាជបញ្ញត្តិថ្ងៃទី ២១ ខែ ឧសភា ១៩០៤ ដែលបញ្ជាអោយលប់ចោលនូវការធ្វើទុក្ខបុកម្នេញលើរាងកាយនៃជនមានទោសនិងលើជនដែលត្រូវជាប់ចោទ ។

www.budinst.gov.kh www.elibraryofcambodia.org

នៅឆ្នាំក្រោយ ព្រះអង្គទ្រង់បានបញ្ញត្តិអោយលប់ចោលនូវ **តំណាងខេត្ត** មិនបញ្ញត្តិ ថា អំណើះតទៅកិច្ចការរដ្ឋបាលទាំងឡាយនៃព្រះរាជាណាចក្រត្រូវស្ថិតក្រោមការត្រួតពិនិត្យដោយលោក **អគ្គមហាសេនា** (រដ្ឋមន្ត្រីទី១) រួចទៅត្រូវយកទៅដាក់ជូនលោករេស៊ីដង់ស៊ុបេរីយ៉េរពិនិត្យទៀត (រាជបញ្ញត្តិថ្ងៃទី ៩ ខែ ឧសភា ១៩០៥) ។ គួរគប្បីជ្រាបថា នៅមុននេះទឹកដីប្រទេសកម្ពុជាទាំងមូលត្រូវបែងចែកជាមណ្ឌលរដ្ឋបាលធំ ៗ ប្រាំ តាមចំនួនរដ្ឋមន្ត្រីទាំងប្រាំដែលត្រូវគ្រប់គ្រងមណ្ឌលនិមួយ ៗ ហើយដែលមានងារជា **តំណាងខេត្ត** ។ ចាប់តាំងពីពេលនោះទៅ ពួកចៅហ្វាយខេត្តមិនឡើងទៅរដ្ឋមន្ត្រីណាមួយទៀតទេ តែត្រូវស្ថិតនៅក្រោមការត្រួតពិនិត្យផ្ទាល់របស់រដ្ឋបាលអាណាព្យាបាលបារាំង ។ នៅឆ្នាំដដែលនោះ តាមព្រះរាជបញ្ញត្តិថ្ងៃទី ៣ ខែកក្កដា ព្រះបាទ **ស៊ីសុវត្ថិ** ទ្រង់បានបញ្ជាក់ពីមុខងាររបស់រដ្ឋមន្ត្រីទាំង ៥ៈ មានដូចតទៅៈ

— **ឧកញ៉ាអគ្គមហាសេនា** ៖ មានមុខងារជារដ្ឋមន្ត្រីក្រសួងមហាផ្ទៃនិងធម្មការ និងជាអធិបតីនៃគណៈរដ្ឋមន្ត្រី ។

— **ឧកញ៉ាយមរាជ** ៖ មានមុខងារជារដ្ឋមន្ត្រីក្រសួងយុត្តិធម៌ ។

— **ឧកញ៉ាវាំង**ៈ មានមុខងារជារដ្ឋមន្ត្រីទទួលខុសត្រូវកិច្ចការក្នុងរាជវាំង ហិរញ្ញវត្ថុ និងរាជវិចិត្រសិល្បៈ ។

— **ឧកញ៉ាក្រឡាហោម** ៖ មានមុខងារជារដ្ឋមន្ត្រីទទួលក្រសួងពាណិជ្ជកម្ម ឧស្សាហកម្មនិងកសិកម្ម ។

— **ឧកញ៉ាចក្រី** ៖ មានមុខងារជារដ្ឋមន្ត្រីទាំងសង្គ្រាម សាធារណការ និងការសិល្បសាធារណៈ ។

ចំពោះទឹកដីដែលត្រូវបាត់បង់ទៅក្នុងដៃសៀមនោះ គេដឹងថាក្នុងឆ្នាំ១៩០៤ ប៉ុន្មានខែក្រោយដែលព្រះបាទ **ស៊ីសុវត្ថិ** បានឡើងសោយរាជ្យ ប្រទេសសៀមបានបង្វិលទៅអោយបារាំងហើយដែលបារាំងបានប្រគល់អោយព្រះអង្គវិញនូវខេត្ត **ត្រាច** (ត្រាត ?) **កោះកុង** ( Ko-Kong ) **មហូព្រៃ** និង **ទន្លេរពៅ** ។ នៅពេលជាមួយគ្នានោះ ខេត្ត **ស្ទឹងត្រែង**

www.budinst.gov.kh www.elibraryofcambodia.org

និងស្រុកសៀមប៉ាំង ក៏ត្រូវដកហូតពីប្រទេសលាវ ហើយប្រគល់មកអោយព្រះរាជាខ្មែរវិញដែរ (10) ។

តាម **សន្ធិសញ្ញាថ្ងៃទី ២៣ ខែមីនា ១៩០៧** រដ្ឋាភិបាលសៀមបានប្រគល់អោយបារាំងវិញនូវខេត្ត **បាត់ដំបង សៀមរាប** និង **ស៊ីសុផុន** ។ ប៉ុន្តែបារាំងត្រូវអោយជាថ្នូរទៅវិញនូវដែនដី **ដាន់ សៃ** (Dan-Sai) និង **ត្រាច** (ត្រាត?) ។ ខេត្តទាំង៣ ខាងលើ បារាំងបានប្រគល់អោយមកខ្មែរវិញ ។

គួរគប្បីជ្រាបថា ការវិលចូលមកក្នុងមាតុភូមិវិញនូវទឹកដីមួយភាគយ៉ាងសំខាន់ដែលត្រូវបាត់បង់ទៅតាំងពីសម័យភញ្ញាអភ័យធិបេសចែន (១៧៩៥) ជាជោគជ័យមួយនៃនយោបាយបារាំងនៅប្រទេសកម្ពុជា ដែលមានចរិតទុកជាអនុស្សាវរីយ៍នៅត្រង់ទិសខាងត្បូងវត្តភ្នំភ្នំពេញសព្វថ្ងៃ ។ ការទាមទារយកបានទឹកដីនេះមកវិញ គឺធ្វើឡើងក្នុងពេលដែលលោក Armand Fallières កាន់តំណែងជាប្រធានាធិបតីនៃសាធារណរដ្ឋបារាំង លោក Paul Beau ជាអគ្គទេសាភិបាលនៃឥណ្ឌូចិន និងលោក Paul Luce ជារេស៊ីដង់ស៊ុបេរីយ៍រនៅប្រទេសកម្ពុជា ។

នាឆ្នាំ ១៩០៧ ដដែលនោះ មានបង្កើតគណៈកម្មការសំរាប់ចងក្រងរាជពង្សាវតារខ្មែរ : គណៈកម្មការទី ១ មានលោកឧកញ៉ា **វាំងជួន** ជាប្រធាន គណៈកម្មការទី ២ មានលោកឧកញ៉ាវង្សាអគ្គរាជ **ឌុច** ជាប្រធាន ។

តាមរាជបញ្ញត្តិថ្ងៃទី ១១ ខែមេសា ១៩១២ ឪពុកម្តាយត្រូវតែបញ្ជូនកូនប្រុសស្រីអោយទៅកាន់សាលារៀន បើពុំនោះទេនឹងត្រូវទទួលទណ្ឌកម្មយ៉ាងធ្ងន់ ។ សូមជ្រាបថានៅសម័យនោះ ក្រៅពីសាលាវត្ត រាជការបានបង្កើតសាលានៅតាមឃុំជាច្រើនទៀត ដើម្បីអោយក្មេងៗសិក្សាភាសារបស់ជាតិខ្លួន ។ ចំពោះក្មេងណាដែលចង់បន្តការសិក្សាថែមទៀត រដ្ឋការអាណាព្យាបាលបារាំងបានបង្កើតសាលាបឋមសិក្សាជាន់ដំបូងខ្លះ ដែលនៅទីនោះគេមានផ្តើមការបង្រៀនភាសាបារាំង ។ នៅពីលើសាលាទាំងនោះ នោះមានសាលាដែលមានកិត្តិវិជ្ជាខ្ពស់ជាងនៅតាមទីរួមខេត្ត ហើយដែលមានចាងហ្វាងជាបារាំង ។

www.budinst.gov.kh www.elibraryofcambodia.org

សំរាប់មធ្យមសិក្សា គេមានតែអនុវិទ្យាល័យស៊ីសុវត្ថិមួយគត់នៅរាជធានីភ្នំពេញ ដែលត្រូវបានបង្កើតឡើងតាំងពីឆ្នាំ ១៩០៤ ម្ល៉េះ ។

ក្នុងវិស័យសិក្សាអប់រំនិងវប្បធម៌នេះ គេបានដឹងថាតាមរាជបញ្ញត្តិថ្ងៃទី ៤ ខែ កញ្ញា ១៩១៥ ព្រះបាទ **ស៊ីសុវត្ថិ** ទ្រង់បានបង្កើតគណៈកម្មការមួយដែលមាននាទីរៀបចំវចនានុក្រមខ្មែរជាលើកដំបូង រួចនៅគ.ស. ១៩២១ ព្រះអង្គទ្រង់បានសាងសាលាបាលីជាន់ខ្ពស់ និង ព្រះរាជបណ្ណាល័យ ។ ម្យ៉ាងទៀត នៅក្នុងរជ្ជកាលរបស់ព្រះអង្គដដែល (១៩១៨) លោក **Georges Groslier** បានបង្កើតសារមន្ទីរមួយនៅក្រុងភ្នំពេញ ដើម្បីប្រមែប្រមូលនូវស្នាដៃខ្មែរដែលជាវត្ថុបុរាណយកមកថែរក្សាអោយបានគង់វង្សតទៅ ។

គួរកត់សំគាល់ដែរថា ចាប់តាំងពីឆ្នាំ ១៩១២ ព្រះរាជាទ្រង់បានប្រកាសអោយប្រើនូវក្រមព្រហ្មទណ្ឌថ្មី ។ នៅឆ្នាំបន្ទាប់ ក្រមស៊ើបអង្កេតបទឧក្រិដ្ឋ និងនៅឆ្នាំ១៩២០ ក្រមរដ្ឋប្បវេណី និងក្រមនីតិវិធីរដ្ឋប្បវេណី ក៏ត្រូវបានប្រកាសអោយប្រើជាបន្តបន្ទាប់គ្នា ។ ក្រោយមកទៀតរាជបញ្ញត្តិ ថ្ងៃ ទី ១៤ ខែ កញ្ញា ១៩២២ បានបង្កើតអោយមានសាលាលហុ សាលាដំបូង សាលាឧទ្ធរណ៍ សាលាឧក្រិដ្ឋ និងសាលាវិនិច្ឆ័យ ។ ប៉ុន្តែសាលាទាំងនោះ ឬ វិស័យតុលាការទាំងមូលត្រូវស្ថិតនៅក្រោមអំណាចគ្រប់គ្រងរបស់រដ្ឋការអាណាព្យាបាលបារាំង ។

ក្នុងវិស័យហិរញ្ញវត្ថុ គួរគប្បីរំលឹកឡើងវិញថាចាប់តាំងពីឆ្នាំ ១៨៩០ មក បញ្ជីចំណូលចំណាយនៃប្រទេសកម្ពុជាត្រូវកាន់កាប់ដោយហិរញ្ញិកម្នាក់ ។ ម្យ៉ាងទៀត នៅរៀងរាល់ឆ្នាំលោករេស៊ីដង់ស៊ុបេរីយ័រត្រូវរៀបចំថវិកាសំរាប់ឆ្នាំខាងមុខ ។ ចាប់ពីឆ្នាំ១៩១២ គេបានគ្រោងក្នុងផ្នែកចំណាយនូវមុខចំណាយដូចតទៅ :

— មុខចំណាយសំរាប់រដ្ឋបាលទាំងខាងខ្មែរទាំងខាងបារាំង
— មុខចំណាយសំរាប់សន្តិសុខសាធារណៈនិងតុលាការ
— មុខចំណាយសំរាប់ហិរញ្ញវត្ថុ និងធនធានសាធារណៈ

www.budinst.gov.kh www.elibraryofcambodia.org

— ចុះចំណាយសំរាប់តុលាការសង្គ្រោះ និងសិក្សាធិការ

ហើយដើម្បីទប់ទល់នឹងចុះចំណាយទាំងប៉ុន្មានខាងលើនេះ គេបានបង្កើតពន្ធប្រភេទពន្ធផ្សេង ៗ មាន៖

— ពន្ធលើខ្លួន

— ពន្ធលើការអោយខ្ចី

— ពន្ធលើដីធ្លីនិងដំណាំ

— ពន្ធបាំគង់

— ពន្ធលើផលិតផលព្រៃឈើ លើផលិតផលជក់កាស៊ី លើផលិតផលអាជីវកម្មឧស្សាហកម្ម និងផលិតផលផ្សេង ១ (10) ។

ក្នុងវិស័យសេដ្ឋកិច្ច គេបានដឹងថាក្នុងរជ្ជកាលរបស់ព្រះបាទ**ស៊ីសុវត្ថិ** ចំការកៅស៊ូត្រូវបានបង្កើតជាលើកដំបូងនៅត្រង់តំបន់ **ជប់** (១៩២១) ។ ដោយការសាកល្បងនេះមានជោគជ័យ ពួកមូលធននិយមបារាំងបានបង្កើតចំការកៅស៊ូធំ ១ ផ្សេងទៀតនៅត្រង់តំបន់ដីក្រហមក្នុងខេត្តកំពង់ចាម និងក្រចេះ ។ ជប់ឆ្នាំក្រោយមក គឺនៅឆ្នាំ ១៩៣១ ទំហំផ្ទៃដីដាំកៅស៊ូឡើងហួសពី ២៥០០០ ហិចតា (59) ។

នៅទីបញ្ចប់នេះ គួរគត់សំគាល់ថាក្នុងរជ្ជកាលរបស់ព្រះបាទ **ស៊ីសុវត្ថិ** រាស្ត្រខ្មែរបានក្រោកឡើងប្រឆាំងនឹងការរំលោភជិះជាន់របស់បារាំងអស់ពីរលើក ។ យ៉ាងណាមិញ នៅឆ្នាំ ១៩១៦ ដើម្បីជាការដឹងគុណចំពោះរដ្ឋការបារាំង ព្រះបាទ **ស៊ីសុវត្ថិ** ទ្រង់បានអនុញ្ញាតអោយពួកនេះកែនរាស្ត្រខ្មែរធ្វើទាហានយកទៅច្បាំងនៅប្រទេសបារាំង ក្នុងសង្គ្រាមសកលលោកលើកទី ១ ( ១៩១៤ - ១៩១៨ ) ។ ប៉ុន្តែ មិនយូរប៉ុន្មានរាស្ត្រខ្មែរចំនួនមួយសែននាក់បានបះឡើងប្រឆាំងនឹងការរំលោភក្នុងកំណែនខាងលើនេះ និងក្នុងការស្លាបខ្មោចផ្លូវថ្នល់ ។ ជាកុសល ព្រះរាជាទ្រង់បានធ្វើអន្តរាគមន៍យ៉ាងសក្តិសិទ្ធិ ហើយប្រជារាស្ត្ររបស់ព្រះអង្គក៏សុខចិត្តព្រមវិលទៅលំនៅស្ថានរៀង ១ ខ្លួនវិញទៅ (58) ។

www.budinst.gov.kh www.elibraryofcambodia.org

ក្រោយមក ប្រហែលជាដោយសារបារាំងត្រូវការលុយកាក់ទាំយកទៅស្រុករបស់ខ្លួន ដែលបានឆ្លើបពីចម្បាំងជាមួយពួកអាល្លឺម៉ង់ បារាំងក៏បានតម្លើងពន្ធដា ហើយគិតទារពីរាស្ត្រខ្មែរដែលមានជីវភាពកាន់តែយ៉ាប់យុឺនទៅ ៗ ។ ម្ល៉ោះហើយរាស្ត្រខ្មែរនៅកន្លែងខ្លះអត់ទ្រាំនឹងអំពើជិះជាន់នេះមិនបានក៏នាំគ្នាបះបោរឡើងវាយប្រហារហួតដល់ហ៊ានសម្លាប់រេស៊ីដង់បារាំង ដូចករណីលោករេស៊ីដង់ Bardez នៅឃុំក្រាំងលាវ ខេត្តកំពង់ឆ្នាំង នៅថ្ងៃទី ១៨ ខែមេសា ១៩២៥ (60) ។

## ព្រះបាទស៊ីសុវត្ថិមុនីវង្ស (១៩២៧-១៩៤១) —



ព្រះបាទស៊ីសុវត្ថិមុនីវង្ស
(រូបស្រង់ចេញពីទស្សនាវដ្តី Le Sangkum លេខ១៧ ខែកុម្ភៈ ១៩៦៦)

ព្រះបាទ **ស៊ីសុវត្ថិ** បានសោយទិវង្គត នៅថ្ងៃទី ៩ ខែសីហា ១៩២៧ ក្នុងជន្មាយុ ៨៧ វស្សា ។ ក្រុមប្រឹក្សារាជបល្ល័ង្ក ដែលស្ថិតនៅក្រោមអធិបតីភាពនៃលោក Le Fol រេស៊ីដង់ស៊ុបេរីយ៉េរ បានជ្រើសរើសព្រះរាជបុត្រច្បងនាម **ស៊ីសុវត្ថិមុនីវង្ស** អោយឡើងសោយរាជ្យស្នងព្រះបិតា ។ ពិធីរាជាភិសេកបានប្រារព្ធធ្វើឡើងនៅរាជធានីភ្នំពេញ ( កក្កដា ១៩២៨ ) នៅចំពោះមុខលោកអគ្គទេសាភិបាលឥណ្ឌូចិន និងលោករេស៊ីដង់ស៊ុបេរីយ៉េរ នៃប្រទេសខ្មែរផង ។

www.budinst.gov.kh www.elibraryofcambodia.org

ព្រះបាទ **ស៊ីសុវត្ថិមុនីវង្ស** ទ្រង់បានយាងទៅសិក្សាយោធាវិជ្ជានៅប្រទេសបារាំង ព្រមទាំងបានក្លាយទៅជាមេទាហានមួយរូបនៃកងទ័ពប្រទេសនេះទៀតផង ។

ដូចយើងបានឃើញរួចមកហើយ នៅឆ្នាំ ១៩៣១ ចំការកៅស៊ូនៅប្រទេសខ្មែរកាន់តែកើនឡើងជាលំដាប់ ។ ចំការកៅស៊ូនៅមេមត់ដែលមានផ្ទៃ ៦០០០ ហិចតា និងមានដើមកៅស៊ូ ៥៥០០០០ ដើមជាចំការធំបំផុតក្នុងពិភពលោកក្នុងសម័យនោះ ។ ដំណាំថ្នាំជក់និងដំណាំពោតក៏ត្រូវបានគេផ្ដើមធ្វើដែរ ។

ក្នុងវិស័យកសិកម្មដដែលនេះ ព្រះបាទ **ស៊ីសុវត្ថិមុនីវង្ស** ទ្រង់បានដាក់អោយបង្កើតផលឡើងវិញនូវដីស្រែដ៏ធំទូលាយ ហើយដែលត្រូវជនជាតិខ្មែរបោះបង់ចោលដោយត្រូវគៀសខ្លួនគេចអោយផុតពីខ្ទាំងឈ្មួញពាន ឬ ដោយព្រៃឈ្លើយ ។ ដូច្នេះ តំបន់ខ្លះដូចជា**ត្រពាំងចក**ជាដើម (ក្នុងខេត្តពោធិ៍សាត់) បានក្លាយទៅជាមណ្ឌលកសិកម្មនិងពាណិជ្ជកម្មមួយយ៉ាងសំខាន់ ។ នៅឆ្នាំ១៩៣០ ព្រះអង្គទ្រង់បានប្រកាសអោយប្រើនូវព្រះរាជបញ្ញត្តិ ដែលបង្កើតធនាគារសំរាប់ផ្ដល់ឥណទានអោយកសិករនៅបាត់ដំបង ព្រៃវែង និង កំពង់ចាម (61) ។

ក្នុងវិស័យផ្លូវគមនាគមន៍ បណ្ដាញផ្លូវថ្នល់ត្រូវបានគេពង្រីកយ៉ាងខ្លាំង ។ ផ្លូវ... ទី ១ ពីភ្នំពេញទៅព្រំដែនសៀមដោយកាត់តាមបាត់ដំបង ត្រូវបានស្ថាបនាឡើងនៅ គ.ស. ១៩៣២ ។ ផ្លូវនេះមានប្រវែង ២៧៥ គ.ម. ។ ក្រៅពីនេះ ស្ពានធ្វើពីបេតុងជាច្រើនក៏ត្រូវបានស្ថាបនាដែរ ជាពិសេសស្ពានដែលឆ្លងកាត់ទន្លេបាសាក់ (ប្រវែង២៩២ម.) ហើយដែលមានឈ្មោះថា**ស្ពានព្រះមុនីវង្ស**ត្រូវបានសម្ពោធនៅថ្ងៃទី១៨ ខែវិច្ឆិកា១៩២៨ ។

ក្នុងវិស័យនយោបាយនិងវប្បធម៌ ព្រះបាទ**ស៊ីសុវត្ថិមុនីវង្ស**ក៏ទ្រង់បានសាងសមិទ្ធិយ៉ាងសំខាន់ៗ ណាស់ដែរដូចជា ៖

— **សភាសំរាប់អោយយោបល់មួយ** (សភាខ្មែរ) តាមរាជបញ្ញត្តិថ្ងៃទី១៨ ខែសីហា ១៩២៨ ។ ប៉ុន្តែបើតាមលោក **Henri Russier** ជាសភានេះ **(Assemblée consultative**

www.budinst.gov.kh www.elibraryofcambodia.org

ត្រូវបានបង្កើតតាំងពីរដ្ឋការលមុនម្ល៉េះ ហើយត្រូវមានភារៈផ្តល់យោបល់លើបញ្ហាពន្ធដា បញ្ហារដ្ឋបាល ឬបញ្ហាបង្កើតផលទាក់ទងនឹងជីវភាពប្រជារាស្ត្រខ្មែរ ។ សភានេះមានសមាជិក៤៦នាក់ៈ ក្នុងចំណោមនេះ៤១នាក់ត្រូវបោះឆ្នោតជ្រើសរើសដោយអ្នកបញ្ញវន្តខ្មែរ និង៥នាក់ទៀត ត្រូវបានតែងតាំងដោយគណៈរដ្ឋមន្ត្រី (10) ។

– **ក្រុមជំនុំប្រែព្រះត្រៃបិដក** ដែលត្រូវបានបង្កើតនៅថ្ងៃទី ១៤ វិច្ឆិកា ១៩២៩ ហើយដែលមានភារៈបកប្រែព្រះ**ត្រៃបិដក** (វិន័យបិដក សុត្តន្តបិដក និង អភិធម្មបិដក)។ សព្វថ្ងៃនេះ គម្ពីរទាំង៣នេះត្រូវបានបកប្រែចប់សព្វគ្រប់ហើយ ហើយមានទាំងអស់ ១១០ ក្បាល ។

– **វិទ្យាស្ថានពុទ្ធសាសនបណ្ឌិត្យ**ដែលត្រូវបានបង្កើតនៅឆ្នាំ១៩៣០ ហើយដែលមានភារៈធ្វើការសិក្សាស្រាវជ្រាវពីព្រះពុទ្ធសាសនានៅក្នុងប្រទេសកម្ពុជាតែម្តង មិនបាច់ចេញទៅបរទេសដូចមុនៗទៀត ។ ក្នុងឆ្នាំដដែល តាមរាជបញ្ញត្តិថ្ងៃទី១៦ ធ្នូ ព្រះបាទ**ស៊ីសុវត្ថិមុនីវង្ស** ទ្រង់បានរៀបចំនូវការសិក្សាភាសាបាលី និងព្រះពុទ្ធលទ្ធិក្នុងខេត្តទាំងឡាយនៃព្រះរាជអាណាចក្រ ។ ដោយហេតុនោះ មានការបង្កើត **សាលាអនុវត្តសំរាប់ព្រះសង្ឃ** ដែលនៅទីនោះព្រះសង្ឃ-គ្រូបានទៅសិក្សាពីវិធីបង្រៀនតាមបែបទំនើប ។

នៅឆ្នាំ១៩៣៩ សង្គ្រាមសកលលោកលើកទី ២ បានផ្ទុះឡើង ។ ប្រទេសសៀមដែលមានវិវាទជាមួយប្រទេសបារាំង ត្រូវបានទទួលការគាំទ្រពីប្រទេសជប៉ុន ហើយនៅទីបំផុតបានកៀបសង្កត់ទៅលើប្រទេសបារាំងដណ្តើមយកទៅវិញនូវខេត្ត **បាត់ដំបង** និងទឹកដីស្ថិតនៅត្រង់ចន្លោះជួរភ្នំដងរែក និងខ្សែស្របក្រាដ (grade) ទី ១៥(61) ។

ដោយឈឺព្រះទ័យនឹងការរំលោភពីសំណាក់សៀមនេះ ព្រះសុខភាពត្រូវទ្រុឌទ្រោមយ៉ាងឆាប់ហើយ ហើយព្រះបាទ**ស៊ីសុវត្ថិមុនីវង្ស** ទ្រង់សោយទិវង្គតនៅរាត្រីទី ២២ ខែមេសា ១៩៤១ នៅបូកគោក្នុងព្រះជន្មាយុ ៦៥ វស្សា ។

* *

*

www.budinst.gov.kh www.elibraryofcambodia.org

សរុបសេចក្ដីមក យើញថា ទោះបីបារាំងបានមកជិះជាន់និងរំលោភលើប្រជារាស្ត្រខ្មែរខ្លះមែន រហូតដល់បានដកហូតទឹកដីពីប្រទេសកម្ពុជាយកទៅបញ្ចូលក្នុងអាណានិគមកូសាំងស៊ីនរបស់ខ្លួន ហើយនៅទីបំផុតបានបញ្ចូលដោយមានសេចក្ដីសំរេចពីរដ្ឋសភាបារាំងដែនដីកូ-សាំងស៊ីនទៅក្នុងទឹកដីរបស់យួនជំនាន់ព្រះចៅបាវដៃ (Bao Dai) នៅឆ្នាំ១៩៤៩ ជាហេតុធ្វើអោយខ្មែរក្រោមរាប់លាននាក់ត្រូវទទួលរងទុក្ខវេទនាបាត់បង់សញ្ជាតិដើមរបស់ខ្លួនខ្លះមែនក៏ដោយ ក៏បារាំងមានឧបការគុណខ្លះៗដែរចំពោះប្រជាជាតិខ្មែរយើង ។

យ៉ាងណាមិញ ពួកមន្ត្រីនិងអ្នកប្រាជ្ញបារាំងបានធ្វើការរុករកនិងសិក្សាស្រាវជ្រាវតាមបែបវិទ្យាសាស្ត្រ ហើយធ្វើអោយពិភពលោកបានស្គាល់នូវអតីតកាលរបស់ខ្មែរ ជាពិសេសពីសម័យមហានគររុងរឿងដែលខ្មែរមានឋានៈជាមហាអំណាចមួយនៅតំបន់អាស៊ីអាគ្នេយ៍នេះ ។ ម្យ៉ាងទៀត អាណាព្យាបាលភាពរបស់បារាំងទំនងជាបានការពារកូនចៅខ្មែរនិងទឹកដីខ្មែរអោយបានគង់វង្សរហូតមកដល់សព្វថ្ងៃ គឺអោយចាកផុតពីការដណ្ដើមគ្នាគ្រប់គ្រងនិងលេបយកទឹកដីខ្មែរពីសំណាក់សៀមនិងយួនដែរ ។ ចំពោះរឿងនេះ មានជននៅជិតខាងខ្លះបានថ្លែងថា ប្រសិនបើបារាំងមកយឺតប្រហែលជា៥០ឆ្នាំប៉ុណ្ណោះ នោះប្រទេសកម្ពុជានឹងត្រូវរលាយជាមិនខាន ។ ក្នុងការកសាងជាតិ រដ្ឋការបារាំងក៏បានជួយធ្វើការកែទំរង់សំខាន់ៗខ្លះក្នុងវិស័យនយោបាយសេដ្ឋកិច្ច និងសង្គមកិច្ច ដើម្បីអោយប្រទេសខ្មែរមានដំណើរជឿនលឿនទៅមុខ ក៏ប៉ុន្តែធម្មតាជាតិជាបរទេសបារាំងតែងបានប្រមែប្រមូលយកទ្រព្យសម្បត្តិខ្មែរ មានសម្បត្តិវប្បធម៌ជាដើមទៅចំរើប្រយោជន៍ខ្លួនផ្ទាល់ ហើយពុំចង់អោយខ្មែរមានការចេះដឹងនិងល្អលាស់ខ្លាំងពេកទេ ព្រោះខ្លាចមានចលនាប្រឆាំងនឹងវត្តមានរបស់ខ្លួនតែប៉ុណ្ណោះ ។

www.budinst.gov.kh www.elibraryofcambodia.org

## បញ្ជីស្តេចខ្មែរសោយរាជ្យពី គ.ស. ១៧៥៨ ដល់ ១៩៤១

| នាមសំរាប់រាជ្យ នាមផ្ទាល់ | កាលកំណត់រជ្ជកាល | រាជធានី | រាជវង្ស |
|---|---|---|---|
| នារាយណ៍រាជាទី២ ឧទ័យរាជា អង្គតន់ | ១៧៥៨-១៧៧៥ | ព្រែកមាត់កណ្ដុរ ព្រែកតាក់ព្រ័ត្រ កោះចិន ឧដុង្គ | ចៅព្រះរាមាធិបតី ទី ៣ អង្គទង |
| រាមរាជា អង្គនន់ | ១៧៧៥-១៧៧៩ | ឧដុង្គ | បុត្រស្រីជ័យជេដ្ឋ អង្គស្ងួន |
| នារាយណ៍រាជាទី ៣ អង្គអេង | ១៧៧៩-១៧៩៦ | ឧដុង្គ | បុត្រព្រះឧទ័យរាជា អង្គតន់ |
| ចៅហ្វ៊ាប៉ុក | ១៧៩៦-១៨០៥ | ឧដុង្គ | |
| ឧទ័យរាជា អង្គចន្ទ | ១៨០៦-១៨៣៤ | ឧដុង្គ ភ្នំពេញ | បុត្រស្តេច ៣ |
| អង្គម៉ីក្សត្រី | ១៨៣៤-១៨៤០ | កោះស្លាកែត | បុត្រីស្តេច ៥ |
| ហរិរក្សរាមាឥស្សរា-ធិបតី អង្គដួង | ១៨៤០-១៨៥៩ | ឃ្លាំងស្បែក ឧដុង្គ | បុត្រស្តេច ៣ |
| នរោត្តម អង្គច្រម្ប៉ឹង-អង្គតើ | ១៨៥៩-១៩០៤ | ឧដុង្គ ភ្នំពេញ | បុត្រស្តេច ៧ |
| ស៊ីសុវត្ថិ | ១៩០៤-១៩២៧ | ភ្នំពេញ | បុត្រស្តេច ៧ |
| ស៊ីសុវត្ថិ មុនីវង្ស | ១៩២៧-១៩៤១ | ភ្នំពេញ | បុត្រស្តេច ៩ |

www.budinst.gov.kh www.elibraryofcambodia.org

# សេចក្តីបញ្ចប់

យើងសូមបញ្ចប់ការសិក្សារបស់យើងត្រឹមរជ្ជកាលព្រះបាទ **ស៊ីសុវត្ថិមុនីវង្ស** នោះ។ ចំណែកឯប្រវត្តិសាស្ត្រខ្មែរសម័យចាប់ពីឆ្នាំ **១៩៤១** តទៅ យើងសូមប្រគល់ភារៈនេះជូនទៅអ្នកស្រាវជ្រាវដទៃទៀតអោយជួយចងក្រងទុកសំរាប់អោយកូនចៅខ្មែរបានដឹងបានលឺផង។

ការសិក្សារួចមកហើយបានបង្ហាញអោយឃើញថា ខ្មែរជាជាតិមួយមានចំណាស់បានកកើតឡើង បានរស់នៅនិងបានវិវត្តហូរហែមកតាំងពីប្រមាណ២០០០ឆ្នាំមុនគ្រិស្តសករាជម៉្លេះនៅភូមិភាគអាស៊ីអាគ្នេយ៍នេះ ។ ប្រជាជាតិខ្មែរក៏ដូចជាជាតិដទៃឯទៀតនៅក្នុងពិភពលោកយើងនេះដែរ តែងតែបានជួបប្រទះនូវការប្រែប្រួល ជួនកាលបានថ្កុំថ្កើងរុងរឿងដូចនៅសម័យនគរភ្នំ សម័យចេនឡា សម័យមហានគរ ជួនកាលទៀតក៏ធ្លាក់ដុនដាបបានដល់នូវសេចក្តីវេទនាកម្រិតបំផុតគ្មានដូចនៅសម័យក្រោយអង្គរ ។ ប៉ុន្តែ យើងមិនត្រូវផ្តេកផ្តួលទៅលើច្បាប់ធម្មជាតិដូចបានពោលខាងលើ ហើយនាំគ្នារស់សង្ឃឹមពីវាសនាប្រទេសជាតិរបស់ខ្លួនទេ ។ ផ្ទុយទៅវិញ ប្រជាពលរដ្ឋខ្មែរគ្រប់ស្រទាប់គ្រប់ជាន់ថ្នាក់ត្រូវតែខិតខំរៀនប្រវត្តិសាស្ត្ររបស់ជាតិខ្លួនអោយបានដឹងច្បាស់គ្រប់គ្នាឡើង ដើម្បីអោយមានការភ្ញាក់រលឹក អោយចាប់អារម្មណ៍លើបញ្ហាជាតិ បានសេចក្តីថាដើម្បីអោយមានមនសិការជាតិដ៏ពេញលេញ ជាពិសេសនៅក្នុងកាលៈទេសៈបច្ចុប្បន្ននេះដែលប្រទេសជាតិកំពុងតែត្រូវការអ្នកស្នេហាជាតិដើម្បីការពារទឹកដី និងដើម្បីធ្វើការកសាងជាតិក្នុងពេលបច្ចុប្បន្ន និងអនាគតខាងមុខនេះ ។

ការដែលយើងដឹងនិងស្គាល់ច្បាស់ពីកំហុស ពីការភ័ន្តច្រឡំរបស់ដូនតាយើង និងពីឧបាយកលផ្សេង ៗ របស់ជនជាតិជិតខាងក្នុងការប្រវ័ញ្ចយកទឹកដីនិងក្នុងបំណងបំបាត់ពូជសាសន៍ខ្មែរ ពុំមែនគ្រាន់តែអោយដឹង អោយឈឺចាប់ទទេ ។ ហើយលាន់មាត់ស្តីបន្ទោស



www.budinst.gov.kh www.elibraryofcambodia.org

រួចបំភ្លេចចោលទៅវិញនោះទេ តែការសំខាន់គឺត្រូវចេះទាញយកមេរៀន ទាញយកការពិសោធន៍ពីហេតុការណ៍ទាំងឡាយដែលបានកើតឡើងរួចហើយ ហើយធ្វើយ៉ាងណាដើម្បីចៀសវាងកុំអោយធ្លាក់ទៅក្នុងគន្លងចាស់ដែលនាំអោយខូចប្រយោជន៍ជាតិទៀត ។

ម្យ៉ាងទៀត យើងក៏សូមបញ្ជាក់ទៀតដែរថា ដែលយើងបង្ហាញការពិតជាក់ស្តែងពីឧបាយកលរបស់ជនជាតិជិតខាងយើង គឺមិនមែនក្នុងគោលបំណងធ្វើអោយមានអរិភាពអោយមានគំនុំគំគួនប្រទូស្តរាយគ្នាមិនចេះចប់នោះទេ ។ ខ្មែរយើងចង់តែរស់នៅដោយសុខសាន្តជាមិត្តជាមួយប្រទេសជិតខាង អោយតែប្រទេសទាំងនោះគោរពបូរណភាពទឹកដី ឯករាជ្យ អធិបតេយ្យ ផលប្រយោជន៍របស់ខ្មែរ ។

ដូច្នេះ យើញថាការសិក្សាប្រវត្តិសាស្ត្រពុំមែនជាការឥតប្រយោជន៍ដូចជនចំពួកខ្លះបានយល់នោះទេ ។ ប្រវត្តិសាស្ត្រជាកញ្ចក់អោយយើងឆ្លុះមើលអោយស្គាល់អតីតកាលជាតិកំណើតរបស់យើងអោយបានច្បាស់លាស់ ដែលជាហេតុអោយយើងបានយល់ព្រឹត្តិការណ៍ក្នុងបច្ចុប្បន្នកាលព្រមទាំងប្រមាណមើលនូវទស្សនវិស័យរបស់ជាតិក្នុងអនាគតកាលថែមទៀត ។

បញ្ហាចម្បងរបស់ខ្មែរក្នុងពាក់កណ្តាលទី ២ នៃសតវត្សនេះ គឺការថែរក្សាពូជសាសន៍ខ្មែរនិងទឹកដីដែលនៅសល់បួយក្រវិចនេះអោយនៅគង់វង្សយូរអង្វែងតទៅទៀត ។ ប្រសិនបើប្រជាពលរដ្ឋខ្មែរមិនបានស្គាល់ច្បាស់ប្រវត្តិសាស្ត្ររបស់ខ្លួន ហើយបណ្តោយអោយប្រទេសជាតិធ្លាក់ទៅក្រោមនឹមត្រួតត្រារបស់បរទេសហើយ កូនចៅខ្មែរនឹងត្រូវបាត់បង់អស់សិទ្ធិសេរីភាពក្នុងការរស់នៅ ហើយមិនយូរប៉ុន្មាននឹងត្រូវរលាយជាតិបាត់ឈ្មោះពីផែនទីសាកលលោកជាមិនខាន ।

ភ្នំពេញ ថ្ងៃ ទី ១១ ខែកញ្ញា ១៩៨៤

អ្នកនិពន្ធ

www.budinst.gov.kh  www.elibraryofcambodia.org

# បញ្ជីឯកសារពិគ្រោះ

1- Henri Marchal , Angkor , Paris , 1955

2- Revue France-Asie, n° spécial pour la civilisation khmère, Saigon, 1955.

3- ឯកសារមហាបុរសខ្មែរ លេខ ១៤ - បោះពុម្ពផ្សាយដោយលោក អេងសុត នៅភ្នំពេញ គ.ស. ១៩៦៩ ។

4. លោកកងគីរី— លោកសែមស្វរ : ប្រជុំអនុពាក្យទំនើប ទំព័រ ៨៤-កំពង់ចាម-១៩៦៣ ។

5- សម្ដេចព្រះមហាសុមេធាធិបតី ជួនណាត - ប្រវត្តិនៃវត្តឧណ្ណាលោម - ភ្នំពេញ គ.ស ១៩៥៣ ។

6- លោកស៊ុមអ៊ាំ និង លោកលីអេង - ប្រវត្តិនៃប្រទេសកម្ពុជា (សាកល្បង) បោះពុម្ពហើយ តែមិនបានផ្សាយនៅភ្នំពេញ គ.ស. ១៩៦៩ ។

7- Etienne Aymonier , Le Cambodge . tome III , Paris , 1904.

8- បែបរៀនសង្ខេបសិក្សាវិជ្ជាប្រវត្តិសាស្ត្រ ថ្នាក់មធ្យមសិក្សាឆ្នាំទី១ របស់ក្រុមវិជ្ជាការក្រសួងសិក្សាធិការ (ភាសាថៃ) - បឹងកក - ព.ស. ២៥១២ គ.ស. ១៩៦៨ ។

9- Dauphin Meunier , Histoire du Cambodge . PUF , Que sais-je ? Paris 1961.

10-12- Henri Russier , Histoire sommaire du royaume du Cambodge dès origines à nos jours (brochure ronéotypée) , 1929 ?

11- Adhémard Leclère , le Sdach Kân , Imprimerie coloniale , Saigon, 1911.

13- Lê Thanh Khôi , Histoire de l'Asie du Sud- est , PUF , Que sais-je ? Paris , 1959.

14- B.P.- Groslier , Angkor et le Cambodge au 16[e] siècle d'après les sources portugaises et espagnoles , Paris , 1958.

www.budinst.gov.kh www.elibraryofcambodia.org

15- France-Asie, n°spécial 118-119, Présence du Royaume lao, Saigon, 1956.

16- ពង្សាវតារប្រទេសលាវ គឺក្រុងហ្លួងព្រះបាង-ក្រុងវៀងចន្ទន៍ ក្រុងជួន និង ចំប៉ាស័ក (ជាភាសាលាវ) - វៀងចន្ទន៍ .គ.ស. ១៩២៧ ។ Annales du Laos - Luang Prabang- Vientiane-Tranninh et Bassac, publiées la 22[e] année du règne de S.M. Sisavang Vong Roi du Luang Prabang, 1926.

17- ឯកសារមហាបុរសខ្មែរ លេខ ២៧-២៨ របស់លោកអេងសុត បោះពុម្ពផ្សាយនៅក្រុងភ្នំពេញ ទៅ គ.ស. ១៩៦៩ ។

18- ប្រវត្តិវិទ្យា ភាគ ១ ថ្នាក់ទី ១ - ខេមរយានកម្ម - ភ្នំពេញ - ១៩៣២ ។

19- Lawrence Palmer Briggs, Les missionnaires portugais et espagnols au Cambodge (1555-1603), texte traduit de l'anglais par Monique Dupont et publié dans Bulletin de la Société des Etudes Indochinoises (Nouvelle série - Tome xxv, n° 1- 1[er] trimestre 1950), Saigon, 1950.

20- H. Sutton, Singapore in history, federal publications, Singapore, 1967.

21- ព្រះរាជពិធីទ្វាទសមាស ភាគ ១ បោះពុម្ពលើកទី ២ · ការផ្សាយរបស់ពុទ្ធសាសនបណ្ឌិត្យ ព.ស. ២៥០០-គ.ស. ១៩៥៦ ។

22- J. Imbert, Histoire des Institutions khmères, volume II, Annales de la Faculté de Droit de Phnompenh, 1961.

23- លោកអនុសេនីយឯក សឺនទី-ប្រវត្តិយោធាខ្មែរ-អត្ថបទផ្សាយតាមទូរទស្សន៍សាធារណរដ្ឋខ្មែរ ខែ មេសា-ឧសភា ១៩៧៤ ។

24- ឯកសារមហាបុរសខ្មែរ របស់លោកអេងសុត- លេខ ៦ -ភ្នំពេញ ១៩៦៩ ។

25- ឯកសារមហាបុរសខ្មែរ របស់លោកអេងសុត-លេខ-១២-១៦-១៨ ភ្នំពេញ ១៩៦៩ ។

26- ឯកសារមហាបុរសខ្មែរ របស់លោកអេងសុត—លេខ ៧ – ភ្នំពេញ – គ.ស. ១៩៦៩ ។

27- ឯកសារមហាបុរសខ្មែរ របស់លោកអេងសុត—លេខ ១៥ – ភ្នំពេញ – គ.ស. ១៩៦៩ ។


www.budinst.gov.kh www.elibraryofcambodia.org

28- សិលាចារឹកនគរវត្តនិងបទានុក្រម — ការផ្សាយរបស់ពុទ្ធសាសនបណ្ឌិត្យ — ភ្នំពេញ — គ.ស.១៩៥៨ ។

29- គោលប្រវត្តិសាស្ត្រនៃអក្សរសាស្ត្រខ្មែរ ដោយប្រជុំសាស្ត្រាចារ្យ - ការផ្សាយរបស់បណ្ណាគារភ្នំពេញ — ភ្នំពេញ — គ.ស.១៩៥៦ ។

30- លោក ឃួន សុខម្ភូ — គំនិតរិះគន់សង្ខេបក្នុងអក្សរសិល្ប៍ខ្មែរ — សន្និសីទធ្វើនៅសាលាជាតិខាងរដ្ឋបាលនៅថ្ងៃទី ១ មិថុនា ១៩៧៤ នៅភ្នំពេញ ។

31- L'organisation buddhique au Cambodge, n° 4, série Culture et Civilisation Khmères, Phnompenh, 1963.

32- ឯកសារមហាបុរសខ្មែររបស់លោក អេង សុត - លេខ ២២-ភ្នំពេញ-គ.ស.១៩៦៩ ។

33- ឯកសារមហាបុរសខ្មែររបស់លោក អេង ស៊ុត - លេខ ២៣-ភ្នំពេញ គ.ស.១៩៦៩ ។

34- ឯកសារមហាបុរសខ្មែររបស់លោក អេង សុត - លេខ ៧ -ភ្នំពេញ គ.ស.១៩៦៩ ។

35- Madeleine Giteau, Depuis un siècle, un effort soutenu pour dégager et restaurer Angkor, dans SOS Angkor, Courrier de l'Unesco, Décembre 1961.

36- ប្រជុំពង្សាវតារ - ច្បាប់បណ្ណាល័យជាតិ - ក្បាលទី ១ - រោងពុម្ពការហ្វា - បោះពុម្ពលើកដំបូង-ក្បាលទី ១-២ ឧសភា ព.ស.២៥០៦ (ជាភាសាថៃ) ។

37- Phan Khoang, Viêt Su : Xu Dang Trong 1558-1777, Saigon, 1969.

38- Lê Huong, Su Cao Miên, Saigon, 1970.

39- Charles Meyer. Phnom penh, à la recherche du passé- Les premiers occidentaux à Phnompenh, article publié dans Nokor Khmer, n°2, Phnompenh, 1970.

40- Tran Trong Kim, Vietnam Su Luoc, Saigon, 1964.

41- G.Nandin, Histoire de la Cochinchine.

www.budinst.gov.kh www.elibraryofcambodia.org

42- Jean Moura, Le Royaume du Cambodge, Paris, 1883

43- ឯកសារមហាបុរសខ្មែរ របស់លោកអេងសុត-លេខ ៦៤-ភ្នំពេញ គ.ស. ...

44- Adhémard Leclère, l'Histoire du Cambodge, Geuthner, Paris, 1914.

45- Lê Huong, Nguoi Viet gôc Miên, Saigon, 1969.

46- P. Schweisguth, un siècle d'histoire dans la péninsule indochinoise (1750-1850), Imprimerie Taupin et cie, Hanôi, 1944.

47- លោកកែវសុវត្ថិ-ចៅហ្វាយគុយ-ភ្នំពេញ-១៩៧១ ។

48- Gérard Groussin, Le protectorat français sur le Cambodge de 1863 à 1884 (ronéotypé), Centre de documentation et de recherche de la Faculté des Lettres et des Sciences humaines de Phnompenh, 1973.

49- Luang Vichitr Vadakarn, Thailand's case, Bangkok, 1941.

50- Charles Meyer, Insurrections nationales du siècle dernier, dans Etudes cambodgiennes n° 9, Phnompenh, 1967.

51- M.Giteau, Histoire du Cambodge, Didier, Paris, 1957.

52- លោកឌឹកគាម-អាចារ្យស្វា-ភ្នំពេញ- គ.ស. ១៩៧៣ ។

53- La monarchie khmère, dans le Sangkum n° 5, décembre 1965, Phnompenh

54- L'histoire de Kralahom Kong par ImChhum (traduction libre Suon On et Charles Meyer), dans Etudes cambodgiennes n° 18, Phnompenh, 1969

55- Gaston Barrault, Cambodgiens de Cochinchine, Editions de la Revue Extrême - Orient, Saigon, 1927.

56- La frontière Khméro - vietnamienne, dans Etudes cambodgiennes n° 7 Phnompenh, 1966.

57- Sarin Chhak, Quelques faits historiques sur le tracé des frontières entre le Cambodge, le Laos et le Vietnam ចុះផ្សាយក្នុងទស្សនាវដ្តីសាស្ត្រា

លេខ ១៤-ឆ្នាំទី ៥-១៩៦៤ ។

58- La monarchie khmère, dans le Sangkum n° 6, Phnompenh, 1966.

59- Ho Tong Peng, L'économie de l'hévéaculture en 1965, dans Etudes cambodgiennes n° 1, Phnom-penh, 1965.

60- លោកឌឹកគាម និង លោកឡៀកអំ-ភូមិគិរិស្ថាន-ភ្នំពេញ - គ.ស. ១៩៧៩ ។

61- L'oeuvre de Sa Majesté Monivong, dans le Sangkum n° 8 Phnompenh, 1966.



www.budinst.gov.kh www.elibraryofcambodia.org

www.budinst.gov.kh www.elibraryofcambodia.org

www.budinst.gov.kh www.elibraryofcambodia.org

www.budinst.gov.kh www.elibraryofcambodia.org